ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដាអំណាន

## សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស



ថ្នាក់ទី

៣

ខែ កញ្ញា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:៥៧៦ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "ស្តង់ដាអំណាន" ថ្នាក់ទី៣
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការអប់រំ
-បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មសិក្សាចំណេះទូទៅ ២០០៥-២០០៩
-យោងសេចក្តីណែនាំលេខ ៣៨៤២ អយក.សណន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០០ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងលិខិតលេខ ២១០០ អយក.ឧទន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចាត់តាំងគណៈកម្មាការដឹងនាំសម្របសម្រួល និងក្រុមពិគ្រោះយោបល់ថ្នាក់ជាតិក្នុងគម្រោង "វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានបន្ថែមសម្រាប់កុមារ" (TRAC Plus )
-យោងរបាយការណ៍បូកសរុប ការសាកល្បងសៀវភៅស្តង់ដាអំណាន ថ្នាក់ទី៣ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស។

## សម្រេច

**ប្រការ១**-អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "**ស្តង់ដាអំណាន**" ថ្នាក់ទី៣ដែលរៀបចំដោយនាយកដ្ឋានបឋមសិក្សា ដើម្បីប្រើប្រាស់នៅតាមសាលាបឋមសិក្សា។

**ប្រការ២**-អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានបឋមសិក្សា និងប្រធាននាយកដ្ឋានពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៦

**កន្លែងទទួល:**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យក្រសួង.អយក
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-ដូចប្រការ២
-កាលប្បវត្តិ-ឯកសារនា.បស

បណ្ឌិត ហង់ ជួន ណារ៉ុន

## គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តម បណ្ឌិត ហង់ ជួនណារ៉ុន

ឯកឧត្តម បណ្ឌិត ណាតប៊ុនរឿន

ឯកឧត្តម ពុត សាមិត្ត

ឯកឧត្តម ឡៅ ឆវណ្ណា

លោក ចាន់ សុភា

## គណៈកម្មការនិពន្ធ

លោកស្រី មៅ តាន់ណារី

លោក គា គីមស្រ៊ុន

លោក ឃិត សុភ័ក្រ្ត

## គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តម ឱម សិទ្ធី

លោក ចាន់ សុភា

លោក អោ សៀម

លោក ង៉ោ ប៉េងឡុង

## អ្នកជំនួយការបច្ចេកទេស

លោក អ៊ុល រុន

លោក អេង សុខ

លោក Kurt Bredenberg

លោកស្រី Jacole Douglas

## គណៈកម្មការរៀបរៀង និងរចនាទំព័រ

លោក ឆាយ សុខចាន់ណា

លោក សៅ ស៊ីថា

# អារម្ភកថា

សៀវភៅណែនាំពង្រឹងសមត្ថភាពអំណាន "ស្តង់ដាអំណាន" នេះបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការអប់រំពិភពលោក (WE) អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងអ្នកពាក់ព័ន្ធជាច្រើនទៀត។ គោលបំណងចម្បងនៃសៀវភៅនេះគឺផ្តល់បំណិនសំខាន់ៗ ក្នុងសមត្ថភាពអានជាក់ស្តែង ដែលសិស្សត្រូវទទួលបានខ្លឹមសារក្នុងមេរៀននីមួយៗនៃសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣។ សៀវភៅនេះគឺជាផ្នែកមួយនៃកិច្ចខិតខំជាបន្តបន្ទាប់របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការលើកកម្ពស់គុណភាពការបង្រៀន និងរៀននៃកម្មវិធីសិក្សាអំណានថ្នាក់ដំបូង ដែលជាបំណិនមួយជាក់លាក់សម្រាប់ឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សាលើគ្រប់មុខវិជ្ជា។

ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងដៃគូអភិវឌ្ឍនានាបានធ្វើការជាមួយគ្នាដើម្បីកំណត់រកកម្រិតស្តង់ដាអំណានគន្លឹះៗចំពោះខ្លឹមសារក្នុងមេរៀននីមួយៗនៃសៀវភៅភាសាខ្មែរអាន-សរសេរ ថ្នាក់ទី៣។ កម្រិតស្តង់ដាទាំងអស់ ត្រូវបានបរិយាយយ៉ាងពេញលេញក្នុងសៀវភៅនេះ ដើម្បីជួយគ្រូបង្រៀនឱ្យចេះវាយតម្លៃជាដំណាក់ និងបន្តបន្ទាប់ដល់សិស្សក្នុងលក្ខណៈមួយដែលធានាបាននូវសុពលភាពនិងភាពអាចទុកចិត្តបានកម្រិតខ្ពស់។ សៀវភៅនេះបានបង្ហាញសកម្មភាពគំរូជាក់ស្តែងនិងល្បែងសិក្សា ដែលគ្រូបង្រៀនបានវាយតម្លៃសិស្ស ហើយឆ្លើយតបទៅនឹងលទ្ធផលសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សា។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារនេះជាជំនួយដ៏សំខាន់ក្នុងការពង្រឹងការបង្រៀននិងរៀនផ្នែកអំណាននិងសំណេរ។ ដូចនេះ លោកគ្រូ អ្នកគ្រូថ្នាក់ទី៣ទាំងអស់គួរត្រួតពិនិត្យជាប្រចាំនូវកម្រិតស្តង់ដាក្នុងសៀវភៅនេះ ដោយធានាថាបានបញ្ចូលក្នុងកិច្ចតែងការបង្រៀន និងការបង្រៀនជាក់ស្តែង ដើម្បីឱ្យសិស្សសម្រេចបានលទ្ធផលអំណាន និងសំណេរប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**គណៈកម្មការនិពន្ធ**

# មាតិកា

**គណៈកម្មការគ្រប់គ្រងកម្មវិធី**

**អារម្ភកថា**

**មាតិកា**

**របៀបប្រើប្រាស់ស្តង់ដាអំណានដើម្បីពង្រឹងសមត្ថភាពអាន សរសេរ** ....................i

១. សារតារ....................i

២. គោលបំណងនៃការបង្កើតស្តង់ដាអំណាន....................i

៣. ទម្រង់ឯកសារ....................iii

៤. អំពីបំណិនអំណាននិងសំណេរ....................vi

៥. ការឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាប្រព័ន្ធ ....................vi

៦. អន្តរាគមន៍មានប្រយោជន៍សម្រាប់ជួយសិស្សមានតម្រូវការរៀនបន្ថែម....................ix

៧. ព័ត៌មានជំនួយបន្ថែមសម្រាប់គ្រូ....................xi

**ដំណាក់កាលទី ១** : មេរៀនទី ១ - ៧....................1

**ដំណាក់កាលទី ២** : មេរៀនទី ៨ - ១៤....................16

**ដំណាក់កាលទី ៣** : មេរៀនទី ១៥ - ២៣.................... 33

**ដំណាក់កាលទី ៤** : មេរៀនទី ២៤ - ៣៤....................53

**ដំណាក់កាលទី ៥** : មេរៀនទី ៣៥ - ៤១....................77

**ដំណាក់កាលទី ៦** : មេរៀនទី ៤២ - ៥២ ....................98

**ដំណាក់កាលទី ៧** : មេរៀនទី ៥៣ - ៦៤ ....................119

**ឧបសម្ព័ន្ធ ១**....................138

បញ្ជីល្បែងសិក្សា ....................139

**ឧបសម្ព័ន្ធ ២** ....................141

តារាងសង្ខេបតេស្តដំណាក់កាលនិងតេស្តផ្ទាល់មាត់ប្រចាំឆមាស....................142

សេចក្តីណែនាំទូទៅសម្រាប់ការធ្វើតេស្តដំណាក់កាលនិងតេស្តផ្ទាល់មាត់ប្រចាំឆមាស ....................143

សេចក្តីណែនាំតេស្តដំណាក់កាលទី១.....144
តេស្តដំណាក់កាលទី ១ .....146
សេចក្តីណែនាំតេស្តដំណាក់កាលទី២.....149
តេស្តដំណាក់កាលទី ២ .....151
សេចក្តីណែនាំតេស្តដំណាក់កាលទី៣.....154
តេស្តដំណាក់កាលទី ៣ .....156
សេចក្តីណែនាំតេស្តដំណាក់កាលទី៤.....160
តេស្តដំណាក់កាលទី ៤ .....162
សេចក្តីណែនាំតេស្តផ្ទាល់មាត់ប្រចាំឆមាសទី១.....166
តេស្តផ្ទាល់មាត់ប្រចាំឆមាសទី ១ .....167
សេចក្តីណែនាំតេស្តដំណាក់កាលទី៥.....169
តេស្តដំណាក់កាលទី ៥ .....171
សេចក្តីណែនាំតេស្តដំណាក់កាលទី៦.....175
តេស្តដំណាក់កាលទី ៦ .....177
សេចក្តីណែនាំតេស្តដំណាក់កាលទី៧.....181
តេស្តដំណាក់កាលទី ៧ .....183
សេចក្តីណែនាំតេស្តផ្ទាល់មាត់ប្រចាំឆមាសទី២ .....186
តេស្តផ្ទាល់មាត់ប្រចាំឆមាសទី ២ .....187
**ឧបសម្ព័ន្ធ ៣** .....189
បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម.....190
របៀបបំពេញ បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម .....191
**ឧបសម្ព័ន្ធ ៤** .....192
បណ្ណពិន្ទុសិស្សសម្រាប់សិស្សដែលមានតម្រូវការរៀនបន្ថែម.....193

# របៀបប្រើប្រាស់ស្តង់ដាអំណាន
# ដើម្បីពង្រឹងសមត្ថភាពអាន - សរសេរ

### ១. សារតារ

ចាប់ពីឆ្នាំ២០១០ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមកែលម្អសៀវភៅភាសាខ្មែរអាន-សរសេរ ថ្នាក់ទី១ដល់ទី៣។ សៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី១ដែលបានអភិវឌ្ឍថ្មីបានដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេសនៅតាមសាលាបឋមសិក្សាក្នុងឆ្នាំ២០១១ ហើយសៀវភៅភាសាខ្មែរ អាន-សរសេរសម្រាប់ថ្នាក់ទី២ និងទី៣បានដាក់ឱ្យសាកល្បងក្នុងឆ្នាំ២០១២និង ២០១៣។ សៀវភៅទាំងនេះបានរៀបចំឡើងដោយមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាដៃគូអភិវឌ្ឍដែលធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ។

មូលហេតុនៃការណែនាំអំពីសៀវភៅភាសាខ្មែរអាន-សរសេរថ្មីនេះ គឺចង់បញ្ឈប់ក្តីកង្វល់ពីមុនអំពីការទទួលបានលទ្ធផលអំណាននិងសំណេរដែលមានកម្រិតទាប។ យោងតាមការធ្វើតេស្តសាកល្បងអំពីសៀវភៅភាសាខ្មែរ អាន- សរសេរថ្មីនេះ លទ្ធផលពិន្ទុសម្រាប់តេស្តមានការកើនឡើងគួរឱ្យកត់សម្គាល់។ នេះបង្ហាញថា យុទ្ធសាស្ត្រដែលក្រសួងអប់រំ យុវជន និងកីឡាប្រើ គឺមានភាពជោគជ័យ។ បន្ទាប់ពីភាពជោគជ័យនេះ ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំឯកសារបន្ថែមដែលនឹងជួយគ្រូទូទាំងប្រទេស ឱ្យប្រើប្រាស់សៀវភៅថ្មីនេះប្រកបដោយប្រសិទ្ធភាព ជាពិសេសក្នុងផ្នែកវង្វាយតម្លៃសិស្ស។

### ២ គោលបំណងនៃការបង្កើតស្តង់ដាអំណាន

ឯកសារនេះត្រូវបានអភិវឌ្ឍឡើងដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីបន្តជួយគាំទ្រភាពជោគជ័យនៃសៀវភៅភាសាខ្មែរ អាន-សរសេរថ្មី។ ចំណុចផ្តោតជាចម្បងនៃឯកសារនេះគឺដើម្បីផ្តល់ឱ្យគ្រូនូវសមត្ថភាពជាក់លាក់ក្នុងការអាននិងសរសេរ ដែលសិស្សត្រូវទទួលបានពីមេរៀននីមួយៗក្នុងសៀវភៅសិក្សាគោលនេះ។ សមត្ថភាពទាំងនោះត្រូវបានបង្ហាញតាម "**កម្រិតស្តង់ដា**" នីមួយៗ។ កម្រិតស្តង់ដាទាំងនេះនឹងជួយឱ្យគ្រូកាន់តែមានភាពប្រសើរឡើងក្នុងការរៀបចំការវាយតម្លៃសិស្សតូចៗ ដែលទើបចាប់ផ្តើមរៀនអាននិងសរសេរនៅថ្នាក់ដំបូង។ នេះជាការវាយតម្លៃមួយដ៏មានសារៈសំខាន់ដែលត្រូវបានធ្វើឡើងជាបណ្តើរៗនៅរាល់ពេលបញ្ចប់ដំណាក់កាលនីមួយៗ។

### ២.១ ហេតុអ្វីបានជាការវាយតម្លៃមានសារៈសំខាន់?

ជារឿយៗ គ្រូវាយតម្លៃសិស្សដោយពុំយល់ថាហេតុអ្វីបានជាពួកគេវាយតម្លៃសិស្ស ឬក៏អ្វីដែលត្រូវធ្វើជាមួយព័ត៌មាននៃការវាយតម្លៃទាំងនោះទេ។ ជាធម្មតាគ្រូគ្រាន់តែកត់ត្រាពិន្ទុវាយតម្លៃទុកក្នុងសៀវភៅពិន្ទុរបស់ពួកគេ រួចហើយបន្តទៅមេរៀនបន្ទាប់ទៀត ទោះបីជាសិស្សយល់ ឬយល់មិនទាន់ច្បាស់មេរៀនមុនក៏ដោយ។ គ្រូភាគច្រើនមិនសូវបានប្រើព័ត៌មានដើម្បីរំឭកផ្នែកដែលសិស្សមិនយល់ ឬដើម្បីកំណត់សិស្សនីមួយៗ ដែលកំពុងព្យាយាមដើម្បីឱ្យដល់កម្រិតស្តង់ដាជាក់លាក់ណាមួយទេ។

ឯកសារនេះនឹងជួយគ្រូឱ្យចាកឆ្ងាយពីការប្រើប្រាស់វង្វាយតម្លៃដើម្បីតែកត់ត្រាទុកក្នុងសៀវភៅពិន្ទុរបស់ពួកគេ។ នេះមិនមែនមានន័យថាវង្វាយតម្លៃបែបនោះមិនមានសារៈសំខាន់នោះទេ ពោលគឺវាមានសារៈសំខាន់ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ក្នុងការនិយាយថាយើងវាយតម្លៃសិស្សបានយ៉ាងល្អនោះទេ។ ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា ឯកសារនេះនឹងជួយគ្រូបង្រៀនឱ្យបំពេញភារកិច្ចដូចជាគ្រូពេទ្យ។ ពោលគឺការធ្វើវង្វាយតម្លៃក្នុងគោលបំណងកំណត់រកអ្វីដែលសិស្សមិនយល់និងធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហាដូចគ្នានឹងគ្រូពេទ្យ

ដែលរកឃើញរោគសញ្ញាអ្នកជំងឺហើយរកវិធីព្យាបាលឱ្យទាន់ពេលវេលា។

ការវាយតម្លៃសិស្សបានល្អប្រសើរនឹងជួយគ្រូឱ្យចេះកំណត់សិស្សជួបការលំបាក ពិសេសក្នុងការអាន។ នៅពេលពួកគេមានព័ត៌មានទាំងនេះ ពួកគេអាចអភិវឌ្ឍឬកំណត់បាននូវសម្ភារៈជំនួយការរៀននិងបង្រៀនជាក់លាក់ដែលនឹងជួយដោះស្រាយភាពខ្វះខាតនេះ ព្រោះឯកសារស្តង់ដាអំណានដែលមានកម្រិតស្តង់ដាត្រូវបានរៀបចំឡើងជាដំណាក់កាលខ្លីៗ (ពីដំណាក់កាលទី១ ដល់ទី៧) ដែលគ្រូអាចដឹងបានយ៉ាងរហ័សថា តើសិស្សណាដែលមានការលំបាកនិងផ្នែកណាខ្លះដែលលំបាកជាជាងការរង់ចាំរហូតដល់ចប់ឆមាសដែលវាមានភាពយឺតយ៉ាវរួចទៅហើយក្នុងការធ្វើសកម្មភាពបំប៉នបន្ថែមជួយសិស្ស។ ដូច្នេះ កម្រិតស្តង់ដាដែលរៀបរាប់ក្នុងឯកសារនេះមានបំណងជួយគ្រូឱ្យធ្វើការវាយតម្លៃនិងផ្តល់ព័ត៌មានត្រឡប់កាន់តែប្រសើរអំពីរបៀបដោះស្រាយបញ្ហាអំណានរបស់សិស្សបានទាន់ពេលវេលា។

## ២.២ គោលបំណងនៃស្តង់ដាអំណាន

គោលបំណងសំខាន់បំផុតនៃឯកសារនេះគឺផ្តល់នូវកម្រិតស្តង់ដាសិក្សាជាក់លាក់ដែលនឹងជួយសម្រួលកិច្ចខំប្រឹងប្រែងរបស់គ្រូក្នុងការចង្អុលបង្ហាញផ្នែកនៃការសិក្សាដែលសិស្សម្នាក់ ឬច្រើននាក់ដែលមិនយល់និងធ្វើសកម្មភាពបំប៉នបន្ថែម។ ឯកសារនេះ ៖

- ជួយគ្រូឱ្យយល់បានកាន់តែប្រសើរអំពី**សមត្ថភាពជាក់លាក់**ដែលសិស្សត្រូវទទួលបាននូវការកំណត់**សមត្ថភាព** អាននិងសរសេររបស់សិស្សមានភាពជោគជ័យ។
- ជួយគ្រូឱ្យយល់បានកាន់តែប្រសើរអំពី**បំណិនអានគន្លឹះទាំង៥** ៖ ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះអានស្ទាត់ ការចេះវាក្យសព្ទ និងការអានដើម្បីយល់ន័យ។ ពោលគឺការកំណត់ **បំណិនអំណានពាក់ព័ន្ធ** និងបំណិនសំណេរ (សរសេរតាមអាន សំណេរអក្សរ ផ្ចង់ តែងល្បះ តែងសេចក្តី) ដែលសិស្សត្រូវទទួលបានតាមរយៈការហ្វឹកហាត់អាននិងសរសេរ សូរស្រៈ ព្យញ្ជនៈ ពាក្យ ឃ្លា ល្បះ។ល។ បានជោគជ័យ។
- ជួយគ្រូរៀបចំ**ខ្លឹមសារ**ដែលដកស្រង់ចេញពីសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ ងាយស្រួលក្នុងការវាយតម្លៃតាមដំណាក់កាលនីមួយៗ។

ស្របជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡាក៏បានកំណត់ **ខ្លឹមសារ** គន្លឹះនិងបំណិនរងមួយចំនួន ដែលបានណែនាំនិងរៀបចំនៅក្នុងសៀវភៅ ស្តង់ដាអំណាន (មើលក្នុងប្រអប់ទី១)

**ប្រអប់ទី១៖ ការវិភាគខ្លឹមសារក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣**

| ខ្លឹមសារមេរៀន | បំណិនពាក់ព័ន្ធនិងផ្នែកផ្សេងៗ | ចំនួនមេរៀន |
|---|---|---|
| អំណាននិងសំណេរ | ការស្គាល់សូរ | ៣៥ |
| | ការស្គាល់តួរអក្សរនិងសូរ | |
| | ការចេះវាក្យសព្ទ | |
| | ការចេះអានស្ទាត់ | |
| | ការអានដើម្បីយល់ន័យ | |
| | ការប្រកប | |
| | អក្សរផ្ចង់ | |
| | សរសេរតាមអាន | |
| | ការតែងល្បះ | |
| តែងសេចក្តី | តែងសេចក្តី | ៤ |
| បំណិនវាក្យសព្ទ | ពាក្យចួន | ៦ |
| | វេវចនសព្ទ បដិសព្ទ និងសទិសសព្ទ | |
| | ការវិភាគតួរអង្គ | |
| | ការវិភាគហេតុ និងផល | |
| វេយ្យាករណ៍ | វេយ្យាករណ៍ | ៧ |
| | វណ្ណយុត្តិ | |
| | វិធីប្រើវណ្ណយុត្តិ | |

- ផ្ដល់ឱ្យគ្រូនូវ**សកម្មភាពគំរូ**មួយចំនួន សម្រាប់គ្រូត ពិនិត្យលទ្ធផលសិក្សារបស់សិស្ស ដែលបានសិក្សា ខ្លឹមសារមេរៀនតាមដំណាក់កាលនីមួយៗ មុននឹង ធ្វើតេស្តតាមដំណាក់កាល។
- ផ្ដល់នូវ**ឧបករណ៍វាយតម្លៃ**(តេស្តតាមដំណាក់កាល នីមួយៗ) ជាក់លាក់ដែលធ្វើឱ្យគ្រូអាចធ្វើការវាយ តម្លៃបានជាប្រចាំ។ដូច្នេះ គ្រូអាចកំណត់បទពិសោធ ចំពោះសិស្សជួបការលំបាកក្នុងការរៀនអាន និង សរសេរ។
- ផ្ដល់សេចក្ដីណែនាំដោយមាន**សម្ភារៈជំនួយស្រប តាមការសិក្សានិងល្បែងសិក្សា**ដែលនឹងជួយសិស្ស ដែលមានតម្រូវការរៀនបន្ថែមទទួលបានសមត្ថភាព ក្នុងការអានកាន់តែប្រសើរឡើង។

## ៣. ទម្រង់ឯកសារ

### ៣.១ តើដំណាក់កាលជាអ្វី?

កម្រិតស្តង់ដានៃការសិក្សាក្នុងសៀវភៅនេះត្រូវបាន រៀបចំឡើងជា **ដំណាក់កាល** ទៅតាមបណ្ដុំនៃប្រធានបទ មេរៀន តិចឬច្រើន អាស្រ័យតាមខ្លឹមសារមេរៀននៃថ្នាក់ នីមួយៗ។ ការរៀបចំដំណាក់កាលនេះ មានការកំណត់ ចំនួនម៉ោងស្របនឹងចំនួនម៉ោងសិក្សានៃមេរៀននីមួយៗ ទៅតាមកាលវិភាគ ដែលសិស្សត្រូវរៀន១៣ម៉ោងក្នុង មួយសប្ដាហ៍។

យោងការណែនាំអំពីចំនួនសប្ដាហ៍ដែលត្រូវបង្រៀន មេរៀន តាមខ្លឹមសារសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣នេះ ក្រុមការងារបានរៀបចំខ្លឹមសារមេរៀនជា៧ ដំណាក់កាល។ ចូរពិនិត្យឧទាហរណ៍អំពីដំណាក់កាល ទី១ បានសង្ខេបនៅក្នុងរូបភាពទី១។

ជាទូទៅដំណាក់កាលនីមួយៗមានបញ្ចូលព័ត៌មាន មួយចំនួនដូចខាងក្រោម ៖

- **ចំនួនមេរៀនដែលគ្របដណ្ដប់**
- **ប្រធានបទ ឬចំណងជើងមេរៀន**
- **ពេលវេលាសន្មតសម្រាប់បង្រៀន ខ្លឹមសារក្នុងកាលវិភាគប្រចាំឆ្នាំ**
- **ចំនួនម៉ោងនិងសប្ដាហ៍ដែលគ្រូគួរចំណាយចំពោះ ប្រធានបទ**

ជាការពិតណាស់ គ្រូត្រូវចំណាយពេលបន្ថែម ចំពោះដំណាក់កាលជាក់លាក់ណាមួយ ប្រសិនបើ ឧបករណ៍វាយតម្លៃតាមកម្រិតស្តង់ដាបង្ហាញថាចំនួន សិស្សភាគច្រើនមិនទាន់ទទួលបានសមត្ថភាពដែលបាន កំណត់ក្នុងកម្រិតស្តង់ដា។

***រូបភាពទី១ ៖ ឧទាហរណ៍អំពីដំណាក់កាលទី១***

**ដំណាក់កាលទី១** : **មេរៀនទី ១-៧**

(**ទំព័រទី២ ដល់២៣**)

*១. មេរៀនទី១ : សាលាកុមារមេត្រី (ចំនួន១០ម៉ោង)*
*២. មេរៀនទី២ : វេវចនសព្ទ (ចំនួន៣ម៉ោង)*
*៣. មេរៀនទី៣ : សិស្សឧស្សាហ៍ (ចំនួន១០ម៉ោង)*
*៤. មេរៀនទី៤ : ការសម្អាតថ្នាក់រៀន (ចំនួន១០ម៉ោង)*
*៥. មេរៀនទី៥ : ពាក្យចួន(ចំនួន៥ម៉ោង)*
*៦. មេរៀនទី៦ : ពេលគោរពទង់ជាតិ (ចំនួន១០ម៉ោង)*
*៧. មេរៀនទី៧ : ការប្រាប់ព័ត៌មានផ្ទាល់ខ្លួន(ចំនួន៣ម៉ោង)*

*( ៥១ ម៉ោង ប្រហែល៤សប្ដាហ៍)*

### ៣.២ សមាសភាគសំខាន់ៗនៃស្តង់ដាអំណាន

ដំណាក់កាលសិក្សានីមួយៗគឺមានបញ្ចូលនូវកម្រិត ស្តង់ដាសិក្សាមួយ ឬច្រើនជាងនេះ។ ឧទាហរណ៍ ដំណាក់កាលទី១ មានកម្រិតស្តង់ដាជាក់លាក់១ក ដល់ ១ជ ហើយត្រូវបានបង្ហាញដោយសញ្ញាបួនជ្រុងបញ្ឈរ




មានទាំងលេខនិងអក្សរ សម្គាល់។ លេខបង្ហាញ ឬ សម្គាល់ពីដំណាក់កាល សិក្សា។ ឧទាហរណ៍ លេខ១ បង្ហាញពីដំណាក់កាល

សិក្សាទី១។ អក្សរបង្ហាញ ឬសម្គាល់ពីកម្រិតស្តង់ដាក្នុងដំណាក់កាល។ ឧទាហរណ៍ "ក" ជាកម្រិតស្តង់ដាទី១ ក្នុងដំណាក់កាលទី១។

សមាសភាគផ្សេងៗទៀតនៃកម្រិតស្តង់ដានីមួយៗ ត្រូវបានសង្ខេបក្នុង**រូបភាពទី២**ទំព័រ V។ សមាសភាគទាំង៦នៃស្តង់ដាអំណានមាន ៖ (១)**សមត្ថភាពសិស្ស** (២)**បំណិនអំណាន ឬសំណេរពាក់ព័ន្ធ** (៣)**ខ្លឹមសារ** (៤) **សកម្មភាពគំរូ** (៥)**ការវាយតម្លៃ** **និង(៦)ល្បែងសិក្សា**។ សមាសភាគទាំងនេះបានរៀបចំឡើងដើម្បីជួយគ្រូក្នុងការវាយតម្លៃ ថាតើសិស្សបានទទួលធាតុស្នូលនៃកម្រិតស្តង់ដានិងអភិវឌ្ឍការយល់ដឹងរបស់ពួកគេបានកម្រិតណា។ ឧទាហរណ៍ **សកម្មភាពគំរូ** ជាឧទាហរណ៍មួយដែលបង្ហាញពីសកម្មភាពបង្រៀនដែលគ្រូអាចអនុវត្តបន្ថែមលើសកម្មភាពបង្រៀនមេរៀនដែលមានក្នុងដំណាក់កាលនីមួយៗ។




## ការវាយតម្លៃ

គឺជាការធ្វើតេស្តសិស្សតាមដំណាក់កាលនីមួយៗ តាមរយៈការប្រើប្រាស់ឧបករណ៍តេស្តដែលមានតេស្តសំណេរ និងតេស្តផ្ទាល់មាត់ប្រចាំឆមាស(ឧបសម្ព័ន្ធ២)។ ការវាយតម្លៃនេះបង្ហាញពីការវាស់ស្ទង់កម្រិតស្តង់ដានីមួយៗ អាចធ្វើមួយវគ្គម្តងៗក្នុងអំឡុងដំណាក់កាល ឬធ្វើជារួមនៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗ។ ឧទាហរណ៍  កម្រិតស្តង់ដា១ក ត្រូវនឹងតេស្ត១ក សម្រាប់វាយតម្លៃកម្រិតស្តង់ដា១ក។ កម្រិតស្តង់ដា១ខ តេស្ត សម្រាប់ការវាយតម្លៃកម្រិតស្តង់ដា១ខ។ល។ ក្នុងឧបសម្ព័ន្ធ២នេះ ក៏មានផ្តល់តេស្តផ្ទាល់មាត់ប្រចាំឆមាស ដើម្បីវាយតម្លៃលើបំណិនអានស្ទាត់។ តេស្តផ្ទាល់មាត់គ្រូត្រូវធ្វើជាមួយសិស្សម្តងម្នាក់ៗ។ ដូច្នេះគ្រូ ត្រូវចំណាយពេលច្រើន។តេស្តផ្ទាល់មាត់ត្រូវធ្វើឡើងនៅចុងបញ្ចប់នៃឆមាសនីមួយៗ។

វាមានសារៈសំខាន់ដែលត្រូវចងចាំថា ឧបករណ៍តេស្តដែលមានផ្តល់ក្នុងឯកសារនេះ**មិនត្រូវ**ប្រើក្នុងបំណងដើម្បីបញ្ចូលពិន្ទុរបស់សិស្សទៅក្នុងសៀវភៅពិន្ទុទេ។ តេស្តកម្រិតស្តង់ដាក្នុងសៀវភៅនេះគឺមានបំណងប្រើជា**ការវាយតម្លៃ** ដើម្បីពង្រឹងការអាន និងសរសេរ។

ករណីគ្រូត្រូវការពិន្ទុតេស្តប្រចាំខែ ឬឆមាសជាផ្លូវការ គ្រូអាចប្រើឧបករណ៍តេស្តដទៃទៀតដើម្បីធ្វើតេស្តសិស្ស និងកត់ត្រាពិន្ទុទុកក្នុងបញ្ជីពិន្ទុសិស្ស។



*សកម្មភាពសិស្សកំពុងធ្វើតេស្តដំណាក់កាលក្នុងថ្នាក់រៀន*

## ល្បែងសិក្សា

ក្នុងកម្រិតស្តង់ដានីមួយៗមានល្បែងសិក្សាដែលជួយពង្រឹងសមត្ថភាពអាន និងសរសេរ និងទាក់ទាញចំណាប់អារម្មណ៍សិស្សឱ្យចូលចិត្តលេង។ ខណៈពេលដែលសិស្សលេងល្បែងទាំងនោះ ពួកគេនឹងពង្រឹងការយល់ដឹងអំពីកម្រិតស្តង់ដាជាក់លាក់។ **គ្រូអាចចាត់ឱ្យសិស្សលេងល្បែងទាំងនេះក្នុងអំឡុងពេលចេញលេងពេលសិក្សា ឬក្នុងបណ្ណាល័យសាលារៀន។** ការរៀបចំកៀនសិក្សាក្នុងបន្ទប់រៀនជាវិធីមួយទៀតដែលគ្រូអាចបង្កឱ្យសិស្សបានលេងល្បែងសិក្សាទាំងនេះ។ ល្បែងសិក្សានីមួយៗត្រូវបានសង្ខេបក្នុង**ឧបសម្ព័ន្ធ១** នៃឯកសារនេះ។ ល្បែងទាំងនេះក៏មានលក់ក្នុងទីផ្សារនៃប្រទេស កម្ពុជា។ ប្រសិនបើសាលារបស់អ្នកមិនសូវមានសម្ភារៈសូមទាក់ទងនាយកសាលារបស់អ្នក។ ដូច្នេះសាលារៀនរបស់អ្នកអាចស្វែងរកវិធីក្នុងការទិញវា។ អ្នកក៏អាចសាកល្បងបង្កើតសម្ភារៈទាំងនេះនិងល្បែងស្រដៀងនេះដោយប្រើសម្ភារៈក្នុងមូលដ្ឋានរបស់អ្នកបានផងដែរ។

*រូបភាពទី២ : សមាសភាគនៃស្តង់ដាអំណាន*

**១. សមត្ថភាពសិស្ស :** ផ្នែកនេះបង្ហាញអំពីសមត្ថភាពអំណានដែលសិស្សត្រូវសម្រេចឱ្យបានក្នុងពេលសិក្សាតាមដំណាក់កាលនីមួយៗ។

**២. បំណិនអំណាន :** ផ្នែកនេះបង្ហាញអំពីបំណិនមួយឬច្រើនក្នុងចំណោមបំណិនអំណានទាំង៥ដែលសិស្សត្រូវចេះរួមមាន ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ។

លេខ ១ក

**សិស្សកំណត់សូរដើមនិងសូរបន្ទាប់តាមរយៈ: ការស្តាប់ពាក្យដែលគ្រូអាន និងសរសេរ**

**បំណិនអំណានពាក់ព័ន្ធ :** ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ

សូមមើល មេរៀនទី ១ ៣ ៤ និង៦ (ទំព័រទី ២ ៧ ១២ ១៧)

**ខ្លឹមសារ**

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី ១ ៣ ៤ និង៦ដូចជា **ការ កុំ ជា តុ ខំ ធំ ឈរ ទី កូន បាន រៀន នេះ លេង...។**

**៣. ខ្លឹមសារ :** ផ្នែកនេះបង្ហាញពីខ្លឹមសារសង្ខេបដែលសិស្សត្រូវរៀនតាមដំណាក់កាលនីមួយៗ ដូចជា តួអក្សរ វណ្ណយុត្តិ។ល។

**សកម្មភាពគំរូ**

☑ ក្រោយពីកំណត់ពាក្យថ្មីក្នុងមេរៀន ឬពាក្យផ្សេងទៀតដែលសិស្សមិនទាន់ចេះ គ្រូត្រូវនិយាយប្រាប់សិស្សឱ្យកំណត់សូរដែលគេឮក្នុងពាក្យនោះ។ (ការស្គាល់សូរ)

*ឧទាហរណ៍*

- ពាក្យ "ថា" មានសូរចំនួន២ គឺ "ថ" សូរដើម និង "អា" សូរបន្ទាប់
- ពាក្យ "រៀន" មានសូរចំនួន៣ គឺ "រ" សូរដើម និង "អៀ" និង "ន" សូរបន្ទាប់ ប៉ុន្តែ មិនមានន័យថាមានតួអក្សរចំនួន២ ឬ៣នោះទេ។

**៤. សកម្មភាពគំរូ :** ផ្នែកនេះ ផ្តល់កិច្ចការជាក់លាក់ឆ្លើយតបទៅនឹងសមត្ថភាពសិស្ស។ បើសិស្សបំពេញកិច្ចការមួយឬច្រើនបានជោគជ័យ នោះមានន័យថាសិស្សទទួលបាននូវសមត្ថភាពអានកាន់តែប្រសើ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ១ក**

**៥. ការវាយតម្លៃ :** ផ្នែកនេះបង្ហាញពីឧបករណ៍តេស្តដែលមានក្នុងឧបសម្ព័ន្ធ២ដែលគ្រូអាចប្រើប្រាស់ដើម្បីវាយតម្លៃសមត្ថភាពសិស្ស ដោយផ្អែកទៅតាមបំណិនអំណានគឺមានទាំង តេស្តសំណេរ និងផ្ទាល់មាត់។

**៦. ល្បែងសិក្សា :** ផ្នែកនេះបង្ហាញអំពីល្បែងសិក្សាដែលគ្រូអាចប្រើប្រាស់ដើម្បីលើកកម្ពស់សមត្ថភាពអានសរសេរដល់សិស្ស។

*សេចក្តីពន្យល់ : ស្តង់ដាអំណាននីមួយៗនៅក្នុងសៀវភៅនេះមានសមាសភាគសំខាន់ៗចំនួន៦។ សូមមើលសេចក្តីពន្យល់ក្នុងដ្យាក្រាមខាងលើដែលដកស្រង់ពីដំណាក់កាលទី១កម្រិតស្តង់ដាលេខ១ក ទំព័រទី២ នៃឯកសារនេះ។*

## ៤. អំពីបំណិនអំណាននិងសំណេរ

### ៤.១. បំណិនអំណាន

ដើម្បីឱ្យការប្រើប្រាស់កម្រិតស្តង់ដានៅក្នុងសៀវភៅនេះឱ្យមានប្រសិទ្ធភាព គ្រូគួរដឹងពីបំណិនអំណានគន្លឹះទាំង៥ដែលមានរៀបរាប់ក្នុងកម្រិតស្តង់ដានីមួយៗ។ ការកត់សម្គាល់បំណិនទាំងនោះត្រូវបានយោងតាមការស្រាវជ្រាវអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ និយមន័យនៃបំណិនទាំងនោះមានដូចខាងក្រោម :

(១) **ការស្គាល់សូរ** គឺសំដៅការបង្រៀនដើម្បីជួយឱ្យសិស្សមានសមត្ថភាពកំណត់ប្រើប្រាស់និងញែកសូរក្នុងពាក្យ។ ***ឧទាហរណ៍*** *សិស្សប្រាប់សូរតួអក្សរក្នុងពាក្យ "ថា" (ថនិងអា "ា")តាមរយៈរូបភាព ឬការស្តាប់ពីគ្រូ។*

(២) **ការស្គាល់តួអក្សរនិងសូរ** គឺសំដៅដល់ការបង្រៀនដែលជួយដល់អ្នកអាន (សិស្ស) យល់និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរនិងសូរ។

***ឧទាហរណ៍*** *សិស្សអាចប្រាប់គ្រូថារូបភាពនៃពាក្យ ថា មានសូរតួអក្សរ ថ។*

(៣) **ការចេះអានស្ទាត់** គឺសំដៅការបង្រៀនដែលជួយពង្រឹងដល់សមត្ថភាពអានឮដោយមានល្បឿនច្បាស់លាស់និងការបង្ហាញគំនិតត្រឹមត្រូវ។

***ឧទាហរណ៍*** *សិស្សអាចអានពាក្យ ឃ្លា ឬល្បះឮខ្លាំងៗហើយលឿន។*

(៤) **ការចេះវាក្យសព្ទ** គឺសំដៅការបង្រៀនដើម្បីបង្កឱ្យមានចំណេះដឹងស្តីពីពាក្យ។ រាប់ទាំងពាក្យប្រើប្រាស់ផ្ទាល់ខ្លួន និងពាក្យសរសេរ ដូចជាតាមរយៈការស្គាល់ពាក្យដោយការឮនិងឃើញ មើល ឬអាន។

***ឧទាហរណ៍*** *សិស្សអាចអានពាក្យចំណាំប្រើញឹកញាប់ដែលគ្រូសរសេរលើក្តារខៀន ឬបង្ហាញលើបណ្ណពាក្យ។*

(៥) **ការអានដើម្បីយល់ន័យ** គឺសំដៅការបង្រៀនដែលធ្វើឱ្យសិស្សមានសមត្ថភាពចូលរួមនិងបញ្ចេញន័យដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។

***ឧទាហរណ៍*** *សិស្សអាចប្រាប់គ្រូអំពីអត្ថន័យនៃល្បះដោយប្រើពាក្យសម្តីផ្ទាល់ខ្លួន។*

ស្តង់ដាអំណានថ្នាក់ទី៣ក៏បានបន្ថែមបំណិនសំណេរសំខាន់ៗមួយចំនួនដូចជា សរសេរតាមអាន សំណេរអក្សរផ្ចង់ និងតែងសេចក្តី។

កម្រិតស្តង់ដានីមួយៗកំណត់បំណិនគន្លឹះមួយឬច្រើនដែលគ្រូត្រូវបង្រៀនក្នុងអំឡុងដំណាក់កាលនីមួយៗ។ គេបានយល់ថាការទទួលយករបស់សិស្សអំពីបំណិនក្នុងការអានមានដំណើរការជាដំណាក់ៗ។ ដូច្នេះបំណិនអំណានគន្លឹះទាំង៥ខាងលើផ្តល់នូវការណែនាំដែលមានសារប្រយោជន៍ដើម្បីកសាងវិធីសាស្ត្រនៃការទទួលយកបំណិនទាំងនោះទៅតាមដំណាក់កាលជាក់លាក់ណាមួយ។ សកម្មភាពគំរូនិងឧបករណ៍វាយតម្លៃផ្តល់ឱ្យគ្រូនូវឧទាហរណ៍ងាយៗជាច្រើននៃបំណិនទាំងនេះ។ ខ្លឹមសារទាំងនេះក៏បានជួយសាងចំណេះដឹងដល់គ្រូទាំងអស់ឱ្យដឹងថាបំណិនអ្វីខ្លះដែលសិស្សត្រូវទទួលយកដើម្បីអាចរៀនបាន។

### ៤.២. បំណិនសរសេរ

សៀវភៅអាន-សរសេរថ្នាក់ទី៣បង្ហាញពីសកម្មភាពក្នុងការពង្រឹងបំណិនសរសេរស្របទៅនឹងអត្ថបទបង្ហាញនៅក្នុងលំហាត់អំណាន។ មានបំណិនមូលដ្ឋាននៃការ-សរសេរចំនួន៤ ដែលបានបង្ហាញ នៅក្នុងសៀវភៅនេះរួមមាន៖

(១) **សំណេរអក្សរផ្ចង់៖** ផ្តល់បំណិនឬសមត្ថភាពសរសេរតួអក្សរបានស្អាតល្អ តាមរយៈការបង្ហាញទម្រង់ទំហំ ក្រុមអក្សរនិងល្វែងក្នុងចន្លោះនីមួយៗ។ ពិសេសរបៀបគូសឬសរសេរ លំនាំគូសបន្ទាត់។ល។

(២) **សរសេរតាមអាន៖** សមត្ថភាពក្នុងការសរសេរពាក្យ ឃ្លា ល្បះ និងអត្ថបទ បានត្រឹមត្រូវទៅតាមការអានរបស់គ្រូ។

(៣) **សំណេរតែងល្បះ ៖** សមត្ថភាពក្នុងការតែងល្បះ បំពេញល្បះ បំពេញល្បះតាមរូបភាព និងការប្រើប្រាស់

សញ្ញាវណ្ណយុត្តិផ្សេងៗបានត្រឹមត្រូវ និងមានន័យគ្រប់គ្រាន់។

(៤) **សំណេរតែងសេចក្ដី៖** សមត្ថភាពសំដែងគំនិតដោយសរសេរល្បះចម្រុះ ដែលបង្ហាញនូវខ្លឹមសារតាមលំដាប់លំដោយបានត្រឹមត្រូវ។ បំណិននេះទាមទារឱ្យសិស្សចេះសរសេរសេចក្ដីផ្ដើម តួសេចក្ដីនិងសេចក្ដីបញ្ចប់បានត្រឹមត្រូវស្របតាមប្រធានបទដែលគ្រូកំណត់។

### ៥.ការឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាប្រព័ន្ធ

នៅក្នុងឯកសារនេះ ផ្ដល់នូវជំហានងាយៗចំនួន៦ ដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីប្រើប្រាស់សម្រាប់កែលម្អសមត្ថភាពអានរបស់សិស្ស។ ជំហានទាំងនេះត្រូវបានសង្ខេបតាមរយៈ**រូបភាពទី៣**ខាងក្រោម ៖

### ៥.១ បង្រៀនមេរៀនរហូតដល់ចប់ដំណាក់កាលនីមួយៗ

គ្រូបង្រៀនត្រូវបង្រៀនខ្លឹមសារមេរៀនក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្របតាមការកំណត់**សមត្ថភាពសិស្ស**ជាសមាសភាគទី១ ក្នុងសៀវភៅស្ដង់ដាអំណាននេះ ឱ្យចប់ដំណាក់កាលនីមួយៗ។ បន្ទាប់មក គ្រូប្រើប្រាស់សកម្មភាពគំរូ និងល្បែងសិក្សា ដើម្បីរៀបចំកិច្ចតែងការបង្រៀនឱ្យមានប្រសិទ្ធភាព។

### ៥.២ វាយតម្លៃសិស្សដោយប្រើប្រាស់តេស្តសំណេរដែលចង្អុលបង្ហាញក្នុងកម្រិតស្តង់ដានីមួយៗ

នៅចុងបញ្ចប់ដំណាក់កាលនីមួយៗ គ្រូត្រូវប្រើប្រាស់ឧបករណ៍វាយតម្លៃដែលមាននូវក្នុងឧបសម្ព័ន្ធ២ សម្រាប់ធ្វើតេស្តសិស្ស។ តេស្តទាំងនេះ គ្រូអាចរៀបចំអ៊ុតជាសន្លឹកប្លាស្ទិកងាយស្រួលប្រើប្រាស់នៅតាមសាលារៀន រៀងខ្លួន។

ការធ្វើតេស្តសិស្សផ្ដោតលើគំនិតសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- សិស្សម្នាក់ត្រូវធ្វើតេស្តជាបុគ្គល។
- ចម្លើយរបស់តេស្តសំណេរត្រូវសរសេរដោយប៊ិកហ្វឺតលើសន្លឹកអ៊ុត។ ការធ្វើបែបនេះគ្រូអាចលុបចម្លើយចេញនៅពេលបញ្ចប់តេស្តសម្រាប់ប្រើលើកក្រោយទៀត។
- គ្រូត្រូវកំណត់ពេលឱ្យបានសមស្របសម្រាប់ធ្វើតេស្ត។ ជាទូទៅរយៈពេលប្រហែល៣០នាទីគឺអាចគ្រប់គ្រាន់ហើយ។
- ពេលបញ្ចប់តេស្ត គ្រូប្រមូលកិច្ចការសិស្សកែ។
- គ្រូត្រូវបញ្ជាក់ប្រាប់សិស្សថា ការធ្វើតេស្តនេះគឺដើម្បីជួយពួកគេ។ ដូច្នេះ វាមិនមានបញ្ហាអ្វីទេ នៅពេលមានចម្លើយខុសនោះ។ គ្រូត្រូវចាំថា តេស្តនេះ គឺប្រើសម្រាប់ជួយសិស្សរៀនយឺត ដើម្បីពង្រឹងសមត្ថភាពអាន និងសរសេរ។ ដូច្នេះ គ្រូមិនចាំបាច់កត់ត្រាពិន្ទុសិស្សក្នុងបញ្ជីពិន្ទុឡើយ។ ពោលគឺ គ្រូត្រូវកត់ត្រាទុកក្នុងបញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម។(**តារាងឧបសម្ព័ន្ធ៣**)
- ចំពោះសិស្សរៀនយឺត មាតាបិតាសិស្សត្រូវជួយណែនាំហើយសិស្សខ្លួនឯងផ្ទាល់ត្រូវហ្វឹកហាត់រៀនបន្ថែមជាមួយគ្នានៅផ្ទះជាប្រចាំ។

### ៥.៣ ត្រួតពិនិត្យលទ្ធផលតេស្តនិងជ្រើសរើសល្បែងសិក្សាសមស្របដើម្បីដោះស្រាយបញ្ហា

គ្រូត្រូវត្រួតពិនិត្យចម្លើយរបស់សិស្ស បន្ទាប់ពីធ្វើតេស្ត។ តេស្តក្នុងដំណាក់កាលនីមួយៗមានច្រើនកម្រិតស្តង់ដា។ ឧទាហរណ៍ កម្រិតស្តង់ដា១ក ១ខ ១គ។ល។ ពិន្ទុតេស្តប្រើដើម្បីកំណត់ឱ្យដឹងពីភាពរីកចម្រើននៃសមត្ថភាពសិស្ស។ (**តារាងទី១ទំព័រទី ix**)

បើសិស្សទទួលបានពិន្ទុក្រោម៥០%ក្នុងកម្រិតស្តង់ដាណាមួយ(**១ក**) ពួកគេត្រូវពង្រឹងបន្ថែមតាមរយៈជាការជ្រើសរើសល្បែងសិក្សា ដើម្បីហ្វឹកហាត់។ សាលារៀនអាចមានល្បែងសិក្សាទាំងនេះនៅក្នុងបណ្ណាល័យ។ បើគ្មានល្បែងសិក្សា គ្រូអាចផលិតដោយប្រើប្រាស់សម្ភារៈងាយៗនៅមូលដ្ឋាន ដើម្បីប្រើប្រាស់ឬស្នើសុំឱ្យនាយក

សាលារៀនទិញដោយប្រើថវិកាសាលារៀន។

### ៥.៤ ជួបជាមួយគ្រូបង្វឹកអំណានដើម្បីពិភាក្សាលទ្ធផលតេស្តកម្រិតស្តង់ដានិងសកម្មភាពតាមដានផ្សេងៗ

បន្ទាប់ពីធ្វើតេស្តកម្រិតស្តង់ដារួច គ្រូត្រូវជួបជាមួយគ្រូបង្វឹកអំណានប្រចាំសាលារៀន ដើម្បីកំណត់រកសិស្សដែលមានតម្រូវការរៀនបន្ថែមនូវកម្រិតស្តង់ដាណាមួយដែលពួកគេជួបការលំបាក។ គ្រូត្រូវកត់ឈ្មោះសិស្សទាំងនេះនិងសកម្មភាពតាមដានជួយផ្សេងៗនៅក្នុងតារាងតាមដានសិស្ស ដែលមានក្នុង**ឧបសម្ព័ន្ធ៣**។

សកម្មភាពតាមដានជួយសិស្សមួយចំនួនមានដូចជា៖

- **ល្បែងសិក្សាក្នុងបណ្ណាល័យ**
- **ល្បែងសិក្សាក្នុងថ្នាក់រៀន (កៀនសិក្សា)**
- **ការសិក្សាតាមសុសវែរល្បែងសិក្សាចល័តក្នុងបណ្ណាល័យ**
- **សៀវភៅបន្ថែមក្នុងបណ្ណាល័យ**
- **ផ្តល់បណ្ណពិន្ទុសិស្សទៅមាតាបិតា**
- **សកម្មភាពសិស្សធំជួយសិស្សតូច**
- **សកម្មភាពបង្រៀនពីមាតាបិតា**
- **ការប្រជុំគ្រូបង្វឹកអំណាន និងមាតាបិតាសិស្ស។**

### ៥.៥ រាយការណ៍លទ្ធផលតេស្ត ទៅមាតាបិតា ដើម្បីឱ្យពួកគាត់ជួយបង្រៀនកូន

នៅពេលបំពេញបណ្ណរបាយការណ៍ពិន្ទុសិស្សដែលមានបង្ហាញក្នុង**ឧបសម្ព័ន្ធ៤** ដើម្បីផ្ញើទៅមាតាបិតា គ្រូបង្រៀនគួរកំណត់សម្គាល់អំពីសមត្ថភាពសិស្ស ឬកម្រិតស្តង់ដាដែលសិស្សជួបការលំបាក។ ពោលគឺសិស្សដែលមានមធ្យមភាគក្រោម៥០% គ្រូត្រូវណែនាំល្បែងសិក្សាដើម្បីជួយសិស្សឱ្យរីកចម្រើន នៅក្នុងកម្រិតស្តង់ដាណាមួយ។ គ្រូត្រូវប្រាប់មាតាបិតាឱ្យពួកគាត់ខ្ចីសម្ភារៈពីបណ្ណាល័យយកទៅជួយបង្រៀនកូននៅផ្ទះបាន។ សម្ភារៈទាំងនោះរួមមាន៖ ល្បែងសិក្សា សៀវភៅអំណានបន្ថែម ព្រមទាំងសុសវែរ អានខ្មែរក្នុងបច្ចេកវិទ្យាចល័ត ល្បែងសិក្សាសម្រាប់ដាក់ក្នុងទូរស័ព្ទទំនើប បើសិនជាពួកគាត់មាន។ សម្ភារៈទាំងនេះអាចខ្ចីបាននៅសាលារៀនក្នុងរយៈពេលយ៉ាងយូរមួយសប្តាហ៍។

*រូបភាពទី៣ : របៀបឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាប្រព័ន្ធ*



*តារាងទី១ : ការកំណត់ពិន្ទុ សម្រាប់វាយតម្លៃសមត្ថភាពសិស្សតាមរយៈតេស្តអំណាន*

| %ចម្លើយត្រឹមត្រូវ | និទ្ទេស |
|---|---|
| ៩៥% ដល់ ១០០% | ល្អណាស់ |
| ៨០% ដល់ ៩៤% | ល្អ |
| ៦៥% ដល់ ៧៩% | បង្គួរ |
| ៥០% ដល់ ៦៤% | មធ្យម |
| ០% ដល់ ៤៩% | ខ្សោយ |

## ៥.៦ រៀបចំឱ្យសិស្សហ្វឹកហាត់រហូតដល់ពេលចាប់ផ្តើមដំណាក់កាលបន្ទាប់ទៀត

សិស្សម្នាក់ៗត្រូវហ្វឹកហាត់ឱ្យបានទៀងទាត់តាមរយៈល្បែងសិក្សាដែលបានបង្ហាញជូននៅខាងក្រោមកម្រិតស្តង់ដានីមួយៗ។ ឧបករណ៍សិក្សាទាំងនេះ ភាគច្រើនជាល្បែងសិក្សាសម្រាប់ពង្រឹងបំណិនអំណានរួមមាន ការចេះអានស្ទាត់ ការអានដើម្បីយល់ន័យ។ល។ ល្បែងសិក្សាទាំងនេះនិងសម្ភារៈផ្សេងៗទៀតគួរមានជាស្រេចនៅក្នុង បណ្ណាល័យ ឬកៀនសិក្សាក្នុងថ្នាក់បើគ្រូបានរៀបចំ។ នាយករងដែលទទួលបន្ទុកបច្ចេកទេសត្រូវតាមដានជួយបណ្ណារក្សដើម្បីធានាថាសកម្មភាពទាំងអស់មានដំណើរការជាទៀងទាត់។ បើសិនជាសាលារៀនមានគ្រូ បង្វឹកអំណានដែលជួយគ្រូបង្រៀនក្នុងការកែលម្អសមត្ថភាពអានរបស់សិស្ស គាត់គឺជាអ្នកដែលត្រូវតាមដានជួយសកម្មភាពទាំងអស់នេះឱ្យបានជាប្រចាំ។ ខណៈដែលសកម្មភាពពង្រឹងអំណានទាំងអស់នេះកើតឡើងនៅក្រៅម៉ោងរៀន គ្រូគួរបន្តបង្រៀនកម្រិតស្តង់ដាផ្សេងៗទៀតនៅក្នុងដំណាក់កាលបន្ទាប់។



*សកម្មភាពសិស្សហ្វឹកហាត់ល្បែងសិក្សាពង្រឹងអំណានក្នុងសាលារៀន*

## ៦. អន្តរាគមន៍មានប្រយោជន៍សម្រាប់ជួយសិស្សដែលមានតម្រូវការរៀនបន្ថែម

គ្រូអាចជ្រើសរើស អន្តរាគមន៍ នៅពេលកំណត់បានសិស្ស ដែលមានតម្រូវការរៀនបន្ថែមជាមួយគ្រូបង្វឹកអំណាននៅតាមសាលារៀននីមួយៗ ដោយសម្រេចចិត្តថា តើគួរជ្រើសរើសសកម្មភាពណាខ្លះដើម្បីជួយសិស្សដែលមានតម្រូវការរៀនបន្ថែម ដូចមានខាងក្រោម៖

### ៦.១ ល្បែងសិក្សាក្នុងបណ្ណាល័យ

កម្រិតស្តង់ដានីមួយៗក្នុងសៀវភៅស្តង់ដាអំណានគឺមានយោងអំពីល្បែងសិក្សាដែលមាននៅក្នុងហិបសម្ភារៈអំណាន ដែលប្រើប្រាស់សម្រាប់ពង្រឹងកម្រិតស្តង់ដានោះ។ តាមរយៈការយោងល្បែងសិក្សានិងលទ្ធផលតេស្តរបស់សិស្សដែលជួបបញ្ហាក្នុងការអាន គ្រូបង្វឹកអំណាន និងគ្រូនឹងអាចកំណត់ថាល្បែងសិក្សាណាមួយដែលមានប្រយោជន៍បំផុតសម្រាប់បម្រើឱ្យការអានកាន់តែប្រសើរដល់សិស្ស។ បណ្ណារក្សដែលបានចូលរួមការប្រជុំជាមួយគ្រូបង្វឹកអំណាននិងគ្រូក៏ត្រូវដឹងថាល្បែងសិក្សាមួយណាសម្រាប់សិស្សលេង។ ល្បែងសិក្សាទាំងនេះគួរមានចំនួនច្រើនល្មមនៅក្នុងបណ្ណាល័យដើម្បីឱ្យសិស្សអាចលេងម្នាក់ឯង ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ឬលេងជាក្រុម។



*សកម្មភាពសិស្សហ្វឹកហាត់ល្បែងសិក្សាពង្រឹងអំណាន នៅក្នុងបណ្ណាល័យ*

## ៦.២ ល្បែងសិក្សាក្នុងថ្នាក់រៀន

គ្រូត្រូវបង្កើតកៀនសិក្សានៅក្នុងថ្នាក់រៀនដើម្បីឱ្យសិស្សអាចលេងល្បែងសិក្សាដែលមាននៅក្នុងហិបសម្ភារៈអំណាន។ ដូចគ្នានេះដែរ ការលេងសិក្សាក្នុងបណ្ណាល័យ គ្រូត្រូវណែនាំសិស្សដែលជួបការលំបាកក្នុងការអានឱ្យហ្វឹកហាត់លេងល្បែងសិក្សាណាមួយតាមការកំណត់របស់គ្រូ ផ្អែកតាមកម្រិតស្តង់ដាដែលពួកគេជួបការលំបាក។ ល្បែងទាំងនេះគួរមានជាស្រេចក្នុងកៀនសិក្សា។ ដូច្នេះ សិស្សអាចលេងបានក្នុងពេលចេញលេងឬពេលឈប់សម្រាក។ ជម្រើសមួយផ្សេងទៀត គ្រូអាចផ្តល់ល្បែងទាំងនេះដល់សិស្សដើម្បីលេងខណៈដែលខ្លួនកំពុងកែ តេស្ត ឬកែកិច្ចការសិស្សធ្វើនៅផ្ទះ។ ដូច្នេះ សិស្សទទួលបានឱកាសច្រើនក្នុងការលេងល្បែងនៅសាលារៀន។

## ៦.៣ សៀវភៅបន្ថែមក្នុងបណ្ណាល័យ

វិធីបង្រៀនអំណានដែលល្អមួយក្នុងចំណោមវិធីផ្សេងៗទៀតគឺ ការផ្តល់ឱកាសឱ្យសិស្ស ហ្វឹកហាត់បំណិនអំណានពាក់ព័ន្ធ។ សៀវភៅអំណានបន្ថែម ត្រូវមាននៅក្នុងបណ្ណាល័យ ដែលសិស្សអាចយកមកអានដោយសេរី និងសប្បាយរីករាយ។ ម្យ៉ាងទៀតគ្រូអាចរៀបចំកៀនអំណាននៅក្នុងថ្នាក់រៀនផងដែរ ដើម្បីឱ្យសិស្សអានពេលចេញលេង។

## ៦.៤ ការផ្តល់បណ្ណពិន្ទុសិស្សទៅមាតាបិតាសិស្សដើម្បីជួយបង្រៀនកូន

តួនាទីរបស់មាតាបិតាសិស្សក្នុងការជួយសិស្សរៀនអានគឺមានសារៈសំខាន់ណាស់។ មាតាបិតាសិស្សអាចផ្តល់នូវការ គាំទ្របានយ៉ាងល្អ នៅពេលពួកគេយល់ដឹងអំពីផ្នែកណាមួយដែលត្រូវជួយកូនរបស់ពួកគេ។ បន្ទាប់ពីធ្វើតេស្តតាមដំណាក់កាលចប់ គ្រូត្រូវបំពេញ**បណ្ណពិន្ទុសិស្ស** ដើម្បីប្រាប់មាតាបិតាសិស្សអំពីផ្នែកឬសមត្ថភាពដែលសិស្សកំពុងជួបការលំបាក។ បណ្ណពិន្ទុនេះគឺប្រើសម្រាប់តែសិស្សណាដែលទទួលបានពិន្ទុក្រោម៥០% ពីតេស្តដំណាក់កាលតែប៉ុណ្ណោះ។ បណ្ណពិន្ទុសិស្សប្រាប់អំពីប្រភេទល្បែងសិក្សានិងសកម្មភាពដែលមាតាបិតាសិស្សគួរលេងជាមួយកូន ដើម្បីពង្រឹងសមត្ថភាពអានរបស់កូន។ មាតាបិតាអាចសុំខ្ចីល្បែងសិក្សាទាំងនេះពីបណ្ណាល័យសាលារៀនតាមរយៈការបង្ហាញបណ្ណពិន្ទុសិស្សដែលមានហត្ថលេខារបស់គ្រូ។ បណ្ណពិន្ទុក៏មាននូវការស្នើឱ្យមាតាបិតាសិស្សជួបជាមួយគ្រូបង្វឹកអំណានដើម្បីឱ្យពួកគាត់ចេះធ្វើផែនការជួយកូនរបស់ពួកគាត់កាន់តែប្រសើរឡើងនៅផ្ទះ។

## ៦.៥ សកម្មភាពសិស្សជួយសិស្ស

ជាទូទៅសិស្សចូលចិត្តលេងជាមួយគ្នា។ ដូច្នេះ សាលារៀនអាចប្រើទម្លាប់ពីធម្មជាតិ នៃការលេងជាមួយគ្នាដោយរៀបចំជាសកម្មភាពសិស្សជួយសិស្ស។ នៅក្នុងសកម្មភាពនេះ សិស្សធំដែលរៀនក្នុងថ្នាក់ទី ៥ និង៦ អាចចាត់ចែងពួកគេជួយបង្រៀនអំណានដល់សិស្សតូច។ សិស្សធំអាចទទួលល្បែងសិក្សាពីសាលារៀនសម្រាប់លេងជាមួយសិស្សតូច ដោយផ្អែកលើអ្វីដែលសិស្សតូចនោះកំពុងជួបការលំបាក។ គ្រូបង្វឹកអំណានត្រូវជួយក្នុងការរៀបចំសកម្មភាពទាក់ទងនឹងការបង្កើតល្បែងសិក្សានិងទីកន្លែងសម្រាប់ដំណើរការសកម្មភាពនេះមាន ដូចជានូវក្រោមដើមឈើនិងលើកៅអីក្នុងទីធ្លាសាលាជា ដើម។



*សកម្មភាពសិស្សធំជួយសិស្សតូចក្នុងសាលារៀន*



*សកម្មភាពមាតាបិតាសិស្សជួយបង្រៀនកូនក្នុងបណ្ណាល័យ*

## ៦.៦ ការជួយបង្រៀនពីមាតាបិតាសិស្ស

គ្រូបង្រៀននិងគ្រូបង្វឹកអំណានគួរលើកទឹកចិត្តមាតាបិតាសិស្សឱ្យចេះជួយកូនរបស់ពួកគេហ្វឹកហាត់រៀនអំណាននៅផ្ទះ។ បណ្ណពិន្ទុសិស្សដែលបានរៀបរាប់ខាងដើម ជាវិធីមួយមានសារៈសំខាន់ក្នុងការផ្តល់ព័ត៌មានដល់មាតាបិតាសិស្ស។សាលារៀនត្រូវរៀបចំ និងណែនាំចំណុចមួយចំនួនដល់មាតាបិតាសិស្សដូចខាងក្រោម ៖

- ផ្តល់បណ្ណពិន្ទុសិស្សទៅមាតាបិតាឱ្យបានទៀងទាត់អំពីសិស្សដែលជួបការលំបាកក្នុងការអាន។
- អនុញ្ញាតឱ្យមាតាបិតាសិស្សខ្ចីល្បែងសិក្សានិងសៀវភៅអានពីបណ្ណាល័យសម្រាប់លេងនិងអានជាមួយកូននៅផ្ទះ។
- ចំពោះមាតាបិតាសិស្សណាដែលមានទូរស័ព្ទទំនើប អាចអញ្ជើញពួកគាត់មកសាលារៀន ហើយដំឡើងសុសវែរ (Software) ល្បែងសិក្សាទាំងនេះទៅក្នុងទូរស័ព្ទរបស់ពួកគាត់។ ដូច្នេះ សិស្សនឹងអាចលេងល្បែងទាំងនៅតាមផ្ទះបានផងដែរ។
- ពន្យល់មាតាបិតាសិស្សអំពីរបៀបតាមដានការសិក្សារបស់កូននៅក្នុងសុសវែរល្បែងសិក្សាដែលប្រើទូរស័ព្ទទំនើប។ ការធ្វើបែបនេះ នឹងជួយឱ្យមាតាបិតាសិស្ស ដឹងអំពីផ្នែកណាមួយដែលពួកគាត់ត្រូវជួយកូនៗបានទាន់ពេលវេលា។

## ៦.៧ ការប្រជុំគ្នារវាងគ្រូបង្វឹកអំណាននិងមាតាបិតាសិស្ស

គ្រូបង្វឹកអំណានគឺជាតួនាទីថ្មីនៅក្នុងសាលារៀនដែលជួយពង្រឹងទំនាក់ទំនងឱ្យកាន់តែប្រសើរឡើង រវាងមាតា-បិតាសិស្សនិងសាលារៀន ជាពិសេសទាក់ទងនឹងការអាន។ គ្រូបង្វឹកអំណានអាចជាមនុស្សមកពីសហគមន៍ សមាជិកក្រុមប្រឹក្សាឃុំ ឬជាគ្រូបង្រៀន។ គ្រូបង្វឹកអំណានជួបប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីផ្តល់ការណែនាំអំពីរបៀបជួយកូនបណ្តុះបំណិនអំណានឱ្យមានភាពរីកចម្រើន។ គ្រូបង្វឹកអំណានមានតួនាទីយ៉ាងសំខាន់ក្នុងការប្រាស្រ័យទាក់ទងជាមួយមាតាបិតាសិស្ស និងគ្រូ ដើម្បីជួយមាតាបិតាសិស្សឱ្យទទួលបានសម្ភារៈពង្រឹងអំណាន ដែលមានក្នុងសាលរៀន។ សម្ភារៈសិក្សាទាំងនេះរួមមាន៖ ល្បែងសិក្សា សៀវភៅរឿង សៀវភៅសិក្សាគោល ។

## ៧. ព័ត៌មានជំនួយបន្ថែមសម្រាប់គ្រូ

### ៧.១. ទីសេចក្តី (Context Clue)

អ្វីទៅជាទីសេចក្តី? ទីសេចក្តីគឺជាប្រភពព័ត៌មាននៃពាក្យក្នុងល្បះដែលស្ថិតនៅខាងមុខឬបន្ទាប់ពាក្យនោះ ដែលជួយបកស្រាយអត្ថន័យនៃពាក្យនោះ។ គោលបំណងសំខាន់នៃការសិក្សាទីសេចក្តី ដើម្បីពង្រីកបន្ថែមលើការសិក្សាវាក្យសព្ទ ដូចជា វេវចនសព្ទ សទិសសព្ទ បដិសព្ទ ។ល។ ទីសេចក្តីមានច្រើនប្រភេទដូចជា ៖

**១. ទីសេចក្តីកំណត់ន័យរបស់ពាក្យ ជំនួសពាក្យឧទាហរណ៍ឬការយល់ដឹងពីអត្ថន័យនៃពាក្យដោយប្រើប្រាស់ពាក្យ " មាន ដូច ដូចជា " ជាពាក្យជំនួសឱ្យពាក្យ " ឧទាហរណ៍ " ។**

**ឧទាហរណ៍** (១) ខ្ញុំសម្តែងការគោរពចំពោះ

*បុព្វការីជន* ដូចជា *ជីដូនជីតា មាតាបិតា*។ល។

**ឧទាហរណ៍** (២) ខ្ញុំទៅផ្សារទិញ

*ម្ហូប អាហារ* មាន *ត្រី សាច់ បន្លែនិងផ្លែឈើ*។

**២. ទីសេចក្តីកំណត់ការប្រើប្រាស់ពាក្យន័យដូច (វេវចនសព្ទ)ឬពាក្យន័យផ្ទុយ (បដិសព្ទ)** នៅក្នុងល្បះ ដើម្បីសន្និដ្ឋានអត្ថន័យនៃពាក្យមួយផ្សេងទៀតដែលយើងមិនទាន់ដឹងអត្ថន័យរបស់វា។

**ឧទាហរណ៍** (១)

សុខមាន*អារម្មណ៍ល្អ*ពីព្រោះគាត់*សប្បាយចិត្ត*។

**ឧទាហរណ៍** (២)

ខ្ញុំ*ស្រឡាញ់មនុស្សល្អ* ប៉ុន្តែខ្ញុំ*ស្អប់ មនុស្សអាក្រក់*។

**៣. ទីសេចក្តីកំណត់អំណាននិងន័យ**ជុំវិញពាក្យនៅក្នុងល្បះឬការប្រើប្រាស់បរិបទនៃល្បះដើម្បីបកស្រាយន័យរបស់ពាក្យ

**ឧទាហរណ៍** ពូសុខយក***លាមក***គោដាក់ស្រែ។

ដូចនេះ បើកំណត់ការអានថា ៖

(ក) " **លាមក** " បើអានថា លា-មក់ មានន័យថាសិស្សត្រូវកំណត់សូរអាន និងន័យរបស់ពាក្យបានត្រឹមត្រូវបែបនេះតាមរយៈពាក្យបញ្ជាក់៖ គោ ស្រែ ក្នុងល្បះ។

(ខ) " **លាមក** " បើអានថា លា-មក មានន័យថាសិស្សកំណត់សូរអានមិនត្រឹមត្រូវ ហើយក៏ធ្វើឱ្យការកំណត់ន័យរបស់ពាក្យខាងក្រោយពាក្យ "លាមក" មិនបានត្រឹមត្រូវដែរ។ ដូច្នេះ ការប្រើប្រាស់បរិបទក្នុងការកំណត់អំណាន និងន័យមិនត្រឹមត្រូវ។

### ៧.២. លំហាត់ក្លូស្ស (Cloze Exercise)

ក្លូស្ស គឺជាអត្ថបទដែលខ្លឹមសារមួយចំនួនត្រូវបានគេលុបចោលឬដកចេញដូចជា តួអក្សរ ពាក្យ ផ្នែកនៃពាក្យ។ សិស្សត្រូវបំពេញខ្លឹមសារដែលគេលុបចោលឬដកចេញនោះ ផ្អែកតាមបញ្ជីពាក្យនៅលើទំព័រក្រោមអត្ថបទនោះឬពាក្យណាមួយដែលយោងទៅលើការយល់ដឹងរបស់សិស្សទាក់ទងនឹងបរិបទជាទីសេចក្តី។ លំហាត់ក្លូស្ស គឺប្រើដើម្បីជួយសិស្សក្នុងអានដោយការយល់ន័យហ្វឹកហាត់វាក្យសព្ទ វេវចនសព្ទ ពង្រឹងការប្រកបពាក្យនិងរំឭកពីសូររបស់តួអក្សរ។ល។ លំហាត់ក្លូស្ស ជាលំហាត់មួយដែលមានប្រសិទ្ធភាពខ្លាំងក្នុងការបង្រៀនអំណាននិងវាក្យសព្ទ។

លំហាត់ក្លូស្សចាប់ផ្តើមដោយការជ្រើសរើសពាក្យនៅលំដាប់លេខរៀងណាមួយក៏បានចាប់ពីលំដាប់លេខរៀងទី៤ ទៅ ៨នៅក្នុងកថាខណ្ឌឬអត្ថបទ។ ការជ្រើសរើសលំដាប់លេខរៀងកាន់តែតូច (លេខ៤) ធ្វើឱ្យលំហាត់ក្លូស្សកាន់តែលំបាក រីឯលំដាប់លេខរៀងខ្ពស់ (លេខ៨) ធ្វើឱ្យលំហាត់ក្លូស្សកាន់តែមានភាពងាយស្រួល។ ឧទាហរណ៍ បើគ្រូជ្រើសរើសយកពាក្យនៅលំដាប់ទី៦ (កម្រិតលំបាកមធ្យម) គ្រូត្រូវរាប់រៀងរាល់ពាក្យទី៦ក្នុងកថាខណ្ឌឬអត្ថបទ រួចលុបចោលឬដកចេញពាក្យទី៦នោះរហូតចប់កថាខណ្ឌឬអត្ថបទ ហើយគ្រូឱ្យសិស្សរកពាក្យមកបំពេញក្នុងចន្លោះពាក្យដែលបានដកចេញនោះវិញ។ សិស្សត្រូវបំពេញពាក្យណាមួយក៏បាន ដើម្បីជំនួសពាក្យដែលលុបចោលឬដកចេញ ដរាបណាវាត្រូវនឹងបរិបទជាទីសេចក្តីនិងមានន័យគ្រប់គ្រាន់សម្រាប់កថាខណ្ឌឬអត្ថបទនោះ។

**ឧទាហរណ៍** ចូរសង្កេតលំហាត់ក្លូស្សខាងក្រោមដែលគេបានដកចេញនូវពាក្យមួយចំនួននៅរៀងរាល់លំដាប់ទី៦។

មានកុមារម្នាក់មិនសូវខិតខំ...(១)និងមានទម្លាប់អាក្រក់មិន...(២)ខ្លួនប្រាណ។ រាល់សម្លៀកបំពាក់របស់គេ...(៣)ដែលស្អាត។ មុនពេលបរិភោគនំ...(៤)កុមាររូបនេះមិនដែល...(៥)ដៃនឹងសាប៊ូសោះ។ ពេល...(៦)វាយកដៃកខ្វក់នោះ...(៧)ជូតនឹងខ្លួន

ប្រាណឬសម្លៀកបំពាក់។...(៨)វាឈឺ សុខភាពវាទ្រុឌទ្រោម...(៩)ចុះខ្សោយជាលំដាប់។

**ចម្លើយ :**

១. សិក្សា រៀនសូត្រ ២. លាងសម្អាត ៣. ពុំ មិន
៤. ចំណី ម្ហូប អាហារ ៥.លាង សម្អាត ៦.ខ្លះ ៧.ទៅ មក
៨. ក្រោយមក បន្ទាប់មក ក្រោយមកទៀត ៩. និង ហើយ

### ៧.៣ យុទ្ធវិធីបុរេអំណាន (មុនអំណាន)

យុទ្ធវិធីបុរេអំណាន ឬការបង្រៀនមុនអំណានជាវិធីមួយដែលផ្តល់នូវមូលដ្ឋានគ្រឹះដល់សិស្សក្នុងការយល់ដឹង និងទទួលបាននូវភាពរីករាយចំពោះអត្ថបទដែលពួកគេបម្រុងនឹងអាន។ ខាងក្រោមនេះគឺជាការបកស្រាយសង្ខេបអំពីយុទ្ធវិធីបុរេអំណានមួយចំនួនដែលជួយលើកកម្ពស់ការយល់ដឹងឱ្យប្រសើរឡើងក្នុងអំឡុងពេលអានៈ

- **ការលើកទឹកចិត្ត** បង្កការចូលរួម និងទាញការចាប់អារម្មណ៍សិស្សដើម្បីឱ្យពួកគេមានទឹកចិត្តចង់អានអត្ថបទ។ **ឧទាហរណ៍** គ្រូបង្ហាញឧទាហរណ៍ជាក់ស្តែង ឬរូបភាពដែលទាក់ទងអត្ថបទរឿងមុនពេលចាប់ផ្តើមការអាន។
- **ការផ្សារភ្ជាប់ទៅនឹងចំណេះដឹងមានស្រាប់** ជំរុញទឹកចិត្តសិស្សឱ្យបង្ហាញនូវចំណេះដឹងមានស្រាប់របស់ពួកគេដែលពាក់ព័ន្ធនឹងប្រធានបទអំណាន និងធ្វើការផ្សារភ្ជាប់គ្នាដើម្បីឱ្យពួកគេមានគោលដៅសម្រាប់ការអាន។ **ឧទាហរណ៍** គ្រូសួរសិស្សថាតើពួកគេបានដឹងអ្វីខ្លះពីប្រធានបទអំណាន និងបទពិសោធស្រដៀងគ្នា។ល។
- **ការមើលអត្ថបទអំណានត្រួសៗជាមុន** មើលអត្ថបទត្រួសៗមុននឹងអានដើម្បីយល់ដឹងអំពីខ្លឹមសារ ប្រភេទអត្ថបទ (ពាក្យរាយ ពាក្យកាព្យ...) និងចំណងជើង ប្លង់អត្ថបទអំណាន។ល។ ឧទាហរណ៍ គ្រូឱ្យសិស្សមើលប្រភេទអត្ថបទ រួចផ្សារភ្ជាប់ទៅនឹងអត្ថបទដែលមានប្រភេទស្រដៀងគ្នាដែលពួកគេធ្លាប់បានដឹងឬអាន ដោយសួរថាតើពួកគេបានដឹងអ្វីខ្លះអំពីប្រភេទអត្ថបទនោះ?
- **បរិបទ** បង្ហាញនូវប្រធានបទឬផ្ទៃរឿងថ្មីដែលទាក់ទងនឹងអត្ថបទអំណានដែលសិស្សបម្រុងនឹងអានដើម្បីឱ្យសិស្សយល់ដឹងកាន់តែទូលំទូលាយអំពីអត្ថបទ។ **ឧទាហរណ៍** បើសិនជាអត្ថបទអំណានពាក់ព័ន្ធនឹងតំបន់ភូមិសាស្ត្រដែលសិស្សអាចនឹងមិនដឹង គ្រូអាចបង្រៀនពួកគេអំពីចំណុចទាំងនោះជាមុនសិន មុននឹងអាន។
- **ការបង្រៀនបញ្ញត្តិ និងវាក្យសព្ទជាមុន** បង្រៀនបញ្ញត្តិឬវាក្យសព្ទថ្មីៗដែលសិស្សមិនទាន់ដឹងឬក៏អ្វីមួយដែលសិស្សមិនអាចកាត់យល់បានពីបរិបទ និងជាចំណុចមួយដែលចាំបាច់សម្រាប់ការស្វែងយល់អត្ថបទអំណាន។ **ឧទាហរណ៍** សម្រាប់ការបង្រៀនបញ្ញត្តិថ្មី គ្រូអាចផ្តល់ឧទាហរណ៍ដែលទាក់ទងនឹងបញ្ញត្តិនោះ។ ការបង្រៀនវាក្យសព្ទថ្មី គ្រូអាចបង្ហាញពាក្យថ្មីនោះ រួមជាមួយនឹងនិយមន័យ ដល់សិស្សទាំងអស់។
- **ការផ្តោតចំណាប់អារម្មណ៍សិស្ស** ផ្តោតចំណាប់អារម្មណ៍សិស្ស និងប្រាប់ពួកគេអំពីចំណុចសំខាន់ៗដែលពួកគេត្រូវចាប់អារម្មណ៍នៅពេលអាន។ សកម្មភាពទាំងនោះរួមមាន ការសួរសំណួរមុនអំណាន និងការទស្សន៍ទាយ។ **ឧទាហរណ៍** គ្រូឱ្យសិស្សមើលចំណងជើង និងរូបភាពអត្ថបទអំណាន រួចសួរសិស្សថា តើអត្ថបទរឿងនេះនិយាយអំពីអ្វីបើផ្អែកលើចំណងជើងនិងរូបភាព។ ម្យ៉ាងវិញទៀតគ្រូក៏អាចសង្ខេបនូវទិដ្ឋភាពរួមមួយឬពីរឃ្លះអំពីអត្ថបទអំណាន ហើយឱ្យសិស្សបង្កើតសំណួរបែបទស្សន៍ទាយ មុននឹងអានអត្ថបទ។

### ៧.៤ ការសរសេរអក្សរផ្ចង់

ការបង្រៀនអក្សរផ្ចង់ ជាការងារសំខាន់សម្រាប់គ្រូក្នុងការនាំសិស្សហ្វឹកហាត់សរសេរតួអក្សរ ពាក្យ ឃ្លា និងល្បះខ្លីៗ បានស្អាតល្អត្រឹមត្រូវតាមទម្រង់ ទំហំ និងក្រុមអក្សរ។ ដើម្បីឱ្យសិស្សសរសេរអក្សរផ្ចង់បានស្អាតល្អ

គ្រូត្រូវស្គាល់ពីគំរូអក្សរផ្ចង់ទាំងអស់ ដែលចែកជា៧ក្រុម តាមទម្រង់អក្សរ ដែលមានលំនាំតួអក្សរស្រដៀងគ្នា ថែមទៀតទៅតាមលំដាប់ព្យញ្ជនៈ ស្រៈនិស្ស័យ និង ស្រៈពេញតួ ដូចខាងក្រោម៖

ក្រុមទី១ : រ វ អ

ក្រុមទី២ : ក ភ គ ត ឥ ឦ

ក្រុមទី៣ : ច ប ម ឫ ឬ ហ ឃ យ

ក្រុមទី៤ : ល ស ណ ឈ

ក្រុមទី៥ : ង ជ ដ ផ ឋ ថ ឯ

ក្រុមទី៦ : ឆ ធ ព ឮ ញ ឭ ឰ ឍ ឧ

ក្រុមទី៧ : ខ ឱ ឪ ឲ ន ទ ឡ។

តួអក្សរទាំង៧ក្រុមខាងលើនេះ ត្រូវបែងចែកជា៤ពួក ទៀតដែលបង្ហាញពីចំនួនល្វែង និងការកំណត់ទំហំដូច ជា ៖

**ពួកទី១** ហៅថាអក្សរ១ល្វែង មាន៣៣តួគឺ "ក ខ គ ង ច ឆ ជ ដ ឋ ឌ ត ថ ទ ធ ន ប ផ ព ភ ម អ ឥ ឧ ឱ ឪ ឫ ឬ ឭ ឮ ឯ ឰ ឲ ឪ"

**ពួកទី ២** ហៅថា អក្សរ២ល្វែង មាន១០តួគឺ "ឃ ញ ឍ យ ល ស ហ ឡ អា ឦ"

**ពួកទី ៣** ហៅថាអក្សរ៣ល្វែងមាន ២តួគឺ "ឈ និង ណ"

**ពួកទី ៤** ហៅថាអក្សរពាក់កណ្ដាលល្វែងមាន ២តួគឺ "រ និង វ" ចំពោះទំហំស្រៈនិស្ស័យ វិញក៏មានការកំណត់ ដែលគ្រូគួរយល់ដឹង និងបង្រៀនសិស្សឱ្យគូរទៅតាមការ កំណត់ដូចខាងក្រោមដែរ៖

- ទទឹងស្រៈ "ា" ជិតស្មើទទឹងតួព្យញ្ជនៈមួយល្វែង
- ទទឹងស្រៈ "ិ ី ឹ ឺ" ជិតស្មើទទឹងតួ ព្យញ្ជនៈ មួយល្វែង
- ទទឹងស្រៈ "ុ" យក ១ភាគ៣ នៃព្យញ្ជនៈ
- ទទឹងស្រៈ "ូ" យក ២ភាគ៣ នៃព្យញ្ជនៈ
- ទទឹងស្រៈ "ួ" យកជិតស្មើតួព្យញ្ជនៈ។ រីឯកម្ពស់ ស្រៈ "ុ ូ ួ" ក៏យកជិតស្មើពាក់កណ្ដាលនៃតួ ព្យញ្ជនៈ។
- ទទឹងស្រៈ "ៀ ឿ" ស្មើនឹងព្យញ្ជនៈ
- ទទឹងស្រៈ "ំ" យក១ភាគ៣នៃតួព្យញ្ជនៈដែរ។

*១. ការបង្ហាញលំនាំគំរូ*

**ក. របៀបគូសបន្ទាត់**

- ដំបូងគ្រូដឹកបន្ទាត់ផ្ដេក៨ប្រឡោះស្មើៗគ្នាដាក់នៅ លើក្ដារខៀនតាមលំនាំគំរូនេះ បន្ទាត់ផ្ដេកធំ១មាន ៤ ប្រឡោះ តូចៗ។

- បន្ទាប់មក ត្រូវគូសរាងចតុកោណកែង២ នៅដើម បន្ទាត់ ដោយចតុកោណកែង១ មានទទឹង១ក្រឡា និងបន្ទាត់បញ្ឈរ ២ក្រឡា (បន្ទាត់បញ្ឈរស្មើ ២ដង នៃក្រឡាបន្ទាត់ផ្ដេក)។
- ធ្វើបែបនេះឱ្យបានចតុកោណកែង ២ជាប់គ្នា។
- បន្ទាប់មកទៀត ដឹកបន្ទាត់តាមអង្កត់ទ្រូងចតុ កោណកែងដោយចាប់ពីជ្រុងមុំខាងស្ដាំមកចំមុំ ជ្រុងខាងឆ្វេងតាមលំនាំគំរូនេះ។




- ដឹកបន្ទាត់ទ្រេតឱ្យស្របនឹងបន្ទាត់ទ្រេតទី១ រហូតដល់ចុងបន្ទាត់ផ្ដេក។

**ខ. របៀបសរសេរ**

គ្រូត្រូវបែងចែកបន្ទាត់ផ្ដេក (ដែលមាន៤បន្ទាត់តូច) ជា៣ភាគ។

- សរសេរអក្សរ រ ត្រូវក្បួចតួខាងក្រោមត្រឹម ១ភាគ៣ តួ ១ភាគ៣និងសក់ ១ភាគ៣នៃក្រឡាបន្ទាត់ ផ្ដេក។ កម្ពស់អក្សរ រ ពេញ១បន្ទាត់ធំ ទទឹង ១ភាគ ២ នៃចន្លោះបន្ទាត់ទ្រេត។
- អក្សរ វ ត្រូវក្បួចខាងក្រោម ១ភាគ៣ ដូច រ ដែរ តួ ១ភាគ៣ និងសក់ ១ភាគ៣ រួចវាត់ទៅលើ ១ ភាគ២ នៃក្រឡាបន្ទាត់ធំខាងលើ។ កម្ពស់ វ ស្មើ

នឹង ១ ក្រឡាបន្ទាត់កន្លះ។ ទទឹង **រ** ស្មើនឹង ១ភាគ ២ នៃចន្លោះបន្ទាត់ទ្រេត។

- អក្សរ **អ** សរសេរដូច អក្សរ **រ** ២ដង។ ទទឹងអក្សរ **អ** ស្មើនឹង ២ភាគ៣ នៃចន្លោះបន្ទាត់ទ្រេត។ ឯស្រៈ ា ត្រូវសរសេរជិតប៉ុនអក្សរមួយល្វែង។

## ២. *លំណែនាំគូសបន្ទាត់*

**ក.** គ្រូណែនាំសិស្សអំពីរបៀបដឹកបន្ទាត់តាមលំនាំគំរូខាងលើ។ ដោយក្នុងសៀវភៅសរសេររបស់សិស្សមានក្រឡាបន្ទាត់រួចស្រេចហើយ គ្រូគ្រាន់តែណែនាំសិស្សឱ្យដឹកបន្ទាត់ទ្រេតតាមក្រឡាបន្ទាត់ក្នុងសៀវភៅសរសេររបស់សិស្ស។

**ខ.** គ្រូសរសេរគំរូនៅលើក្ដារខៀនយឺតៗ តាមចលនានីមួយៗ។ ឧទាហរណ៍ **រ រ អ អារ ារ** ។

- ដំបូងសរសេរអក្សរ **រ រ អ** កម្ពស់ពេញបន្ទាត់ (ចំនួន១បន្ទាត់)។
- បន្ទាប់មក សរសេរពាក្យ **អារ** កម្ពស់ពេញបន្ទាត់ (ចំនួន១បន្ទាត់)។
- ទីបញ្ចប់សរសេរពាក្យ **ារ** កន្លះបន្ទាត់ (ចំនួន១ បន្ទាត់)។



## ៧.៥. យុទ្ធវិធីគន្លឹះ ក្នុងការសរសេរតែងសេចក្ដី

សំណេរគឺជាមធ្យោបាយទាក់ទងមួយយ៉ាងសំខាន់។ ហេតុនេះ ចាំបាច់សិស្សត្រូវរៀនពីរបៀបបញ្ចេញគំនិតឱ្យបានច្បាស់លាស់ តាមរយៈការសរសេរនៅក្នុងដំណាក់កាលអប់រំដំបូងមកម្ល៉េះ។ ខាងក្រោមនេះជាការណែនាំមួយចំនួនដល់គ្រូក្នុងការបង្រៀនសិស្សផ្នែកសំណេរឱ្យមានបំណិនច្បាស់លាស់។

- **ការសរសេរប្រចាំថ្ងៃ** ជាវិធីល្អបំផុតសម្រាប់សិស្សក្នុងការក្លាយជាអ្នកសរសេរដ៏ពូកែម្នាក់។ គ្រូគួរតែព្យាយាមផ្ដល់ឱកាសឱ្យសិស្សសរសេររាល់ថ្ងៃ។ ការប្រើប្រាស់លំនាំសរសេររួមមាន៖ ការធ្វើសេចក្ដីព្រាង ការចែករំលែក ការកែលម្អ ការត្រួតពិនិត្យ ការវាយតម្លៃ និងការផ្សព្វផ្សាយលទ្ធផលចុងក្រោយ។
- **សំណេរតែងសេចក្ដីមានគម្រោងតែងសំខាន់ៗបីះ** សេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់។ សិស្សត្រូវអនុវត្តការសរសេររបស់ខ្លួនកទៅតាមការណែនាំនិងស្របតាមការកំណត់ប្រធានបទរបស់គ្រូ។
- **យន្តការក្នុងការសរសេរ** សិស្សគួរតែមានទំនុកចិត្តនិងបំណិនមូលដ្ឋានក្នុងការសរសេរ។ កិច្ចការទាំងនេះជំរុញពួកគេឱ្យមានគំនិតសរសេរតាមលំដាប់លំដោយគំនិតទាក់ទងគ្នា ពីល្បះមួយទៅល្បះមួយទៀត និងលំដាប់លំដោយសារៈសំខាន់។
- **បរិស្ថានគាំទ្រ** ពេលខ្លះ សិស្សគួរមានឱកាសជ្រើសរើសប្រធានបទផ្ទាល់ខ្លួនមកសរសេរ ដោយសហការជាមួយមិត្តភក្ដិ តាមការណែនាំរបស់គ្រូ ហើយទទួលព័ត៌មានត្រឡប់ឬការកែលម្អពីមិត្តភក្ដិ និងគ្រូ ក្រោយពេលបញ្ចប់សំណេរ។
- **ពាក្យឬឃ្លាភ្ជាប់សេចក្ដី** ពាក្យឬឃ្លាភ្ជាប់សេចក្ដីមានតួនាទីសំខាន់មួយក្នុងការសរសេរ។ វាជួយឱ្យការសរសេរកាន់តែច្បាស់លាស់ ហើយទំនាក់ទំនងពីគំនិតមួយទៅគំនិតមួយ ពីល្បះមួយទៅល្បះមួយទៀត ធ្វើឱ្យអ្នកជក់ចិត្ត ចាប់អារម្មណ៍។ គ្រូគួរលើកទឹកចិត្តសិស្សឱ្យប្រើប្រាស់ពាក្យឬឃ្លាភ្ជាប់សេចក្ដី ក្នុងការសរសេរ ដើម្បីធ្វើឱ្យល្បះកាន់តែមានភាពសំបូរបែបនិងភ្ជាប់ពីគំនិតមួយទៅមួយ កាន់តែប្រសើរឡើង។

ខាងក្រោមនេះជា តារាងពាក្យ ឃ្លាភ្ជាប់សេចក្ដី ពីល្បះទៅល្បះមួយទៀតតាមតម្រូវការជាក់ស្ដែង។

### ប្រអប់ទី២៖ ឈ្នាប់សំខាន់ៗនិងកិរិយាវិសេសជាជំនួយក្នុងការសរសេរភ្ជាប់ទំនាក់ទំនងល្បះនីមួយៗ

| ផ្នែកសំខាន់ៗ | ឧទាហរណ៍ ៖ ពាក្យ/ឃ្លាមសារ ជាឈ្នាប់សម្រាប់សរសេរ |
|---|---|
| ពេលវេលា/ដំណាក់កាល | បន្ទាប់ ដូចជា មុន ចុងក្រោយ រហូតដល់ នៅពេលដែល ពេលណាក៏ដោយ កំឡុងពេល |
| ហេតុនិងផល | ជាលទ្ធផល ពីព្រោះ ដើម្បី ដោយហេតុ តាំងពី ដូច្នេះ សរុបមក ដែល |
| បន្ថែមទៀត | ផងដែរ លើសពីនោះទៀត បន្ថែមពីនោះ |
| សេចក្ដីសន្និដ្ឋាន | ជាលទ្ធផល ដូច្នេះ ថាតើ |
| ការផ្លាស់ប្ដូរ | ទោះបីជា ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ដរាបណា |
| ការប្រៀបធៀប | ទោះបីជា ច្រើនដូច ដែលដូច ថាតើ ដូចកន្លែងមុន ខណៈដែល នៅឡើយ |
| លក្ខខណ្ឌ | ប្រសិនបើ សូម្បីតែ ក្នុងករណី អ្វីដែលបានបង្ហាញ ដរាបណា |
| ទីកន្លែង | ទីកន្លែងដែល គ្រប់ទីកន្លែង |

# ដំណាក់កាលទី ១ : មេរៀនទី១ ដល់ទី៧ (១៩)

## (ទំព័រទី២ ដល់ទី២៣)

*១. មេរៀនទី១ : សាលាកុមារមេត្រី*

*២. មេរៀនទី២ : វេរចនសព្ទ*

*៣. មេរៀនទី៣ : សិស្សឧស្សាហ៍*

*៤. មេរៀនទី៤ : ការសម្អាតថ្នាក់រៀន*

*៥. មេរៀនទី៥ : ពាក្យជូន*

*៦. មេរៀនទី៦ : ពេលគោរពទង់ជាតិ*

*៧. មេរៀនទី៧ : ការប្រាប់ព័ត៌មានផ្ទាល់ខ្លួន*

*( ៥១ ម៉ោង ប្រហែល៤សប្តាហ៍)*

**កំណត់សម្គាល់ :** **(១៩)** ចំពោះមេរៀនទី៧ សមត្ថភាពនិយាយមានចំនួន៣ម៉ោងសិក្សា។ មេរៀននេះមិនទាក់ទងនឹងស្តង់ដារអំណានទេ។ គ្រូត្រូវបង្រៀនមេរៀននេះតាមធម្មតា។

**លេខ ១ក**

# សិស្សកំណត់សូរដើមនិងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យ ដែលគ្រូអាន និងសរសេរ

*ឧទាហរណ៍* រៀន = រ + ៀ + ន

- "រ" សូរដើម
- "អៀ" និង "ន" សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី២ ទី៧ ទី១២ និងទី១៧)

## ខ្លឹមសារ

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១ ទី៣ ទី៤ និងទី៦ ដូចជា **ការ កុំ ជា តុ ខំ ធំ ឈរ ទី កូន បាន រៀន នេះ លេង...។**
- ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ ក្រោយពីកំណត់ពាក្យថ្មីក្នុងមេរៀន ឬពាក្យផ្សេងទៀតដែលសិស្សមិនទាន់ចេះ គ្រូត្រូវនិយាយប្រាប់សិស្សឱ្យកំណត់សូរដែលគេឮក្នុងពាក្យនោះ។ (ការស្គាល់សូរ)

*ឧទាហរណ៍*

- ពាក្យ "ថា" មានសូរចំនួន២ គឺ "ថ" សូរដើម និង "អា" សូរបន្ទាប់
- ពាក្យ "រៀន" មានសូរចំនួន៣ គឺ "រ" សូរដើម និង "អៀ" និង "ន" សូរបន្ទាប់

ប៉ុន្តែ មិនមានន័យថាមានតួអក្សរចំនួន២ ឬ៣នោះទេ។

សម្គាល់ : គ្រូត្រូវចាំថា មិនត្រូវពណ៌នាសូរនេះទៅជាតួអក្សរទេ ព្រោះនេះជាបំណិនរៀនពី "***ការស្គាល់សូរ***" *តាមរយៈការស្ដាប់*តែប៉ុណ្ណោះ។ គ្រូត្រូវបង្ហាញពីសូរតែម្យ៉ាងប៉ុណ្ណោះ។

☑ គ្រូណែនាំសិស្សឱ្យកំណត់សូរដើមរបស់ពាក្យ តាមរយៈការពន្យល់និងលើកឧទាហរណ៍បញ្ជាក់ ដូចជាពាក្យ "ធំ" គ្រូសួរសិស្សថា តើពាក្យ "ធំ" មានសូរដើម និងសូរបន្ទាប់អ្វីខ្លះ? (ចម្លើយមានសូរដើម "ធ" និងសូរបន្ទាប់ "អុំ")។ (ស្គាល់តួអក្សរនិងសូរ)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ១ក

**លេខ ១ខ**

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ ទេវចនសព្ទនិងសទិសសព្ទ ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការបេះវាក្យសព្ទ**

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី៣ ទី៨ ទី១៣ និងទី១៨)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១ ទី៣ ទី៤ និងទី៦ ដូចជា ៖

**ពន្យល់ពាក្យ**

**មេរៀនទី ១**

- បរិវេណ (ន.) : ទីជិតខាងដែលព័ទ្ធជុំវិញ។
- អគារ (ន.) : មន្ទីរ ផ្ទះ ផាង។
- សួនជីវចម្រុះ (ន.) : ច្បារដំណាំដែលមានរុក្ខជាតិច្រើនមុខនៅក្នុងសាលារៀន។(រុក្ខជាតិគោក អាកាស និងទឹក)។
- ពាក្យស្លោក (ន.) : ពាក្យសម្រាប់អប់រំ ទូន្មាន។
- កុមារមេត្រី (គុ.) : ដែលជាទីសប្បាយរីករាយរបស់កុមារ។

**មេរៀនទី ៣**

- មិត្តភក្តិ (ន.) : អ្នកដែលរាប់អាន ស្រឡាញ់គ្នាជិតស្និទ្ធ។
- ឧស្សាហ៍ (គុ.) : ដែលខិតខំ ព្យាយាម ប្រឹងប្រែង។
- បទបញ្ជា (ន.) : ការបង្គាប់។
- លទ្ធផល (ន.) : ផលសម្រេចបានរួចហើយ។

**មេរៀនទី៤**

- ធូលី (ន.) : ផង់ លម្អង ល្អង។ *ឧទាហរណ៍* ធូលីដីហុយទ្រលោម។
- ភារកិច្ច (ន.) : ការទទួលបន្ទុកការងារ។
- សមាជិក (ន.) : អ្នកដែលចូលរួមប្រជុំ។ *ឧទាហរណ៍* សមាជិកអង្គការ សមាជិកគ្រួសារ។
- កន្ទប (ន.) : សំពត់ចាស់ប្រើសម្រាប់ជូតសម្អាត។

**មេរៀនទី៦**

- សញ្ញាណជាតិ (ន.) : គ្រឿងសញ្ញាសម្គាល់របស់ជាតិ។
- សញ្ជប់ (កិ.) : ជ្រប់មុខ ស្រពោន ស្រពាប់ ក្រៀមក្រំ។
- បុព្វ (គុ.) : មុខ ខាងដើម ពីមុន។
- ជ្វាលា (ន.) : អណ្តាតភ្លើង សេចក្តីរុងរឿង បន្លឺដែភ្លឺព្រោងព្រាត ប្រទីបជ្វាលា។

**បដិសព្ទ**

| | | | | | | |
|---|---|---|---|---|---|---|
| មេរៀនទី១ : | ធំ | ≠ | តូច | ស្រស់ | ≠ | ស្រពោន |
| មេរៀនទី៣ : | ឧស្សាហ៍ | ≠ | ខ្ជិល | ផ្តេសផ្តាស | ≠ | ត្រឹមត្រូវ |
| មេរៀនទី៤ : | ប្រមូល | ≠ | ពង្រាយ | មិត្ត | ≠ | សត្រូវ |
| មេរៀនទី៦ : | រួតរះ | ≠ | ដំអក់ | ជជែក | ≠ | ស្ងៀមស្ងាត់ |

លេខ ១ខ

**បន្ត...**

## ខ្លឹមសារ

**វេវចនសព្ទ**

មេរៀនទី១ : វេវចនសព្ទនឹងពាក្យ "**មេត្រី** ស្រឡាញ់ ស្នេហា ប្រតិព័ទ្ធ"

មេរៀនទី៣ : វេវចនសព្ទនឹងពាក្យ "**មិត្តភក្តិ** សម្លាញ់ ភ្លើ ម្រាក់ ភឿន គូកន"

មេរៀនទី៤ : វេវចនសព្ទនឹងពាក្យ "**ទឹក** គង្គា វារី"

មេរៀនទី៦ : វេវចនសព្ទនឹងពាក្យ "**ភ្នែក** នេត្រា ចក្ខុ ព្រះនេត្រ"។

**សទិសសព្ទ**

មេរៀនទី១ : សទិសសព្ទនឹងពាក្យ " **ជុំ** "

- ជុំ (កិ.) : មូលគ្នា ដំណើរវិលមកកន្លែងដដែលវិញ។ *ឧទាហរណ៍* ដើរមួយជុំ។
- ជំ (កិ.) : ពិគ្រោះ ស្នើឱ្យដឹងការណ៍។ *ឧទាហរណ៍* ចាំជំញាតិមើលសិន។

មេរៀនទី៣ : សទិសសព្ទនឹងពាក្យ " **ចិត្ត** "

- ចិត្ត (ន.) : វិញ្ញាណខាងក្នុងសម្រាប់គិត។ *ឧទាហរណ៍* ចិត្តល្អ សប្បាយចិត្ត។
- ចិត (កិ.) : កាត់ជាចំណិតៗ។ *ឧទាហរណ៍* ចិតបន្លែ។
- ចិត្រ (ន.) : ការដែលគេធ្វើដោយផ្ចិតផ្ចង់រួចហើយ។ *ឧទាហរណ៍* វិចិត្រករ។

មេរៀនទី៤ : សទិសសព្ទនឹងពាក្យ "**ភក្តិ**"

- ភក្តិ (ន.) : សេចក្តីរាប់អាន សេចក្តីស្រឡាញ់ សេចក្តីស្មោះត្រង់ ។
- ភក្ត្រ (ន.) : មុខ ។
- ភ័ក (កិ.) : ឈប់ស្នាក់នៅមួយពេល មួយគ្រា ។

មេរៀនទី ៦ : សទិសសព្ទនឹងពាក្យ "**ជាតិ**"

- ជាតិ (ន.) : កំណើត មនុស្សដែលមានសញ្ជាតិផ្សេងគ្នា។ *ឧទាហរណ៍* ជាតិខ្មែរ ជាតិចិន ។ល។
- ជាត (គុ.) : ដែលកើតហើយ ដែលប្រាកដហើយ។

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យរបស់ពាក្យពិបាកនេះ។ *ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្តាំ ឱ្យត្រូវនឹងនិយមន័យរបស់វា។

| ពាក្យពិបាក | និយមន័យ |
|---|---|
| បរិវេណ | • ទីជិតខាងឆ្ងាយពីគ្នា។<br>• ទីជិតខាងក្បែរៗគ្នា។<br>• ទីជិតខាងដែលព័ទ្ធជុំវិញ។ |
| មិត្តភក្តិ | • អ្នកដែលយើងធ្វើការជាមួយ។<br>• អ្នកដែលរាប់អានស្រឡាញ់គ្នាជិតស្និទ្ធ។<br>• អ្នកដែលយើងរស់នៅជាមួយ។ |

លេខ ១ខ

## បន្ត...

## សកម្មភាពគំរូ

☑ គ្រូបង្កើតបណ្ណពាក្យ ឬសរសេរពាក្យបង្ហាញសិស្សនៅលើក្ដារខៀន រួចឱ្យសិស្សរកបដិសព្ទនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| ធំ | ស្រស់ | ឧស្សាហ៍ | ប្រមូល | រួតរះ | ជជែក | ផ្គេសផ្គាស |

- បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្ដារខៀន។ សិស្សត្រូវនឹករកពាក្យផ្សេងទៀត ដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាននិយមន័យដូចគ្នាទេ តែមានទំនាក់ទំនងជាមួយគ្នាតាមដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ** ដោយមានការបង្ហាញគំនិតពាក់ព័ន្ធផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ "**មិត្តភក្តិ**" ដាក់ក្នុងដ្យាក្រាមនៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដទៃទៀតដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែមិនមែនមានន័យថា រកពាក្យដែលន័យដូចគ្នានោះទេ។ បន្ទាប់មក គ្រូគូសដ្យាក្រាមមួយទៀត រួចសរសេរពាក្យ "ទង់ជាតិ" ហើយឱ្យសិស្សហ្វឹកហាត់រកពាក្យដទៃទៀត ដែលមានទាក់ទងនឹងពាក្យនេះដែរ។







☑ គ្រូគូសតារាងពីរនៅលើក្ដារខៀន។ តារាងទី១វេវចនសព្ទ តារាងទី២បដិសព្ទ។ បន្ទាប់មក គ្រូសរសេរបញ្ជីពាក្យនៅលើក្ដារខៀន ហើយឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទៅតាមប្រភេទនៃតារាងនីមួយៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ ស្រឡាញ់ លើ ស្រស់ តូច ឧស្សាហ៍ ជានិច្ច មេត្រី ធំ មិត្តភក្តិ សម្លាញ់។ គ្រូបង្ហាញឧទាហរណ៍មួយជាគំរូលើតារាងនេះ រួចឱ្យសិស្សរកពាក្យដទៃទៀតដោយខ្លួនឯង។

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| មិត្តភក្តិ សម្លាញ់<br>............................ | ធំ ≠ តូច<br>.................. ≠ .................. |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ តេស្តដំណាក់កាលទី ១ខ

លេខ ១គ

# សិស្សអានពាក្យ អត្ថបទ ដោយមិនបាច់ផ្សំនិងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់ ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី៤ ទី៩ ទី១៤ និងទី១៩)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១ ទី៣ ទី៤ និងទី៦ ដូចជា ៖

**មេរៀនទី១ :** មេត្រី អគារ បរិវេណ ជានិច្ច សិស្សានុសិស្ស ព័ទ្ធ អនាម័យ (ទំព័រទី៤)

**មេរៀនទី៣ :** ឧស្សាហ៍ មិត្តភក្តិ កិច្ចការ បទបញ្ជា ផ្លេសផ្លាស លទ្ធផល (ទំព័រទី៩)

**មេរៀនទី៤ :** ភារកិច្ច កន្ទប បង្គួច ស្អាត បន្ទប់សារសើរ កម្ទេចកម្ទី សម្អាត ថ្នាក់រៀន (ទំព័រទី១៤)

**មេរៀនទី៦ :** ខេមរា សញ្ញាណ សញ្ជាប់ បុព្វបុរស រូតរះ ខ្ទីឃ្មាត បុត្រខេមរា ជាតិប្រជា បុរសជាតិខ្មែរ (ទំព័រទី១៩)។

## សកម្មភាពគំរូ

☑ សិស្សអានពាក្យដោយមិនបាច់ផ្សំ និងប្រកបបានយ៉ាងលឿន តាមការកំណត់របស់គ្រូឬតាមបញ្ជីពាក្យក្នុងលំហាត់។ *ឧទាហរណ៍* មេត្រី អគារ ជានិច្ច បរិវេណ សិស្សានុសិស្ស ព័ទ្ធ អនាម័យ ។

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរ ឬបិទនៅលើក្ដារខៀន។ បន្ទាប់មក គ្រូឱ្យសិស្ស២នាក់ព្យាយាមអានបញ្ជីពាក្យនោះឱ្យបានលឿន ដោយមិនបាច់ផ្សំ និងប្រកបតាមដែលអាចធ្វើទៅបាន។ សិស្សអានបានគ្រប់ពាក្យបានត្រឹមត្រូវហើយចប់មុនគេ សិស្សនោះជាអ្នកឈ្នះ។ គ្រូត្រូវលើកទឹកចិត្តសិស្ស។

*ឧទាហរណ៍*

| | | | |
|---|---|---|---|
| ♦ មេត្រី | ♦ សិស្សានុសិស្ស | ♦ ឧស្សាហ៍ | ♦ បទបញ្ជា |
| ♦ អគារ | ♦ ព័ទ្ធ | ♦ មិត្តភក្តិ | ♦ ផ្លេសផ្លាស |
| ♦ ជានិច្ច | ♦ អនាម័យ | ♦ កិច្ចការ | ♦ លទ្ធផល |
| ♦ បរិវេណ | | | |

☑ គ្រូអានអត្ថបទក្នុងមេរៀនឱ្យសិស្សស្ដាប់។ បន្ទាប់មក គ្រូឱ្យសិស្សក្នុងថ្នាក់ អានបន្ត ឬអានបណ្ដាក់គ្នាម្ដង២ ឬ៣ល្បះរហូតចប់អត្ថបទ។

☑ គ្រូឱ្យសិស្សចាប់ដៃគូជាក្រុម២នាក់។ សិស្សក្នុងក្រុមម្នាក់អានឱ្យឮៗរហូតដល់ចប់ឱ្យសិស្សក្រុមដទៃទៀតស្ដាប់។ បន្ទាប់មក សិស្សដទៃទៀតក្នុងក្រុមអានរហូតចប់អត្ថបទដដែល។ សិស្សក្នុងក្រុមអាចជួយគ្នាទៅវិញទៅមក ប្រសិនគេជួបការលំបាកក្នុងការអានពាក្យពិបាក។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ១គ**

លេខ ១៣

# សិស្សរកសូរចួនក្នុងពាក្យដែលត្រូវអាននិងសរសេរ

- <u>សម្គាល់</u> : មុនបង្រៀនពាក្យចួន ក្នុងអត្ថបទសំណេរគ្រូគួរ ពន្យល់បញ្ញត្តិពាក្យចួនដោយប្រើភាសានិយាយសិន។

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៥ និងទី៦ (ទំព័រទី១៦ និងទី១៧ )**

## ខ្លឹមសារ

និយមន័យ "ពាក្យចួន"

<u>**ពាក្យចួន**</u> គឺជាពាក្យមានសូរស្រៈដូចគ្នា ឬសូរព្យញ្ជនៈប្រកបដូចគ្នានៅក្នុងវគ្គរបស់មេសូត្រ ឬកំណាព្យ។

*ឧទាហរណ៍* មេសូត្រ (បទកាកគតិ) មេរៀន ទី៦ ទំព័រទី១៧

- ពាក្យ "ខេមរា" ចួននឹង "សិក្សា"
- ពាក្យ "ជាតិ" ចួននឹង "ឃ្លាត" ចួននឹង "ឆ្លៀត" ។

## សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យចួនមួយចំនួនលើក្ដារខៀន រួចឱ្យសិស្សរកសូរព្យញ្ជនៈ និងស្រៈណា ដែលមានសូរដូចគ្នានៅខាងចុងឱ្យបានច្រើនតាមដែលអាចធ្វើបាន។

ឧទាហរណ៍

- ពាក្យ "**នារី**" និង "សំភី" គឺព្យញ្ជនៈ "រ" និងស្រៈ "អ៊ី" ចួននឹងព្យញ្ជនៈ "ភ" និងស្រៈ "អ៊ី" ដូចគ្នា។
- ពាក្យ "**កែ**" និង "**ដៃ**" គឺព្យញ្ជនៈ "ក" និងស្រៈ "**អែ**" ចួននឹងព្យញ្ជនៈ "**ដ**" និងស្រៈ "**អៃ**" ដូចគ្នា។
- ពាក្យ "**ដី**" និង "**កី**" គឺព្យញ្ជនៈ "ដ" និងស្រៈ "**អី**" ចួននឹងព្យញ្ជនៈ "**ក**" និងស្រៈ "**អី**" ដូចគ្នា។

| | | | | | | |
|---|---|---|---|---|---|---|
| ដូចនេះ | **នារីនិងសំភី** | ⟶ | **រី** | ⟷ | **ភី** | (រី ចួននឹងភី) |
| | **កែនិងដៃ** | ⟶ | **កែ** | ⟷ | **ដៃ** | (កែ ចួននឹងដៃ) |
| | **ដីនិងកី** | ⟶ | **ដី** | ⟷ | **កី** | (ដី ចួននឹងកី) |

☑ គ្រូប្រាប់សិស្សថា គ្រូនឹងនិយាយ ឬរាប់ពាក្យចំនួន ៤។ ចូរប្អូនឆ្លើយមកគ្រូវិញថា ពាក្យមួយណាក្នុងចំណោមពាក្យទាំងបួន ដែលមិនមែនជាពាក្យចួន។

| | | | | | |
|---|---|---|---|---|---|
| ឧទាហរណ៍ | ពាក្យ | សិក្សា | កុមារ | **ខិតខំ** | សាលា |
| | ពាក្យ | សំភី | **ធានា** | គីរី | នារី |
| | ពាក្យ | រំហើយ | កន្ត្រើយ | **រំដោះ** | ស្បើយ |
| | ពាក្យ | ប្រពៃ | ថ្ងៃ | **ប្រជា** | ពន្លៃ |

ដូចនេះ ពាក្យដែលមានសូរស្រៈ និងព្យញ្ជនៈប្រកបដូចគ្នា គឺជាពាក្យចួន។

លេខ ១ឃ

## បន្ត...

## សកម្មភាពគំរូ

☑ គ្រូសរសេរអត្ថបទមេសូត្រ ដាក់លើក្ដារខៀន រួចឱ្យសិស្សឡើងគូសពាក្យចួននៅលើក្ដារខៀន។

យើងបុត្រ**ខេមរា** មុនចូល**សិក្សា** គោរព**ទង់ជាតិ**

ឈរតម្រង់ជួរ រូតរះខ្មី**ឃ្មាត** កុំគេចកុំ**ឆ្វៀត**

មករៀនទាន់ពេល។

.................. ........................ .................

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ១ឃ**

លេខ ១ង

# សិស្សបកស្រាយន័យ ល្បះ អត្ថបទ និងកំណាព្យនៅតាមមេរៀនកំណត់

## បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី២ ទី៧ ទី១២ និងទី១៧)

### ខ្លឹមសារ

មេរៀនដែលសិស្សបានរៀនក្នុងមេរៀនទី១ ទី៣ ទី៤ និងទី៦ ដូចជា

មេរៀនទី ១ : សាលាកុមារមេត្រី
មេរៀនទី ៣ : សិស្សឧស្សាហ៍
មេរៀនទី ៤ : ការសម្អាតថ្នាក់រៀន
មេរៀនទី ៦ : ពេលគោរពទង់ជាតិ

### សកម្មភាពគំរូ

☑ សិស្សអាចឆ្លើយសំណួរក្នុងសៀវភៅសិក្សាគោលមេរៀនទី១ ទី៣ ទី៤ និងទី៦ :

**មេរៀនទី១**

១. តើសាលារៀននេះមានបរិវេណដូចម្ដេច?
២. តើក្នុងទីធ្លាសាលារៀននេះមានអ្វីខ្លះ?
៣. តើនៅខាងក្រោយអគារមានអ្វីខ្លះ?
៤. តើនៅក្នុងបន្ទប់រៀនមានអ្វីខ្លះ?
៥. តើប្អូនចូលចិត្តរៀននៅសាលានេះដែរឬទេ? ព្រោះអ្វី? ★

**មេរៀនទី ៣**

១. តើសុខាជាសិស្សដូចម្ដេច?
២. តើនៅសាលារៀន សុខាបានធ្វើអ្វីខ្លះ?
៣. តើនៅផ្ទះ សុខាបានធ្វើអ្វីខ្លះ?
៤. ហេតុអ្វីបានជាឪពុកម្ដាយសុខាសប្បាយចិត្ត?
៥. តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យឪពុកម្ដាយអ្នកសប្បាយចិត្ត?

**មេរៀនទី៦**

១. តើសិស្សទាំងអស់ត្រូវគោរពទង់ជាតិនៅពេលណា?
២. នៅពេលគោរពទង់ជាតិ តើប្អូនៗត្រូវធ្វើដូចម្ដេចខ្លះ?
៣. តើទង់ជាតិ ជាសញ្ញាណតំណាងឱ្យអ្វី?
៤. ហេតុអ្វីបានជាយើងត្រូវគោរពទង់ជាតិ?

**មេរៀនទី ៤**

១. តើការសម្អាតថ្នាក់រៀនជាភារកិច្ចរបស់អ្នកណាខ្លះ?
២. តើប្អូនត្រូវមានសម្ភារៈអ្វីខ្លះ សម្រាប់យកទៅសម្អាតថ្នាក់រៀន?
៣. តើប្អូនត្រូវសម្អាតនៅកន្លែងណាខ្លះ?
៤. ហេតុអ្វីបានជាត្រូវយកសំរាមទៅដាក់ក្នុងធុងសំរាម?
៥. តើថ្នាក់រៀនស្អាតផ្ដល់ប្រយោជន៍អ្វីខ្លះដល់ប្អូន?

សម្គាល់ : សំណួរដែលមានសញ្ញា ★ (ផ្កាយ) ជាសំណួរបន្ថែម ដើម្បីពង្រឹងបំណិនវិភាគ និងដោះស្រាយបញ្ហា។ សម្រាប់សំណួរនេះគ្រូគួរតែទទួលចម្លើយពីសិស្សដែលឆ្លើយសមហេតុផល ទោះចម្លើយគ្មានក្នុងអត្ថបទក៏ដោយ។

លេខ ១ង

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សសង្ខេបអត្ថបទឱ្យបាន១០ពាក្យដោយប្រើគំនិតសំខាន់ក្នុងការសង្ខេប។

*ឧទាហរណ៍* អត្ថបទ "**គោរពទង់ជាតិ**"

**សង្ខេប**អត្ថបទនេះ ពណ៌នាសារៈសំខាន់របស់ទង់ជាតិ និងការគោរពទង់ជាតិ។

☑ គ្រូជួយសិស្សឱ្យចេះគិតរកចម្លើយផ្សេងៗក្រៅពីគំនិតចម្បងនៃអត្ថបទ តាមរយៈផែនទីគំនិតដូចខាងក្រោមជាឧទាហរណ៍៖ "**សុខាជាសិស្សឧស្សាហ៍មករៀនទៀងទាត់ពេលវេលា**" ដូចនេះក្រៅពីសុខា តើមានសិស្សឧស្សាហ៍ផ្សេងទៀតរៀនអ្វីខ្លះ?




<u>សម្គាល់</u> : រាល់គំនិតថ្មីទាំងអស់ខាងលើនេះជាចម្លើយ ឬគំនិតក្រៅពីអត្ថបទ ដែលពង្រីកការយល់ដឹង បានទូលំទូលាយ។

☑ **ទីសេចក្តីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ** : គ្រូឱ្យសិស្សអានអត្ថបទអំណានឡើងវិញ រួចសរសេរពាក្យទាំងឡាយដែលគេមិនទាន់ចេះ។ បន្ទាប់មក គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យពាក្យដែលគេមិនទាន់ចេះនោះដោយមើលពាក្យជុំវិញ។ សិស្សត្រូវសរសេរនិយមន័យរបស់ពាក្យដែលគេមិនទាន់ចេះទៅតាមការវិភាគនេះ។ ប្រសិនបើពាក្យនោះសិស្សនៅតែមិនអាចបកស្រាយបានទេ គេត្រូវសួរលោកគ្រូអ្នកគ្រូ ឬឱ្យគ្រូពន្យល់ពេលគេចូលក្រុមធំ វិញ។ ពេលនោះគ្រូគួរតែសរសេរពាក្យទាំងអស់នោះ ដែលគេមិនទាន់ចេះនៅលើក្តារខៀនឱ្យសិស្សផ្សេងទៀតមើល ហើយពិភាក្សាគ្នា។ គ្រូពិនិត្យ និយមន័យកំណត់ដោយសិស្សថាតើមានន័យត្រឹមត្រូវគ្រប់គ្រាន់ហើយ ឬនៅ។

*ឧទាហរណ៍* អាល្លូព្រួសពន្លាំងៗ។ ពាក្យ "**ព្រួស**" ជួយយើងឱ្យដឹងន័យថា "**អាល្លូ**" ជាឈ្មោះ "**ផ្លែ**" ។

☑ គ្រូឱ្យសិស្សជ្រើសរើសពាក្យក្នុងប្រអប់បំពេញល្បះ។ *ឧទាហរណ៍*

| ព្រឹកនេះ | ភារកិច្ច | ធូលី | ប្រមូល |
|---|---|---|---|

លេខ ១ង

**បន្ត...**

## សកម្មភាពគំរូ

១. ការសម្អាតថ្នាក់ជា.............របស់យើងទាំងអស់គ្នា។

២. ............ដល់វេនក្រុមខ្ញុំសម្អាតបន្ទប់រៀន។

៣. អ្នកខ្លះ..........យកសំរាមកម្ទេចកម្ទីកើប...........យកទៅដាក់ក្នុងធុងសំរាម។

☑ សិស្សបំពេញលំហាត់ក្លូស្ស (**Cloze Exercise**) តាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទនៅរៀងរាល់លំដាប់ពាក្យទី៤ មកបំពេញបានត្រឹមត្រូវ។ (មេរៀនទី៣ទំព័រទី៧) *ឧទាហរណ៍*

សុខាជាសិស្ស...(១)។ រាល់ថ្ងៃនាង...(២)រៀនទៀងទាត់...(៣)ទាន់ពេលជានិច្ច...(៤)គោរពបទបញ្ជា...(៥)បានត្រឹមត្រូវក្នុង...(៦)យកចិត្តទុកដាក់...(៧)គ្រូពន្យល់នឹង...(៨)ជម្រាបសួរគ្រូ...(៩)ពេលមិនយល់។ ...(១០)ខ្លះ នាងជួយ...(១១)មិត្តរួមថ្នាក់...(១២)រៀនយឺតទៀត...(១៣)។ សុខាតែងតែណែនាំ...(១៤)កុំឱ្យដើរ...(១៥)ផ្តេសផ្តាស។ នៅផ្ទះ...(១៦)ខំធ្វើលំហាត់...(១៧)សៀវភៅស្រាវជ្រាវនិង...(១៨)ធ្វើកិច្ចការផ្ទះ។

**ចម្លើយ**

| | | |
|---|---|---|
| ១. ឧស្សាហ៍ ល្អ | ៧. ស្តាប់ | ១៣. ផង |
| ២. ទៅ | ៨. ហ៊ាន ក្លាហាន | ១៤. មិត្តភក្តិ |
| ៣. និង | ៩. នៅ | ១៥. លេង ច្រៀង រាំ |
| ៤. សុខា | ១០. ពេល | ១៦. សុខា |
| ៥. សាលារៀន បន្ទប់រៀន | ១១. ពន្យល់ បង្ហាញ | ១៧. អាន មើល |
| ៦. ថ្នាក់រៀន | ១២. ដែល | ១៨. ជួយ |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ១ង**

**លេខ ១៧**

# សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងល្បះតាម រយៈលំហាត់សរសេរតាមអានក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី៤ ទី១០ ទី១៥ និងទី២០)

## ខ្លឹមសារ

សរសេរតាមអានរៀបចំ និងត្រួតពិនិត្យអំពីពាក្យ កន្សោមពាក្យ និងល្បះក្នុងសៀវភៅភាសាខ្មែរអាន-សរសេរ ថ្នាក់ទី៣

មេរៀនទី១ : ទំព័រទី ៤ មេរៀនទី៣ : ទំព័រទី ១០ មេរៀនទី៤ : ទំព័រទី ១៥ មេរៀនទី៦ : ទំព័រទី ២០

## សកម្មភាពគំរូ

- ☑ សិស្សចម្លងពាក្យលើក្ដារខៀនតាមខ្លឹមសារដែលគ្រូកំណត់ខាងលើដាក់ក្នុងសៀវភៅសរសេររៀងខ្លួន។
- ☑ សិស្សក្នុងក្រុម "ក" មានគ្នា៤នាក់ និងសិស្សក្នុងក្រុម "ខ" មានគ្នា៤នាក់សរសេរពាក្យចំនួន ៥ពាក្យក្នុងមួយក្រុមៗ តាមការជ្រើសរើសរបស់ក្រុមនីមួយៗ រួចដូរគ្នាពិនិត្យ និងកែលម្អគ្នាទៅវិញទៅមក។ ឯគ្រូជាអ្នកណែនាំ និងសម្របសម្រួលសិស្សតាមក្រុម។
- ☑ គ្រូជ្រើសរើសពាក្យពីក្នុងមេរៀនចំនួន ៨ ទៅ ១០ ពាក្យចម្រុះគ្នាឱ្យសិស្សសរសេរតាមដាក់ក្នុងសៀវភៅសរសេររៀងខ្លួន បន្ទាប់មកឱ្យសិស្សរៀបចំពាក្យទាំងនោះទៅជាល្បះ មានន័យពេញលេញឱ្យបានពីរ ឬបីល្បះខុសៗគ្នា។ គ្រូជួយសម្របសម្រួល។ *ឧទាហរណ៍* ពាក្យខាងក្រោមសម្រាប់សិស្សជ្រើសរើសដើម្បីតែងល្បះ។

  **រៀនសូត្រ ព្យាយាម សុខា ឧស្សាហ៍ សិស្ស គ្រូ ជា គេ ជាង ចូលចិត្ត។**

  ១. គ្រូចូលចិត្តសុខាជាងគេ។

  ២. សុខាជាសិស្សចូលចិត្តរៀនសូត្រ។

  ៣. សុខាជាសិស្សឧស្សាហ៍ព្យាយាម រៀនសូត្រជាងគេ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ១៧**

លេខ ១៨

# សិស្សសរសេរតួអក្សរផ្ចង់បានស្អាតល្អ

## បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់

សូមមើល មេរៀនទី១ និងទី៤ (ទំព័រទី៥ និងទី១១)

### ខ្លឹមសារ

- រំឭកអំពីរបៀបគូសបន្ទាត់ សរសេរអក្សរផ្ចង់ (សូមមើលការណែនាំក្នុងសៀវភៅស្តង់ដាអំណានថ្នាក់ទី៣ទំព័រ xiii និងសំណេរអក្សរផ្ចង់អំពីអក្សរ "គ" (ទំព័រទី ១១) ក្នុងសៀវភៅភាសាខ្មែរអាន-សរសេរ ថ្នាក់ទី ៣។

### សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរ "គ" បានស្អាតល្អតាមទម្រង់អក្សរជ្រៀង និងការណែនាំពីរបៀបគូសបន្ទាត់ សរសេរលើក្តារខៀន ក្តារឆ្នួន និងក្នុងសៀវភៅសរសេររៀងខ្លួនបានត្រឹមត្រូវ ។ *ឧទាហរណ៍*




- ជួរទី១តួអក្សរយកកម្ពស់(បន្ទាត់ឈរ)៤/៤(ពេញបន្ទាត់) និងទទឹង(ជួរដេក)យក ២/៣
- ជួរទី២ តួអក្សរយកកម្ពស់(បន្ទាត់ឈរ)២/៤(ពាក់កណ្តាលបន្ទាត់) និងទទឹង(ជួរដេក)យក១/៣
- ជួរទី៣ តួអក្សរយកកម្ពស់ (បន្ទាត់ឈរ) ១/៤ និងទទឹង(ជួរដេក) យក ១/៣

☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ ដូចជាអក្សរ **ក ត ច ឆ ...** ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មក គ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តខាងលើចម្លងចូលក្នុងសៀវភៅសរសេររៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្តារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ុត...

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

លេខ
១៨

# សិស្សបំពេញល្បះ តាមរូបភាពក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ តាមការកំណត់របស់គ្រូ

## បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី១ ទី៣ ទី៤ និងទី៦ (ទំព័រទី៥ ទី១១ ទី១៥ ទី២០ និងទី២១)

**ខ្លឹមសារ**

ពាក្យ ល្បះ រូបភាពក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ មេរៀនទី១ ទី៣ ទី៤ និងទី៦ ទំព័រទី៥ ទី១១ ទី១៥ ទី២០ និងទី២១។

## សកម្មភាពគំរូ

☑ សិស្សអាចជ្រើសរើសពាក្យក្នុងប្រអប់ទំព័រទី១០ មកបំពេញក្នុងល្បះតាមរូបភាពនៅទំព័រទី១១។

| | | |
|---|---|---|
| រៀនឃើត | ខំរៀន | កិច្ចការ |



១. សុខា.......នៅផ្ទះ។



២. សុខាជួយធ្វើ.......ផ្ទះ។



៣. សុខាជួយមិត្តភក្តិ......។

☑ សិស្សអាចតែងល្បះតាមរូបភាព ដោយប្រើពាក្យបង្ហាញសកម្មភាព (ពាក្យ សម្អាត ជូត)ទំព័រទី១៥។



១. "សម្អាត" .........។



២. "ជូត" ...........។

☑ គ្រូបង្ហាញសិស្ស ល្បះខ្លីចំនួន២ដូចខាងក្រោម រួចឱ្យសិស្សរៀប ឬផ្សំល្បះទាំងពីរទៅជាល្បះតែមួយ។ *ឧទាហរណ៍*

**១.** សុខាជាសិស្សឧស្សាហ៍។ **២.** សុខាជាសិស្សល្អ។

= សុខាជាសិស្សឧស្សាហ៍ + សុខាជាសិស្សល្អ។ ⟶ សុខាជាសិស្សល្អ និងឧស្សាហ៍។

**៣.** តារាសម្អាតថ្នាក់រៀន ។ **៤.** តារាជូតថ្នាក់រៀន។

= តារាសម្អាតថ្នាក់រៀន + តារាជូតថ្នាក់រៀន។ ⟶ តារាសម្អាត និងជូតថ្នាក់រៀន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ១៨




**ដំណាក់កាលទី១ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី១

នៃឧបសម្ព័ន្ធ២ក្នុងសៀវភៅនេះ

ទំព័រទី ១៩៦ ដល់ ១៩៨

## ដំណាក់កាលទី២ : មេរៀនទី៨ ដល់ទី១៤

(ទំព័រទី២៤ ដល់ទី៥០)

១. មេរៀនទី៨ : រឿងទឹកចិត្តដំប្រពៃ

២. មេរៀនទី៩ : សិស្សគំរូ

៣. មេរៀនទី១០ : សមាជិកគ្រួសារខ្ញុំ

៤. មេរៀនទី១១ : បំណិន បដិសណ្ឋា

៥. មេរៀនទី១២ : គុណម្ដាយ ឪពុក

៦. មេរៀនទី១៣ : ការពណ៌នាអំពីមនុស្ស

៧. មេរៀនទី១៤ : រឿងគោ ក្របីគ្មានធ្មេញលើ

( ៦៣ ម៉ោងប្រហែល៥សប្ដាហ៍)

**លេខ ២ក**

# សិស្សកំណត់សូរដើម និងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យ ដែលគ្រូអាន និងសរសេរ។

*ឧទាហរណ៍* កូន = ក + ូ + ន

♦ "ក" សូរដើម ស្រៈ "អូ" និង "ន" សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ (ទំព័រទី ២៤ ទី២៨ ទី៣២ ទី៣៩ និងទី៤៧)**

## ខ្លឹមសារ

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ ដូចជា : កូន ទេ មីង ចាស នៅ ខែ ចេះ ដូច បង ពុក គេ នៅ មេ ខំ ដេរ គុណ ពូ ស៊ី គោ ចង សើច . . .
- ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ គ្រូបង្ហាញ "**កែវ**" ដល់សិស្សរួចសួរសិស្សថា តើវត្ថុនេះមានសូរដើមអ្វី? (ចម្លើយគឺសូរដើម"**ក**" សូរបន្ទាប់ "អែ" និង"វ" ។ បន្ទាប់មក គ្រូឱ្យសិស្សរកវត្ថុផ្សេងៗក្នុងថ្នាក់រៀនដែលមានសូរដើម "ក" ដូចគ្នា។

*ឧទាហរណ៍* ក្ដារ កូន កៅអី ក្រដាស ...។

**សម្គាល់ : ចំពោះ**ពាក្យក្រដាស ជាពាក្យផ្ញើជើងដែលមានព្យញ្ជនៈចំនួន២។ សូរដើមគឺ "ក្រ" សូរបន្ទាប់គឺ "ដាស"។ គ្រូត្រូវចាំ ថាមិនត្រូវពណ៌នាសូរនេះទៅជាតួអក្សរទេ ព្រោះនេះជាបំណិនរៀនពី "**ការស្គាល់សូរ**" តាមរយៈការស្ដាប់តែប៉ុណ្ណោះ។ គ្រូនឹងបង្ហាញតែពីសូរប៉ុណ្ណោះ។ (ការស្គាល់សូរ)

☑ គ្រូប្រាប់សិស្សរកសូរដើម និងសូរបន្ទាប់នៃពាក្យ "មីង" និងពាក្យដទៃទៀតដែលមានសូរដើម និងសូរបន្ទាប់ដូចគ្នា។

*ឧទាហរណ៍* ចាំ យើង លើក ជួយ...។ សកម្មភាពនេះអាចឱ្យសិស្សធ្វើការជាដៃគូ ឬសិស្សម្នាក់ៗក្នុងថ្នាក់ទាំងមូលក៏បាន។ (ការស្គាល់សូរ)

☑ គ្រូប្រាប់សិស្សពាក្យណាមួយដោយទាញសំឡេងឱ្យវែងដូចជាពាក្យ "កែវ" ក អែ កែ កែនិងវ ប៉ុន្តែគ្រូត្រូវចាំថា ត្រូវថាតាមលំដាប់នៃការផ្សំពីព្យញ្ជនៈក ែ និងវ កែវ។ រួចឱ្យសិស្សទាយថា តើពាក្យនោះជាពាក្យអ្វី? (**កែវ**)។ (ការស្គាល់សូរ)

☑ គ្រូឱ្យសិស្សកំណត់សូរដើម និងសូរបន្ទាប់ ដែលគ្រូសរសេរនៅលើក្ដារខៀន។

*ឧទាហរណ៍* ក្រោយពីសរសេរពាក្យ "**កូន**" សិស្សត្រូវកំណត់រកសូរដើម និងសូរបន្ទាប់។ កូន = ក + ូ + ន

♦ សូរដើម "ក" សូរបន្ទាប់ "អូ" និង "ន" ។ (ការស្គាល់តួអក្សរនិងសូរ)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ២ក**

## លេខ ២ខ

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ ទេវចនសព្ទ និងសទិសសព្ទ ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

**សូមមើល មេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ (ទំព័រទី២៥ ទី២៩ ទី៣៣ ទី៤០ និងទី៤៨)**

**ខ្លឹមសារ**

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៨ ទី៩ ទី១០ ទី១២ និង១៤ ដូចជា ៖

**មេរៀនទី៨**

- មណ្ឌលសុខភាព (ន.) : ទីកន្លែងសម្រាកពិនិត្យព្យាបាលអ្នកជំងឺនៅក្នុងឃុំ។
- ព្យាបាល (ន.) : ការថែរក្សាជំងឺ។
- សះស្បើយ (គុ.) : ដែលស្រាក ស្រាលជាពីជំងឺ។

**មេរៀនទី៩**

- វិន័យ (ន.) : ការដឹកនាំទៅរកផ្លូវល្អ ច្បាប់ប្រដៅឱ្យប្រព្រឹត្តត្រឹមត្រូវ។
- មារយាទ (ន.) : សណ្ដាប់ធ្នាប់ របៀប ឫកពា។
- ទីសាធារណៈ (ន.) : កន្លែងដែលមិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់។
- ក្រុមប្រឹក្សាកុមារ (ន.) : ក្រុមកុមារដែលរៀបចំឡើងសម្រាប់ជួយគ្រប់គ្រង និងដឹកនាំកុមារនៅក្នុងសាលារៀន។

**មេរៀនទី១០**

- ធុរៈ (ន.) : រវល់ ដំណើរជំពាក់ដោយកិច្ចការ។
- មេគ្រួសារ (ន.) : អ្នកទទួលរ៉ាប់រងគ្រប់បែបយ៉ាងក្នុងគ្រួសារ។
- ផ្គត់ផ្គង់ (កិ.) : ទំនុកបម្រុងមិនឱ្យខ្វះខាត។
- បន្ទុក (ន.) : កិច្ចការធុរៈខុសត្រូវសព្វគ្រប់។

**មេរៀនទី១២**

- ដែន (ន.) : រដ្ឋ ប្រទេស ផែនដី។
- ទ្វេហារ (ន.) : ទាំងពីរ។
- ចិញ្ចឹម (កិ.) : គ្រប់គ្រងរក្សាបន្តជីវិត បីបាច់រក្សាឱ្យរស់ ឱ្យធំធាត់។
- រាជការ (ន.) : ការរក្សាប្រទេសជាតិ ធ្វើរាជការ អ្នករាជការ។

**មេរៀនទី១៤**

- ប្រាជ្ញា (ន.) : ការយល់ដឹងជាក់ច្បាស់។
- ទឹម (កិ.) : ដាក់នឹមលើ ក បំពាក់ឱ្យសត្វពាហនៈឱ្យអូសនង្គ័ល។
- សំពង (កិ.) : វាយពេញកម្លាំងដៃដោយដំបង ឬកំណាត់ឈើ។

**បដិសព្ទ**

| | | | | | | |
|---|---|---|---|---|---|---|
| មេរៀនទី៨ : | គុណ | ≠ | ទោស | សុខ | ≠ | ទុក្ខ |
| មេរៀនទី៩ : | ពូកែ | ≠ | ខ្សោយ | សាធារណៈ | ≠ | អសាធារណៈ |
| មេរៀនទី១០ : | ជរា | ≠ | រឹងមាំ | សុភមង្គល | ≠ | អពមង្គល |

លេខ
២ខ

បន្ត...

## ខ្លឹមសារ

មេរៀនទី១២ : មាន ≠ គ្មាន នឿយហត់ ≠ ស្រណុក
មេរៀនទី១៤ : ព្រម ≠ បដិសេធ ចង ≠ ស្រាយ

**វេវចនសព្ទ**

មេរៀនទី៨ : វេវចនសព្ទនឹងពាក្យ "**សប្បាយ**" **សប្បាយ** ឥតព្រួយ ត្រេកអរ រីករាយ ស្រួលចិត្ត អំណរ ស្រស់ស្រាយ

មេរៀនទី៩ : វេវចនសព្ទនឹងពាក្យ "**ទូន្មាន**" **ទូន្មាន** ប្រដៅ អប់រំ ណែនាំ

មេរៀនទី១០ : វេវចនសព្ទនឹងពាក្យ "**ទទួលទាន**" **ទទួលទាន** ហូប បរិភោគ ញ៉ាំ ស៊ី ឆាន់ សោយ ពិសា

មេរៀនទី១២ : វេវចនសព្ទនឹងពាក្យ "**ត្លុញត្លៃ** **ទ្វេ**"**ត្លុញត្លៃ** អ៊ូរទាំ តម្អូញ
**ទ្វេ** ទ្វី ពីរ មួយគូ ភ្លោះ

មេរៀនទី១៤ : វេវចនសព្ទនឹងពាក្យ "**ផ្អេញ**"**ផ្អេញ** ទន្ត។

**សទិសសព្ទ**

មេរៀនទី៨ : សទិសសព្ទនឹងពាក្យ "**ពរ**"

- ពរ (ន.) : គុណដ៏ប្រសើរ គុណដែលប្រាថ្នា ចង់បាន។ *ឧទាហរណ៍* ជូនពរ។
- ព (កិ.) : លើកដាក់លើចង្កេះកៀកនឹងដៃ។ *ឧទាហរណ៍* ពកូន។

មេរៀនទី៩ : សទិសសព្ទនឹងពាក្យ "**ទុំ**"

- ទុំ (គុ.) : ទីទៃពីខ្ចី។ *ឧទាហរណ៍* ផ្លែឈើទុំ។
- ទំ (កិ.) : ស្ថិតនៅលើទ្រនំ។ *ឧទាហរណ៍* សត្វទំលើចុងឈើ។

មេរៀនទី១០ : សទិសសព្ទនឹងពាក្យ "**មា**"

- មា (ន.) : ប្អូនប្រុសរបស់ម្ដាយឬឪពុក (ព)។
- មារ (ន.) : សេចក្ដីអាក្រក់ ដំណើររារាំង សេចក្ដីស្លាប់។

មេរៀនទី១២ : សទិសសព្ទនឹងពាក្យ "**គុណ**"

- គុណ (ន.) : ដំណើរធ្វើឱ្យចម្រើនកើនឡើង។ *ឧទាហរណ៍* លេខគុណ។
- គុន (ន.) : ក្បាច់គុន។
- គណ (ន.) : ពួក ក្រុម បន ហ្វូង។ *ឧទាហរណ៍* មេគណ។
- គន់ (កិ.) : រកមើល។

មេរៀនទី១៤ : សទិសសព្ទនឹងពាក្យ "**សួរ**"

- សួរ (កិ.) : ពោលពាក្យឆ្ពោះទៅរកអ្នកដទៃ ឱ្យគេឆ្លើយ។ *ឧទាហរណ៍* សួរសំណួរ។
- សួគ៌ (ន.) : ឋានទេវ ឋានសួគ៌។
- សួ (កិ.) : សរសៀរនៅលើស្នួ ឬលើអ្វីៗ មានគ្រឿងតោង។

លេខ ២ខ

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូបែងចែកសិស្ស ជាក្រុមតូចមាន ៤ ឬ ៥នាក់មួយក្រុម។ គ្រូសរសេរពាក្យលើក្ដារខៀន រួចឱ្យសិស្សរកពាក្យន័យដូចច្រើនបំផុតដែលអាចធ្វើបាន។ គ្រូឱ្យក្រុមនីមួយៗ រកពាក្យក្នុងរយៈពេល ១ទៅ៤នាទីតែប៉ុណ្ណោះ ដើម្បីរកពាក្យន័យដូចទាំងនោះ។ ក្រុមដែលរកពាក្យបានច្រើនបំផុតជាអ្នកឈ្នះ។ គ្រូអាចធ្វើលំហាត់នេះតាមលំនាំខាងលើនេះ សម្រាប់ពាក្យផ្ទុយ ក៏ដូចវេចនសព្ទដែរ។

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យរបស់ពាក្យពិបាកនោះ។

*ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្ដាំ ឱ្យត្រូវនឹងនិយមន័យនៃពាក្យនីមួយៗ។

| ពាក្យពិបាក | និយមន័យ |
|---|---|
| មណ្ឌលសុខភាព | ♦ កន្លែងសម្រាប់ទៅបោះឆ្នោត។<br>♦ កន្លែងសម្រាប់ពិនិត្យព្យាបាលអ្នកជំងឺ។<br>♦ កន្លែងសម្រាប់ទៅចុះឈ្មោះធ្វើសំបុត្រកំណើត។ |
| ដែន | ♦ រដ្ឋ ប្រទេស ដែនដី។<br>♦ កន្លែងនៅ ជម្រករបស់មនុស្ស។<br>♦ កន្លែងរវាងប្រទេសមួយ ទៅប្រទេសមួយទៀត។ |
| ប្រាជ្ញា | ♦ ការមានស្នាដៃ។<br>♦ ការមានភាពវៃឆ្លាត។<br>♦ ការយល់ដឹងជាក់ច្បាស់។ |

☑ គ្រូបង្កើតបណ្ដុំពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| គុណ | សុខ | ពូកែ | ជរា | ចង | ព្រម | សុភមង្គល | មាន | នឿយ |

- ♦ បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្ដារខៀន។ សិស្សត្រូវនឹករកពាក្យផ្សេងទៀត ដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាននិយមន័យដូចគ្នាទេ តែមានទំនាក់ទំនង ជាមួយគ្នាតាមដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ**ដោយមានការបង្ហាញគំនិតពាក់ពន្ធ័ផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ "**មណ្ឌលសុខភាព**" នៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដទៃដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែមិនមែនមានន័យថា រកពាក្យដែលន័យដូចនោះទេ។ បន្ទាប់មក គ្រូឱ្យសិស្សរកពាក្យដូចលំនាំនេះនឹងពាក្យ "អាហារ" ដោយខ្លួនឯងបន្តទៀត។

**លេខ ២ខ**

## បន្ត...

# សកម្មភាពគំរូ







☑ គ្រូគូសតារាងពីរនៅលើក្ដារខៀន។ តារាងទី១ វេវចនសព្ទ  តារាងទី២ បដិសព្ទ។ បន្ទាប់មក គ្រូសរសេរបញ្ជីពាក្យនៅលើក្ដារខៀន ហើយឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទៅតាមប្រភេទនៃតារាងនីមួយៗ។ *ឧទាហរណ៍* គ្រូសរសេរពាក្យខាងក្រោម ដាក់លើក្ដារខៀនរួចបង្ហាញជាឧទាហរណ៍ខាងក្រោមពន្យល់សិស្ស។ បន្ទាប់មក ឱ្យសិស្សរកដោយខ្លួនឯង។
សប្បាយ  ស្រឡាញ់  ក្ដួញក្ដែរ  ទ្វេ  ធ្មេញ  រីករាយ  ស្អប់  ទន្ត  រអ៊ូរទាំ  ពីរ

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| **សប្បាយ** រីករាយ<br>................................... | ស្អប់ ≠ ស្រឡាញ់<br>.................. ≠ .................... |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០


**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ២ខ

លេខ ២គ

# សិស្សអានពាក្យក្នុងអត្ថបទដោយមិនបាច់ផ្ទុំ និងប្រកប

**បំណិនអំណានពាក់ព័ន្ធ : ការចេះអានស្ទាត់ ការចេះវាក្យសព្ទ**

**សូមមើល មេរៀនទី៨ ទី៩ និងទី១០ (ទំព័រទី២៥ ទី២៩ និងទី៣៣)**

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៨ ទី៩ និងទី១០ ទំព័រទី២៥ ទី២៩ ទី៣៣ ដូចជា ៖

មេរៀនទី៨ : សុខទុក្ខ បន្តិចបន្តួច គោរព អារម្មណ៍ ត្រេកអរ ជាសះស្បើយ មណ្ឌលសុខភាព ដឹងគុណគ្រូ

មេរៀនទី៩ : សាធារណៈ វិន័យ ក្រុមប្រឹក្សាកុមារ ចរិយា មារយាទ ទូន្មាន ប្រៀនប្រដៅ នាយក ខ្ជាប់ខ្ជួន

មេរៀនទី១០ : ជរា គ្រួសារ ជីវភាព បន្ទុក កិច្ចការ ទុក្ខធុរៈ សុភមង្គល យោគយល់។

## សកម្មភាពគំរូ

☑ សិស្សមើលបញ្ជីពាក្យដែលគ្រូសរសេរ ឬបិទនៅលើក្ដារខៀន។ បន្ទាប់មក គ្រូឱ្យសិស្ស២នាក់ ព្យាយាមអានបញ្ជីពាក្យនោះឱ្យបានលឿន ដោយមិនបាច់ផ្ទុំ និងប្រកបតាមដែលអាចធ្វើទៅបាន។ សិស្សអានបានគ្រប់ពាក្យបានត្រឹមត្រូវហើយចប់មុនគេសិស្សនោះជាអ្នកឈ្នះ។ គ្រូត្រូវលើកទឹកចិត្តសិស្ស។ *ឧទាហរណ៍*

| បញ្ជីទី១ | | | បញ្ជីទី២ | | |
|---|---|---|---|---|---|
| • សុខទុក្ខ | • ត្រេកអរ | • សាធារណៈ | • មណ្ឌលសុខភាព | • ចរិយា | • ទុក្ខធុរៈ |
| • បន្តិចបន្តួច | • សះស្បើយ | • ប្រៀនប្រដៅ | • ដឹងគុណ | • នាយក | • សុភមង្គល |
| • គោរព | • មារយាទ | • ខ្ជាប់ខ្ជួន | • វិន័យ | • ជីវភាព | • យោគយល់ |
| • អារម្មណ៍ | • ទូន្មាន | • ជរា | • ក្រុមប្រឹក្សាកុមារ | • បន្ទុក | • ក្ងាន |
| | | | | | • សារិកា |

☑ គ្រូឱ្យសិស្សធ្វើជាអ្នកនិយាយតាមវិទ្យុប្រកាសដំណឹងអ្វីមួយតាមរយៈវិទ្យុ។ រួចគ្រូជ្រើសរើសអត្ថបទពីសៀវភៅសិក្សាគោលឱ្យសិស្សអានរបៀបជាសេចក្តីប្រកាសដូចក្នុងវិទ្យុ ដោយអានមិនឈប់ ឬមិនអាក់នៅកណ្តាលទី(ល្បះ)។ នៅពេលនិយាយសិស្សប្រើប៊ិកជំនួសមីក្រូ។

**សម្គាល់ :** អត្ថបទដែលសិស្សអាននេះ ជាអត្ថបទសិស្សធ្លាប់អានពីមុន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ២គ**

## លេខ ២យ សិស្សបកស្រាយន័យ នៃល្បះ អត្ថបទ និងចម្រៀងទៅតាមមេរៀនដែលបានកំណត់

### បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទីគ ទី៩ ទី១០ ទី១២ និងទី១៤ (ទំព័រទី២៥ ទី២៩ ទី៣៤ ទី៤០ ទី៤១ និងទី៤៨)

### ខ្លឹមសារ

ល្បះ អត្ថបទ និងចម្រៀង ក្នុងមេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤

មេរៀនទី៨ : រឿងទឹកចិត្តដ៏ប្រពៃ (ទំព័រទី២៥)

មេរៀនទី៩ : សិស្សគំរូ (ទំព័រទី២៩)

មេរៀនទី១០ : សមាជិកគ្រួសារខ្ញុំ (ទំព័រទី៣៤)

មេរៀនទី១២ : គុណម្តាយឪពុក (ទំព័រទី៤០ និងទី៤១)

មេរៀនទី១៤ : រឿងគោ ក្របីគ្មានធ្មេញលើ (ទំព័រទី៤៨)

### សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ មេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ ៖

**មេរៀនទី៨**

១. តើតួអង្គខាងលើមានប៉ុន្មាននាក់?

២. តើស្រីនាថ និងម្តាយនាំគ្នាទៅណា?

៣. តើស្រីនាថមានទឹកចិត្តដូចម្តេចចំពោះអ្នកគ្រូ?

៤. បើអ្នកគ្រូប្អូនវិញ តើប្អូនមានអារម្មណ៍ដូចម្តេច?

**មេរៀនទី៩**

១. តើសុធា រៀនបានជាប់ចំណាត់ថ្នាក់ដូចម្តេច?

២. ក្រៅពីការរៀនសូត្រ តើសុធាជាសិស្សយ៉ាងដូចម្តេច?

៣. តើនៅក្នុងសាលា និងនៅតាមទីសាធារណៈសុធាធ្វើដូចម្តេច?

៤. ហេតុអ្វីគេជ្រើសរើសសុធាជាសិស្សឆ្នើម និងជាប្រធានក្រុមប្រឹក្សាកុមារ?

៥. តើអ្នកគួរយកតម្រាប់តាមសុធាឬទេ? ព្រោះអ្វី? ★

**មេរៀនទី១០**

១. តើជីដូនជីតានៅផ្ទះមានភារកិច្ចធ្វើអ្វី?

២. តើពុកមានភារកិច្ចធ្វើអ្វី?

៣. តើអ្នកណាមានភារកិច្ចសំខាន់ជាងគេ? ធ្វើអ្វី?

៤. តើសមាជិកគ្រួសារនេះជាមនុស្សដូចម្តេច?

៥. ដើម្បីឱ្យគ្រួសារមានសុភមង្គល តើប្អូនត្រូវធ្វើដូចម្តេចខ្លះ? ★

**មេរៀនទី១២**

១. តើពុកម៉ែបានធ្វើអ្វីខ្លះ ដើម្បីចិញ្ចឹមគ្រួសារ?

២. តើឪពុកម្តាយមានគុណចំពោះកូនដូចម្តេច?

៣. តើកូនត្រូវធ្វើអ្វីខ្លះ ដើម្បីតបស្នងសងគុណចំពោះឪពុកម្តាយ?

៤. តើប្អូនស្រឡាញ់ឪពុកម្តាយប្អូនដែរឬទេ? ព្រោះអ្វី?

**មេរៀនទី១៤**

១. តើខ្លានិយាយជាមួយគោដូចម្តេច?

២. តើខ្លាសួរកសិកររកអ្វី? តើកសិករឆ្លើយដូចម្តេច?

៣. ហេតុអ្វីបានជាគោ និងក្របីបាក់ធ្មេញលើអស់?

៤. តើក្នុងរឿងនេះ មានតួអង្គអ្វីខ្លះ?

៥. បើសិនជាមានបញ្ហាកើតមានចំពោះមុខ តើយកអ្វីមកដោះស្រាយ? ★

**សម្គាល់ :** សំណួរដែលមានសញ្ញា ★ (ផ្កាយ) ជាសំណួរវិភាគ។ សម្រាប់សំណួរនេះ គ្រូត្រូវទទួល និងសម្របសម្រួលចម្លើយពីសិស្ស ដែលឆ្លើយសមហេតុផល ទោះចម្លើយគ្មានក្នុងអត្ថបទក៏ដោយ។

អ្នកគ្រូឱ្យពន្យល់ក្នុងក្រុមធំ។ នៅពេល

☑ **ទីសេចក្តីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ** គ្រូឱ្យសិស្សអានអត្ថបទអំណានឡើងវិញ រួចសរសេរពាក្យទាំងឡាយដែលគេមិនទាន់ចេះ។ ក្រោយពីនោះរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យ ដែលគេមិនទាន់ចេះទៅតាមការវិភាគនេះ។ ប្រសិនបើមានពាក្យ ដែលសិស្សនៅតែមិនអាចបកស្រាយបានទេ គេត្រូវសួរលោកគ្រូ

លេខ ២យ

**បន្ត...**

## សកម្មភាពគំរូ

អ្នកគ្រូឱ្យពន្យល់ក្នុងក្រុមធំ ។នៅពេលនោះ គ្រូគួរតែសរសេរពាក្យដែលសិស្សមិនចេះអានទាំងនោះនៅលើក្តារខៀនឱ្យសិស្សផ្សេងទៀតមើល និងពិភាក្សាគ្នា។ គ្រូពិនិត្យថានិយមន័យកំណត់ដោយសិស្សថាតើមានន័យគ្រប់គ្រាន់ហើយឬនៅ។ *ឧទាហរណ៍* កសិករទាញដំបង**សំពង**ខ្លា។ ក្នុងល្បះនេះពាក្យ "**សំពង**" ជួយឱ្យយើងបកស្រាយ "**ន័យ**" របស់ពាក្យ "**ដំបង**" ដែលជា "**វត្ថុ**" សម្រាប់វាយ។ មានន័យថា "**វាយ**" ដោយ "**ដំបង**" ។

☑ គ្រូគូរដ្យាក្រាមដូចខាងក្រោមនៅលើក្តារខៀន ដើម្បីឱ្យសិស្សបំពេញព័ត៌មានបន្ថែមទាក់ទងគំនិតសំខាន់អំពី "**គ្រួសារ**" ដោយពិភាក្សាគ្នាជាបុគ្គល។ បន្ទាប់មក ក្រុមធំរកចម្លើយតាមរយៈសំណួរក្នុងដ្យាក្រាម ជាចំណាត់ថ្នាក់គំនិតទៅតាមជំពូកនៃសំណួរនីមួយៗ។ គ្រូសម្គាល់ទៅសិស្សថា ការរកព័ត៌មាននេះ មិនចាំបាច់មើលអត្ថបទទេ គឺសិស្សគិតដោយខ្លួនឯង ប៉ុន្តែនៅពេលឆ្លងការពិភាក្សារួច គ្រូអាចឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយក្នុងអត្ថបទបាន។

លំហាត់នេះមានសារៈសំខាន់ចំពោះសិស្ស ក្នុងការជួយឱ្យគេចេះរៀបចំចំណាត់ថ្នាក់ព័ត៌មាន ក្នុងអត្ថបទ។

*ឧទាហរណ៍* ដកស្រង់ពីអត្ថបទក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ មេរៀនទី១០ ទំព័រទី ៣២។









**លេខ ២យ**

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សជ្រើសរើសពាក្យក្នុងប្រអប់បំពេញ ក្នុងកថាខណ្ឌឱ្យបានត្រឹមត្រូវ។ (មេរៀនទី១០ ទំព័រទី៣៥)។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទៅមក | យើង | ខ្ញុំ | រួម | រស់នៅ | យោគយល់ | ជជែក | សុភមង្គល |

សមាជិកគ្រួសារ . . .ចេះគោរពស្រឡាញ់គ្នា. . .និងជួយទុក្ខធុរៈគ្នាទៅវិញទៅមក. . .។ ពួក. . .តែងជួបជុំទទួលទានអាហារ. . .គ្នានិង. . . លេងយ៉ាងសប្បាយរីករាយ។ គ្រួសារខ្ញុំ. . .ប្រកបដោយ. .។



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ២យ**

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

លេខ
២ង

# សិស្សសរសេរតាមអានអំពី ពាក្យ កន្សោមពាក្យ ល្បះនិង អត្ថបទខ្លី លំហាត់សរសេរតាមអានក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

**សូមមើល មេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ (ទំព័រទី២៦ ទី៣០ ទី៣៥ ទី៤១ និងទី៤៩)**

## ខ្លឹមសារ

ដកស្រង់អត្ថបទសរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

មេរៀនទី៨ ទំព័រទី ២៦ មេរៀនទី៩ ទំព័រទី ៣០ មេរៀនទី១០ ទំព័រទី ៣៥
មេរៀនទី១២ ទំព័រទី ៤១ មេរៀនទី១៤ ទំព័រទី ៤៩

## សកម្មភាពគំរូ

☑ សិស្សអាចចម្លងពាក្យលើក្ដារខៀនតាមខ្លឹមសារ ដែលគ្រូកំណត់ខាងលើដាក់ក្នុងសៀវភៅសរសេររៀងខ្លួន។

☑ សិស្សក្នុងក្រុម **ក** មានគ្នា៤នាក់ និងសិស្សក្នុងក្រុម **ខ** មានគ្នា៤នាក់សរសេរពាក្យចំនួន ៥ ពាក្យក្នុងមួយក្រុមៗ តាមការជ្រើសរើសរបស់ក្រុមនីមួយៗ រួចដូរគ្នាពិនិត្យ និងកែលម្អគ្នាទៅវិញទៅមក។ ឯគ្រូជាអ្នកណែនាំ និងសម្របសម្រួលសិស្សតាមក្រុម។

☑ គ្រូជ្រើសរើសពាក្យពីចំនួន ៨ទៅ១០ពាក្យចម្រុះគ្នាឱ្យសិស្សសរសេរតាមដាក់ក្នុងសៀវភៅសរសេររបស់សិស្សរៀងៗខ្លួន។ បន្ទាប់មក ឱ្យសិស្សរៀបចំពាក្យទាំងនោះទៅជាល្បះមានន័យពេញលេញឱ្យបានពីរ ឬបីល្បះខុសៗគ្នា។ គ្រូជួយសម្របសម្រួល។ *ឧទាហរណ៍* ចូរសរសេរតាមអានរៀបចំពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម។

គុណ ការងារ រាជការ ភ្នំ ស្រែ ចម្ការ សមុទ្រ ត្អូញត្អែរ ទ្វេហារ ចម្អិន។
យើងត្រូវតែបស្នងសងគុណលោក ដោយការខិតខំរៀនសូត្រ។
ខ្ញុំស្រឡាញ់ពុកម៉ែ ព្រោះគាត់ជាអ្នកមានគុណបានចិញ្ចឹម និងថែរក្សាខ្ញុំគ្រប់ពេល។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០


ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ២ង**

**លេខ ២៤**

# សិស្សសរសេរតួអក្សរ និងពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់**

សូមមើល មេរៀនទី៨ និងទី១៤ (ទំព័រទី២៧ និងទី៥០)

## ខ្លឹមសារ

មេរៀនទី៨ "គ" និង "គាត់" (ទំព័រទី២៧)　　មេរៀនទី១៤ "ព" និង "ពាហនៈ" (ទំព័រទី៥០)

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីអក្សរ "**គ ព**" និងពាក្យ "**គាត់ ពាហនៈ**" បានស្អាតល្អតាមទម្រង់អក្សរជ្រៀង និងការណែនាំពីរបៀបគូសបន្ទាត់ សរសេរលើក្ដារខៀន ក្ដារឆ្នួន និងក្នុងសៀវភៅសរសេររៀងៗខ្លួនបានត្រឹមត្រូវ។

*ឧទាហរណ៍*







- ជួរទី១ តួអក្សរ យកកម្ពស់ (បន្ទាត់ឈរ) ៤/៤ (ពេញបន្ទាត់) និងទទឹង (ជួរដេក) យក ២/៣
- ជួរទី២ តួអក្សរយកកម្ពស់ (បន្ទាត់ឈរ) ២/៤ (ពាក់កណ្ដាលបន្ទាត់) និងទទឹង (ជួរដេក) យក ១/៣
- ជួរទី៣ តួអក្សរ យកកម្ពស់ (បន្ទាត់ឈរ) ១/៤ និងទទឹង (ជួរដេក) យក ១/៣

☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ ដូចជាអក្សរ **ភ ធ ជ ដ ឌ** ... ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មក គ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តខាងលើរួចចម្លងចូលក្នុងសៀវភៅសរសេររៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ិត...



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

លេខ
២៨

# សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ តាមការកំណត់របស់គ្រូ

## បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី៨ ទី៩ ទី១០ ទី១២ និងទី១៤ (ទំព័រទី២៧ ទី៣១ ទី៣៥ ទី៣៦ ទី៤២ និងទី៥០)

### ខ្លឹមសារ

ពាក្យ បណ្ដពាក្យ ឬល្បះ ក្នុងលំហាត់បំពេញល្បះកថាខណ្ឌ និងលំហាត់តែងល្បះ នឹងរូបភាពក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

| | | | | | |
|---|---|---|---|---|---|
| មេរៀនទី៨ | ទំព័រទី ២៧ | មេរៀនទី៩ | ទំព័រទី ៣១ | មេរៀនទី ១០ | ទំព័រទី ៣៥ ៣៦ |
| មេរៀនទី ១២ | ទំព័រទី ៤២ | មេរៀនទី ១៤ | ទំព័រទី ៥០ | | |

### សកម្មភាពគំរូ

☑ សិស្សជ្រើសរើសពាក្យក្នុងប្រអប់មកបំពេញក្នុងល្បះតាមរូបភាព (ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ទំព័រទី២៧)។

| | | |
|---|---|---|
| សួរសុខទុក្ខ | មណ្ឌលសុខភាព | លើកដៃសំពះ |




១. នេះជា........ក្នុងឃុំយើង។




២. ស្រីនាថ និងម្ដាយទៅ........អ្នកជំងឺ។




៣. កុមារី.....ពេលជួបអ្នកគ្រូ។

☑ គ្រូបង្ហាញពាក្យចម្រុះ ឬមិនលំដាប់ ឱ្យសិស្សសង្កេត និងអានរួចរៀបពាក្យ កន្សោមពាក្យ ទាំងនោះជាល្បះមានន័យត្រឹមត្រូវ។

| | | | | | | |
|---|---|---|---|---|---|---|
| សិស្ស | មណ្ឌលសុខភាព | ដើម្បី | ទៅ | អ្នកគ្រូ។ | សុខទុក្ខ | សួរ |

*ឧទាហរណ៍*

| | | | | | |
|---|---|---|---|---|---|
| មណ្ឌលសុខភាព។ | មានជំងឺ | ទៅ | ពេល | យើង | ត្រូវ |

១. សិស្សទៅមណ្ឌលសុខភាព ដើម្បីសួរសុខទុក្ខអ្នកគ្រូ។

លេខ
២៨

**បន្ត...**

## សកម្មភាពគំរូ

២. ពេលមានជំងឺ យើងត្រូវទៅមណ្ឌលសុខភាព។

| | | | |
|---|---|---|---|
| និយាយថា | អ្នកទាំងអស់គ្នា។ | គាត់សូមអរគុណ | អ្នកគ្រូ |

៣. អ្នកគ្រូនិយាយថា គាត់សូមអរគុណអ្នកទាំងអស់គ្នា។

☑ គ្រូឱ្យឧទាហរណ៍ពីការរៀបពាក្យ និងកន្សោមពាក្យ ល្បះខ្លីៗចំនួនបី រួចឱ្យសិស្សរៀប ឬផ្សំល្បះទាំងបីទៅជាល្បះតែមួយ។

*ឧទាហរណ៍* ក្របីសើច។ ក្របីដួល។ ក្របីបាក់ធ្មេញលើ។

= ក្របីសើច + ក្របីដួល + ក្របីបាក់ធ្មេញលើ ។ ⟶ ក្របីសើច ដួល ហើយបាក់ធ្មេញលើ។

☑ គ្រូសរសេរបញ្ជីពាក្យគន្លឹះ ដែលស្រង់ពីមេរៀនឱ្យសិស្សសង្កេត រួចយកពាក្យគន្លឹះនោះមកតែងជាល្បះមួយដោយប្រើ

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០


ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ២៨**

**លេខ ២៨**

# សិស្សសរសេរតែងសេចក្តីពណ៌នាអំពីមនុស្ស ដោយប្រើលំនាំតាមគម្រោងតែង និងសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ ទំព័រទី៤៥ ទី៤៦។

## បំណិនសំណេរពាក់ព័ន្ធ : តែងសេចក្តី

សូមមើល មេរៀនទី១៣ (ទំព័រទី៤៣ និងទី៤៦)

### ខ្លឹមសារ

ការពណ៌នាគំរូអំពីមនុស្ស គម្រោងតែង និងសំណួរក្នុងសៀវភៅសិក្សាគោលទំព័រទី៤៥ និងទី៤៦។

### សកម្មភាពគំរូ

☑ គ្រូសរសេរអត្ថបទទំព័រទី៤៣ ជាល្បះនៅលើបណ្ណ (សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់) បិទលើក្ដារខៀនមិនតាមលំដាប់ ហើយឱ្យសិស្សសង្កេត។ បន្ទាប់មក ឱ្យសិស្សអានអត្ថបទគំរូទំព័រទី៤៣ រួចឱ្យសិស្សរៀបបណ្ណល្បះទាំងនោះជាសេចក្តីផ្តើម តួសេចក្តី និង សេចក្តីបញ្ចប់ (រួមមាន៩ល្បះ) ដូចលំនាំខាងក្រោម ៖

| សេចក្តីផ្តើម | តួសេចក្តី | សេចក្តីបញ្ចប់ |
|---|---|---|
| | | |

| | | |
|---|---|---|
| ខ្ញុំគោរព និងស្រឡាញ់.......។ | ម្តាយខ្ញុំមានមាឌ.......។ | ម្តាយខ្ញុំឈ្មោះគន្ធា.......។ |
| សព្វថ្ងៃគ្រួសារខ្ញុំ.......។ | គាត់ជាអ្នករួសរាយ.......។ | ម្តាយខ្ញុំឧស្សាហ៍.......។ |
| នៅពេលមានបុណ្យ.......។ | គាត់និយាយស្តី.......។ | គាត់ចូលចិត្ត.......។ |

☑ គ្រូឱ្យសិស្សឆ្លើយសំណួរនៅទំព័រទី៤៤ អំពីតែងសេចក្តីជាលំនាំគំរូ ដើម្បីឱ្យសិស្សស្គាល់ និងយល់ពីព័ត៌មានផ្សេងៗទាក់ទងនឹងគោលបំណងរបស់លំហាត់នេះ។

☑ គ្រូណែនាំសិស្សឱ្យបំពេញព័ត៌មានក្នុងប្រអប់សេចក្តីអធិប្បាយតាមរយៈប្រអប់គម្រោងតែងសេចក្តី ខាងឆ្វេងដើម្បីជាជំនួយក្នុងការត្រៀមសរសេរតែងសេចក្តីតាមលំនាំដែលកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ទំព័រទី៤៥ ដូចតារាងខាងក្រោម។ បន្ទាប់មក ឱ្យសិស្សហាត់សរសេរតែងសេចក្តីពណ៌នាអំពីលោកគ្រូ អ្នកគ្រូ ដោយសរសេរតាមលំណែនាំសំណួរដូចខាងក្រោម ៖

- ♦ តើគ្រូរបស់ប្អូនជាលោកគ្រូ ឬអ្នកគ្រូ? ឈ្មោះអ្វី? អាយុប៉ុន្មាន? រស់នៅឯណា? មានលក្ខណៈសម្បត្តិដូចម្តេច?
- ♦ តើគ្រូរបស់ប្អូនមានមាឌ កម្ពស់ សម្បុរ សក់ មុខ មាត់ ដៃ ជើង និយាយដូចម្តេច?
- ♦ តើគ្រូរបស់ប្អូន ស្លូត កាច ?
- ♦ តើគ្រូរបស់ប្អូនធ្វើកិច្ចការអ្វីខ្លះ?
- ♦ តើប្អូនចូលចិត្តគ្រូប្អូនឬទេ? ព្រោះអ្វី?

**លេខ ២៨**

## បន្ត...

## សកម្មភាពគំរូ

| គម្រោង | សេចក្តីអធិប្បាយ |
|---|---|
| **សេចក្តីផ្តើម** | |
| បង្ហាញពី ឈ្មោះ ភេទ អាយុ ទីលំនៅ... | ??? |
| **តួសេចក្តី** | |
| បង្ហាញពី រូបរាង អាកប្បកិរិយា ចិត្តគំនិត (លក្ខណៈសម្បត្តិ ចំណុចល្អ មិនល្អ) | ??? |
| **សេចក្តីបញ្ចប់** | |
| បង្ហាញពី ការវាយតម្លៃ ចំណាប់អារម្មណ៍ | ??? |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់




**ដំណាក់កាលទី ២ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ២

នៃឧបសម្ព័ន្ធ ២ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៥១ ដល់ ១៥៣

# ដំណាក់កាលទី ៣ : មេរៀនទី១៥ ដល់ទី២៣ (២០)

(ទំព័រទី៥១ ដល់ទី៧៥)

*១. មេរៀនទី១៥ : អំពីនាម*

*២. មេរៀនទី១៦ : អ្នកមានគុណ*

*៣. មេរៀនទី១៧ : អនាម័យ*

*៤. មេរៀនទី១៨ : កិច្ចការយើងនៅផ្ទះ*

*៥. មេរៀនទី១៩ : តួអង្គ*

*៦. មេរៀនទី២០ : មេរៀនកូនចាំ*

*៧. មេរៀនទី២១ : សញ្ញាខណ្ឌ "។"*

*៨. មេរៀនទី២២ : កុមារចេះសន្សំសំចៃ*

*៩. មេរៀនទី២៣ : ការពណ៌នាអំពីសត្វ*

*( ៥៩ ម៉ោងប្រហែល៥សប្តាហ៍)*

**កំណត់សម្គាល់ :** (២០) ចំពោះមេរៀនទី១៦ សមត្ថភាពស្តាប់មានចំនួន៥ម៉ោងសិក្សា និងមេរៀនទី២២សមត្ថភាពស្តាប់មានចំនួន៥ម៉ោងសិក្សាដែរ។ មេរៀនទាំងនេះមិនទាក់ទងនឹងស្តង់ដាអំណានទេ។ គ្រូត្រូវបង្រៀនតាមធម្មតា។

# លេខ ៣ក

# សិស្សប្រាប់បានពីពាក្យជា នាម តាមនិយមន័យដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនពាក់ព័ន្ធ : វេយ្យាករណ៍

សូមមើល មេរៀនទី១៥ (ទំព័រទី៥១ និងទី៥២)

### ខ្លឹមសារ

- អំពីនាម
- និយមន័យ : ជាពាក្យសម្រាប់សម្គាល់មនុស្ស សត្វ វត្ថុ ទីកន្លែង និងរុក្ខជាតិ...។

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១៥ ពាក្យជានាម ដូចជាពាក្យ សុខា ជ្រូក ទា មាន់ ទ្រុង ទឹក សាប៊ូ លាមក ម៉ាស់ ដើមស្វាយ ចម្ការ មេរោគ។

**សម្គាល់ :** ពាក្យ **មេរោគ** ជានាម។

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សគូសរង្វង់ជុំវិញពាក្យដែលជានាមក្នុងប្រអប់តារាងខាងក្រោម (ទំព័រ៥២)។

| | | | | |
|---|---|---|---|---|
| (ធីតា) | ដើរ | ខ្មៅ | (ក្របី) | សរសេរ |
| ទាប | (ដើមត្នោត) | ក្រហម | (កាតាប) | ឡើង |

☑ គ្រូឱ្យសិស្សអានអត្ថបទនៅទំព័រ៤៧ រឿងគោ និងក្របីគ្មានធ្មេញលើ រួចឱ្យសិស្សស្រង់ និងសរសេរពាក្យដែលជានាមដាក់ក្នុងសៀវភៅសរសេររៀងខ្លួន។

**សម្គាល់ :** ពាក្យ**ប្រាជ្ញា**ជានាម។

☑ គ្រូឱ្យសិស្សចាប់ដៃគូ រួចតែងល្បះដែលមានប្រើនាម ឱ្យបានចំនួន៣ល្បះស្តីអំពី "**សាលារៀន**"។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញពាក្យ "**នាម**" ក្នុងល្បះទាំងនោះ។ ក្នុងល្បះនីមួយៗអាចមានប្រើពាក្យជា "**នាម**" ចំនួន១ ឬ២ ក៏បាន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣ក**

**លេខ ៣២**

# សិស្សកំណត់សូរដើម និងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យដែលគ្រូអាននិងសរសេរ

*ឧទាហរណ៍* ជួយ = ជ + ួ + យ

- "ជ" សូរដើម "អួ" និង "យ" សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ :** ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ

**សូមមើល** មេរៀនទី១៧ ទី១៨ ទី១៩ និងទី២០ (ទំព័រទី៥៦ ទី៦១ ទី៦៥ និងទី៦៧)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១៧ ទី១៨ ទី១៩ និងទី២០ ដូចជា ខំ នាំ នំ លាង ចេះ ជួយ លើក មេ ទា ទេ គិត យើង សុំ សួរ ធំ ទិស ប្រឹង តាម។

♦ ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ គ្រូបង្ហាញរូបភាពនំ ឬ "នំ" ជាក់ស្ដែងអ្វីមួយដល់សិស្ស រួចសួរសិស្សថា តើសូរដើមនៃពាក្យ "នំ" មានសូរអ្វី?

**ចម្លើយ** សូរដើមគឺ "**ន**" សូរបន្ទាប់គឺ "អុំ"។ (ការស្គាល់សូរ)

បន្ទាប់មក គ្រូឱ្យសិស្សរកសូរដើមរបស់ពាក្យផ្សេងទៀតដែលមានសូរដើម និងសូរបន្ទាប់ដូចគ្នានឹងព្យញ្ជនៈ "ន"។

*ឧទាហរណ៍* ពាក្យ " **នាំ និង នាង នេះ នោះ នៅ នា នាក់** . . . "។

☑ គ្រូបង្កើតល្បែងសិក្សាប្រដេញពាក្យ ដែលកំណត់ដោយសូរដើមរបស់ពាក្យ ដែលចាប់ផ្ដើមពីសិស្ស ដំបូង ឬមុនគេ បន្តរហូតដល់សិស្សចុងក្រោយ។ (ការស្គាល់តួអក្សរនិងសូរ)

*ឧទាហរណ៍* សិស្សដំបូងថាពាក្យ "**ចន្ទ**" សិស្សបន្ទាប់ត្រូវចាប់សូរ បន្តពីសូរដើមរបស់ពាក្យ "**ចន្ទ**" គឺ "**ច**" ទៅពាក្យដើមដោយសូរ "**ច**" ផ្សេងទៀតដូចជា "ចាប ចេះ ..." ធ្វើបែបនេះរហូតដល់វេនសិស្សចុងក្រោយទៅតាមការគិត និងការពេញចិត្តរបស់គេរហូតចប់។ (ការស្គាល់តួអក្សរនិងសូរ)

( ពាក្យ "**ចន្ទ**" ចាប ចូល ចេញ ចង់ ចេះ ចាំ ចុះ ចឹក . . . )

**សម្គាល់ :** **ក.** ប្រសិនបើសិស្សណារកសូរដើមរបស់ពាក្យ ដូចសិស្សមុនថារួចហើយជាន់គ្នា ឬដូចគ្នាចាត់ទុកថាចាញ់រួចគ្រូឱ្យសិស្សថ្មីម្នាក់ទៀតរកបន្ត។

**ខ.** គ្រូអាចប្ដូរពាក្យថ្មីដែលមានសូរដើមផ្សេងទៀត និងធ្វើដូចលំនាំខាងលើ។

☑ គ្រូប្រាប់សិស្ស ពាក្យណាមួយដោយទាញសំឡេងឱ្យវែង ដូចជាពាក្យ "កែវ" ក អែ កែនិងវ រួចឱ្យសិស្សទាយថាពាក្យនោះជាពាក្យអ្វី(**កែវ**)។ (ការស្គាល់សូរ)

☑ គ្រូឱ្យសិស្សកំណត់សូរដើម និងសូរបន្ទាប់ដែលគ្រូសរសេរនៅលើក្ដារខៀន។

*ឧទាហរណ៍* ក្រោយពីសរសេរពាក្យ "**គិត**" សិស្សត្រូវកំណត់រកសូរដើម និងសូរបន្ទាប់។

គិត = **គ** + ិ + **ត**

♦ សូរដើម " **គ** " សូរបន្ទាប់ " អិ " និង "**ត**" (ការស្គាល់តួអក្សរនិងសូរ)។

## លេខ ៣ខ

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣ខ**

លេខ ៣គ

# សិស្សប្រើសញ្ញាខណ្ឌ "។" ក្នុងល្បះបានត្រឹមត្រូវតាមការកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣

**បំណិនពាក់ព័ន្ធ : វេយ្យាករណ៍**

**សូមមើល មេរៀនទី២១ (ទំព័រទី ៧១ និងទី៧២)**

## ខ្លឹមសារ

- សញ្ញាខណ្ឌ "។" ជាសញ្ញាដែលគេប្រើដើម្បីបញ្ចប់សេចក្ដីនៅខាងចុងនៃល្បះ ឬល្បះជាកន្សោមពាក្យ ឬក្រុមពាក្យមានន័យគ្រប់គ្រាន់។ (មាននាមជាអ្នកធ្វើអំពើណាមួយ)

## សកម្មភាពគំរូ

☑ គ្រូឱ្យល្បះមួយចំនួនចម្រុះគ្នា រួចឱ្យសិស្សដាក់សញ្ញាខណ្ឌ "។" ក្នុងល្បះទាំងនោះឱ្យបានត្រឹមត្រូវ។

*ឧទាហរណ៍* ចូរដាក់សញ្ញាខណ្ឌបញ្ចប់ល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

- យើងត្រូវខិតខំរៀនសូត្រទាន់ខ្លួននៅក្មេង
- យើងនាំគ្នារៀនលេខ និងអក្សរឱ្យបានពូកែ
- ការខ្ជិលច្រអូស
- កូនល្អស្ដាប់ម៉ែ សិស្សពូកែស្ដាប់គ្រូ
- ការឧស្សាហ៍ព្យាយាម

គ្រូសរសេរឃ្លា ល្បះ ថ្មីខ្លះទៀត ដែលគ្មានសញ្ញាផ្សេងៗ ដាក់លើក្ដារខៀន រួចឱ្យសិស្សអាន និងដាក់សញ្ញាទាំងនោះក្នុងឃ្លា ល្បះ ឱ្យបានត្រឹមត្រូវ។

*ឧទាហរណ៍* ផ្ទះខ្ញុំតូចតែស្អាត បន្ទប់ដេករបស់ខ្ញុំមានគ្រែតូចមួយ ហើយមានបង្អួចបើកចំហនាំឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ ថ្វីត្បិតផ្ទះខ្ញុំតូច តែវាមានបរិស្ថានល្អស្រស់បំព្រងព្រោះវាមានរបងព័ទ្ធជុំវិញ សួនច្បារមានដំណាំហូបផ្លែ និងបន្លែគ្រប់ប្រភេទសម្រាប់គ្រួសារ។

☑ គ្រូឱ្យសិស្សសរសេរល្បះចំនួន២ ឬ៣អំពីភូមិរបស់គេ ដោយខ្លួនឯង រួចឱ្យសិស្សដាក់សញ្ញា "។" បានត្រឹមត្រូវ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣គ**

លេខ ៣យ

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និង សទិសសព្ទ ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី១៧ ទី១៨ និងទី២០ (ទំព័រទី៥៧ ទី៦២ និងទី៦៨)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី១៧ ទី១៨ និងទី២០ដូចជា ៖

**ពន្យល់ពាក្យ**

**មេរៀនទី១៧**

- បរិភោគ (កិ.) : ហូប ពិសានំ ចំណី អាហារ។
- អនុវត្ត (កិ.) : ធ្វើតាម ប្រតិបត្តិតាម គោរពតាម។
- សុខភាព (ន.) : ភាពជាសុខ សេចក្តីសុខ។

**មេរៀនទី១៨**

- ដំបូន្មាន (ន.) : សេចក្តីទូន្មាន ឱវាទ ពាក្យប្រដៅ។
- បវរ (គុ.) : ប្រសើរលើសលប់ ថ្លៃថ្លា។
- ស្មោះសរ (ន.) : សេចក្តីកែរាយរាក់ទាក់។
- សុខសាន្ត (គុ.) : ដែលស្ងប់។

**មេរៀនទី២០**

- បូព៌ (ន.) : ទិសខាងកើត។
- ទក្សិណ (ន.) : ទិសខាងត្បូង។
- ឧត្តរ (ន.) : ទិសខាងជើង។
- បស្ចិម (ន.) : ទិសខាងលិច។

**បដិសព្ទ**

**មេរៀនទី១៧**

មុខ ≠ ក្រោយ ខ្ជិល ≠ ឧស្សាហ៍

**មេរៀនទី១៨**

សុខសាន្ត ≠ ទុក្ខព្រួយ ស្មោះ ≠ ក្បត់

**មេរៀនទី២០**

ខ្ចីឃ្លាត ≠ ប្រមូល មាំមួន ≠ ទន់ជ្រាយ

**វេវចនសព្ទ**

**មេរៀនទី១៧** វេវចនសព្ទនឹងពាក្យ "ល្អ"

**ល្អ** ត្រឹមត្រូវ ប្រពៃ ហ្មត់ហ្មង។

**មេរៀនទី១៨** វេវចនសព្ទនឹងពាក្យ "រូតរះ"

**រូតរះ** ម៉ីម្នា ឃ្មាតខ្មី រួសរាន់ ហ៊ាស៊រហួន។

**មេរៀនទី២០** វេវចនសព្ទនឹងពាក្យ "ប្រឹង"

**ប្រឹង** ខិតខំ ប្រឹងប្រែង សង្វាត ព្យាយាម

**សទិសសព្ទ**

**មេរៀនទី១៧** សទិសសព្ទនឹងពាក្យ "រស់"

- រស់ (គុ.) : ដែលមានជីវិតរស់នៅ។
- រស (ន.) : រសជាតិអាហារ រសជាតិនំចំណី។

**មេរៀនទី២០** សទិសសព្ទនឹងពាក្យ "ពីរ"

- ពីរ (គុ.) : មួយគូបគ្នា គឺមួយនិងមួយ(២)។
- ពី (ន.) :(អា.និ) អំពី ពីនេះពីនោះ។

*ឧទាហរណ៍* មកពីណា។

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យ របស់ពាក្យពិបាកនោះ ដោយគូសភ្ជាប់សញ្ញាព្រួញ។ *ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្តាំ ឱ្យត្រូវនឹងនិយមន័យរបស់វា។

| ពាក្យពិបាក | និយមន័យ | ពាក្យពិបាក | និយមន័យ | ពាក្យពិបាក | និយមន័យ |
|---|---|---|---|---|---|
| ដំបូន្មាន | ♦ ពាក្យគោរព<br>♦ ពាក្យសរសើរ<br>♦ ពាក្យប្រដៅ | បវរ | ♦ ភាពស្មោះត្រង់<br>♦ ភាពកោតសរសើរ<br>♦ ភាពល្អប្រសើរ លើសលប់។ | បូព៌ | ♦ ទិសខាងលិច<br>♦ ទិសខាងកើត<br>♦ ទិសខាងជើង |

លេខ
៣យ

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូបង្កើតបណ្ណពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដែលមានន័យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | |
|---|---|---|---|---|---|
| ខ្ជិល | ស្មោះ | មុន | សុខសាន្ត | មាំមួន | ខ្មីឃ្មាត |

- ♦ បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្ដារខៀន។ សិស្សត្រូវនឹករកពាក្យផ្សេងទៀត ដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាន និយមន័យដូចគ្នាទេ តែមានទំនាក់ទំនងជាមួយគ្នាតាមដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ** ដោយមានការបង្ហាញគំនិតពាក់ព័ន្ធផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ "**សុខភាព**" នៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដទៃដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែមិនមែនមានន័យថារកពាក្យដែលន័យដូចនោះទេ។ បន្ទាប់មក គ្រូឱ្យសិស្សហាត់រកពាក្យ "ទិស" ដោយខ្លួនឯង។







☑ គ្រូសរសេរបញ្ជីពាក្យនិងគូសតារាងនៅលើក្ដារខៀន។ តារាងទី១ជាវេវចនសព្ទ តារាងទី២ជាបដិសព្ទ។ បន្ទាប់មក គ្រូឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទាំងនេះទៅតាមប្រភេទតារាងនីមួយៗជាវេវចនសព្ទ និងបដិសព្ទ។

*ឧទាហរណ៍* គ្រូសរសេរពាក្យខាងក្រោម ដាក់លើក្ដារខៀន រួចបង្ហាញឧទាហរណ៍ខាងក្រោមពន្យល់សិស្ស។ បន្ទាប់មក ឱ្យសិស្សរកដោយខ្លួនឯង។

ខាងកើត ម្នីម្នា ឧស្សាហ៍ ព្យាយាម មុន រួតរះ បូព៌ា រៀនសូត្រ ខ្ជិល ក្រោយ ខិតខំ សិក្សា។ បន្ទាប់មក គ្រូបង្ហាញជាឧទាហរណ៍លើតារាងនេះ រួចឱ្យសិស្សរកពាក្យដទៃទៀតដោយខ្លួនឯង។

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| ព្យាយាម ខិតខំ<br>.................... | មុន ≠ ក្រោយ<br>............. ≠ .............. |

**លេខ ៣យ**

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី៣យ**

លេខ
៣៦

## សិស្សរកសូរចួនក្នុងពាក្យដែលត្រូវអាននិងសរសេរ

**សម្គាល់ :** មុនបង្រៀនពាក្យចួន ក្នុងអត្ថបទសំណេរគ្រូគួររំឭកបញ្ញត្តិពាក្យចួន ដោយប្រើភាសានិយាយសិន។

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី១៨ និងទី២០ (ទំព័រទី៦១ និងទី៦៧)**

### ខ្លឹមសារ

និយមន័យ "ពាក្យចួន" **ពាក្យចួន** គឺជាពាក្យមានសូរស្រៈដូចគ្នា ឬសូរស្រៈប្រកបនឹងព្យញ្ជនៈដូចគ្នា ក្នុងវគ្គរបស់កំណាព្យ ឬ មេសូត្រ។ *ឧទាហរណ៍* មេសូត្រ (បទកាកគតិ)មេរៀនទី១៨ ទំព័រទី៦១។

- ពាក្យ "សាលា" ចួននឹង "សិក្សា"
- ពាក្យ "អក្សរ" ចួននឹង "បន្ត" ចួននឹង "ល្អ" ។

### សកម្មភាពគំរូ

☑ គ្រូនិយាយប្រាប់សិស្សថា គ្រូនឹងអានពាក្យចំនួន ៤។ ចូរប្អូនស្តាប់ដោយយកចិត្តទុកដាក់ ហើយឆ្លើយមកគ្រូវិញថា តើពាក្យមួយណាក្នុងចំណោមពាក្យទាំងបួននោះ ដែលមិនមែនជាពាក្យចួន (សូរខុសគេ)។

*ឧទាហរណ៍*

| | | | |
|---|---|---|---|
| ប្រដាប់ប្រដា | សិក្សា | **គោរព** | សាលា |
| ប្រពៃ | **ជួរ** | ដៃ | បំភ្លៃ |
| បើ | ដើរ | តើ | **ហើយ** |
| **ខំ** | ត្រី | ដី | ស្រី |

☑ គ្រូសរសេរពាក្យចួនមួយចំនួនលើក្តារខៀន រួចឱ្យសិស្សរកសូរអក្សរណា ដែលមានសូរដូចគ្នានៅខាងចុងឱ្យបានច្រើនតាមដែលអាចធ្វើបាន។ *ឧទាហរណ៍*

- ពាក្យ "**ការពារ**" និង "**ធានា**" គឺមានតួអក្សរ "**ព**" និង "**អា**" ចួននឹងតួអក្សរ "**ន**" និង "**អា**" ដូចគ្នា។
- ពាក្យ "**រង់**" និង "**នៃ**" គឺមានតួអក្សរ "**រ**" និង "**អៃ**" ចួននឹងតួអក្សរ "**ន**" និង "**អៃ**" ដូចគ្នា
- ពាក្យ "**សោះ**" និង "**កោះ**" គឺមានតួអក្សរ "**ស**" និងស្រៈ " **អោះ**" ចួននឹងតួអក្សរ "**ក**" និងស្រៈ "**អោះ**" ដូចគ្នា។

ដូចនេះ ពាក្យ **ការពារ** និង**ធានា** ⟶ **ពារ** ⟷ **នា** (**ពារ** ចួននឹង**នា**)

ពាក្យ **រង់** និង**នៃ** ⟶ **រង់** ⟷ **នៃ** (**រង់** ចួននឹង**នៃ**)

ពាក្យ **សោះ** និង**កោះ** ⟶ **សោះ** ⟷ **កោះ** (**សោះ** ចួននឹង**កោះ**)

☑ គ្រូសរសេរអត្ថបទមេសូត្រ ដាក់លើក្តារខៀន រួចឱ្យសិស្សឡើងគូសគំនូសតាងពាក្យចួននៅលើក្តារខៀន។

*ឧទាហរណ៍*

កូនទៅសាលា ខិតខំសិក្សា រៀនលេខអក្សរ

ពេលមកដល់ផ្ទះ ខំរៀនបន្ត ឱ្យចេះចាំល្អ

នោះទើបប្រសើរ។

**លេខ ៣ង**

## បន្ត...

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣ង**

**លេខ ៣៤**

# សិស្សបកស្រាយន័យនៃល្បះ អត្ថបទ និងមេសូត្រនៅតាមមេរៀនដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី១៧ ទី១៨ ទី១៩ និងទី២០ (ទំព័រទី៥៧ ទី៦២ ទី៦៦ និងទី៦៨)

### ខ្លឹមសារ

ល្បះ អត្ថបទ និងមេសូត្រ ក្នុងមេរៀនទី១៧ ទី១៨ ទី១៩ និងទី២០ ដូចជា ៖

- មេរៀនទី១៧ : អនាម័យ
- មេរៀនទី១៨: កិច្ចការយើងនៅផ្ទះ
- មេរៀនទី១៩ : តួអង្គ
- មេរៀនទី២០ : មេរៀនកូនចាំ

### សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរក្នុងសៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី៣ មេរៀនទី១៧ ទី១៨ ទី១៩ និងទី២០

**មេរៀនទី១៧**

១. តើកុមារមានទម្លាប់អាក្រក់មានលក្ខណៈយ៉ាងណាខ្លះ?
២. មុនពេលញ៉ាំនំចំណី តើកុមាររូបនោះបានធ្វើដូចម្ដេច?
៣. ដោយសារគ្មានអនាម័យនាំឱ្យកុមាររូបនោះមានសុខភាពដូចម្ដេច?
៤. ហេតុអ្វីបានជាសុខភាពរបស់កុមារនោះល្អឡើងវិញ?

**មេរៀនទី១៨**

១. តើនៅក្នុងសាលារៀនកូនបានធ្វើអ្វីខ្លះ?
២. តើនៅផ្ទះកូនបានធ្វើអ្វីខ្លះ?
៣. តើកូនចូលចិត្តជួយធ្វើកិច្ចការផ្ទះជាមួយឪពុកម្ដាយកូនដែរឬទេ? ព្រោះអ្វី? ★

**មេរៀនទី១៩**

១. តើតួអង្គក្នុងរឿងនេះមាននរណាខ្លះ?
២. តើលោកចៅហ្វាយប្រាប់ទៅនរណាឱ្យសម្លាប់ជ្រូក?
៣. តើលោកចៅហ្វាយឱ្យអ្នកបម្រើសម្លាប់ជ្រូក យកអ្វីមកជូនគាត់?
៤. ហេតុអ្វីបានជាអ្នកបម្រើយកបេះដូង និងអណ្ដាត ជូនចៅហ្វាយដដែលៗ? ★

**មេរៀនទី២០**

១. តើអត្ថបទមេសូត្រខាងលើ កូននិយាយពីអ្វីប្រាប់ឪពុកម្ដាយ?
២. តើទិសធំទាំងអស់មានប៉ុន្មាន? មានឈ្មោះអ្វីខ្លះ?
៣. តើទិសតូចទាំងអស់មានប៉ុន្មាន? មានឈ្មោះអ្វីខ្លះ?

☑ គ្រូអាចសួរសំណួរបន្ថែម ដើម្បីពង្រឹងការគិត វិភាគរបស់សិស្ស។

១. តើមានអ្វីដែលប្អូនអាចធ្វើបាននៅសាលារៀន ដើម្បីកែលម្អអនាម័យ? (មេរៀនទី១៧)
២. តើអណ្ដាតតំណាងអ្វីក្នុងរឿងនេះ? (មេរៀនទី១៩)

លេខ ៣ច

បន្ត...

## សកម្មភាពគំរូ

៣. តើបេះដូងតំណាងអ្វីក្នុងរឿងនេះ? (មេរៀនទី១៩)

៤. តើទិសមានសារៈសំខាន់អ្វី? (មេរៀនទី២០)

*សម្គាល់* : សំណួរដែលមានសញ្ញា ★(ផ្កាយ) ជាសំណួរវិភាគ។ សម្រាប់សំណួរនេះ គ្រូគួរតែទទួលចម្លើយពីសិស្សដែលឆ្លើយសមហេតុផល ទោះចម្លើយគ្មានក្នុងអត្ថបទក៏ដោយ។

☑ ក្រោយពីអានរឿងគ្រូសរសេរព្រឹត្តិការណ៍សំខាន់ៗក្នុងរឿងមិនតាមលំដាប់លំដោយ។ សិស្សត្រូវដាក់លេខខាងមុខព្រឹត្តិការណ៍នីមួយៗទៅតាមលំដាប់លំដោយបានកើតឡើងក្នុងរឿង។ *ឧទាហរណ៍* គ្រូណែនាំសិស្សឱ្យបង់លេខក្នុងប្រអប់ល្បះនីមួយៗតាមលំដាប់លំដោយព្រឹត្តិការណ៍។

- ☐ អ្នកបម្រើឆ្លើយថា ល្អ ឬអាក្រក់មកពីសំដី និងចិត្ត គឺអណ្ដាត និងបេះដូងនេះឯង។ (៦)
- ☐ ចៅហ្វាយបញ្ជាឱ្យយកអ្វីដែលល្អក្នុងខ្លួនជ្រូកមកជូនគាត់។ បុរសនោះយកអណ្ដាត និងបេះដូងជ្រូកជូនគាត់។ (២)
- ☐ បន្ទាប់មក អ្នកបម្រើយកអណ្ដាត និងបេះដូងជូនចៅហ្វាយ។ (៣)
- ☐ ថ្ងៃមួយអ្នកបម្រើសម្លាប់ជ្រូកតាម បញ្ជារបស់ចៅហ្វាយ។ (១)
- ☐ បន្ទាប់មកទៀត ចៅហ្វាយឱ្យបុរសនោះយកអ្វីក្នុងខ្លួនជ្រូក ដែលអាក្រក់មកជូនគាត់ម្ដងទៀត។ បុរសនោះក៏យកអណ្ដាត និងបេះដូងជ្រូកជូនគាត់ដដែល។ (៤)
- ☐ ចៅហ្វាយឆ្ងល់សួរ ហេតុអ្វីបានជាយកអណ្ដាត និងបេះដូងដដែលៗមកជូនគាត់។ (៥)

☑ សិស្សអាចបំពេញលំហាត់ក្លូសតាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទមកបំពេញបានត្រឹមត្រូវ។ (មេរៀនទី១៧ទំព័រទី៥៦)

មានកុមារម្នាក់មិនសូវខិតខំ...(១) និងមានទម្លាប់អាក្រក់មិន...(២)ខ្លួនប្រាណ។ រាល់សម្លៀកបំពាក់របស់គេ...(៣)ដែលស្អាត។ មុនពេលបរិភោគនំ...(៤)កុមាររូបនេះមិនដែល...(៥)ដៃនឹងសាប៊ូសោះ។ ពេល ...(៦)វាយកដៃកខ្វក់នោះ...(៧)ជូតនឹងខ្លួនប្រាណ ឬសម្លៀកបំពាក់។...(៨)វាឈឺ សុខភាពវាទ្រុឌទ្រោម...(៩)ចុះខ្សោយជាលំដាប់។

**ចម្លើយ :** ១. សិក្សា រៀនសូត្រ ២. លាង សម្អាត ៣. ពុំ មិន ៤. ចំណី ម្ហូប អាហារ ៥. លាង សម្អាត ៦. ខ្វះ ៧. ទៅ មក ៨. ក្រោយមក បន្ទាប់មក ក្រោយមកទៀត ៩. និង ហើយ

☑ គ្រូឱ្យសិស្សអានអត្ថបទណាមួយឡើងវិញ រួចឱ្យសិស្សសរសេរពាក្យដែលមិនទាន់ចេះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ បន្ទាប់មក គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យពាក្យមិនចេះនោះតាមទីសេចក្ដី (**ទីសេចក្ដីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ**)។ បន្ទាប់មក សិស្សសរសេរនិយមន័យពាក្យដែលកំណត់តាមការវិភាគនេះ។

ប្រសិនបើសិស្សមិនអាចបកស្រាយនិយមន័យពាក្យណាមួយបាន គេអាចសួរគ្រូក្នុងក្រុមធំបាន។ គ្រូគួរសរសេរពាក្យទាំងអស់នោះនៅលើក្ដារខៀនឱ្យសិស្សដទៃទៀតមើល ដើម្បីផ្ដល់យោបល់ ហើយគ្រូជួយកែលម្អ។

*ឧទាហរណ៍* ចូរបកស្រាយនិយមន័យពាក្យតាមទីសេចក្ដី។

- មេមាន់ឃើញកូនទា**កំព្រា**ក៏យកមក**ចិញ្ចឹម**។

  ដូចនេះឃ្លា "... **យកមកចិញ្ចឹម**" សម្គាល់ថា "**កំព្រា**"។

  ពាក្យ "**កំព្រា**" មានន័យថា ជាអ្នកគ្មានមេបា ឪពុកម្ដាយ ឬគ្មានអ្នក "**ចិញ្ចឹម**"។

  ក្នុងល្បះខាងលើនេះពាក្យ "**សំពង**" ជួយឱ្យយើងបកស្រាយ "**ន័យ**" របស់ពាក្យ "**ដំបង**" ដែលជា

លេខ ៣ច

**បន្ត...**

## សកម្មភាពគំរូ

‶**វត្ថុ**″ សម្រាប់វាយ។ មានន័យថា ‶**វាយ**″ ដោយ ‶**ដំបង**″ ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣ច**

លេខ ៣៨

# សិស្សសរសេរតាមអានអត្ថបទខ្លីដែលបានកំណត់ក្នុងលំហាត់សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

សូមមើល មេរៀនទី១៧ ទី១៨ និងទី២០ (ទំព័រទី៥៨ ទី៦៣ និងទី៦៩ និងទី៧០)

## ខ្លឹមសារ

សរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

មេរៀនទី១៧ ទំព័រទី៥៨ មេរៀនទី១៨ ទំព័រទី៦៣ មេរៀនទី២០ ទំព័រទី៦៩

## សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យពិបាកមួយចំនួនដែលដកស្រង់ពីអត្ថបទក្នុងសៀវភៅសិក្សាគោល ឬការកំណត់ដោយគ្រូដាក់លើក្ដារខៀន ហើយឱ្យសិស្ស អានពាក្យទាំងនោះម្ដងមួយពាក្យៗឱ្យឮៗចឱ្យសិស្ស២ ឬ៣នាក់ចង្អុល និងអានតាមដោយធ្វើអក្ខរាវិរុទ្ធ... អក្ខរវិញ្ញាស(រាប់តួអក្សរតាមលំដាប់លំដោយនៅក្នុងពាក្យ)ផង។

*ឧទាហរណ៍* ពាក្យពិបាកស្រង់ពី អត្ថបទសរសេរតាមអាន "ការភ្ញាក់រព្ញក" (ទំព័រទី៥៨)

ខ្ជិល ប្រអូស សម្អាត ទ្រុឌទ្រោម អនាម័យ ភ្ញាក់រព្ញក អនុវត្ត សុខភាព។

- បន្ទាប់មក គ្រូហៅពាក្យទាំងនោះឱ្យសិស្សសរសេរលើក្ដារឆ្នួនរួចកែលម្អ។

☑ គ្រូហៅអត្ថបទក្នុងមេរៀន ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឱ្យសិស្ស ហើយឆ្លើយសំណួរ និងលំហាត់តាមការកំណត់របស់គ្រូ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣៨**

**លេខ ៣៨**

## សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ

**បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ**

**សូមមើល មេរៀនទី១៧ ទី១៨ និងទី២០ (ទំព័រទី៥៩ ទី៦៤ និងទី៧០)**

**ខ្លឹមសារ**

ពាក្យ កន្សោមពាក្យ ឬល្បះ ក្នុងលំហាត់បំពេញល្បះ ឬលំហាត់តែងល្បះតាមរូបភាពក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖ មេរៀនទី១៧ ទំព័រទី៥៩ មេរៀនទី១៨ ទំព័រទី៦៤ មេរៀនទី២០ទំព័រទី៧០

**សកម្មភាពគំរូ**

☑ គ្រូសរសេរល្បះមួយចំនួនដែលបានដកស្រង់ពីមេរៀនណាមួយ ដាក់លើក្ដារខៀនរួច ឱ្យសិស្សគូសបន្ទាត់ខណ្ឌពាក្យនីមួយៗ ក្នុងល្បះនោះដើម្បីជួយសិស្សឱ្យយល់ពី "**ល្បះ**" ដែលកើតចេញពីពាក្យច្រើនផ្គុំគ្នាមានន័យពេញលេញស្ដាប់បាន។ *ឧទាហរណ៍*

មេមាន់ | ភ្ញាស់ | កូន | បាន | មួយ | សំបុក។

☑ គ្រូបង្ហាញពាក្យ កន្សោមពាក្យចម្រុះ ឬមិនតាមលំដាប់ រួចឱ្យសិស្សសង្កេត និងអាន (មេរៀនទី ១៩ ទំព័រទី៦៥) ហើយបំពេញក្នុងល្បះតាមការកំណត់របស់គ្រូ។ *ឧទាហរណ៍* ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងវគ្គនៃមេសូត្រខាងក្រោម ៖

| | | | | | |
|---|---|---|---|---|---|
| ប្រើ | បរ | ដើរ | ជួយ | ស្មោះត្រង់ | ផ្ទះ ប្រសើរ |

រៀនរួចរូតរះ
ជួយតាមកម្លាំង

កូនល្អចេះ.....
ស្ដាប់ដំបូន្មាន

ជួយកិច្ចការ.....
កុំគិតគេច.....
ថាជាបុត្រល្អ។
ខិតខំលើកស្ទួយ
ដោយចិត្ត.....
គ្រួសារសុខសាន្ត។

ម៉ាក់ប៉ាលោក.....
ទើបគេសរសើរ

គ្រួសារ.....
ពុកម៉ែត្រេកអរ

☑ គ្រូឱ្យឧទាហរណ៍ល្បះខ្លីៗចំនួនពីរល្បះ រួចឱ្យសិស្សរៀប ឬផ្សំល្បះទាំងពីរនេះទៅជាល្បះតែមួយ។

*ឧទាហរណ៍*

- សិស្សខិតខំរៀនសូត្រ។
- សិស្សមានទម្លាប់ល្អសម្អាតខ្លួនប្រាណ។

= សិស្សខិតខំរៀនសូត្រ + សិស្សមានទម្លាប់ល្អសម្អាតខ្លួនប្រាណ។

⟶ សិស្សខិតខំរៀនសូត្រ និង មានទម្លាប់ល្អសម្អាតខ្លួនប្រាណ។

លេខ ៣៨

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សដាក់ចំណងជើងរូបភាព និងតែងល្បះតាមរូបភាពក្នុងលំហាត់តែងល្បះ ដែលគ្រូបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣។ (មេរៀនទី១៧ ទំព័រទី៥៩ មេរៀនទី១៨ ទំព័រទី៦៤ និងមេរៀនទី២០ ទំព័រទី៧០)




១. ..................



២. ..................



៣. ..................



កុមារី ................។



..........កំពុងរៀន។



.........................។

.........................។



........................។

........................។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៣៨**

លេខ ៣ឈ

# សិស្សសរសេរតែងសេចក្តីពណ៌នាអំពីសត្វ ដោយប្រើលំនាំតាមគម្រោងតែងនិងសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនសំណេរពាក់ព័ន្ធ : តែងសេចក្តី

សូមមើល មេរៀនទី២៣ (ទំព័រទី៧៤ និងទី៧៥)

### ខ្លឹមសារ

អត្ថបទការពណ៌នាអំពីសត្វ គម្រោងតែង និងសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ទំព័រទី៧៤ និងទី៧៥។

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សឆ្លើយសំណួរអំពីសត្វ នៅទំព័រទី៧៤ ក្នុងសៀវភៅសភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣។

សំណួរ

១. តើចម្រើនជាឈ្មោះសត្វអ្វី? ញី ឬឈ្មោល?
២. តើចម្រើនជាសត្វមានរូបរាង សម្បុរដូចម្តេច?
៣. តើប្អូនយល់ថាចម្រើន ជាសត្វដូចម្តេច?
៤. តើប្អូនមានអារម្មណ៍ដូចម្តេច ចំពោះការចិញ្ចឹមសត្វឆ្មា?

☑ គ្រូបង្ហាញតារាងសង្ខេបពាក្យ សម្រាប់ប្រើក្នុងការភ្ជាប់គំនិត ពីល្បះមួយទៅល្បះមួយ ក្នុងការតែងសេចក្តីឱ្យសិស្សពិនិត្យ។ គ្រូពន្យល់ថាពាក្យនេះមានសារប្រយោជន៍ជួយយើងក្នុងការឆ្លងឬផ្លាស់ប្តូរពីគំនិតមួយទៅគំនិតមួយថ្មីទៀត។ ដូចជាមានការសម្គាល់អំពីពេលវេលា ទីកន្លែង ហេតុផល ការបន្ថែមគំនិត។ល។ ចូរសង្កេតតារាងខាងក្រោមបន្ថែម ៖

| | |
|---|---|
| ពេលវេលា | ក្រោយពី ពីមុន រហូតដល់ ទីបំផុត ពេល ក្នុងពេលដែល |
| ហេតុផល | ដោយសារ ដូចនេះ ដើម្បី ហេតុនេះ ពីព្រោះ |
| ការបន្ថែម | ម្យ៉ាងទៀត ហើយ ហើយនិង ព្រមទាំង លើសពីនេះទៀត យ៉ាងណាមិញ |
| សេចក្តីសន្និដ្ឋាន | ដូចនេះ ហេតុនេះ អាស្រ័យហេតុនេះ |
| ការផ្លាស់ប្តូរ | ក៏ប៉ុន្តែ ទោះបីជា យ៉ាងណាក៏ដោយ |
| ការប្រៀបធៀប | ដូចជា ប្រហាក់ប្រហែល |
| លក្ខខណ្ឌ | ប្រសិនបើ លើកលែងតែ |
| ទីកន្លែង | ទីណាដែល កន្លែងណាដែល |

រួចឱ្យសិស្សធ្វើលំហាត់បំពេញលើក្តារខៀន ដោយប្រើពាក្យសម្រាប់ភ្ជាប់គំនិតពីល្បះមួយទៅល្បះមួយដូចមានក្នុងតារាងខាងលើ។ សិស្សអាចធ្វើលំហាត់ជាក្រុមតូច ឬបុគ្គល។

ពេលសិស្សធ្វើរួច គ្រូឱ្យសិស្សប្រៀបធៀបពាក្យផ្សេងទៀតដែលគេបានប្រើ ដើម្បីបំពេញល្បះហើយពិនិត្យពាក្យ

លេខ ៣ឈ

**បន្ត...**

## សកម្មភាពគំរូ

ដែលគេប្រើនោះឱ្យបានត្រឹមត្រូវកុំឱ្យប្រើពាក្យខុស ឬមានកំហុសឆ្គង។ *ឧទាហរណ៍*

... (១)ឆ្កែក្រោកពីដេកវាឃ្លានយ៉ាងខ្លាំង។ ឆ្កែនោះចាប់ផ្ដើមព្រូសឱ្យសុខាយកចំណីឱ្យវាស៊ី។ ...(២)សុខាឮឆ្កែព្រូសវាបានត្រៀមឱ្យចំណីឆ្កែស៊ី។ ...(៣)សុខាបានត្រៀមទឹកឱ្យវាផឹកដែរ។ ...(៤)ឆ្កែពេញចិត្ត ...(៥) វាមានទាំងទឹក និងចំណីស៊ី។ .....(៦) សុខារវល់ធ្វើកិច្ចការផ្ទះក៏ដោយ .....(៧) វាចេះថែទាំឆ្កែរបស់វា ...(៨) វាស្រឡាញ់ឆ្កែវានេះ។

**សម្គាល់ :** ពាក្យបំពេញលំហាត់ខាងលើក្នុងចន្លោះ ៖

(១) ពេល ក្រោយពេល (២) ពេល ដោយសារ (៣) ម៉្យាងទៀត លើសពីនេះ(៤) ដូចនេះ (៥) ពីព្រោះ

(៦) ទោះបីជា (៧) ក៏ប៉ុន្តែ (៨) ព្រោះ

☑ គ្រូសរសេរល្បះទាំង១១ ជាបណ្ណល្បះ ដែលដកស្រង់ពីអត្ថបទ"**ចម្រើនឆ្មាខ្ញុំ**" នៅទំព័រទី៧៤។ បន្ទាប់មក គ្រូគូសតារាងនៅលើក្ដារខៀន: សេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ រួចបិទបណ្ណល្បះទាំង១១ខាងលើមិនតាមលំដាប់នៅលើក្ដារខៀន ហើយឱ្យសិស្សសង្កេត។ បន្ទាប់មកទៀត គ្រូពន្យល់អំពីគម្រោងតែងសេចក្ដី (លំនាំអត្ថបទគំរូទំព័រ ៧៤) រួចឱ្យសិស្សរៀបល្បះទាំងនោះ ឱ្យត្រូវតាមសេចក្ដីផ្ដើម តួសេចក្ដី និង សេចក្ដីបញ្ចប់ ដូចលំនាំខាងក្រោម ៖

| សេចក្ដីផ្ដើម | តួសេចក្ដី | សេចក្ដីបញ្ចប់ |
|---|---|---|
| | | |

| | | |
|---|---|---|
| វាចាសត្វចតុបាទ.......។ | វាមានរាងតូច.......។ | ខ្ញុំមានឆ្មាឈ្មោលមួយ..។ |
| ក្បាលវារាងមូលភ្នែកធំៗ....។ | សព្វថ្ងៃគ្រួសារខ្ញុំ......។ | ចម្រើនមានរោម......។ |
| នៅពេលវាចាប់កណ្ដុរ......។ | ឯច្រមុះវាតូចតែ.......។ | ធ្មេញវាស្រួច.......។ |
| ខ្ញុំស្រឡាញ់ចម្រើន......។ | ជើងទាំង៤របស់វាមាន......។ | ចំណែកត្រចៀកទាំង....។ |

☑ គ្រូឱ្យសិស្សឆ្លើយសំណួរនៅទំព័រទី៧៥ អំពីតែងសេចក្ដីជាលំនាំគំរូ ដើម្បីឱ្យសិស្សស្គាល់ពីគោលបំណងរបស់លំហាត់នេះ ពោលឱ្យសិស្សយល់ពីព័ត៌មានផ្សេងៗ ដែលបានកំណត់ក្នុងការតែងសេចក្ដី ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣។ បន្ទាប់មក គ្រូឱ្យសិស្សហាត់សរសេរតែងសេចក្ដីពណ៌នាអំពីសត្វ ចិញ្ចឹមណាមួយដូចជា សត្វឆ្កែ ឆ្មា គោ ក្របីឬជ្រូកដោយសរសេរតាមលំណែនាំសំណួរដូចខាងក្រោម ៖

១. តើសត្វដែលប្អូនចិញ្ចឹមនោះជាសត្វអ្វី? ឈ្មោះអ្វី? អាយុប៉ុន្មាន? ញី ឬឈ្មោល?
២. តើវាមានមាឌដូចម្ដេច? មានកម្ពស់ប្រហែលប៉ុន្មាន?
៣. តើវាមានសម្បុរអ្វី ? រោមដូចម្ដេច? មានស្នែងដូចម្ដេច?
៤. តើវាកាចឬស្លូត? ឧស្សាហ៍ ឬខ្ជិល?

លេខ ៣ឈ

**បន្ត...**

# សកម្មភាពគំរូ

៥. តើប្អូនថែរក្សាវាយ៉ាងណាខ្លះ?
៦. តើវាផ្តល់ប្រយោជន៍ដល់ប្អូនដូចម្តេចខ្លះ?
៨. តើប្អូនស្រឡាញ់វាដែរឬទេ? ព្រោះអ្វី?

☑ សិស្សបំពេញព័ត៌មានក្នុងប្រអប់សេចក្តីអធិប្បាយខាងស្តាំតាមរយៈប្រអប់គម្រោងតែងសេចក្តីខាងឆ្វេង ដើម្បីជាជំនួយក្នុងការត្រៀមសរសេរតែងសេចក្តី តាមលំនាំដែលកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ទំព័រទី ៤៥។

| គម្រោង | សេចក្តីអធិប្បាយ |
|---|---|
| សេចក្តីផ្តើម | |
| បង្ហាញពី ឈ្មោះ ភេទ អាយុ ទីលំនៅ ... | |
| តួសេចក្តី | |
| បង្ហាញពី រូបរាង អាកប្បកិរិយា ចិត្តគំនិត (លក្ខណៈសម្បត្តិ ចំណុចល្អ មិនល្អ) | |
| សេចក្តីបញ្ចប់ | |
| បង្ហាញពី ការវាយតម្លៃ ចំណាប់អារម្មណ៍ | |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់រៀន




**ដំណាក់កាលទី ៣ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ៣

នៃឧបសម្ព័ន្ធ ២ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៥៦ ដល់ ១៥៩

# ដំណាក់កាលទី ៤ : មេរៀនទី ២៤ ដល់ទី៣៤ (២១)

**(ទំព័រទី៧៦ ដល់ទី១១១)**

*១. មេរៀនទី២៤ : អ្នកជិតខាងល្អ*

*២. មេរៀនទី២៥ : សទិសសព្ទ*

*៣. មេរៀនទី២៦ : ពិធីបុណ្យដារលានទៅភូមិខ្ញុំ*

*៤. មេរៀនទី២៧ : អំពីគុណនាម*

*៥. មេរៀនទី២៨ : ល្បែងបោះអង្គញ់*

*៦. មេរៀនទី២៩ : ការណែនាំទីកន្លែងទេសចរណ៍ក្នុងភូមិ*

*៧. មេរៀនទី៣០ : ទឹកជំនន់នៅភូមិខ្ញុំ*

*៨. មេរៀនទី៣១ : ការស្គាល់ហេតុ និងផល*

*៩. មេរៀនទី៣២ : មុខរបរចិញ្ចឹមត្រី*

*១០. មេរៀនទី៣៣ : ការរៀបរាប់ពីសុខភាព និងអាកាសធាតុ*

*១១. មេរៀនទី៣៤ : ការលក់ដូរ*

*( ៦៣ ម៉ោងប្រហែល៥សប្តាហ៍)*

---

**កំណត់សម្គាល់ : (២១)** ចំពោះមេរៀនទី២៩ សមត្ថភាពនិយាយមានចំនួន ៣ ម៉ោងសិក្សា មេរៀនទី៣០ សមត្ថភាពស្តាប់មានចំនួន ៥ ម៉ោងសិក្សា និងមេរៀនទី៣៣ សមត្ថភាពនិយាយមាន ៣ ម៉ោងសិក្សាដែរ។ មេរៀនទាំងនេះ មិនទាក់ទងស្តង់ដាអំណានទេ។ គ្រូត្រូវបង្រៀនតាមធម្មតា។

លេខ ៥ក

# សិស្សប្រាប់បានពាក្យជាគុណនាមតាមនិយមន័យដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

**បំណិនពាក់ព័ន្ធ : វេយ្យាករណ៍**

សូមមើល មេរៀនទី២៧ (ទំព័រទី៨៦ និងទី៨៧)

## ខ្លឹមសារ

- និយមន័យ គឺជាពាក្យសម្ដីសំដែង ឬបង្ហាញពីលក្ខណៈរបស់នាម។ ភាគច្រើនគុណនាមស្ថិតនៅខាងស្ដាំនាម។
- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី២៧ ពាក្យជាគុណនាមដូចជា ៖ ពាក្យ ឧស្សាហ៍ ខ្ពស់ ខ្មៅ ពូកែ ល្អ ខ្ជិល ស្អាត ឆ្លាត វែង សុភាពរាបសា ស្លូតបូត។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សមើលន័យពាក្យ ដែលមានថ្នាក់ពាក្យខុសៗគ្នា រួចឱ្យសិស្សកំណត់ពាក្យទាំងនោះដែលជាគុណនាមទៅតាមនិយមន័យគុណនាមដែលបានកំណត់។

| | | | | |
|---|---|---|---|---|
| វែង | អាន | ខ្ពស់ | ស្អាត | សរសើរ |
| នាង | ពូកែ | ស្លូតបូត | សិស្ស | ឧស្សាហ៍ |

☑ គ្រូឱ្យសិស្សអានអត្ថបទក្នុងមេរៀនទី២៤ ទំព័រទី៧៦ "**អ្នកជិតខាងល្អ**" រួចឱ្យសិស្សស្រង់ និងសរសេរពាក្យដែលជាគុណនាមដាក់ក្នុងសៀវភៅសរសេររៀងខ្លួន។

☑ គ្រូឱ្យសិស្សចាប់ដៃគូ រួចតែងល្បះដែលមានប្រើគុណនាមឱ្យបានចំនួន ៣ល្បះ អំពី "**ភូមិខ្ញុំ**"។ បន្ទាប់មក ឱ្យសិស្សគូសវង់ជុំវិញពាក្យ "**គុណនាម**" ក្នុងល្បះទាំងនោះ។ ក្នុងល្បះនីមួយៗអាចមានប្រើពាក្យជា "**គុណនាម**" ចំនួន១ ឬ២ ក៏បាន។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ក**

លេខ ៤ខ

# សិស្សកំណត់សូរដើម និងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យដែលគ្រូអាននិងសរសេរ

*ឧទាហរណ៍* ផ្ទះ = ផ្ទ + ះ

- "ផ្ទ" សូរដើម "អះ" សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ  ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ (ទំព័រទី៧៦ ទី៨២ ទី៨៨ ទី៩៨ និងទី១០៦)**

## ខ្លឹមសារ

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ ដូចជា៖ ជិត ផ្ទះ ចេះ កើត ខ្ញុំ ជុំ ខ្លះ ផល ស្រែ ខ្មែរ ឈូង គេ កោយ ដោះ បាយ ចក ទុក ស៊ី ទិញ ខ្ញី ដូរ រើ ផ្សារ ដើរ ញឹក ចោក . . .។
- ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ គ្រូបង្ហាញរូបភាព "តា" រួចសួរសិស្សថា តើសូរដើមនៃពាក្យ "តា" មានសូរអ្វី?

**ចម្លើយ :** សូរដើមគឺ "ត"។ បន្ទាប់មកគ្រូសួរសិស្ស ចុះសូរបន្ទាប់នៃពាក្យ "តា" គឺអ្វី?

**ចម្លើយ :** សូរបន្ទាប់គឺ "អា"។ **(ការស្គាល់សូរ)**

- បន្ទាប់មក គ្រូឱ្យសិស្សរកសូរដើមរបស់ពាក្យផ្សេងៗទៀត ដែលមានសូរដើម និងសូរបន្ទាប់ដូចគ្នា។

*ឧទាហរណ៍* ពាក្យ "តួ តា តើ តែ តុ តឿ តោ តាំ តោះ ..."។ **(ការស្គាល់សូរ)**

☑ គ្រូបង្កើតល្បែងសិក្សាប្រដេញពាក្យ ដែលកំណត់ដោយសូរដើមរបស់ពាក្យ ដែលចាប់ផ្ដើមពីសិស្ស ដំបូង ឬមុនគេ បន្តរហូតដល់សិស្សចុងក្រោយ។ *ឧទាហរណ៍* សិស្សដំបូងថាពាក្យ "ជុំ" សិស្សបន្ទាប់ត្រូវចាប់សូរបន្តពីសូរដើមរបស់ពាក្យ "ជុំ" គឺ "ជ" ទៅពាក្យដើមដោយសូរ "ជ" ផ្សេងទៀតដូចជា "ជា ជិត ជាប់ ជួប ..." ធ្វើបែបនេះរហូតដល់វេនសិស្សចុងក្រោយទៅតាមការគិត និងការពេញចិត្តរបស់គេរហូតចប់។ ( ពាក្យ **"ជុំ"** → ជួរ → ជាយ → ជិះ → ជាតិ → ជាំ → ជាន់ → ជីរ → ជុច→ ជូត→ ជូន→ ជើង . . . ) **(ការស្គាល់សូរ)**

**សម្គាល់ :** **ក.** ប្រសិនបើសិស្សណារកសូរដើមរបស់ពាក្យ ដូចសិស្សមុនថារួចហើយជាន់គ្នា ឬដូចគ្នាចាត់ទុកថាចាញ់រួច គ្រូឱ្យសិស្សថ្មីម្នាក់ទៀតរកបន្ត។

**ខ.** គ្រូអាចប្ដូរពាក្យថ្មីដែលមានសូរដើមផ្សេងទៀត និងធ្វើដូចលំនាំខាងលើ។

☑ គ្រូប្រាប់សិស្ស ពាក្យណាមួយដោយទាញសំឡេងឱ្យវែង ដូចជាពាក្យ **"កើត"** ក អើ កើនិងត រួចឱ្យសិស្សទាយថាពាក្យនោះជាពាក្យអ្វី។ **(ការស្គាល់សូរ)**

☑ គ្រូឱ្យសិស្សកំណត់សូរដើម និងសូរបន្ទាប់ដែលគ្រូសរសេរនៅលើក្ដារខៀន។

*ឧទាហរណ៍* ក្រោយពីសរសេរពាក្យ **"ទិញ"** សិស្សត្រូវកំណត់រកសូរដើម និងសូរបន្ទាប់។

ទិញ = **ទ** + ិ + **ញ**

- សូរដើម " **ទ** "
- សូរបន្ទាប់ "អិ" និង "ញ" **(ការស្គាល់តួអក្សរនិងសូរ)**។

**លេខ ៤ខ**

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៤ខ**

លេខ
៤គ

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិស-សព្ទ ដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ (ទំព័រទី៧៧ ទី៨៣ ទី៨៩ ទី៩៩ និងទី១០៧)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី២៤ និង២៦ និង២៨ និង៣២ និងទី៣៤ ដូចជា ៖

### ពន្យល់ពាក្យ

#### មេរៀនទី២៤

- រើសអើង (កិ.) : ប្រកាន់យកតែតាមគាប់ចិត្ត។
- អាសន្ន (ន.) : ភ័យ គឺហេតុ ឬអ្វីៗដែលគួរខ្លាច។
- សិទ្ធិ (ន.) : ការសមតាមបំណង សេចក្ដីសម្រេចតាម អំណាចច្បាប់។
- សហគមន៍ (ន.) : ប្រជុំភូមិ ឬតំបន់ដែលមានប្រជាជនរស់នៅ និងប្រកបមុខរបរចូលគ្នា។

#### មេរៀនទី២៦

- ផ្ដាំ (កិ.) : ផ្ញើពាក្យ សម្ដីទុកឱ្យអ្នកទទួលចងចាំហើយធ្វើតាម។
- បុណ្យដារ (ន.) : ឈ្មោះពិធីបុណ្យតូចម្យ៉ាងក្នុងពុទ្ធសាសនា ច្រើនរៀបចំនៅក្រោមដើមឈើធំ ឬជិតទួលអ្នកតា ដោយមានការរាប់បាត្រប្រគេនព្រះសង្ឃផង។
- តម្រា (ន.) : សេចក្ដីកត់ត្រាទុក រឿងដែលកត់ទុកដោយសង្ខេបក្បួនតូចៗ។
- មនោរម្យ (ន.) : ភាពរីករាយ ឬសប្បាយចិត្ត។

#### មេរៀនទី២៨

- កោយ (ន.) : មេអង្គញ់។
- ជោះ (កិ.) : អុកគោះលើក្បាលជង្គង់ដោយគ្រាប់អង្គញ់ចំនួនពីរ មួយផ្ដេក មួយបញ្ឈរ។
- ប្រជាប្រិយ (គុ.) : ដែលប្រជាជន និយមចូលចិត្ត។
- កេរមរតក (ន.) : ទ្រព្យដ៏ប្រសើរដែលបានបន្សល់ទុកមកតាំងពីដូនតា។

#### មេរៀនទី៣២

- អាជីព (ន.) : ការប្រកបមុខរបរចិញ្ចឹមជីវិត។
- អភិវឌ្ឍ (កិ.) : ចម្រើនក្រៃលែង។
- សេដ្ឋកិច្ច (ន.) : កិច្ចការប្រសើរបំផុត មុខរបរដ៏ឧត្ដម មុខរបរដែលមានប្រយោជន៍ដ៏សំខាន់ក្នុងប្រទេសនីមួយៗ។
- ថែរក្សា (កិ.) : មើលថែទាំ។

#### មេរៀនទី៣៤

- អីវ៉ាន់ (ន.) : វត្ថុឬរបស់នេះខ្លះ នោះខ្លះ ពុំចេញឈ្មោះរបស់ដែលហៅរួម។
- អុរ (ន.) : មុខមាត់ដែលទើបភ្ញាក់ពីដេកមិនទាន់លុបលាងមុខ នៅឡើយ។
- គ្រឿងទេស (ន.) : គ្រឿងសម្រាប់ស្លដូចជា អំបិល ប៊ីចេង ខ្ទឹម ស្ករ ម្រេច។ល។
- និទ្រា (ន.) : ដំណើរដេកលក់។

លេខ ៩គ

**បន្ត...**

## ខ្លឹមសារ

**បដិសព្ទ**

| | | | | | |
|---|---|---|---|---|---|
| មេរៀនទី២៤ : | បញ្ចេញ | ≠ | បញ្ចូល | រស់ | ≠ | ស្លាប់ |
| មេរៀនទី២៦ : | ជួប | ≠ | ព្រាត់ | រុងរឿង | ≠ | អាប់ឱន |
| មេរៀនទី២៨ : | ចាញ់ | ≠ | ឈ្នះ | បុរស | ≠ | ស្ត្រី |
| មេរៀនទី៣២ : | ខុស | ≠ | ត្រូវ | ធូរធារ | ≠ | ខ្វះខាត |
| មេរៀនទី៣៤ : | ទិញ | ≠ | លក់ | ថោក | ≠ | ថ្លៃ |

**វេវចនសព្ទ**

មេរៀនទី២៤ : វេវចនសព្ទនឹងពាក្យ "**ទុក្ខ**" **ទុក្ខ ព្រួយ បារម្ភ ភ័យ**

មេរៀនទី២៨ : វេវចនសព្ទនឹងពាក្យ "**ក្បាល**" **ក្បាល** ព្រះសិរ សិរសា

មេរៀនទី៣២ : វេវចនសព្ទនឹងពាក្យ "**ឱ្យ**" **ឱ្យ** ជូន ផ្តល់ ប្រគេន ថ្វាយ

មេរៀនទី៣៤ : វេវចនសព្ទនឹងពាក្យ "**និទ្រា**" **និទ្រា** ដេក សិង ផ្ទំ គេង។

**សទិសសព្ទ**

មេរៀនទី២៤ : សទិសសព្ទនឹងពាក្យ "ក"

- ក (ន.) : អវយវៈដែលតពីក្បាលទៅស្មា ឬទៅនឹងខ្លួននៃមនុស្ស។
- ក (កិ) : កសាង កកើត កកូរ។
- ករណ៍ (ន.) : រឿងហេតុ ជម្លោះ។
- ក៏ (និ) : អ្នកក៏ទៅ ខ្ញុំក៏ទៅ។

មេរៀនទី២៦ : សទិសសព្ទនឹងពាក្យ "បាត្រ"

- បាត្រ (ន.) : ប្រដាប់សម្រាប់ដាក់ចង្ហាន់ព្រះសង្ឃ។ *ឧទាហរណ៍* បាត្រលោក។
- បាត (ន.) : ប៉ែកខាងក្រោមនៃជម្រៅ។ *ឧទាហរណ៍* បាតបឹង បាតជើង ឬសដូងបាត។
- បាទ (និ) : ពាក្យសម្រាប់បុរសឆ្លើយ។ *ឧទាហរណ៍* ខ្ញុំបាទ។

មេរៀនទី២៨ : សទិសសព្ទនឹងពាក្យ "ព្រ័ត្រ"

- ព្រ័ត្រ (ន.) : ពួរ ឬខ្សែត្រកួញធ្វើអំពីស្បែកគោ ឬក្របី។ *ឧទាហរណ៍* ល្បែងទាញព្រ័ត្រ។
- ព្រាត់ (កិ.) : បែកឃ្លាតចាកបុគ្គលជាទីស្រឡាញ់ ឃ្លាតបាត់លែងបានជួបគ្នាទៀត។

*ឧទាហរណ៍* កូនព្រាត់ម៉ែ។

មេរៀនទី៣២ : សទិសសព្ទនឹងពាក្យ "សុខ "

- សុខ (គុ.) : ដែលសប្បាយ ងាយ ស្រណុក។
- សុក្រ (ន.) : ឈ្មោះថ្ងៃទី ៦(ថ្ងៃសុក្រ)។
- សុក (ន.) : ស្រោមស្រោបកូនក្នុងផ្ទៃ។
- សុក្កឬសុក្កៈ (គុ.) : ស ស្អាត បរិសុទ្ធ ថ្លា ឮ។

មេរៀនទី៣៤ : សទិសសព្ទនឹងពាក្យ "ភ្ញៀវ"

- ភ្ញៀវ (ន.) : អ្នកទីទៃក្រៅពីគ្នាឯងក្នុងផ្ទះ។ *ឧទាហរណ៍* ភ្ញៀវមកលេងផ្ទះ។
- ផ្ទៀវ (ន.) : ឈ្មោះឈើមួយប្រភេទមានផ្លែចេញពីមែក ឬពីដើមជាចង្កោមៗមានរសជាតិជូរអែម។

លេខ
៩គ

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យរបស់ពាក្យពិបាកនោះ ដោយគូសភ្ជាប់សញ្ញាព្រួញ។

*ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្តាំ ឱ្យត្រូវនឹងនិយមន័យ នៃពាក្យនីមួយៗ។

| ពាក្យពិបាក | និយមន័យ |
|---|---|
| អាសន្ន | ◆ ភ័យ គឺហេតុអ្វីៗដែលគួរីករាយ។<br>◆ ភ័យ គឺហេតុអ្វីៗដែលគួរឱ្យខ្លាច។<br>◆ ភ័យ គឺហេតុអ្វីៗដែលគួររំភើប។ |
| កោយ | ◆ មេអុក។<br>◆ មេឃ្លី។<br>◆ មេអង្គញ់។ |
| តម្រា | ◆ រឿងដែលកត់ត្រាទុកដោយសៀវភៅ។<br>◆ រឿងដែលសរសេរទុកដោយសៀវភៅ។<br>◆ រឿងដែលកត់ត្រាទុកដោយសង្ខេប ក្បួនតូចៗ។ |

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្តារខៀន។ សិស្សត្រូវនឹករកពាក្យ ផ្សេងទៀត ដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាន និយមន័យដូចគ្នាទេ តែមានទំនាក់ទំនងជាមួយគ្នាតាមដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ** ដោយមានការបង្ហាញគំនិតពាក់ព័ន្ធផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ **"ទំនិញ"** នៅលើក្តារខៀន រួចឱ្យសិស្សរកពាក្យដទៃដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែមិនមែនមានន័យថា រកពាក្យដែលន័យដូចនោះទេ។







☑ គ្រូបង្កើតបណ្តុំពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្តារខៀន រួចឱ្យសិស្សរកពាក្យដែលមានន័យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| រស់ | បញ្ចេញ | រុងរឿង | សន្តិភាព | ជួប | ចាញ់ | ខុស | ទិញ |

លេខ
៤គ

**បន្ត...**

## សកម្មភាពគំរូ

♦ បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូបង្កើតដ្យាក្រាម ហើយសរសេរពាក្យនៅចំកណ្ដាល។ បន្ទាប់មក គ្រូឱ្យសិស្សស្វែងរកពាក្យផ្សេងទៀតដែលមាន(ន័យផ្ទុយ) បដិសព្ទ ហើយសរសេរពាក្យទាំងនោះនៅជុំវិញពាក្យកណ្ដាល។




**សម្គាល់ :** ពាក្យដែលគ្រូអាចជ្រើសរើសមកធ្វើលំហាត់ ជាបដិសព្ទ ឬពាក្យផ្ទុយអាចមានពាក្យផ្ទុយច្រើន(ដូចជាពាក្យ **រស់** អាចផ្ទុយនឹងពាក្យ ស្លាប់ ងាប់ មរណៈ សុគត ចែកឋាន . . .) ខ្លះទៀតអាចមានពាក្យផ្ទុយតែមួយ ឬពីរប៉ុណ្ណោះ។

☑ គ្រូចែកសិស្សជាក្រុមៗដែលមួយក្រុមមានគ្នា ៤ ទៅ៥នាក់។ គ្រូសរសេរពាក្យមួយនៅលើក្ដារខៀន ហើយឱ្យសិស្សរកវេវចនសព្ទទាក់ទងនឹងពាក្យនោះឱ្យបានច្រើនតាមដែលអាចរកបាន។ គ្រូផ្ដល់ពេលប្រហែលបីឬបួននាទីប៉ុណ្ណោះសម្រាប់ស្វែងរក **ហើយ**ក្រុមណាដែលរកពាក្យវេវចនសព្ទបានច្រើនជាងគេគឺជាក្រុមឈ្នះ។ គ្រូអាចធ្វើសកម្មភាពដូចគ្នានេះសម្រាប់ ពាក្យបដិសព្ទ ឬវេវចនសព្ទផ្សេងទៀតក៏បាន។

☑ គ្រូសរសេរបញ្ជីពាក្យនិងគូសតារាងនៅលើក្ដារខៀន។ តារាងទី១ វេវចនសព្ទ តារាងទី២ បដិសព្ទ។ បន្ទាប់មក គ្រូឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទាំងនេះទៅតាមតារាងប្រភេទ វេវចនសព្ទ និងបដិសព្ទ។

*ឧទាហរណ៍* គ្រូសរសេរពាក្យខាងក្រោមដាក់លើក្ដារ ខៀនរួចបង្ហាញឧទាហរណ៍ខាងក្រោមពន្យល់សិស្ស។ បន្ទាប់មក ឱ្យសិស្សរកដោយខ្លួនឯង។

**បញ្ជីពាក្យ :** ទុក្ខ ត្រូវ លក់ និទ្រា សន្តិភាព ខុស ប្រគេន ព្រួយ សង្គ្រាម ជូន ដេក ព្រះសិរ

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| ជូន ប្រគេន<br>.................... | សន្តិភាព ≠ សង្គ្រាម<br>........... ≠ ............... |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ១៧


ល្បែងទី ១៨


ល្បែងទី ១៩


ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៤គ

លេខ ៥យ

# សិស្សរកសូរចួនក្នុងពាក្យដែលគ្រូអាននិងសរសេរ

**សម្គាល់ :** មុនបង្រៀនពាក្យចួន ក្នុងអត្ថបទសំណេរគ្រូគួររំឭកបញ្ញត្តិពាក្យចួនដោយប្រើភាសានិយាយសិន។

**បំណិនអំណានពាក់ព័ន្ធ :** ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ

សូមមើល មេរៀនទី២៦ (ទំព័រទី៨២)

## ខ្លឹមសារ

និយមន័យ " ពាក្យចួន" **ពាក្យចួន** គឺជាពាក្យមានសូរស្រៈដូចគ្នា ឬសូរស្រៈប្រកបនឹងព្យញ្ជនៈដូចគ្នា ក្នុងវគ្គរបស់កំណាព្យ ឬមេសូត្រ។ *ឧទាហរណ៍* មេសូត្រ (បទកាកគតិ) មេរៀនទី២៦ និងទំព័រទី៨២

- ពាក្យ "ខ្ញុំ" ចួននឹង "ជុំ"
- ពាក្យ "រីករាយ" ចួននឹង "ពព្រាយ" ចួននឹង "ស្តាយ"

## សកម្មភាពគំរូ

☑ គ្រូនិយាយប្រាប់សិស្សថា គ្រូនឹងអានពាក្យចំនួន៤។ ចូរប្អូនស្តាប់ដោយយកចិត្តទុកដាក់ ហើយឆ្លើយមកគ្រូវិញថា តើពាក្យមួយណាក្នុងចំណោមពាក្យទាំង៤នោះ ដែលមិនមែនជាពាក្យចួននឹងពាក្យ៣ទៀត (សូរខុសគេ)។ (ការស្គាល់សូរ)

| | | | | |
|---|---|---|---|---|
| *ឧទាហរណ៍* | សាលា | កិច្ចការ | **មាន** | ផលា |
| | ដៅ | **ជិត** | ខ្មៅ | ផៅ |
| | ស្រែ | ក្បែរ | ថៃ | **ខ្ពស់** |
| | គឺ | **ថ្លា** | ឮ | ជំងឺ |

**សម្គាល់ :** គ្រូគួរចាំថានៅពេលធ្វើលំហាត់នេះ គឺមិនត្រូវសរសេរពាក្យទាំងនេះនៅលើក្ដារខៀននោះទេ ប៉ុន្តែគ្រូត្រូវធ្វើដោយផ្ទាល់មាត់ ព្រោះនេះជាការបង្រៀនពីការស្គាល់សូរ។

☑ គ្រូសរសេរពាក្យចួនមួយចំនួនលើក្ដារខៀន រួចឱ្យសិស្សរកសូរអក្សរណា ដែលមានសូរដូចគ្នានៅខាងចុងឱ្យបានច្រើនតាមអាចធ្វើបាន។ *ឧទាហរណ៍*

- ពាក្យ "**អាហារ**" និង "**ប្រការ**" គឺមានតួអក្សរ "**ហ**" និង"**អា**" (រ) ចួននឹងតួអក្សរ "**ក**" និង"**អា**" (រ)ដូចគ្នា
- ពាក្យ"**ត្រី**" និង"**ស្រី**" គឺមានតួអក្សរ "**ត**" ជើង ្រ និង"**អី**" ចួននឹងតួអក្សរ"**ស**" ្រ និង"**អី**" ដូចគ្នា។
- ពាក្យ"**ចេះ**" និង "**កេះ**" គឺមានតួអក្សរ "**ច**" និង "**អេះ**" ចួននឹងតួអក្សរ "**ក**" និង "**អេះ**" ដូចគ្នា។

ដូចនេះ ពាក្យ **អាហារ** និង**ប្រការ** ⟶ **ហារ** ⊟ **ការ** (**ហារ** ចួននឹង**ការ**)

ពាក្យ **ត្រី** និងនៃ ⟶ **ស្រី** ⊟ **ត្រី** (**ស្រី** ចួននឹង**ត្រី**)

ពាក្យ **ចេះ** និង**កេះ** ⟶ **ចេះ** ⊟ **កេះ** (**ចេះ** ចួននឹង**កេះ**) (ការស្គាល់តួអក្សរនិងសូរ)

☑ គ្រូសរសេរអត្ថបទមេសូត្រ ដាក់លើក្តារខៀន រួចឱ្យសិស្សឡើងគូសពាក្យចួននៅលើក្តារខៀន។

លេខ ៤យ

**បន្ត...**

## សកម្មភាពគំរូ

| | | |
|---|---|---|
| បុណ្យដារភូមិខ្ញុំ | មីងពូជួបជុំ | សប្បាយរីករាយ |
| នៅក្រោមដើមពោធិ៍ | ញញឹមពព្រាយ<br>នាំម្ហូបអាហារ។ | ខ្លះរែកទូលស្ពាយ |
| មីងពូទាំងអស់ | ចាស់ទុំស្រីប្រុស | រួមទាំងអាចារ្យ |
| រាប់បាត្រព្រះសង្ឃ | បួងសួងទេវតា<br>ប្រាថ្នាសុខសាន្ត។ | ស្តាប់លោកទេសនា |

☑ គ្រូផ្ដល់កំណាព្យមួយ ដែលមិនពេញលេញដល់សិស្ស ដោយមានលុបចេញពាក្យចួនមួយចំនួន។ គ្រូឱ្យសិស្សសរសេរកំណាព្យដែលមិនពេញលេញនោះដាក់ក្នុងសៀវភៅ ហើយធ្វើការជាក្រុមស្វែងរកពាក្យចួនដែលត្រូវបំពេញ (ពាក្យចួនដូចមានក្នុងចម្លើយរំពឹងទុកខាងក្រោម)។ ពាក្យដែលមានអក្សរដិត គឺជាពាក្យសម្រាប់ឱ្យសិស្សមើល ងាយរកពាក្យចួននឹងពាក្យនោះ ហើយពាក្យចួនទាំងនោះសិស្សអាចគិតដោយខ្លួនឯងដើម្បីបំពេញកំណាព្យនេះ។ ដោយសារលំហាត់នេះអាចនឹងត្រូវការពេលវេលាច្រើន គ្រូអាចដាក់កិច្ចការនេះឱ្យសិស្សធ្វើជាកិច្ចការធ្វើនៅផ្ទះ។

*ឧទាហរណ៍*

| | | |
|---|---|---|
| ពលរដ្ឋភូមិ**ខ្ញុំ**មាន | (១)..............រុងរឿង | (២) .................... |
| សន្សំកុសល | មង្គលគ្រប់**ប្រាណ**<br>ទុក្ខគ្រប់**ប្រការ**។ | ដោយ (៣) ............. |
| ដល់កាល**វេលា** | ពួកគាត់ (៤) .......... | ស្តាប់សង្ឃ (៥) ............ |
| ដោយចិត្តរីករាយ | នៅក្នុង**វត្តអា**<br>ដែលលោកទូន្មាន។ | ចងចាំ (៦) ............. |

**ចម្លើយរំពឹងទុក**

១. សុខគ្រប់ក្រុម សុខដុម ភាពសុខុម ក្ដីសុខុម...
២. ថ្កើងថ្កាន ក្សេមក្សាន្ត សុខសាន្ត...
៣. ជៀសចាកស្ពាន ជៀសឱ្យបាន...
៤. មិ្ទមា ជួបគ្នា មូលគ្នា ជុំគ្នា គ្រប់គ្នា...
៥. ទេសនា វាចា ដីកា...
៦. ឥតម្រា ប្រការ វាចា ខ្លឹមសារ... ។

**លេខ ៤យ**

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៤យ**

## លេខ ៥ង

## សិស្សរកនិយមន័យនៃពាក្យហេតុ និងផល។ ព្រឹត្តិការណ៍ ឬរឿងអ្វីមួយជាហេតុ។ ការបង្កឱ្យកើតព្រឹត្តិការណ៍ ឬរឿងមួយផ្សេងទៀតជាផល។

**សម្គាល់ :** គ្រូគួរពន្យល់សិស្សផងដែរថា **ផល**អាចកើតចេញពី **ហេតុ**ច្រើនយ៉ាង ហើយព្រឹត្តិការណ៍ ឬរឿងអ្វីមួយក៏អាចជា**ហេតុ**ផង និង **ផល**ផងក្នុងពេលតែមួយ។

**បំណិនពាក់ព័ន្ធ : ការស្គាល់ហេតុ និងផល**

**សូមមើល មេរៀនទី៣១ (ទំព័រទី៩៦ និងទី៩៧)**

### ខ្លឹមសារ

មេរៀនទី៣១ : ទំព័រទី៩៦ និងទី៩៧

- និយមន័យ "ហេតុ និងផល" ហេតុគឺព្រឹត្តិការណ៍ ឬរឿងអ្វីមួយដែលកើតឡើង។ ផលគឺជាលទ្ធផលកើតមានឡើងអាស្រ័យដោយហេតុ។
- ការប្រើប្រាស់និយមន័យដើម្បីកំណត់រកព្រឹត្តិការណ៍ ឬរឿងអ្វីមួយដែលជា **ហេតុ** និង **ផល**។

### សកម្មភាពគំរូ

☑ គ្រូបង្ហាញល្បះមួយដល់សិស្សដែលពិពណ៌នាអំពីហេតុ និងផល។ សិស្សត្រូវប្រាប់ថា ឃ្លាមួយណាក្នុងល្បះបង្ហាញហេតុ និងផល។ *ឧទាហរណ៍* មនុស្សអាចបង្កើតយានអវកាសបាន ដោយសារវិទ្យាសាស្ត្ររីកចម្រើន។ ក្នុងឃ្លា "... អាចបង្កើត យានអវកាសបាន" ជាឃ្លាបង្ហាញអំពីផល។ ឃ្លា "ដោយសារវិទ្យាសាស្ត្ររីកចម្រើន" ជាឃ្លាបង្ហាញអំពីហេតុ។

☑ គ្រូសរសេរឃ្លាមួយចំនួនអំពី ហេតុ និងផល នៅលើក្ដារខៀន ហើយឱ្យសិស្សគិតអំពីព្រឹត្តិការណ៍ ឬរឿងអ្វីមួយដែលសមស្របទៅនឹង ហេតុ និងផលទាំងនោះ ដោយប្រើគំនិតផ្ទាល់ខ្លួន។ លំហាត់នេះអាចធ្វើជាបុគ្គល ឬក្រុម។

*ឧទាហរណ៍* ភូមិខ្ញុំកើតទឹកជំនន់ដោយសារ <u>ភ្លៀងពេញមួយសប្ដាហ៍</u>។
ខ្ញុំប្រឹងប្រែងរៀនសូត្រណាស់ ដូច្នេះ .......................................។
ស្រូវលូតលាស់យ៉ាងលឿន ពីព្រោះ .........................................។
ភូមិយើងរីកចម្រើន ដោយសារ ...............................................។
សុខាមានបំណិនច្រើន ហេតុនេះ ...............................................។

☑ គ្រូផ្ដល់ឱ្យសិស្សនូវប្រធានបទមួយ ហើយឱ្យពួកគេសរសេរល្បះហេតុ ផលដោយប្រើប្រាស់ពាក្យភ្ជាប់ដែលបានផ្ដល់នៅក្នុងមេរៀនដូចជាពាក្យ ពីព្រោះ ដោយសារ។ល។ *ឧទាហរណ៍*

ប្រធានបទទី១ : រឿងអ្វីមួយដែលកើតឡើងនៅផ្ទះ។
*ខ្ញុំអាចលេងជាមួយមិត្តរបស់ខ្ញុំបាន ដោយសារខ្ញុំបានធ្វើកិច្ចការផ្ទះរួចហើយ។*

ប្រធានបទទី២ : រឿងអ្វីមួយដែលកើតឡើងនៅសាលារៀន។
.......................................................................................................។

ប្រធានបទទី៣ : រឿងអ្វីមួយដែលបានកើតឡើង ខណៈពេលខ្ញុំកំពុងត្រឡប់មកពីសាលារៀន។
.........................................................................................................។

**លេខ ៥ង**

## បន្ត...

# សកម្មភាពគំរូ

**ប្រធានបទទី៤ :** រឿងអ្វីមួយដែលបានកើតឡើង ខណៈពេលខ្ញុំកំពុងលេងជាមួយមិត្តភក្តិ។ ............................................................................................................។

☑ គោលបំណងនៃលំហាត់នេះគឺចង់បង្ហាញសិស្សថា **ផល** អាចកើតពី**ហេតុ** ច្រើនយ៉ាង ហើយ**ផល** មួយចំនួនក៏អាចក្លាយជា ហេតុ បង្កទៅជាព្រឹត្តិការណ៍ឬរឿងផ្សេងទៀតផងដែរ។ គ្រូគួរបង្ហាញសិស្សនូវដ្យាក្រាមខាងក្រោម ហើយសួរសិស្សថា៖ តើព្រឹត្តិការណ៍ ឬរឿងមួយណាដែលជាហេតុ? តើមួយណាជាផល? តើមួយណាជាហេតុ និងផល?

*ឧទាហរណ៍* *ដ្យាក្រាមខាងក្រោមបង្ហាញពីលំដាប់លំដោយ ហេតុនិងផលទាក់ទងនឹងទឹកជំនន់។ សូមសរសេរ លេខនៃព្រឹត្តិការណ៍រឿងនៅខាងចុងល្បះខាងក្រោម ដោយយោងទៅតាមល្បះណាដែលជាហេតុ ល្បះណាដែលជា ផល ឬល្បះណាដែលជាហេតុផង និងផល ផងក្នុងពេលតែមួយ។*

**ទឹកជំនន់ : ហេតុ និងផលនៃទឹកជំនន់**

ប្រអប់ទី១ : មនុស្សកាប់ឈើ

ប្រអប់ទី២ : ភ្លៀងធ្លាក់យ៉ាងខ្លាំង

→ ប្រអប់ទី៣ : ទន្លេកើតទឹកជំនន់

→ ប្រអប់ទី៤ : ផ្ទះសម្បែងត្រូវបំផ្លាញ

→ ប្រអប់ទី៥ : ប្រជាជនរងគ្រោះ

ក. ប្រអប់ណាខ្លះបង្ហាញ ហេតុ :.......................

ខ. ប្រអប់ណាខ្លះបង្ហាញ ផល :.......................

គ. ប្រអប់ណាខ្លះបង្ហាញហេតុផង និងផលផង : ............

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ង**

លេខ ៤ច

# សិស្សបកស្រាយន័យនៃល្បះ អត្ថបទ និងមេសូត្រតាមមេរៀន ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ តាមរយៈលំហាត់ផ្សេងៗ។

*ឧទាហរណ៍* ឆ្លើយសំណួរយល់ដឹង បំពេញចន្លោះ បំពេញល្បះ លំហាត់ក្លូស្ស។ល។

**បំណិនអំណានពាក់ព័ន្ធ : អានដើម្បីយល់ន័យ**

**សូមមើល មេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ (ទំព័រទី៧៧ ទី៨៤ ទី៩០ ទី១០០ និងទី១០៨)**

## ខ្លឹមសារ

ល្បះ អត្ថបទ និងមេសូត្រ ក្នុងមេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ ៖

- មេរៀនទី២៤ : អ្នកជិតខាងល្អ
- មេរៀនទី២៦ : ពិធីបុណ្យដារលាននៅភូមិខ្ញុំ
- មេរៀនទី២៨ : ល្បែងបោះអង្គញ់
- មេរៀនទី៣២ : មុខរបរចិញ្ចឹមត្រី
- មេរៀនទី៣៤ : ការលក់ដូរ

## សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ មេរៀនទី២៤ ២៦ ២៨ ៣២ និងទី៣៤

**មេរៀនទី២៤**

១. តើអ្នកជិតខាងល្អជាមនុស្សដូចម្ដេច?
២. តើអ្វីខ្លះដែលយើងមិនគួរធ្វើចំពោះអ្នកជិតខាង?
៣. តើអ្វីខ្លះដែលយើងគួរធ្វើចំពោះអ្នកជិតខាង?
៤. ហេតុអ្វីបានជាត្រូវគោរពស្រឡាញ់អ្នកជិតខាង។ ★

**មេរៀនទី២៦**

១. តើបុណ្យដារលានគេធ្វើនៅឯណា?
២. តើនរណាខ្លះចូលរួមក្នុងពិធីបុណ្យនេះ?
៣. តើគេធ្វើបុណ្យដារលានដើម្បីអ្វី?

**មេរៀនទី២៨**

១. តើខ្មែរយើងមានល្បែងប្រជាប្រិយអ្វីខ្លះ?
២. តើគេនិយមលេងល្បែងបោះអង្គញ់នៅពេលណា?
៣. តើគេលេងល្បែងបោះអង្គញ់យ៉ាងដូចម្ដេច?
៤. តើអ្នកចូលចិត្តលេងល្បែងបោះអង្គញ់ឬទេ? ព្រោះអ្វី? ★

**មេរៀនទី៣២**

១. តើពូសុខ មីងយនមានមុខរបរជាអ្វី?
២. តើពួកគាត់ចិញ្ចឹមត្រីនៅឯណា?
៣. ហេតុអ្វីបានជាត្រីរបស់គាត់ឆាប់បានទទួលផល?
៤. ហេតុអ្វីបានជាគ្រួសារពូសុខ មីងយនមានជីវភាពធូរធារ?

**មេរៀនទី៣៤**

១. តើម្ដាយសុភីប្រកបរបរអ្វី?
២. តើម្ដាយសុភីលក់អ្វីខ្លះ?
៣. ហេតុអ្វីបានជាគេចូលចិត្តទិញអីវ៉ាន់មីងសឿន?
៤. តើគ្រួសារមីងសឿនមានជីវភាពដូចម្ដេច?

**សម្គាល់ :** ក. សំណួរដែលមានសញ្ញា ★ (ផ្កាយ) ជាសំណួរបន្ថែម ដើម្បីពង្រឹងបំណិនវិភាគ និងដោះស្រាយបញ្ហា។ សម្រាប់សំណួរនេះគ្រូគួរតែទទួលចម្លើយពីសិស្ស ដែលឆ្លើយសមហេតុផល ទោះចម្លើយគ្មានក្នុងអត្ថបទក៏ដោយ។

ខ. សំណួរបន្ថែមខាងក្រោមនេះ គ្រូអាចពិភាក្សាជាមួយសិស្ស ដើម្បីជួយកែលម្អសមត្ថភាពគំនិតដោយវិភាគ ក្នុងអត្ថបទ មេរៀនទី២៦ ទី៣២ និងទី៣៤ ៖

លេខ ៤ច

**បន្ត...**

## សកម្មភាពគំរូ

**មេរៀនទី២៦ :** ប្រសិនបើគេមិនបានធ្វើបុណ្យដារលាន តើមានផលប៉ះពាល់អ្វីអ្វីខ្លះដល់ប្រពៃណីទំនៀមទម្លាប់ខ្មែរ? ព្រោះអ្វី?

**មេរៀនទី៣២ :** តើមានអ្វីកើតឡើងចំពោះជីវភាពពូសុខ មីងយន ប្រសិនគ្មានភ្លៀង?

**មេរៀនទី៣៤ :** ប្រសិនបើ ប្រទេសរីកចម្រើនកាន់តែខ្លាំង តើជីវភាពមីងសឿនយ៉ាងដូចម្ដេច?

☑ សិស្សបំពេញលំហាត់ក្លូស្ស តាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទ មកបំពេញឱ្យបានត្រឹមត្រូវ។ (មេរៀនទី២៤ទំព័រទី៧៦)

អ្នកជិតខាងគឺជា...(១) ដែលរស់នៅក្បែរផ្ទះ...(២) គ្រប់គ្នា គ្រប់ទីកន្លែង។ អ្នក...(៣) ខាង ល្អគឺជាអ្នក...(៤) ចេះគោរពស្រឡាញ់រាប់អានគ្នា ...(៥) ចេះគួរសមដោយមិនរើសអើង...(៦) គ្នា។ ពេលមានទុក្ខធុរៈ...(៧) មានពិធីរៀបការ ពិធីបុណ្យទាន ...(៨) មានអាសន្ន និងមានកិច្ច...(៩) ផ្សេងៗ អ្នកជិតខាង តែងតែ...(១០) គ្នាទៅវិញទៅមក។

**ចម្លើយ** ១. អ្នក មនុស្ស២. យើង អ្នក ៣. ក្បែ ជិត ៤. តែងតែ រមែង ៥. ហើយ និង ៦. ចំពោះ នឹងដាក់ ៧. ដូចជា ឧទាហរណ៍ ៨. ពេល វេលា គ្រា ឱកាស៩. រវល់ ធុរៈ មមាញឹក ១០. ជួយ យកអាសា។

☑ គ្រូឱ្យសិស្សអានអត្ថបទណាមួយឡើងវិញ។ បន្ទាប់មក ឱ្យសិស្ស សរសេរពាក្យដែលមិនទាន់ចេះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យ ពាក្យមិនចេះនោះ។ សិស្សសរសេរនិយមន័យពាក្យដែលកំណត់តាមការវិភាគនេះ (**ទីសេចក្ដីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ**)។ ប្រសិនបើសិស្សមិនអាចបកស្រាយនិយមន័យពាក្យណាមួយបាន គេអាចសួរគ្រូក្នុងក្រុមធំបាន។ គ្រូគួរសរសេរពាក្យទាំងអស់នោះនៅលើក្ដារខៀនឱ្យសិស្សដទៃទៀតមើល ដើម្បីផ្ដល់យោបល់ ហើយគ្រូជួយកែលម្អ។

*ឧទាហរណ៍* ចូរបង្ហាញពាក្យទីសេចក្ដីជាឧទាហរណ៍ក្នុងល្បះខាងក្រោម។

ខ្មែរយើង មាន**ល្បែងប្រជាប្រិយ**ជាច្រើនសម្រាប់លេងកំសាន្ត **ដូចជា** បោះអង្គញ់ លាក់កន្សែង ទាញព្រ័ត្រ ចោលឈូង ដូចនេះពាក្យ "**ដូចជា**" គឺជាទីសេចក្ដីសម្គាល់ពាក្យជំនួសពាក្យថា "ឧទាហរណ៍" (បោះអង្គញ់ លាក់កន្សែង ទាញព្រ័ត្រ ចោលឈូង។ល។) និងន័យរបស់ពាក្យ "**ល្បែងប្រជាប្រិយ**" ។

☑ ការរៀបចំលំដាប់ព្រឹត្តិការណ៍ក្នុងរឿងតាមលំដាប់លំដោយត្រឹមត្រូវ។ ក្រោយពីអានរឿងរួច គ្រូសរសេរព្រឹត្តិការណ៍សំខាន់ៗក្នុងរឿងមិនតាមលំដាប់លំដោយ។ សិស្សត្រូវដាក់លេខខាងមុខព្រឹត្តិការណ៍នីមួយៗ ទៅតាមលំដាប់លំដោយបានកើតឡើងក្នុងរឿង។ *ឧទាហរណ៍* គ្រូណែនាំសិស្សឱ្យបង់លេខក្នុងប្រអប់ល្បះនីមួយៗតាមលំដាប់លំដោយព្រឹត្តិការណ៍រឿង។

☐ លើសពីនេះ ពូសុខតែងកាប់ជម្រះស្មៅ និងព្រៃតូចៗ ដើម្បីឱ្យមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់ចូលក្នុងស្រះ។ (៤)

☐ រាល់ព្រឹក និងល្ងាចពួកគាត់ទាំងពីរ តែងតែឱ្យចំណីត្រី ព្រោះទឹកនៅវេលានេះត្រជាក់។ (២)

☐ ពូសុខ មីងយនចិញ្ចឹមត្រីក្នុងស្រះមួយ ក្បែរភូមិដែលមានត្រីរាប់ពាន់ក្បាល។(១)

☐ មុខរបរចិញ្ចឹមត្រី បានជួយដល់ជីវភាពគ្រួសារពូសុខបានធូរធារ មិនបាច់ខ្ចីបុលប្រាក់គេ។(៥)

☐ ពូសុខបានរៀនពីរបៀបផលិតចំណីត្រី ដោយយក ចក ត្រកួន និងសមាសធាតុផ្សំផ្សេងៗទៀតដូចជា កន្ទក់ ចុងអង្ករ។ល។ (៣)

**លេខ ៤ច**

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៤ច**

លេខ ៤៨

# សិស្សសរសេរតួអក្សរនិងពាក្យបានស្អាតល្អ

## បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់

សូមមើល មេរៀនទី២៦ និងទី២៨ (ទំព័រទី៨៥ និងទី៩១)

**ខ្លឹមសារ**

មេរៀនទី២៦ "ណ" និង "បុណ្យ" ទំព័រទី៨៥

មេរៀនទី២៨ "យ" និង "ប្រជាប្រិយ" ទំព័រទី៩១

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីអក្សរ "**ណ យ**" និងពាក្យ "**បុណ្យ ប្រជាប្រិយ**" បានស្អាត ល្អតាមទម្រង់អក្សរជ្រៀង និងការណែនាំពីរបៀបគូសបន្ទាត់ សរសេរលើក្ដារខៀន ក្ដារឆ្នួន និងក្នុងសៀវភៅសរសេរៀងខ្លួនបានស្អាតល្អ។

*ឧទាហរណ៍*







☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ដូចជា អក្សរ **យ ឈ ញ ល ស** ... ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មក គ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តខាងលើ រួចចម្លងចូលក្នុងសៀវភៅសរសេរៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ិត...



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់រៀន

# លេខ ៤ជ សិស្សសរសេរតាមអាន អត្ថបទខ្លី ក្នុងលំហាត់សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

**សូមមើល មេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ (ទំព័រទី៧៨ ទី៨៤ ទី៩០ ទី១០២ និងទី១០៩)**

## ខ្លឹមសារ

ការសរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

- មេរៀនទី២៤ ទំព័រទី៧៨
- មេរៀនទី២៦ ទំព័រទី៨៤
- មេរៀនទី២៨ ទំព័រទី៩០
- មេរៀនទី៣២ ទំព័រទី១០២
- មេរៀនទី៣៤ ទំព័រទី១០៩

## សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យពិបាកមួយចំនួនដែលដកស្រង់ពីអត្ថបទសៀវភៅភាសាខ្មែរ អាន -សរសេរ ថ្នាក់ទី៣ ឬការកំណត់ដោយគ្រូដាក់លើក្ដារខៀន ហើយឱ្យសិស្សអានពាក្យទាំងនោះម្ដងមួយពាក្យៗឱ្យឮ រួចឱ្យសិស្ស២ ឬ៣នាក់ចង្អុល និងអានតាមដោយធ្វើអក្ខរវិញ្ញាសផង។

*ឧទាហរណ៍* ពាក្យពិបាកស្រង់ពីអត្ថបទសរសេរតាមអាន ទំព័រទី៧៨ "អ្នកជិតខាងខ្ញុំ" ៖

គោរព ប្រាស្រ័យ សុភាពរាបសា ទន់ភ្លន់ ថ្លៃថ្នូរ អធ្យាស្រ័យ ជិតស្និទ្ធ។

- បន្ទាប់មក គ្រូហៅពាក្យទាំងនោះឱ្យសិស្សសរសេរលើក្ដារឆ្នួន រួចកែលម្អ។

☑ គ្រូហៅអត្ថបទក្នុងមេរៀនដែលបានកំណត់ក្នុងសៀវភៅសិក្សាភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឱ្យសិស្សសរសេរ ហើយឆ្លើយសំណួរ និងលំហាត់តាមការកំណត់របស់គ្រូ (សំណួរ និងលំហាត់មានក្នុងតារាងខ្លឹមសារខាងលើ)។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៤ជ**

**លេខ ៨ឈ**

# សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

## បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី២៤ ទី២៦ ទី២៨ ទី៣២ និងទី៣៤ (ទំព័រទី៧៩ ទី៨៥ ទី៩១ ទី១០២ ទី១០៣ ទី១០៩ និងទី១១០)

↓

### ខ្លឹមសារ

ពាក្យ កន្សោមពាក្យឬល្បះ ក្នុងលំហាត់បំពេញល្បះ ឬលំហាត់តែងល្បះតាមរូបភាពក្នុង សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

- មេរៀនទី២៤ ទំព័រទី៧៩
- មេរៀនទី២៦ ទំព័រទី៨៥
- មេរៀនទី២៨ ទំព័រទី៩១
- មេរៀនទី៣២ ទំព័រទី១០២ និងទី១០៣
- មេរៀនទី៣៤ ទំព័រទី១០៩ និងទី១១០

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សជ្រើសរើសពាក្យពីក្នុងប្រអប់ មេរៀនទី២៦ ទំព័រទី៨៥ ទៅបំពេញល្បះ។

*ឧទាហរណ៍* ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អាហារ | ញញឹម | ពព្រាយ | ខ្ញុំ | ប្រុសស្រី | ទេសនា | ស្ពាយ | ស្រីប្រុស | ព្រះសង្ឃ |

បុណ្យដារភូមិ... នៅក្រោមដើមពោធិ៍

មីងពូជួបជុំ ញញឹម..... នំម្ហូបអាហារ។

សប្បាយរីករាយ ខ្លះរែកទូល......

មីងពូទាំងអស់ រាប់បាត្រព្រះសង្ឃ

ចាស់ទុំ...... បួងសួងទេវតា ប្រាថ្នាសុខសាន្ត។

រួមទាំងអាចារ្យ ស្តាប់លោក......

☑ គ្រូសរសេរល្បះមួយចំនួនដែលបានដកស្រង់ពីមេរៀនណាមួយ ដាក់លើក្តារខៀន រួចឱ្យសិស្សគូសបន្ទាត់ខណ្ឌពាក្យនីមួយៗ ក្នុងល្បះនោះដើម្បីជួយសិស្សឱ្យយល់ពី "**ល្បះ**" ដែលកើតចេញពីពាក្យច្រើនផ្គុំគ្នា មានន័យពេញលេញស្តាប់បាន។ *ឧទាហរណ៍* ចូររៀបពាក្យខាងក្រោមជាល្បះត្រឹមត្រូវ។ (មេរៀនទី២៤ ទំព័រ៧៩)

ខ្ញុំ | អ្នកជិតខាង | ណាស់។ | ស្រឡាញ់ | ខ្ញុំគោរព

ចម្លើយ : ខ្ញុំគោរពស្រឡាញ់អ្នកជិតខាងខ្ញុំណាស់។

☑ គ្រូផ្តល់ឱ្យសិស្សនូវបញ្ជីពាក្យ ដែលពាក្យក្នុងជួរនីមួយៗ ដាក់ចម្រុះគ្នាតាមបែបចៃដន្យ។ សិស្សអានពាក្យក្នុងលំដាប់ជួរនីមួយៗ ហើយបង្កើតល្បះដែលមានន័យ ដោយគូសវង់ជុំវិញពាក្យទាំងនោះដើម្បីបង្កើតជាល្បះ។ បន្ទាប់មកសរសេរល្បះទាំងនោះនៅខាងក្រោមតារាង។

លេខ
៤ឈ

**បន្ត...**

## សកម្មភាពគំរូ

ឧទាហរណ៍

| | | | | |
|---|---|---|---|---|
| (សុភី) | នាង | នៅ | និង | ពី |
| (ម្ដាយ) | មក | (ក្រោក) | ធ្វើ | នៅ |
| ព្រឹក | (ពី) | ផ្សារ | (និទ្រា) | (តាំងពី) |
| ថ្ងៃ | (ព្រលឹមអរុ) | ធ្វើ | ទៅ | (រៀបចំ) |
| ញាំ | (អីវ៉ាន់) | | | |

ចម្លើយ : **សុភី និងម្ដាយក្រោកពីនិទ្រាតាំងពីព្រលឹមអរុរៀបចំអីវ៉ាន់។**

☑ គ្រូផ្ដល់ឃ្លាខ្លីៗចំនួន៣ដល់សិស្ស ហើយឱ្យពួកគេផ្សំឃ្លាទាំងនេះទៅជាល្បះមួយដោយប្រើប្រាស់ពាក្យភ្ជាប់ដើម្បីបង្ហាញអំពីហេតុ និងផល។ គ្រូនាំសិស្សធ្វើលំហាត់ប្រភេទនេះ ដើម្បីបង្កើតល្បះខ្លីផ្សេងៗទៀតឱ្យបានច្រើន។ ពាក្យភ្ជាប់ផ្សេងៗសម្រាប់បង្ហាញហេតុ និងផលមានក្នុងមេរៀនទី៣១។

ឧទាហរណ៍ សុភីជាសិស្សល្អ មកសាលារៀនរាល់ថ្ងៃ គាត់ប្រឹងប្រែងរៀន។

ល្បះដែលអាចបង្កើតបានរួមមានដូចខាងក្រោម ៖

*សុភីជាសិស្សល្អ* **ដោយសារ** *គាត់ប្រឹងប្រែងរៀន និងមកសាលារៀនរាល់ថ្ងៃ។*

*សុភីជាសិស្សល្អ* **ពីព្រោះ** *គាត់ប្រឹងប្រែងរៀន ហើយមកសាលារៀនរាល់ថ្ងៃ។*

*សុភីជាសិស្សល្អ* **មកពី** *គាត់ប្រឹងប្រែងរៀន ព្រមទាំងមកសាលារៀនរាល់ថ្ងៃ។*

☑ គ្រូផ្ដល់បញ្ជីពាក្យសំខាន់ៗដល់សិស្សដែលស្រង់ចេញពីមេរៀន។ គ្រូត្រូវប្រាកដថា សិស្សដឹងពីន័យរបស់ពាក្យទាំងនោះ។ បន្ទាប់មក សិស្សត្រូវសរសេរជាល្បះពេញលេញ ដោយប្រើប្រាស់ពាក្យនេះ ហើយបន្ថែមល្បះមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងល្បះទី១។

ឧទាហរណ៍ ពាក្យសំខាន់ "**អ្នកជិតខាង**" **អ្នកជិតខាង**របស់ខ្ញុំចិត្តល្អណាស់។ ខ្ញុំតែងតែទៅលេងគាត់។

សម្គាល់ : បើសិស្សពិបាកសរសេរល្បះបន្ថែមមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងល្បះទី១ គ្រូអាចឱ្យសិស្សសរសេរល្បះតែមួយល្បះ ទាក់ទងពាក្យសំខាន់ ឬប្រធានបទសរសេរក៏បាន។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៤ឈ**

**លេខ ៤៣**

# សិស្សសរសេរតែងសេចក្តីពណ៌នាអំពីសត្វ ដោយប្រើលំនាំតាមគម្រោងតែង និងសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

**បំណិនសំណេរពាក់ព័ន្ធ : តែងសេចក្តី**

**សូមមើល មេរៀនទី៣៤ (ទំព័រទី១១១)**

## ខ្លឹមសារ

គម្រោងតែងសេចក្តីពណ៌នាអំពីសត្វ ដោយប្រើប្រាស់គម្រោងតែង និងសំណួរក្នុងមេរៀនទី៣៤ ទំព័រទី១១១។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សអានសំណួរ និងគម្រោងតែងសេចក្តីនៅទំព័រទី១១១ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

សំណួរ

**១. សេចក្តីផ្តើម** : តើសត្វមានឈ្មោះអ្វី? ញី ឬឈ្មោល? រស់នៅឯណា?

**២. តួសេចក្តី** : តើវាមានមាឌតូច ឬធំ? ស្គម ឬធាត់? ទាប ឬខ្ពស់? សម្បុរអ្វី? តើក្បាលវាមានអ្វីខ្លះ? (ភ្នែក ច្រមុះ ត្រចៀក ធ្មេញ ចង្កូម...) តើដងខ្លួនវាដូចម្តេច? (ជើង ក កន្ទុយ រោម...) តើវាមានចរិតលក្ខណៈដូចម្តេច? (ស្លូត ឬកាច ឧស្សាហ៍ ឬខ្ជិល...) តើវាមានប្រយោជន៍អ្វីខ្លះដល់អ្នក? (យាមផ្ទះ ចាប់សត្វចង្រៃ...)

**៣. សេចក្តីបញ្ចប់** : តើប្អូនមានអារម្មណ៍ដូចម្តេច ចំពោះសត្វនោះ? ព្រោះអ្វី? (ស្រឡាញ់ចូលចិត្ត ឬស្អប់)

☑ គ្រូសរសេរល្បះនីមួយៗជាគំរូតែងសេចក្តីនៅទំព័រទី៧៤ នៃសៀវភៅសិក្សាគោលនៅចំរៀកក្រដាស។ បិទចំរៀកក្រដាសនៃល្បះបែបចែជន្យនៅលើក្តារខៀន ឱ្យសិស្សទាំងអស់គ្នាមើល។ បន្ទាប់មក គ្រូពន្យល់អំពីគម្រោងតែងសេចក្តី ឱ្យត្រូវតាមសេចក្តីផ្តើម តួសេចក្តី និង សេចក្តីបញ្ចប់នៅទំព័រទី៧៤ រួចឱ្យសិស្សរៀបល្បះទាំងនោះទៅតាមផ្នែកនីមួយៗខាងក្រោម។

| សេចក្តីផ្តើម | តួសេចក្តី | សេចក្តីបញ្ចប់ |
|---|---|---|
| | | |

ខ្ញុំស្រឡាញ់ចម្រើនណាស់ ព្រោះវាប៉ិនចាប់កណ្តុរ ហើយមិនចេះលួចត្រីអាំង ឬសាច់របស់ម្តាយខ្ញុំ...។

ខ្ញុំមានឆ្មាឈ្មោលមួយឈ្មោះចម្រើន។

វាមានរាងតូចបន្តិច តែធាត់ ហើយមានសម្បុរត្រសក់។

☑ គ្រូរៀបចំសិស្សជាក្រុម។ ក្នុងមួយក្រុមមានគ្នាយ៉ាងតិច៦នាក់។ គ្រូដាក់ប្រធានបទឱ្យសិស្សសរសេរ រួចណែនាំសិស្សម្នាក់ៗក្នុងក្រុមនីមួយៗ ចាប់ផ្តើមសរសេរសេចក្តីផ្តើមមួយល្បះម្នាក់ៗរៀងខ្លួន។ បន្ទាប់មក សិស្សម្នាក់ៗឱ្យល្បះនោះទៅសិស្សបន្ទាប់អាន និងសរសេរបន្តទៅតួសេចក្តីមួយល្បះម្នាក់ៗ លើសន្លឹកក្រដាសបន្តពីសេចក្តីផ្តើម

លេខ ៤៧

**បន្ត...**

## សកម្មភាពគំរូ

បន្តរហូតអស់ចំនួនល្បះក្នុងតួសេចក្ដី ទើបបន្តឱ្យសិស្សសរសេរបញ្ចប់លើសន្លឹកក្រដាសតពីតួសេចក្ដីពីម្នាក់ទៅម្នាក់ដើម្បីអាន និងសរសេរបញ្ចប់សេចក្ដីមួយល្បះម្នាក់ៗទៀតរហូតអស់។

**សម្គាល់ :** ចំនួនសិស្សក្នុងក្រុម ស្មើនឹងចំនួនល្បះដែលសិស្សត្រូវសរសេរ។ មានន័យថា សិស្សម្នាក់ៗត្រូវសរសេរល្បះដែលមានល្បះសេចក្ដីផ្ដើមមួយ ល្បះតួសេចក្ដី១ឬ២ល្បះ និងសេចក្ដីបញ្ចប់ម្នាក់មួយល្បះ។ គ្រូរៀបសិស្សជាក្រុម។ បន្ទាប់មក គ្រូផ្ដល់ប្រធានបទមួយដើម្បីឱ្យសិស្សសរសេរតែងសេចក្ដីខ្លី។ សិស្សម្នាក់ត្រូវសរសេរមួយល្បះនៅលើសន្លឹកក្រដាស មួយ។ ល្បះដំបូងត្រូវជាសេចក្ដីផ្ដើម ល្បះបន្ទាប់ជាតួសេចក្ដី និងល្បះចុងក្រោយគឺសេចក្ដីបញ្ចប់។ ក្រុមសិស្សមានគ្នា៦នាក់ ត្រូវសរសេរមួយល្បះសម្រាប់សេចក្ដីផ្ដើម បួនល្បះសម្រាប់តួសេចក្ដី និងមួយល្បះសេចក្ដីបញ្ចប់។ សិស្សម្នាក់ៗក្នុងក្រុមនឹងត្រូវសរសេរល្បះសេចក្ដីផ្ដើមទាំងអស់គ្នា។ នៅពេលពួកគេបានសរសេរចប់ ពួកគេត្រូវហុចក្រដាសរបស់ខ្លួនទៅសិស្សដែលនៅក្បែរ។ បន្ទាប់មក សិស្សម្នាក់ៗត្រូវបន្តសរសេរល្បះមួយទៀតសម្រាប់តួសេចក្ដី។ មុននឹងសរសេរល្បះបន្តទៀត ពួកគេត្រូវហុចសំណេររបស់ខ្លួនទៅសិស្សបន្ទាប់ដែលនៅក្បែរ ដើម្បីឱ្យពួកគេសរសេរល្បះបន្ត ហើយសកម្មភាពនេះត្រូវធ្វើរហូតដល់ការសរសេរល្បះ សម្រាប់សេចក្ដីបញ្ចប់។ សិស្សម្នាក់ៗត្រូវអានអ្វីដែលសិស្សផ្សេងបានសរសេរមុននឹងពួកគេសរសេរល្បះផ្ទាល់ខ្លួនដើម្បីធានាថា តែងសេចក្ដីនោះមានន័យសមស្រប។ នៅពេលសិស្សទាំងអស់សរសេរចប់ សិស្សនីមួយៗ ត្រូវយកសំណេរដើមរបស់ខ្លួន ដែលបានសរសេរក្នុងសេចក្ដីផ្ដើមដើម្បីពិនិត្យមើលថា តើសិស្សផ្សេងទៀតបានសរសេរអ្វីខ្លះ។

| | |
|---|---|
| ពេលវេលា | ក្រោយពី ពីមុន រហូតដល់ ជាទីបំផុត ពេល ខណៈដែល |
| ហេតុ និង ផល | ដោយសារ ដូចនេះ ដើម្បី ហេតុនេះ ពីព្រោះ មកពី ទើប ដូច្នោះ នោះ |
| ការបន្ថែម | ម្យ៉ាងទៀត ហើយ ហើយនឹង ព្រមទាំង លើសពីនេះទៀត យ៉ាងណាមិញ |
| សេចក្ដីសន្និដ្ឋាន | ជាលទ្ធផល ដូចនេះ ហេតុនេះ អាស្រ័យហេតុនេះ |
| ការផ្លាស់ប្ដូរ | ក៏ប៉ុន្តែ ទោះបីជា យ៉ាងណាក៏ដោយ លុះត្រាតែ |
| ការប្រៀបធៀប | ដូចជា ប្រហាក់ប្រហែល ចំណែកឯ ខណៈដែល ដរាបណា |
| លក្ខខណ្ឌ | ប្រសិនបើ  លើកលែងតែ ក្នុងករណី លុះត្រាតែ |
| ទីកន្លែង | ទីណាដែល កន្លែងដែល |

☑ គ្រូរំឭកឱ្យសិស្សប្រើប្រាស់ពាក្យភ្ជាប់ ដើម្បីធ្វើឱ្យល្បះមានភាពរលូនពីមួយទៅមួយ។ ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួនមានបង្ហាញជូនខាងក្រោម ៖

*ឧទាហរណ៍* ប្រធានបទគំរូ ៖ ទីកន្លែងដែលខ្ញុំចូលចិត្ត

***ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួន សម្រាប់ជួយសិស្សក្នុងការសរសេរតែងសេចក្ដី ៖***

**លេខ ៤ញ**

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សបំពេញតារាងខាងក្រោម ដោយប្រើព័ត៌មានដែលត្រូវការអំពី សត្វឆ្កែដែលបង្ហាញក្នុងទំព័រ១១១ ធ្វើជាកិច្ចការមុនសំណេរ ដើម្បីជួយពួកគេឱ្យចេះរៀបចំព័ត៌មានផ្អែកតាមសំណួរ។ *ឧទាហរណ៍* លំហាត់មុនសំណេរ សម្រាប់ សរសេរតែងសេចក្តីអំពី "សត្វឆ្កែ"។

| **សេចក្តីផ្តើម** | |
|---|---|
| **ប្រភេទព័ត៌មាន** | **ព័ត៌មានជាក់លាក់** |
| ព័ត៌មានមូលដ្ឋាន (សត្វនោះឈ្មោះអ្វី? ញីឬឈ្មោល? រស់នៅឯណា?) | ……………………….. |
| **តួសេចក្តី** | |
| រូបរាង ៖ តើវាមានមាឌធំឬតូច? ស្គមឬធាត់ ទាបឬខ្ពស់ សម្បុរអ្វី? | ……………………….. |
| ទម្រង់មុខ ៖ តើវាមាន ភ្នែក ច្រមុះ ត្រចៀក ធ្មេញ ចង្កូមដូចម្តេច? | ……………………….. |
| ដងខ្លួន ៖ តើវាមាន ដៃជើង ក កន្ទុយ រោមដូចម្តេច? | ……………………….. |
| ចរិតលក្ខណៈ ៖ តើវាស្លូត ឬកាច ឧស្សាហ៍ឬខ្ជិល? | ……………………….. |
| ប្រយោជន៍ ៖ តើវាចេះយាមផ្ទះ ចាប់សត្វចង្រៃ? | ……………………….. |
| **សេចក្តីបញ្ចប់** | |
| ការវាយតម្លៃ ៖ តើអ្នកមានអារម្មណ៍បែបណាចំពោះសត្វឆ្កែ? ព្រោះអ្វី? | ……………………….. |

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ១៧



ល្បែងទី ១៨



ល្បែងទី ១៩



ល្បែងទី ២០



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់រៀន




**ដំណាក់កាលទី ៤ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី ៤

នៃឧបសម្ព័ន្ធ ២ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៦២ ដល់ ១៦៥

# ដំណាក់កាលទី ៥ : មេរៀនទី៣៥ ដល់ទី៤១ (២២)

(ទំព័រទី១១២ ដល់ទី១៣២)

*១. មេរៀនទី៣៥ : អំពីកិរិយា*

*២. មេរៀនទី៣៦ : ការបហាត់ប្រាណ*

*៣. មេរៀនទី៣៧ : យើងទៅមណ្ឌលសុខភាព*

*៤. មេរៀនទី៣៨ : ពណ៌នាអំពីព្រឹត្តិការណ៍*

*៥. មេរៀនទី៣៩ : ទោសនៃគ្រឿងញៀន*

*៦. មេរៀនទី៤០ : រៀបរាប់ពីសមាជិកគ្រួសារ និងមុខរបរ*

*៧. មេរៀនទី៤១ : ឥទ្ធិពលនៃគ្រឿងស្រវឹង*

*( ៦៣ ម៉ោងប្រហែល៥សប្តាហ៍)*

**កំណត់សម្គាល់ :** **(២២)** ចំពោះមេរៀនទី៤០ សមត្ថភាពនិយាយមានចំនួន៣ម៉ោងសិក្សា។ មេរៀននេះមិនទាក់ទងនឹងស្តង់ដាអំណានទេ។ គ្រូត្រូវបង្រៀនមេរៀននេះតាមធម្មតា។

លេខ ៥ក

# សិស្សប្រាប់បានពាក្យជាកិរិយា តាមនិយមន័យដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនពាក់ព័ន្ធ : វេយ្យាករណ៍

សូមមើល មេរៀនទី៣៥ (ទំព័រទី១១២ ទី១១៣)

### ខ្លឹមសារ

**និយមន័យ** : ជាពាក្យសម្ដែងអំពី ឬបង្ហាញសកម្មភាព។ ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៣៥ ពាក្យជា**កិរិយា** ដូចជាពាក្យ ភ្ជួរ ពរ និទាន ដើរ ច្រៀង សរសេរ សើច មើល លេង លក់ លោត។

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សគូសរង្វង់ជុំវិញពាក្យដែលជាកិរិយាក្នុងប្រអប់តារាងខាងក្រោម (ទំព័រទី១១៣)។

| | | | | |
|---|---|---|---|---|
| ទេសភាព | រៀន | ប្រាសាទ | ដេរ | ល្អ |
| ថ្ម | ក្ដៅ | ច្រៀង | សើច | ឧស្សាហ៍ |

☑ គ្រូឱ្យសិស្សអានអត្ថបទក្នុងមេរៀនទី៣៤ ទំព័រ១០៦ "**ការលក់ដូរ**" រួចឱ្យសិស្សស្រង់ និងសរសេរ ពាក្យដែលជាកិរិយាដាក់ក្នុងសៀវភៅសរសេររៀងខ្លួន។

☑ គ្រូឱ្យសិស្សចាប់ដៃគូ រួចតែងល្បះដែលមានប្រើកិរិយាឱ្យបានចំនួន ៣ល្បះអំពី "**សាលារៀនខ្ញុំ**"។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញពាក្យ "**កិរិយា**" ក្នុងល្បះទាំងនោះ។ ក្នុងល្បះនីមួយៗអាចមានប្រើពាក្យជា "**កិរិយា**" ចំនួន១ ឬ២ក៏បាន។ សិស្សម្នាក់ៗគួរតែងល្បះដោយខ្លួនឯងជាមុនសិន។ បន្ទាប់មក គ្រូឱ្យពួកគេប្ដូរក្រដាសគ្នា ដើម្បីគូសរង្វង់ជុំវិញពាក្យដែលជាកិរិយា។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ២១


ល្បែងទី ២២


ល្បែងទី ២៣




ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ក**

លេខ ៥២

# សិស្សកំណត់សូរដើម និងសូរបន្ទាប់ តាមរយៈការស្តាប់ពាក្យដែលគ្រូអាន និងសរសេរ

ឧទាហរណ៍ ភ្លឺ = ភ្ល + "ឺ"

- "ភ្ល" សូរដើម អ៊ឺ សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៤ ទី១១៨ ទី១២៦ ទី១៣២ )**

## ខ្លឹមសារ

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ ដូចជា គេង ក្រោក ចេញ បណ្តើរ ញ៉ាំ វក្សា ប្រើ ប្រាប់ រៀនសូត្រ អួត ផឹក ស៊ី បញ្ចាំ បំពាន . . .។
- ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ គ្រូបង្ហាញរូបភាព "មាន់" ដល់សិស្សរួចសួរថា តើសូរដើមនៃពាក្យ មាន់ មានសូរអ្វី?

ចម្លើយ : សូរដើមគឺ "**ម**"។ បន្ទាប់មក គ្រូសួរសិស្ស ចុះសូរបន្ទាប់នៃពាក្យ មាន់ គឺអ្វី?

ចម្លើយ : សូរបន្ទាប់គឺ "អា" "ន" និង "់"។ (ការស្គាល់សូរ)

បន្ទាប់មក គ្រូឱ្យសិស្សរកសូរដើមរបស់ពាក្យផ្សេងទៀតដែលមានសូរដើម និងសូរបន្ទាប់ដែលផ្តើមពីព្យញ្ជនៈដូចគ្នា។

ឧទាហរណ៍ ពាក្យ " ចាប ចាំ ចាស់ ចុះ ចេះ ចារ ចោះ ចាប់ ចុក . . . "។

☑ គ្រូបង្កើតល្បែងសិក្សាប្រដេញពាក្យ ដែលកំណត់ដោយសូរដើមរបស់ពាក្យ ដែលចាប់ផ្តើមពីសិស្ស ដំបូង ឬមុនគេ ហើយបន្តរហូតដល់សិស្សចុងក្រោយ។ ឧទាហរណ៍ សិស្សដំបូងថាពាក្យ "សុខ" សិស្សបន្ទាប់ត្រូវចាប់សូរបន្តពីសូរដើមរបស់ពាក្យផ្តើមពីព្យញ្ជនៈ ស ដែរ "សុខ" គឺ "ស" ទៅពាក្យដើមដោយសូរ "ស" ផ្សេងទៀតដូចជា "សារ ស៊ី សំ សូរ សួរ សើម សុំ សេះ សល់ សៀម សោយ ..." ធ្វើបែបនេះរហូតដល់វេនសិស្សចុងក្រោយទៅតាមការគិត និងការពេញចិត្តរបស់គេរហូតចប់។ (ការស្គាល់សូរ)

(ពាក្យ "**សុខ**"→សារ→ស៊ី→សំ→សូរ→សួរ→សើម→សុំ→សេះ→សល់→សៀម→សោយ . . . )

សម្គាល់ **ក.** ប្រសិនបើសិស្សណារកសូរដើមរបស់ពាក្យ ដូចសិស្សមុនថាទាំងព្យញ្ជនៈ និងស្រៈ ឬទាំងព្យញ្ជនៈ និងស្រៈប្រកប ដូចគ្នាចាត់ទុកថាចាញ់រួចគ្រូឱ្យសិស្សថ្មីម្នាក់ទៀតរកបន្តរហូតចប់។

**ខ.** គ្រូអាចប្តូរពាក្យថ្មីដែលមានសូរដើមផ្សេងទៀត និងធ្វើដូចលំនាំខាងលើ។

☑ គ្រូប្រាប់សិស្ស ពាក្យណាមួយដោយទាញសំឡេងឱ្យវែង ដូចជាពាក្យ "សូម" ស អូ សូនិងម រួចឱ្យសិស្សទាយថាពាក្យនោះជាពាក្យអ្វី។ (ការស្គាល់សូរ)

☑ គ្រូឱ្យសិស្សកំណត់សូរដើម និងសូរបន្ទាប់ដែលគ្រូសរសេរនៅលើក្តារខៀន។ ឧទាហរណ៍ ក្រោយពីសរសេរពាក្យ"**ជួយ**" សិស្សត្រូវកំណត់រកសូរដើម និងសូរបន្ទាប់។ (ការស្គាល់តួអក្សរនិងសូរ)

សូរដើម **ជ** សូរបន្ទាប់ "អួ" និង**យ**

លេខ ៥ខ

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ខ**

លេខ ៥គ

## សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទ ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៥ ទី១១៩ ទី១២៧ និងទី១៣៣)

### ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ដូចជា ៖

**ពន្យល់ពាក្យ**

**មេរៀនទី៣៦**

- សម្ងំ (គុ.) : ដែលនៅស្ងៀម។
- បណ្ដើរ (កិ.) : ដើរត្រសងទៅព្រមគ្នា។
- ភ្លឺស្រាងៗ (គុ.កិ.) : ភ្លឺជិតព្រឹក។

**មេរៀនទី៣៧**

- រក្សា (កិ.) : ថែទាំ បីបាច់ ចិញ្ចឹម ការពារ។
- អនាម័យ (ន.) : ដំណើរមិនមានរោគ សេចក្ដីសុខសប្បាយ។
- បញ្ហា (ន.) : ពាក្យ ឬសម្ដីដែលមានអាថ៌កំបាំងទាល់ តែអ្នកមានប្រាជ្ញាទើបអាចដឹងបាន(ចំណោទ ប្រស្នា)។

**មេរៀនទី៣៩**

- អន្តរាយ (ន.) : សេចក្ដីវិនាស។
- ចោរកម្ម (ន.) : អំពើលួចឆក់ ប្លន់។

**មេរៀនទី៤១**

- អួត (កិ.) : និយាយបំផ្លើសការពិត ប្រកាសគុណ និយាយហួសការពិត។
- បញ្ចាំ (កិ.) : ដាក់ទ្រព្យរបស់អ្វីមួយទុកជាភស្តុតាង ដើម្បីយកប្រាក់មកប្រើប្រាស់។
- បំពាន (កិ.) : ពានពារលើ រំលោភលើ ធ្វើបំពានលើច្បាប់។

**បដិសព្ទ**

| | | | | | | |
|---|---|---|---|---|---|---|
| មេរៀនទី៣៦ : | សប្បាយ | ≠ | កើតទុក្ខ | បង | ≠ | ប្អូន |
| មេរៀនទី៣៧ : | ច្រើន | ≠ | តិច | ទុក្ខ | ≠ | សុខ |
| មេរៀនទី៣៩ : | ហិង្សា | ≠ | អហិង្សា | វង្វេង | ≠ | ភ្លឺស្វាង |
| មេរៀនទី៤១ : | ក្មេង | ≠ | ចាស់ | មាន | ≠ | ក្រ |

**វេវចនសព្ទ**

មេរៀនទី៣៦ : វេវចនសព្ទនឹងពាក្យ "**ព្រះអាទិត្យ**" ព្រះអាទិត្យ ថ្ងៃ ព្រះទិនករ ទិវាទិវ៉ែន ព្រះសូរ្យ ព្រះសូរ្យសែង

មេរៀនទី៣៧ : វេវចនសព្ទនឹងពាក្យ "**កាយា**" **កាយា** ខ្លួន រាងកាយ កាយ

មេរៀនទី៣៩ : វេវចនសព្ទនឹងពាក្យ "**ថវិកា**" **ថវិកា** ប្រាក់ លុយ បច្ច័យ រូបិយប័ណ្ណ

មេរៀនទី៤១ : វេវចនសព្ទនឹងពាក្យ "**ខ្សត់**" **ខ្សត់** ទ័ល ក្រ ខ្វះខាត

**សទិសសព្ទ**

មេរៀនទី៣៦ : សទិសសព្ទនឹងពាក្យ "**ព្រោះ**"

លេខ ៥គ

**បន្ត...**

## ខ្លឹមសារ

- ព្រោះ (កិ.) : បាចគ្រាប់ពូជល្អិត។ *ឧទាហរណ៍* ព្រោះគ្រាប់ស្ពៃ ព្រោះគ្រាប់ស្រូវ។
- ព្រួស (កិ.) : បញ្ចេញទឹក ឬទឹកមាត់ពីក្នុងឱ្យខ្ចាយព្រោងដោយកម្លាំង។ *ឧទាហរណ៍* ព្រួសទឹក ពស់ព្រួសពិស។
- ព្រោះ (អា.និ.) : ហេតុ ត្បិត។ *ឧទាហរណ៍* រៀនពុំចេះពីព្រោះខ្ជិល។

**មេរៀនទី៣៧ :** សទិសសព្ទនឹងពាក្យ "**រស់**"

- រស់ (គុ.) : ដែលមានជីវិតរស់នៅ មិនទាន់ស្លាប់។
- រស (ន.) : សម្ផស្សប្លែកៗដែលប៉ះពាល់ជីវ្ហាប្រសាទដឹងថា ជូរ ប្រៃ ចត់ ល្វីង ផ្អែម ជាដើម។

**មេរៀនទី៣៩ :** សទិសសព្ទនឹងពាក្យ "**វា**"

- វា (ន.) : ពាក្យសម្រាប់និយាយជំនួសឈ្មោះមនុស្សក្មេងជាងមនុស្សថ្នាក់តូច។
- វារ (កិ.) : លូនដោយប្រវារ។ *ឧទាហរណ៍* ល្ពៅវារ កូនក្មេងចេះវារ....។
- វៀរ (គុ.) : ដែលលើកលែង តម ឈប់ ខាន។ *ឧទាហរណ៍* វៀរចាកគ្រឿងញៀន។

**មេរៀនទី៤១ :** សទិសសព្ទនឹងពាក្យ "**កម្ម**"

- កម្ម (ន.) : អំពើ ទោះអំពើល្អក្តី អាក្រក់ក្តី។ *ឧទាហរណ៍* កម្មពីជាតិមុន.....។
- កាំ (ន.) : អ្វីៗដែលរៀបជាជាន់ ជាថ្នាក់សម្រាប់ទល់ សម្រាប់ទ្រ។ *ឧទាហរណ៍* កាំជណ្តើរ.....។

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យរបស់ពាក្យពិបាកនោះដោយគូសភ្ជាប់សញ្ញាព្រួញ។ *ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្តាំ ឱ្យត្រូវនឹងនិយមន័យរបស់វា។

| ពាក្យពិបាក | និយមន័យ | ពាក្យពិបាក | និយមន័យ |
|---|---|---|---|
| អនាម័យ | ♦ ដំណើរមានរោគ។<br>♦ ដំណើរមិនមានរោគ។<br>♦ ដំណើរឈឺ។ | បញ្ញាំ | ♦ ដាក់របស់អ្វីមួយតម្កល់ទុកប្រើប្រាស់។<br>♦ ដាក់របស់អ្វីមួយទុកជាភស្តុតាងដើម្បីប្រើប្រាស់។<br>♦ ដាក់របស់អ្វីមួយទុកជាប្រផ្នូរនៃវត្ថុប្រើប្រាស់។ |
| អន្តរាយ | ♦ សេចក្តីរុងរឿង។<br>♦ សេចក្តីចម្រើន។<br>♦ សេចក្តីវិនាស។ | | |

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្តារខៀន។ សិស្សត្រូវនឹករកពាក្យផ្សេងទៀត ដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាន និយមន័យដូចគ្នាទេ តែមានទំនាក់ទំនងជាមួយគ្នាតាម ដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ** ដោយមានការបង្ហាញគំនិតពាក់ពន្ធ័ផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ "**បក្សី**" នៅលើក្តារខៀន រួចឱ្យសិស្សរកពាក្យដទៃដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែ

លេខ ៥គ

**បន្ត...**

## សកម្មភាពគំរូ

មិនមែនមានន័យថា រកពាក្យដែលន័យដូចនោះទេ។




☑ គ្រូបង្កើតបណ្ណពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្តារខៀន រួចឱ្យសិស្សរកពាក្យដែលមានន័យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| បង | សប្បាយ | ច្រើន | ហិង្សា | ក្មេង | វង្វេង | ក្រ | ទុក្ខ |

- បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូបង្កើតដ្យាក្រាម ហើយសរសេរពាក្យនៅចំកណ្តាល។ បន្ទាប់មក គ្រូឱ្យសិស្សស្វែងរកពាក្យផ្សេងទៀតដែលមានន័យផ្ទុយ (បដិសព្ទ) ហើយសរសេរពាក្យទាំងនោះនៅជុំវិញពាក្យកណ្តាល។ *ឧទាហរណ៍*




**សម្គាល់ :** ពាក្យដែលគ្រូអាចជ្រើសរើសមកធ្វើលំហាត់ ជាបដិសព្ទ ឬពាក្យផ្ទុយបាន អាចមានពាក្យផ្ទុយច្រើន(ដូចជាពាក្យ **ទុក្ខ**អាចផ្ទុយនឹងពាក្យ សុខ រីករាយ សប្បាយ ក្សេមក្សាន្ត . . .) ខ្លះទៀតអាចមានពាក្យផ្ទុយតែមួយឬពីរប៉ុណ្ណោះ។

**លេខ ៥គ**

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូចែកសិស្សជាក្រុមៗដែលមួយក្រុមមានគ្នា៤ ទៅ៥នាក់។ គ្រូសរសេរពាក្យមួយ នៅលើក្ដារខៀន ហើយឱ្យសិស្សរកវេវចនសព្ទទាក់ទងនឹងពាក្យនោះឱ្យបានច្រើនតាមដែលអាចរកបាន។ គ្រូផ្ដល់ពេលប្រហែលបីឬបួននាទីប៉ុណ្ណោះសម្រាប់ស្វែងរក ហើយក្រុមណាដែលរកពាក្យវេវចនសព្ទបានច្រើនជាងគេគឺជាក្រុមឈ្នះ។ គ្រូអាចធ្វើសកម្មភាពដូចគ្នានេះ សម្រាប់ពាក្យបដិសព្ទ ឬវេវចសព្ទផ្សេងទៀតក៏បាន។

☑ គ្រូគូសតារាងនៅលើក្ដារខៀន។ តារាងទី១ជាវេវចនសព្ទ តារាងទី២ជាបដិសព្ទ។ បន្ទាប់មក គ្រូសរសេរបញ្ជីពាក្យនៅលើក្ដារខៀន ហើយឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទាំងនេះទៅតាមតារាង វេវចនសព្ទនិងបដិសព្ទឱ្យបានត្រឹមត្រូវ។
*ឧទាហរណ៍* គ្រូសរសេរពាក្យខាងក្រោម ដាក់លើក្ដារខៀន រួចបង្ហាញឧទាហរណ៍ខាងក្រោមពន្យល់សិស្ស។ បន្ទាប់មក ឱ្យសិស្សរកដោយខ្លួនឯង។
**បញ្ជីពាក្យ :** ព្រះអាទិត្យ គេង បរិបូរណ៌ កាយា ទាប តិច ថវិកា ដេក ខ្ពស់ ច្រើន ខ្សត់

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| គេង ដេក<br>................. | ខ្ពស់ ≠ ទាប<br>.......... ≠ ............ |

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣




ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥គ**

លេខ ៥យ

## សិស្សរកសូរចួនក្នុងពាក្យដែលគ្រូអាន និងសរសេរ

**សម្គាល់ :** មុនបង្រៀនពាក្យចួន ក្នុងអត្ថបទសំណេរគ្រូគួរ រំឭកបញ្ញត្តិពាក្យចួនដោយប្រើភាសានិយាយសិន។

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៣៧ និងទី៤១ (ទំព័រទី១១៨ និងទី១៣២)**

### ខ្លឹមសារ

និយមន័យ "ពាក្យចួន"

<u>**ពាក្យចួន**</u> គឺជាពាក្យមានសូរស្រៈដូចគ្នា ឬសូរស្រៈប្រកបនឹងព្យញ្ជនៈដូចគ្នា ក្នុងវគ្គរបស់កំណាព្យ ឬមេសូត្រ។

*ឧទាហរណ៍* មេសូត្រ (បទកាកគតិ) មេរៀនទី៣៧ និងទំព័រទី១១៨

- ពាក្យ "ផ្កាំ" ចួននឹង "ចាំ"
- ពាក្យ "ថា" ចួននឹង"អាហារ" ចួននឹង "រក្សា" ។

### សកម្មភាពគំរូ

☑ គ្រូនិយាយប្រាប់សិស្សថា គ្រូនឹងប្រាប់ពាក្យចំនួន៤។ ចូរប្អូនស្ដាប់ដោយយកចិត្តទុកដាក់ ហើយឆ្លើយមកវិញថា តើពាក្យមួយណាក្នុងចំណោមពាក្យទាំងបួននោះ ដែលមិនមែនជាពាក្យចួន។ (ការស្គាល់សូរ) គ្រូ

*ឧទាហរណ៍*

| | | | | |
|---|---|---|---|---|
| | ផ្កាំ | ថ្នាំ | **មាន** | ចាំ |
| | មាន | **ជិត** | ឃ្លាន | លាន |
| | ចេះ | ផេះ | កេះ | **ខ្ពស់** |
| | **ធំ** | ឆ្នា | ការ | ចារ |

**សម្គាល់ :** គ្រូគួរចាំថានៅពេលធ្វើលំហាត់នេះ គឺមិនត្រូវសរសេរពាក្យទាំងនេះនៅលើក្ដារខៀននោះទេ ប៉ុន្តែគ្រូត្រូវធ្វើដោយផ្ទាល់មាត់ ព្រោះនេះជាការបង្រៀនពីការស្គាល់សូរ។

☑ គ្រូសរសេរពាក្យចួនមួយចំនួនលើក្ដារខៀន រួចឱ្យសិស្សរកសូរអក្សរណា ដែលមានសូរដូចគ្នានៅខាងចុងឱ្យបានច្រើនតាមអាចធ្វើបាន។ *ឧទាហរណ៍*

- ពាក្យ "**តឹង**" និង "**ប្រឹង**" គឺមានតួអក្សរ "**ត**" ស្រៈ "អឹ" និង"ង" ចួននឹង "ប្រ" ស្រៈ "អឹ" និង "**ង**" ដូចគ្នា។
- ពាក្យ "**ត្រី**" និង "**ស្រី**" គឺមានតួអក្សរ "**ត្រ**" និងស្រៈ "**អី**" ចួននឹងតួអក្សរ "**ស្រ**" និងស្រៈ "**អី**" ដូចគ្នា។
- ពាក្យ "**ចោះ**" និង "**កោះ**" គឺមានតួអក្សរ "**ច**" និងស្រៈ "**អោះ**" ចួននឹងតួអក្សរ "**ក**" និងស្រៈ "**អោះ**" ដូចគ្នា។

ដូចនេះ ពាក្យ តឹង និងប្រឹង ⟶ **តឹង** ☰ **ប្រឹង** (**តឹង** ចួននឹង**ប្រឹង**)

ពាក្យ **ត្រី** និង**ស្រី** ⟶ **ត្រី** ☰ **ស្រី** (**ត្រី** ចួននឹង**ស្រី**)

ពាក្យ **ចោះ** និង**កោះ** ⟶ **ចោះ** ☰ **កោះ** (**ចោះ** ចួននឹង**កោះ**)

☑ គ្រូសរសេរអត្ថបទមេសូត្រដាក់លើក្ដារខៀន រួចឱ្យសិស្សឡើងគូសពាក្យចួននៅលើក្ដារខៀន។

លេខ ៥យ

**បន្ត**

## សកម្មភាពគំរូ

ឯអ្នកប្រមឹក ប្រមូលកន**ផឹក** ធ្វើភឿននឹង**ក្មេង**
សម្តីច្រើនតឹង ស្រវឹង**វង្វេង** ជំហរអួត**ក្អេង**
មិនចេះក្រ**ខ្សត់**។
អួតទាំង**បំពាន** ផឹកម៉្លៃលុយ**មាន** ផឹកម៉្លៃលុយ**អត់**
ឯងចេះតែកិន ចិនចេះតែ**កត់** ផឹកដល់**កំណត់**
យកស្រែបញ្ចាំ។

☑ គ្រូផ្តល់កំណាព្យមួយដែលមិនពេញលេញដល់សិស្ស ដោយមានលុបចេញពាក្យចួនមួយចំនួន។ គ្រូឱ្យសិស្សសរសេរកំណាព្យដែលមិនពេញលេញនោះដាក់ក្នុងសៀវភៅ ហើយធ្វើការជាក្រុមស្វែងរកពាក្យចួន ដែលត្រូវបំពេញ (ពាក្យចួនដូចមានក្នុងចម្លើយរំពឹងទុកខាងក្រោម)។ ពាក្យដែលមានអក្សរដិត គឺជាពាក្យសម្រាប់ឱ្យសិស្សមើល ដើម្បីរកពាក្យចួននឹងពាក្យនោះ ហើយពាក្យចួនទាំងនោះសិស្សអាចគិតដោយខ្លួនឯងដើម្បីបំពេញកំណាព្យនេះ។

*ឧទាហរណ៍*

បុណ្យជារភូមិខ្ញុំ មីងពូ(១)... សប្បាយរីករាយ
នៅក្រោមដើមពោធិ ញញឹម(២)... ខ្លះរែកទូលស្ពាយ
នំម្ហូបអាហារ។
មីងពូទាំងអស់ ចាស់ទុំ(៣)... រួមទាំងអាចារ្យ
រាប់បាត្រព្រះសង្ឃ បួងសួង(៤)... ស្តាប់លោកទេសនា
ប្រាថ្នាសុខសាន្ត។

**ចម្លើយ :**

(១) ជួបជុំ មូលផ្តុំប្រជុំ...
(២) ពព្រាយ រីករាយ សប្បាយ ...
(៣) ស្រីប្រុស ផុសផុល...
(៤) រក្សា ទេវតា អ្នកតា ...

លេខ
៥យ

## បន្ត

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ២១


ល្បែងទី ២២


ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥យ**

## លេខ ៥ង

# សិស្សបកស្រាយន័យនៃល្បះអត្ថបទ និងមេសូត្រនៅតាមមេរៀនដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ តាមរយៈលំហាត់ផ្សេងៗ

*ឧទាហរណ៍* សិស្សឆ្លើយសំណួរយល់ដឹង បំពេញល្បះ លំហាត់ក្លូស្ស។ល។

### បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៦ ទី១១៩ ទី១២៨ និងទី១៣៣)

### ខ្លឹមសារ

ល្បះអត្ថបទ និងមេសូត្រក្នុងមេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១

- មេរៀនទី៣៦ : ការហាត់ប្រាណ
- មេរៀនទី៣៧ : យើងទៅមណ្ឌលសុខភាព
- មេរៀនទី៣៩ : ទោសនៃគ្រឿងញៀន
- មេរៀនទី៤១ : ឥទ្ធិពលនៃគ្រឿងស្រវឹង

### សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរ មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១

**មេរៀនទី៣៦**

១. តើនរណាខ្លះដែលដាស់បូណាទៅហាត់ប្រាណ?

២. ពេលក្រោកពីដំណេក តើបូណានិយាយដូចម្ដេចខ្លះទៅកាន់អ្នកទាំងបី?

៣. តើនរណាខ្លះទៅហាត់ប្រាណជាមួយបូណា?

៤. ហេតុអ្វីបានជាពួកគេទៅហាត់ប្រាណ?

**មេរៀនទី៣៧**

១. តើគ្រូបានផ្ដាំប្អូនឱ្យចងចាំអ្វីខ្លះ?

២. តើប្អូនស្គាល់ជំងឺអ្វីខ្លះ នៅក្នុងស្រុកយើង?

៣. ប្រសិនជាប្អូនមានជំងឺ តើត្រូវទៅព្យាបាលនៅកន្លែងណា?

៤. តើប្អូនត្រូវធ្វើអ្វីខ្លះ ដើម្បីបង្ការជំងឺឆ្លង។ ★

**មេរៀនទី៣៩**

១. តើសុភក្ត្រឃើញសកម្មភាពអ្វី ពេលគេត្រឡប់ពីសាលារៀនវិញ?

២. តើម្ដាយសុភក្ត្រ និយាយពន្យល់កូនដូចម្ដេចខ្លះ?

៣. តើម្ដាយសុភក្ត្រ បានទូន្មានសុភក្ត្រដូចម្ដេចខ្លះ?

៤. តើសុភក្ត្រប្ដេជ្ញាចិត្តដូចម្ដេចខ្លះ? ហេតុអ្វី? ★

**មេរៀនទី៤១**

១. តើអ្នកផឹកស្រាច្រើនប្រើសម្ដីដូចម្ដេច?

២. បើផឹកស្រាដល់កំណត់ តើគាត់យកអ្វីទៅបញ្ចាំ?

៣. បើគ្មានស្រែទៅបញ្ចាំ តើគាត់យកអ្វីទៅបញ្ចាំទៀត?

៤. តើអ្នកផឹកស្រាតែងជួបនឹងផលអាក្រក់អ្វីខ្លះ?

**សម្គាល់:** ក. សំណួរដែលមានសញ្ញា ★ (ផ្កាយ) គឺជាសំណួរបន្ថែម ដើម្បីពង្រឹងបំណិនវិភាគ និងដោះស្រាយបញ្ហា។ រាល់ចម្លើយរបស់សិស្សឱ្យតែសមហេតុ ផល ទោះបីជាមិនមាននៅក្នុងអត្ថបទអំណានក៏ដោយ គ្រូត្រូវទទួលទាំងអស់។

ខ. សំណួរបន្ថែមខាងក្រោមនេះ គ្រូអាចពិភាក្សាជាមួយសិស្ស ដើម្បីជួយកែលម្អសមត្ថភាពគំនិតដោយវិភាគក្នុងអត្ថបទមេរៀនទី៣៦ និង៤១ ៖

- មេរៀនទី៣៦ : តើមានអ្វីកើតឡើង បើយើងមិនបានហាត់ប្រាណ?
- មេរៀនទី៤១ : តើមានសកម្មភាពល្អអ្វីខ្លះ ជំនួសការផឹកស្រា?

**លេខ ៥ង**

## បន្ត...

# សកម្មភាពគំរូ

☑ សិស្សបំពេញលំហាត់ cloze តាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទមកបំពេញ បានត្រឹមត្រូវ។ (មេរៀនទី៣៦ ទំព័រទី១១៤)

នៅពេលព្រលឹមភ្លឺស្រាងៗ។ នៅ...(**១**)បង្អួចក្បែរបន្ទប់បូណាគេង ...(**២**)ឮសំឡេងមាន់រងាវដាស់...(**៣**) "កុកគីកែកឺត! កុកគីកែកឺត! ក្រោក ...(**៤**)បូណា"។ ចាបក៏ជួយស្រែក...(**៥**) ៖ "ជីប! ជីប! ភ្ញាក់ឡើង! ឮ...(**៦**)បូណា"។

បូណានៅតែសម្ងំគេង...(**៧**)យ៉ាងស្កប់ស្កល់ដដែល។ ព្រះអាទិត្យក៏...(**៨**)ក្រើនបូណាឱ្យក្រោកឡើង! ...(**៩**)ទៅហាត់ប្រាណជាមួយគ្នា!។

ចម្លើយ : **១.** មាត់ ជិត **២.** គេ ពួកគេ **៣.** បូណា វា **៤.** ឡើង ងើប **៥.** ដាស់ ឮឡើង **៦.** ហើយ ល្មម ល្មមហើយ **៧.** លក់ លង់លក់ **៨.** ជួយ ខំ **៩.** យើង ពួកយើង

☑ គ្រូឱ្យសិស្សអានអត្ថបទណាមួយឡើងវិញ។ រួចឱ្យសិស្សសរសេរពាក្យដែលមិនទាន់ចេះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ បន្ទាប់មក គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យ ពាក្យមិនចេះនោះតាមទីសេចក្ដី "**ទីសេចក្ដីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ**" ។ រួចសិស្សសរសេរនិយមន័យពាក្យដែលកំណត់តាមការវិភាគនេះ។

ប្រសិនបើសិស្សមិនអាចបកស្រាយនិយមន័យពាក្យណាមួយបាន គេអាចសួរគ្រូក្នុងក្រុមធំបាន។ គ្រូគួរសរសេរពាក្យទាំងអស់នោះនៅលើក្ដារខៀនឱ្យសិស្សដទៃទៀតមើល ដើម្បីផ្ដល់យោបល់ ហើយគ្រូជួយកែលម្អ។

*ឧទាហរណ៍* ចូរបង្ហាញពាក្យទីសេចក្ដីកំណត់ន័យរបស់ពាក្យ "ជីប! ជីប! ..." ចាបក៏ជួយស្រែកដាស់ : "ជីប! ជីប! ភ្ញាក់ឡើង! ឮហើយបូណា"។ ដូចនេះពាក្យ "**ជីប! ជីប!**" គឺជាទីសេចក្ដីបញ្ជាក់ន័យរបស់ពាក្យ "**ចាប**" ។

☑ ក្រោយពីអានរឿងគ្រូសរសេរព្រឹត្តិការណ៍សំខាន់ៗក្នុងរឿងមិនតាមលំដាប់លំដោយ។ សិស្សត្រូវដាក់លេខខាងមុខព្រឹត្តិការណ៍ នីមួយៗទៅតាមលំដាប់លំដោយបានកើតឡើងក្នុងរឿង។ *ឧទាហរណ៍* គ្រូណែនាំសិស្សឱ្យបង់លេខក្នុងប្រអប់ល្បះនីមួយៗតាមលំដាប់លំដោយព្រឹត្តិការណ៍។

- ☐ នៅពេលព្រលឹមភ្លឺស្រាងៗ។ នៅមាត់បង្អួចក្បែរបន្ទប់បូណាគេង គេឮសំឡេងមាន់រងាវដាស់បូណា (១)
- ☐ ព្រះអាទិត្យក៏ជួយក្រើនបូណាឱ្យក្រោកឡើង!(៥)
- ☐ បូណានៅតែសម្ងំគេងលក់យ៉ាងស្កប់ស្កល់ដដែល។(៤)
- ☐ "កុកគីកែកឺត! កុកគីកែកឺត! ក្រោកឡើង! ក្រោកឡើងបូណា"។ (២)
- ☐ យើងទៅហាត់ប្រាណជាមួយគ្នា។(៦)
- ☐ ចាបក៏ជួយស្រែកដាស់ "ជីប! ជីប! ភ្ញាក់ឡើង! ភ្លឺហើយបូណា"។(៣)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ង**

**លេខ ៥ច**

# សិស្សសរសេរតួអក្សរនិងពាក្យបានស្អាតល្អ

**បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់**

សូមមើល មេរៀនទី៣៦ ទី៣៧ និងទី៣៨ (ទំព័រទី១១៧ ទី១២១ និងទី១២៨)

## ខ្លឹមសារ

មេរៀនទី៣៦ : អក្សរ "ហ" និងពាក្យ "ហាត់"

មេរៀនទី៣៧ : អក្សរ "ញ" និងពាក្យ "ញញឹម"

មេរៀនទី៣៨ : អក្សរ "ល" និងពាក្យ "លីលា"

## សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរអំពីអក្សរផ្ចង់ "**ហ ញ ល**" និងពាក្យ "**ហាត់ ញញឹម លីលា**" បានស្អាតល្អតាមទម្រង់អក្សរជ្រៀង និងការណែនាំពីរបៀបគូសបន្ទាត់ សរសេរលើក្ដារខៀន ក្ដារឆ្នួន និងក្នុងសៀវភៅសរសេររៀងខ្លួនបានត្រឹមត្រូវ។ *ឧទាហរណ៍*










☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ ដូចជាអក្សរ **ព ធ ភ ថ ...** ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មកគ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តរួចចម្លងចូលក្នុងសៀវភៅសរសេររៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ិត...

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់រៀន

**លេខ ៥៨**

# សិស្សសរសេរតាមអានអត្ថបទខ្លីក្នុងលំហាត់សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

**សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៤ ទី១១៨ ទី១២៨ និងទី១៣៥)**

## ខ្លឹមសារ

ការសរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣៖

| | |
|---|---|
| មេរៀនទី៣៦ : ទំព័រទី១១៦ | មេរៀនទី៣៩ : ទំព័រទី១២៨ |
| មេរៀនទី៣៧ : ទំព័រទី១២០ | មេរៀនទី៤១ : ទំព័រទី១៣៥ |

## សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យពិបាកមួយចំនួនដែលដកស្រង់ពីអត្ថបទសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬការកំណត់ដោយគ្រូដាក់លើក្ដារខៀន ហើយឱ្យសិស្ស អានពាក្យទាំងនោះម្ដងមួយពាក្យៗឱ្យឮៗ ឬឱ្យសិស្ស២ឬ៣នាក់ចង្អុល និងអានតាមដោយធ្វើអក្ខរាវិរុទ្ធ ផង។

*ឧទាហរណ៍* ពាក្យពិបាកស្រង់ពី អត្ថបទសរសេរតាមអាន "ការហាត់ប្រាណ" (ទំព័រទី១១៦)

ភ្លឺស្រាង សម្ងំ ស្កប់ស្កល់ ម៉ឺម្នា បណ្ដើរ ត្រសង។

បន្ទាប់មក គ្រូហៅពាក្យទាំងនោះឱ្យសិស្សសរសេរលើក្ដារឆ្នួនរួចកែលម្អ។

☑ គ្រូហៅអត្ថបទក្នុងមេរៀនដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឱ្យសិស្សសរសេរតាមអាន ហើយឆ្លើយសំណួរ និងលំហាត់តាមការកំណត់របស់គ្រូ(សំណួរ និងលំហាត់មានក្នុងតារាងខ្លឹមសារខាងលើ)។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៥ឆ

លេខ ៥ជ

# សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

## បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៧ ទី១២១ ទី១២៩ និងទី១៣៦ )

### ខ្លឹមសារ

ពាក្យ កន្សោមពាក្យឬល្បះ ក្នុងលំហាត់បំពេញល ល្បះ ឬលំហាត់តែងល្បះតាមរូបភាពក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣៖

| | | | |
|---|---|---|---|
| មេរៀនទី៣៦ : | ទំព័រទី១១៧ | មេរៀនទី៣៩ : | ទំព័រទី១២៩ |
| មេរៀនទី៣៧ : | ទំព័រទី១២១ | មេរៀនទី៤១ : | ទំព័រទី១៣៦ |

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សជ្រើសរើសពាក្យក្នុងប្រអប់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ទំព័រ១២៩ ទៅបំពេញល្បះ។ *ឧទាហរណ៍* ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ឈប់ | គ្រឿងញៀន | នៅ | សាក | ផ្ញើ |

- អ្នកប្រើប្រាស់.......................ធ្វើឱ្យបាត់បង់ការចងចាំ។
- សុភក្ត្រ..............................ដើរលេងទៀតហើយ។
- កូនមិនត្រូវចង់ដឹង ឬចង់.................គ្រឿងញៀននោះទេ។
- កូន និងមិត្តភក្តិត្រូវ............ឱ្យឆ្ងាយពីវា។

☑ គ្រូសរសេរពាក្យមួយចំនួនដែលបានដកស្រង់ពីមេរៀនណាមួយដាក់លើក្ដារខៀន មិនតាមលំដាប់ រួចឱ្យសិស្សរៀបជាល្បះពេញលេញ ដើម្បីជួយសិស្សឱ្យយល់ពី "**ល្បះ**" ដែលកើតចេញពីពាក្យច្រើនផ្គុំគ្នា មានន័យពេញលេញស្ដាប់បាន។ *ឧទាហរណ៍* ចូររៀបពាក្យខាងក្រោមទៅជាល្បះត្រឹមត្រូវ។ (មេរៀនទី៣៦ ទំព័រទី១១៥)

| | | | | |
|---|---|---|---|---|
| នាំមក | នូវ | ហាត់ប្រាណ | ការ | សុខភាព។ |

ចម្លើយ : ការហាត់ប្រាណ នាំមកនូវសុខភាព។

☑ គ្រូផ្ដល់បញ្ជីពាក្យសំខាន់ៗដល់សិស្សដែលស្រង់ចេញពីមេរៀន។ គ្រូត្រូវប្រាកដថា សិស្សដឹងពីន័យរបស់ពាក្យទាំងនោះ។ បន្ទាប់មក សិស្សត្រូវសរសេរជាល្បះពេញលេញ ដោយប្រើប្រាស់ពាក្យនេះ ហើយបន្ថែមល្បះមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងល្បះទី១។

*ឧទាហរណ៍* ពាក្យសំខាន់ "**ការហាត់ប្រាណ**" ។ ការហាត់ប្រាណ មានសារៈសំខាន់ចំពោះសុខភាព។ យើងហាត់ប្រាណដើម្បីសុខភាព។

**លេខ ៥៨**

**បន្ត...**

## សកម្មភាពគំរូ

**សម្គាល់ :** បើសិស្សពិបាកសរសេរល្បះបន្ថែមមួយផ្សេងទៀត ដែលមានទំនាក់ទំនងទៅនឹងល្បះទី១ គ្រូអាចឱ្យសិស្សសរសេរល្បះតែមួយល្បះ ទាក់ទងពាក្យសំខាន់ ឬប្រធានបទសំណេរក៏បាន។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៥ង**

**លេខ ៥ឈ**

# សិស្សសរសេរតែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍ តាមរយៈការសិក្សាលំនាំអត្ថបទគំរូ គម្រោងតែង សំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

**បំណិនសំណេរពាក់ព័ន្ធ : តែងសេចក្តី**

**សូមមើល មេរៀនទី៣៨ (ទំព័រទី១២២ និងទី១២៥)**

## ខ្លឹមសារ

តែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍ តាមរយៈការសិក្សាអត្ថបទគំរូ គម្រោងតែងនិងលំហាត់ក្នុងមេរៀនទី៣៨។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សអានអត្ថបទគំរូនៅទំព័រទី១២២ (អំពីតែងសេចក្តីគំរូ)។ គោលបំណងនៃលំហាត់នេះគឺចង់ឱ្យសិស្សយល់ពីប្រភេទព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការសរសេរតែងសេចក្តី។ បន្ទាប់មក គ្រូឱ្យសសិស្សឆ្លើយសំណួរ ៖

១-តើព្រឹត្តិការណ៍នេះកើតឡើងនៅពេលណា? កន្លែងណា ?

២-តើគ្រោះថ្នាក់ចរាចរណ៍នេះបង្កឡើងដោយសារអ្វី ?

៣-ក្រោយពេលកើតហេតុ តើមានអ្វីកើតឡើង ?

៤-ដើម្បីចៀសវាងគ្រោះថ្នាក់ចរាចរណ៍ តើប្អូនត្រូវធ្វើដូចម្តេច ?

☑ គ្រូសរសេរល្បះនីមួយៗពីគំរូតែងសេចក្តីនៅទំព័រទី១២២ជាចំរៀកក្រដាសតូចៗ។ គ្រូបិទចំរៀកក្រដាសនៃល្បះចម្រុះទាំងនោះ នៅលើក្តារខៀន រួចឱ្យសិស្សទាំងអស់គ្នាអាន។ បន្ទាប់មក គ្រូពន្យល់អំពីគម្រោងតែងសេចក្តីឱ្យត្រូវតាមសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់នៅទំព័រទី១២៤ រួចឱ្យសិស្សរៀបល្បះទាំងនោះទៅតាមផ្នែកនីមួយៗដូចខាងក្រោម៖

*ឧទាហរណ៍*

| សេចក្តីផ្តើម | តួសេចក្តី | សេចក្តីបញ្ចប់ |
|---|---|---|
| | | |

ដូច្នេះយើងគ្រប់គ្នា ត្រូវប្រុងប្រយ័ត្នជានិច្ច និងគោរព ច្បាប់ចរាចរណ៍ឱ្យបានភ្ជាប់ខ្លួននៅពេលធ្វើដំណើរ។

បច្ចុប្បន្ន អ្នកធ្វើដំណើរតាមផ្លូវសាធារណៈមួយចំនួន មិនគោរពច្បាប់ចរាចរណ៍ ដោយបើកហួសល្បឿនកំណត់ ឬស្រវឹង។

កាលពីថ្ងៃអាទិត្យមុន មានគ្រោះថ្នាក់ចរាចរណ៍កើតឡើងនៅផ្លូវកោងក្បែរសាលារៀនមួយ។

☑ គ្រូរៀបចំសិស្សជាក្រុម។ ក្នុងមួយក្រុមមានគ្នាយ៉ាងតិច៦នាក់។ គ្រូដាក់ប្រធានបទឱ្យសិស្សសរសេរ រួចណែនាំសិស្សម្នាក់ៗក្នុងក្រុមនីមួយៗ ចាប់ផ្តើមសរសេរសេចក្តីផ្តើមមួយល្បះម្នាក់ៗរៀងខ្លួន។ បន្ទាប់មក សិស្សម្នាក់ៗឱ្យល្បះនោះទៅសិស្សបន្ទាប់អាន និងសរសេរបន្តទៅតួសេចក្តីមួយល្បះម្នាក់ៗ លើសន្លឹកក្រដាសបន្តពីសេចក្តីផ្តើម បន្តរហូតអស់ចំនួនល្បះក្នុងតួសេចក្តី ទើបបន្តឱ្យសិស្សសរសេរបញ្ចប់លើសន្លឹកក្រដាសតពីតួសេចក្តីពីម្នាក់ទៅម្នាក់ ដោយឱ្យសិស្សអាននិងសរសេរបញ្ចប់សេចក្តីមួយល្បះម្នាក់ៗទៀតរហូតអស់។

លេខ
៥ឈ

**បន្ត...**

## សកម្មភាពគំរូ

**សម្គាល់ :** **ក.** ចំនួនសិស្សក្នុងក្រុមស្មើនឹងចំនួនល្បះដែលសិស្សត្រូវសរសេរ។ មានន័យថា សិស្សម្នាក់ៗត្រូវសរសេរល្បះ ដែលមានល្បះសេចក្តីផ្តើមមួយ ល្បះតួសេចក្តី១ ឬ២ល្បះ និងសេចក្តីបញ្ចប់ម្នាក់មួយល្បះ រហូតចប់ និងអស់ចំនួនសិស្សក្នុងក្រុម។

**ខ.** គ្រូរំឭកសិស្សឱ្យប្រើប្រាស់ពាក្យភ្ជាប់ ដើម្បីធ្វើឱ្យល្បះមានភាពរលូនពីមួយទៅមួយ។ ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួនមានបង្ហាញជូនខាងក្រោម :

*ឧទាហរណ៍* ប្រធានបទគំរូ "ទីកន្លែងដែលខ្ញុំចូលចិត្ត"។

***ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួនសម្រាប់ជួយសិស្សក្នុងការសរសេរតែងសេចក្តី៖***

☑ គ្រូឱ្យសិស្សបំពេញតារាងខាងក្រោម ដោយប្រើព័ត៌មានដែលត្រូវការពណ៌នាអំពីព្រឹត្តិការណ៍ "គ្រោះថ្នាក់ចរាចរណ៍" មួយ។

| | |
|---|---|
| ពេលវេលា | ក្រោយពី ពីមុន រហូតដល់ ជាទីបំផុត ពេល ខណៈដែល |
| ហេតុ និង ផល | ដោយសារ ដូចនេះ ដើម្បី ហេតុនេះ ពីព្រោះ មកពី ទើប ដូច្នោះ នោះ |
| ការបន្ថែម | ម្យ៉ាងទៀត ហើយ ហើយនឹង ព្រមទាំង លើសពីនេះទៀត យ៉ាងណាមិញ |
| សេចក្តីសន្និដ្ឋាន | ជាលទ្ធផល ដូចនេះ ហេតុនេះ អាស្រ័យហេតុនេះ ដូច្នោះ |
| ការផ្លាស់ប្តូរ | ក៏ប៉ុន្តែ ទោះបីជា យ៉ាងណាក៏ដោយ លុះត្រាតែ |
| ការប្រៀបធៀប | ដូចជា ប្រហែល ប្រហាក់ប្រហែល ចំណែកឯ ខណៈដែល ដរាបណា |
| លក្ខខណ្ឌ | ប្រសិនបើ លើកលែងតែ ក្នុងករណី លុះត្រាតែ |
| ទីកន្លែង | ទីណាដែល កន្លែងដែល |

ដូចបង្ហាញក្នុងទំព័រទី១២២ធ្វើជាកិច្ចការមុនសំណេរ ដើម្បីជួយពួកគេឱ្យចេះរៀបចំព័ត៌មានផ្អែកតាមសំណួរ នៅក្នុងតារាង "ប្រភេទព័ត៌មាន" ខាងឆ្វេង ចម្លើយនៅក្នុងតារាង "ព័ត៌មានជាក់លាក់" ខាងស្តាំ។

*ឧទាហរណ៍* លំហាត់មុនសំណេរ សម្រាប់សរសេរតែងសេចក្តីពណ៌នា អំពីព្រឹត្តិការណ៍នោះ។

| សេចក្តីផ្តើម | |
|---|---|
| **ប្រភេទព័ត៌មាន** | **ព័ត៌មានជាក់លាក់** |
| តើព្រឹត្តិការណ៍នោះកើតឡើង<br>♦ នៅពេលណា?<br>♦ កន្លែងណា?<br>♦ មានព្រឹត្តិការណ៍អ្វីខ្លះ? | |

លេខ ៥ឈ

បន្ត...

## សកម្មភាពគំរូ

| តួសេចក្ដី | |
|---|---|
| **ប្រភេទព័ត៌មាន** | **ព័ត៌មានជាក់លាក់** |
| សកម្មភាព<br>♦ មុនពេលកើតហេតុ<br>♦ ព្រឹត្តិការណ៍ចាប់ផ្ដើមកើតឡើង<br>♦ ព្រឹត្តិការណ៍កំពុងកើត<br>♦ ក្រោយពេលកើតហេតុ<br>♦ ការខូចខាត<br>♦ សកម្មភាពអ្នកទៅមើលហេតុការណ៍<br>♦ សកម្មភាពរបស់កម្លាំងមានសមត្ថភាពជួយអន្តរាគមន៍ | |
| **សេចក្ដីបញ្ចប់** | |
| ចំណាប់អារម្មណ៍ចំពោះគ្រោះថ្នាក់ចរាចរណ៍។ | |

បន្ទាប់ពីសិស្សបានឆ្លើយសំណួរទាំងនេះរួចហើយ ពួកគេគួរចាប់ផ្ដើមសរសេរតែងសេចក្ដីឱ្យចេញជាទម្រង់ល្បះ និងកថាខណ្ឌពេញលេញ (តារាងខាងស្ដាំជាចម្លើយខ្លឹមសារតែង)។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់រៀន




**ដំណាក់កាលទី ៥ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

តេស្តដំណាក់កាលទី៥

នៃឧបសម្ព័ន្ធ ២ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៧១ ដល់ ១៧៤

# ដំណាក់កាលទី ៦ : មេរៀនទី៤២ ដល់ទី៥២(២៣)

## (ទំព័រទី១៣៨ ដល់ទី១៦៨)

*១. មេរៀនទី៤២ : សញ្ញាសួរ " ? "*

*២. មេរៀនទី៤៣ : សិប្បកម្មថ្មកែវ*

*៣. មេរៀនទី៤៤ : ដំណាំដំឡូងមី*

*៤. មេរៀនទី៤៥ : ការពណ៌នាពីទីកន្លែង*

*៥. មេរៀនទី៤៦ : សុជីវធម៌តាមទីសាធារណៈ*

*៧. មេរៀនទី៤៧ : មូសិកទន្ត ឬធ្មេញកណ្ដុរ*

*៨. មេរៀនទី៤៨ : បកស្រាយភ្លើង និងស្លាកសញ្ញាចរាចរណ៍*

*៩. មេរៀនទី៤៩ : ស្លាកសញ្ញាសុវត្ថិភាពនានា*

*១០. មេរៀនទី៥០ : សមិទ្ធផលថ្មីៗ*

*១១. មេរៀនទី៥១ : រឿងទឹកចិត្តប៉ូលីស*

*១២. មេរៀនទី៥២ : ត្រីសព្ទ " ៍ "*

*( ៦៧ម៉ោងប្រហែល៥.១ សប្ដាហ៍)*

**កំណត់សម្គាល់ :** **(២៣)** ចំពោះមេរៀនទី៤៤ សមត្ថភាពស្ដាប់មានចំនួន៥ម៉ោងសិក្សា និងមេរៀនទី៤៨ សមត្ថភាពនិយាយមានចំនួន៣ម៉ោងសិក្សា។ មេរៀនទាំងនេះមិនទាក់ទងនឹងស្ដង់ដាអំណានទេ។ គ្រូត្រូវបង្រៀនតាមធម្មតា។

លេខ ៦ក

# សិស្សប្រើសញ្ញាសួរនៅក្នុងល្បះសំណួរបានត្រឹមត្រូវតាមនិយមន័យដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនពាក់ព័ន្ធ : វេយ្យាករណ៍

សូមមើល មេរៀនទី៤២ (ទំព័រទី១៣៨ និងទី១៣៩ )

### ខ្លឹមសារ

- សញ្ញាសួរ " ? "
- និយមន័យសញ្ញាសួរ : សញ្ញាសួរសំដៅលើល្បះណាមួយដែលមានបំណងរកព័ត៌មាន ហើយប្រើពាក្យដូចជា តើ អ្វី នរណា ឯណា ប៉ុន្មាន ឬទេ ដូចម្ដេច ហេតុអ្វី កន្លែងណា។ល។

### សកម្មភាពគំរូ

☑ គ្រូបង្ហាញល្បះសំណួរ និងល្បះប្រាប់ព័ត៌មានចម្រុះគ្នាមួយចំនួនដល់សិស្ស។ សិស្សត្រូវអានល្បះនីមួយៗ រួចដាក់សញ្ញា "?" នៅខាងចុងល្បះណាដែលជាល្បះសំណួរ ហើយដាក់សញ្ញា "។" នៅខាងចុងល្បះណាដែលជាល្បះប្រាប់ព័ត៌មានដើម្បីបញ្ចប់ល្បះឱ្យបានសមស្រប។

- យើងខិតខំរៀនទាន់ខ្លួននៅក្មេង ...
- តើគ្រឿងស្រវឹងធ្វើឱ្យយើងបាត់បង់ស្មារតីមែនឬទេ ...
- តើសព្វថ្ងៃអ្នករៀននៅឯណា ...
- គ្រូកំពុងបង្រៀនសិស្សក្នុងថ្នាក់ ...

☑ គ្រូផ្ដល់កថាខណ្ឌមួយដែលមិនមានសញ្ញាសួរ ឬសញ្ញាខណ្ឌនៅទំព័រ១៣៩ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣។ សិស្សត្រូវដាក់សញ្ញា " ? " និង សញ្ញា "។" ក្នុងកថាខណ្ឌនោះឱ្យបានត្រឹមត្រូវ។

ម្យ៉ាងទៀត គ្រូអាចតែងកថាខណ្ឌមួយដោយខ្លួនឯងនៅលើក្ដារខៀនដោយមិនមានដាក់សញ្ញាទាំងនេះ ហើយឱ្យសិស្សបំពេញសញ្ញា "។" និងសញ្ញា "?" ក្នុងទីតាំងល្បះឱ្យបានត្រឹមត្រូវ។

☑ ការប្ដូរល្បះធម្មតា ទៅជាល្បះសំណួរ។ គ្រូសរសេរល្បះធម្មតាមួយចំនួននៅលើក្ដារខៀន ហើយសរសេរសំណួរមួយឬច្រើននៅពីក្រោយល្បះនោះ។ បន្ទាប់មក សិស្សត្រូវប្ដូរល្បះទាំងនោះទៅជាល្បះសំណួរ ដូចមានក្នុងឧទាហរណ៍ខាងក្រោម ដោយមានដាក់សញ្ញាសួរ "?" ផងដែរ។ ក្រៅពីនេះ សិស្សក៏អាចបង្កើតសំណួរផ្សេងៗបានដែរ។

*ឧទាហរណ៍* គាត់រស់នៅក្នុងភូមិក្បែរនេះ។ (តើ ....ឯណា ) ⟶ តើគាត់រស់នៅឯណា ?

- គាត់នឹងត្រឡប់មកវិញឆាប់ៗ។ (តើ ....ពេលណា ) ⟶ ............................
- គាត់ក្រណាស់។ (តើ ....ឬទេ) ⟶ .....................................
- គាត់កំពុងអានសៀវភៅ។ (តើ ....អ្វី ) ⟶ ......................................

☑ គ្រូឱ្យសិស្សតែងសំណួរមួយឬច្រើនអំពីភូមិរបស់ពួកគេដោយប្រើប្រាស់សញ្ញា "?"

## លេខ ៦ក

## បន្ត...

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៦ក**

# លេខ ៦២

# សិស្សកំណត់សូរដើម និងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យដែលគ្រូអាន និងសរសេរ

*ឧទាហរណ៍* កែវ = ក+ ែ + វ

- "ក" សូរដើម "**អែ** និង **វ**" សូរបន្ទាប់

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១ (ទំព័រទី១៤០ ទី១៤៨ ទី១៥៦ ទី១៦០ និងទី១៦៤)**

## ខ្លឹមសារ

- ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១ ដូចជា :
  គេង ក្រោក ចេញ ញ៉ាំ ប្រើ ប្រាប់ រៀន អូត ដឹក ស៊ី ...។
- ពាក្យថ្មីទាំងឡាយណា ដែលសិស្សមិនទាន់ចេះ។

## សកម្មភាពគំរូ

☑ គ្រូបង្ហាញដុំ "**ថ្ម**" ដល់សិស្សរួចសួរថា តើពាក្យថ្មមាន សូរដើមអ្វី? **ចម្លើយ :** សូរដើមគឺ "**ថ្ម**"។ បន្ទាប់មក គ្រូសួរសិស្សបន្តតើពាក្យ**ថ្ម** មានសូរបន្ទាប់អ្វី? **ចម្លើយ:** សូរបន្ទាប់គឺ "**អ**"។ បន្ទាប់មក គ្រូឱ្យសិស្សរកសូរដើមរបស់ពាក្យផ្សេងទៀត ដូចជាពាក្យ ថ្មី ថ្មើរ... និងសូរបន្ទាប់។ (ការស្គាល់សូរ)

☑ គ្រូបង្កើតល្បែងសិក្សាដោយឱ្យសិស្សកំណត់សូរដើមរបស់ពាក្យ ដែលចាប់ផ្ដើមពីសិស្ស ដំបូង ឬមុនគេហើយបន្តរហូតដល់សិស្សចុងក្រោយ។ *ឧទាហរណ៍* សិស្សដំបូងថាពាក្យ "**ដើរ**" បន្ទាប់មក សិស្សដែលអង្គុយបន្ទាប់ត្រូវឆ្លើយសូរដើមរបស់ពាក្យនោះគឺ "**ដ**"។ បន្ទាប់មកសិស្សម្នាក់ទៀតរកពាក្យផ្សេង ហើយសិស្សដែលអង្គុយក្បែរត្រូវរកសូរដើមរបស់ពាក្យនោះ។ គ្រូអាចបន្តធ្វើល្បែងសិក្សារបៀបនេះជាមួយសិស្សផ្សេងទៀតឱ្យបានច្រើនតាមដែលអាចធ្វើបាន។ (ការស្គាល់សូរ)

☑ គ្រូឱ្យសិស្សកំណត់សូរដើម និងសូរបន្ទាប់សម្រាប់ពាក្យដែលគ្រូសរសេរនៅលើក្ដារខៀន។
*ឧទាហរណ៍* ក្រោយពីសរសេរពាក្យ "**គ្រា**" សិស្សត្រូវកំណត់រកសូរដើម និងសូរបន្ទាប់។

គ្រា = **គ្រ** + **អា**

- សូរដើម "**គ្រ**" សូរបន្ទាប់ "**អា**" (ការស្គាល់តួអក្សរនិងសូរ)

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣




ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៦២

លេខ
៦គ

# សិស្សប្រើមូសិកទន្តសម្រាប់ដាក់លើព្យញ្ជនៈពួក អ៊ ៖ “ង ញ ម យ រ វ” ឱ្យទៅជាសូរព្យញ្ជនៈពួក អ “ង៉ ញ៉ ម៉ យ៉ រ៉ វ៉”។ លើសពីនេះទៀតសិស្សអាចប្រើមូសិកទន្ត ជាមួយព្យញ្ជនៈ ប ដើម្បីទៅជាព្យញ្ជនៈ “ប៉”

បំណិនពាក់ព័ន្ធ : វេយ្យាករណ៍

សូមមើល មេរៀនទី៤៧ (ទំព័រទី១៥២)

## ខ្លឹមសារ

- សញ្ញាមូសិកទន្ត “៉”
- និយមន័យរបស់មូសិកទន្តជាសញ្ញាសម្រាប់ដាក់លើ៖
- ព្យញ្ជនៈពួកអ៊ “ង ញ ម យ រ វ” ទៅជាព្យញ្ជនៈពួកអ “ង៉ ញ៉ ម៉ យ៉ រ៉ វ៉”

**សម្គាល់ :** មូសិកទន្តអាចប្រើជាមួយព្យញ្ជនៈ “ប” ដើម្បីឱ្យបានជាព្យញ្ជនៈ “ប៉” ។ មូសិកទន្ត ឬធ្មេញកណ្ដុរប្ដូរជាបុកជើង “ុ” វិញកាលណាព្យញ្ជនៈ “ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉” ប្រើជាមួយស្រះ “ិ ី ឹ ឺ ើ ាំ”។ *ឧទាហរណ៍* ញុាំ មុាំ ចំប៊ី...។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សអានអត្ថបទខ្លីមួយក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ទំព័រទី១៥៣ ដែលមានពាក្យជាច្រើនប្រើប្រាស់មូសិកទន្ត (៉)ឬបុកជើង (ុ) ហើយឱ្យពសិស្សស្រង់ពាក្យទាំងនោះដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន។

☑ គ្រូឱ្យបញ្ចីពាក្យមួយចំនួន (ដូចក្នុងទំព័រទី១៥៣) ដែលប្រើមូសិកទន្ត (៉)ឬបុកជើង (ុ) ហើយឱ្យសិស្សសរសេរឱ្យបានត្រឹមត្រូវឡើងវិញដោយប្រើវណ្ណយុត្តិទាំងនោះ។

*ឧទាហរណ៍* (១) ងឹកងក់ ⟶ ង៉ឹកង៉ក់ (២) ចាបី ⟶ ចាប៉ី

☑ គ្រូឱ្យសិស្សធ្វើការជាដៃគូ ដើម្បីស្វែងរកពាក្យដែលប្រើមូសិកទន្ត (៉) ឬបុកជើង (ុ) តាមការកំណត់របស់គ្រូ ហើយសរសេរដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន។ សិស្សអាចអានអត្ថបទក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬអត្ថបទអំណានផ្សេងៗទៀតដើម្បីរកពាក្យទាំងនោះ។ គ្រូផ្ដល់ពេលឱ្យសិស្សប្រហែល១០នាទីសម្រាប់ធ្វើកិច្ចការនេះ។ ដៃគូណាដែលរកពាក្យបានច្រើនជាងគេគឺជាអ្នកឈ្នះក្នុងល្បែងសិក្សានេះ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ២១


ល្បែងទី ២២


ល្បែងទី ២៣




ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៦គ

## លេខ ៦ឃ

# សិស្សប្រើត្រីសព្ទ ឬសញ្ញាសក់ក "៊"សម្រាប់ដាក់លើព្យញ្ជនៈពួក អ ៖ "ប ស ហ អ" ឱ្យទៅជាសូរព្យញ្ជនៈពួក អ៊ ៖ "ប៊ ស៊ ហ៊ អ៊"

បំណិនពាក់ព័ន្ធ : វេយ្យាករណ៍

សូមមើល មេរៀនទី៥២ (ទំព័រទី១៦៨ និងទី១៦៩)

## ខ្លឹមសារ

- ត្រីសព្ទ ឬសញ្ញាសក់ ក "៊"
- និយមន័យរបស់ត្រីសព្ទ ឬសញ្ញាសក់ក "៊" : ប្រើសម្រាប់ដាក់លើព្យញ្ជនៈពួក **អ** ៤ តួ "ប ស ហ អ" ឱ្យទៅជាសូរព្យញ្ជនៈពួក អ៊ "**ប៊ ស៊ ហ៊ អ៊**"។

**សម្គាល់ :** ១. ព្យញ្ជនៈពួក អ៊ "**ប៊ ស៊ ហ៊ អ៊**" កាលណាប្រើជាមួយស្រៈ "ិ ី ឹ ឺ ើ ាំ" ប្តូរជាបុកជើង "ុ" វិញ ។
២. លើកលែងពាក្យកម្ចីបរទេសដូចជា ប៊ិក ប៊ីចេង ប៉ាំ ប៊ីយែរ ប៊ិះ ប៊ីដុង ប៊ិហ្វតិក។ល។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សអានអត្ថបទនៅទំព័រទី១៦៩ រកមើលពាក្យដែលប្រើសញ្ញាត្រីសព្ទ "៊" ឬបុកជើង "ុ" រួចឱ្យសិស្សសរសេរពាក្យទាំងនោះដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន។

☑ គ្រូឱ្យសិស្សពិនិត្យរូបភាពដូចមានក្នុងទំព័រទី១៦៩ រួចឱ្យសិស្សសរសេរពាក្យដែលមានប្រើត្រីសព្ទ "៊" តាមរូបភាពទាំងនេះឱ្យបានត្រឹមត្រូវ


ប៊ិក


ស.........


ទ្រ............


ហ...........

☑ គ្រូឱ្យសិស្សធ្វើការជាដៃគូ ហើយឱ្យសិស្សរកពាក្យដែលមានប្រើត្រីសព្ទឱ្យបានច្រើនតាមដែលអាចធ្វើបានក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ រួចសរសេរពាក្យទាំងនោះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ ដៃគូណាដែលរកពាក្យបានច្រើនជាងគេក្នុងរយៈពេល១០នាទីដៃគូនោះជាអ្នកឈ្នះ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**


ល្បែងទី ២១


ល្បែងទី ២២


ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៦ឃ

លេខ
៦ង

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ ទេវចនសព្ទ និងសទិសសព្ទ ដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬកំណត់ដោយគ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ**

សូមមើល មេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១ (ទំព័រទី១៤០ ទី១៤៨ ទី១៥៦ ទី១៦០ ទី១៦៤)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១ដូចជា ៖

ពន្យល់ពាក្យ

មេរៀនទី៤៣

- សក្ការៈ (ន.) : ការធ្វើគោរព សេចក្តីគោរព។
- សិប្បកម្ម (ន.) : ការជាងផ្សេងៗ។
- អារម្មណ៍ (ន.) : គ្រឿងតោងរបស់ចិត្ត គំនិត ការដឹង។
- អនុស្សាវរីយ៍ (ន.) : ការដែលគួររលឹកនឹកឃើញ។

មេរៀនទី៤៦

- ទីសាធារណៈ (ន.) : កន្លែងទូទៅ កន្លែងប្រើបានទាំងអស់គ្នា។
- សុជីវធម៌ (ន.) : ការរស់នៅដោយល្អ។
- ពិការ (គុ.) : ដែលខូចអវយវៈណាមួយ ប្រើការមិនកើតដូចជា បាក់ដៃ បាក់ជើង។

មេរៀនទី៤៩

- សញ្ញា (ន.) : ការសម្គាល់ ការចំណាំ។
- សុវត្ថិភាព (ន.) : ការប្រកបដោយសេចក្តីសុខ។
- ព័ត៌មាន (ន.) : ព្រឹត្តិការណ៍ ដំណឹងក្នុងបច្ចុប្បន្ន។
- ការដ្ឋាន (ន.) : កន្លែងធ្វើការងារ ទីធ្វើការងារ។
- ប្រព័ន្ធ (ន.) : បណ្តាញប្រទាក់គ្នា។

មេរៀនទី៥០

- សមិទ្ធផល (ន.) : ផលដែលសម្រេចបាន។
- ស្ពានអាកាស (ន.) : ស្ពានដែលគេសង់រំលងលើផ្លូវដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍។
- អគ្គិសនី (ន.) : ភ្លើងចង្កៀង ភ្លើងគោម ភ្លើងអេឡិចត្រូនិច។

មេរៀនទី៥១

- ភ្លើងសញ្ញាចរាចរណ៍ (ន.) : ភ្លើងសម្រាប់បញ្ជាការធ្វើដំណើរទៅមកដែលមានបីព៌ណដើម្បីសម្រួលក្នុងធ្វើដំណើរកុំឱ្យកកស្ទះ ឬមានគ្រោះថ្នាក់។ (ពណ៌បៃតង : បញ្ជាឱ្យទៅ ពណ៌ក្រហម : បញ្ជាឱ្យឈប់ ពណ៌លឿង : បញ្ជាឱ្យប្រុងប្រយ័ត្ន)
- ថ្មើរជើង (ន.) : ការធ្វើដំណើរដោយដើរ។
- បារម្ភ (ន.) : ដំណើរនឹក ព្រួយជាមុន។
- មហាវិថី (ន.) : ផ្លូវធំៗនៅក្នុងរាជធានី។

លេខ ៦ង

**បន្ត...**

## ខ្លឹមសារ

**បដិសព្ទ**

| | | | | | | |
|---|---|---|---|---|---|---|
| មេរៀនទី៤៣ : | ភ្លឺរលោង | ≠ | ស្រអាប់ | សរសើរ | ≠ | បង្អាប់ |
| មេរៀនទី៤៦ : | ទ្រុឌទ្រោម | ≠ | មាំមួន | រាក់ទាក់ | ≠ | ព្រងើយ |
| មេរៀនទី៤៩ : | ប្រយ័ត្ន | ≠ | ប្រហែស | សុវត្ថិភាព | ≠ | គ្រោះថ្នាក់ |
| មេរៀនទី៥០ : | រាយ | ≠ | ផ្តុំ | សន្តិភាព | ≠ | សង្គ្រាម |
| មេរៀនទី៥១ : | ញញឹម | ≠ | ក្រៀមក្រំ | អរគុណ | ≠ | រមិលគុណ អគុណ |

**វេវចនសព្ទ**

មេរៀនទី៤៣ : វេវចនសព្ទនឹងពាក្យ "**ធន ប្រជាជន**"

- **ធន** ធនធាន ទ្រព្យ សម្បត្តិ ទុន
- **ប្រជាជន** ប្រជាពលរដ្ឋ ប្រជារាស្ត្រ

មេរៀនទី៤៦ : វេវចនសព្ទនឹងពាក្យ "ដើរ" **ដើរ** យាត្រា យាង និមន្ត ចរ

មេរៀនទី៤៩ : វេវចនសព្ទនឹងពាក្យ "ផ្តល់ និយាយ"

- **ផ្តល់** ជូន ឱ្យ ប្រគេន ថ្វាយ
- **និយាយ** ប្រសាសន៍ ដីកា ថា ព្រះបន្ទូល

មេរៀនទី៥០ : វេវចនសព្ទនឹងពាក្យ "**វារី**" **វារី** គង្គា ទឹក

មេរៀនទី៥១ : វេវចនសព្ទនឹងពាក្យ "ទោចក្រយាន ត្រីចក្រយាន"

- **ទោចក្រយាន** កង់ ។
- **ត្រីចក្រយាន** ស៊ីក្លូ។

**សទិសសព្ទ**

មេរៀនទី៤៣ : សទិសសព្ទនឹងពាក្យ "កេរ្តិ៍"

- កេរ្តិ៍ (ន.) : សេចក្តីសរសើរ ការល្បីលេចឮ ខ្ចរខ្ចាយ។
- កេរ (ន.) : ទ្រព្យ ដំណែល ជាសម្បត្តិរបស់ដូនតា ឬមាតាបិតាបន្សល់ទុកឱ្យ។

មេរៀនទី៤៦ : សទិសសព្ទនឹងពាក្យ "រដ្ឋ"

- រដ្ឋ (ន.) : ដែន បុរី សីមា ប្រទេស។
- រត្ន ឬរតន៍ (ន.) : កែវ ត្បូង ពេជ្រ គ្រប់ប្រភេទ។
- រាត់ (កិ.) :ទាញកន្ត្រាក់ដោយបង្ខំ។ ឧ.ទាញរាត់ផ្តាច់ វាយរាត់។

មេរៀនទី៤៩ : សទិសសព្ទនឹងពាក្យ " គ "

- គ (ន.) : មនុស្សឥតសម្តី ឈ្មោះរុក្ខជាតិម្យ៉ាង។ឧ.មនុស្សគ ដើមគ។
- គរ (កិ.) : ធ្វើជាគំនរ។ ឧ.គរចំបើង។

មេរៀនទី៥០ : សទិសសព្ទនឹងពាក្យ "ដា"

- ដា (ន.) : បន្ទះថ្មធំរាបដូចក្តារបែន ផ្ទាំងថ្មដា។
- ដារ (ន.) : ឈ្មោះបុណ្យតូចម្យ៉ាងក្នុងពុទ្ធសាសនា បុណ្យដារ។

មេរៀនទី៥១ : សទិសសព្ទនឹងពាក្យ " គ្រា "

លេខ
៦ង

**ចន្ទ...**

# ខ្លឹមសារ

- ◆ គ្រា (ន.) : កាល សម័យ គ្រាកន្លង គ្រានោះ។
- ◆ គ្រាហ៍ (កិ.) : ដំណើរអេង អបអង កៀកអង។ *ឧទាហរណ៍* គ្រាហ៍មនុស្សមានរបួស។

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យ របស់ពាក្យពិបាក នោះដោយគូសភ្ជាប់សញ្ញាព្រួញ។

*ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្តាំ ឱ្យត្រូវនឹងនិយមន័យនៃពាក្យនីមួយៗ។

| ពាក្យពិបាក | និយមន័យ |
|---|---|
| ទីសាធារណៈ | ◆ កន្លែងឯកជនសម្រាប់ប្រើបានខ្លះ។<br>◆ កន្លែងសារធារណៈ កន្លែងប្រើបានទាំងអស់គ្នា។<br>◆ កន្លែងដែលមិនមែនទូទៅ កន្លែងប្រើបានខ្លះៗ។ |
| សុជីវធម៌ | ◆ ការរស់នៅដោយល្អ។<br>◆ ការប្រឹងប្រែងរៀនសូត្រ។<br>◆ ការគោរពច្បាប់។ |
| ពិការ | ◆ ដែលគ្មានអវយវៈ។<br>◆ ដែលខូចអវយវៈណាមួយប្រើការមិនកើត។<br>◆ ដែលខូចសមត្ថភាពជំនាញ។ |

☑ គ្រូជ្រើសរើសពាក្យណាមួយ ហើយសរសេរនៅលើក្តារខៀន។ សិស្សត្រូវនឹករកពាក្យផ្សេងទៀតដែលអាចរកឃើញ ហើយទាក់ទងជាមួយពាក្យនោះ។ ពាក្យនោះមិនចាំបាច់មាននិយមន័យដូចគ្នាទេ តែមានទំនាក់ទំនងជាមួយគ្នាតាម ដែលគ្រូបានកំណត់។ លំហាត់នេះជួយពង្រឹង**ការពន្យល់ពាក្យ** ដោយមានការបង្ហាញគំនិតពាក់ពន្ធ័ផ្សេងៗ។

*ឧទាហរណ៍* គ្រូសរសេរពាក្យ "**ថ្មកែវ**" នៅលើក្តារខៀន រួចឱ្យសិស្សរកពាក្យដទៃដែលមានទំនាក់ទំនងនឹងពាក្យនេះ ប៉ុន្តែមិនមែនមានន័យថា រកពាក្យដែលន័យដូចនោះទេ។ បន្ទាប់មក ឱ្យសិស្សរកពាក្យ "សមិទ្ធផល" ដោយខ្លួនឯង។






**លេខ ៦ង**

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូបង្កើតបណ្ណពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដែលមានន័យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| រាយ | សង្គ្រាម | ទ្រុឌទ្រោម | រាក់ទាក់ | ឮរលោង | សរសើរ | ល្បីល្បាញ | ប្រហែស | សុវត្ថិភាព |

♦ បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូចែកសិស្សជាក្រុមៗដែលមួយក្រុមមានគ្នា ៤ ទៅ៥នាក់។ គ្រូសរសេរពាក្យមួយ នៅលើក្ដារខៀន ហើយឱ្យសិស្សរកវេវចនសព្ទទាក់ទងនឹងពាក្យនោះឱ្យបានច្រើនតាមដែលអាចរកបាន។ គ្រូផ្ដល់ពេលប្រហែលបីឬបួននាទីប៉ុណ្ណោះសម្រាប់ស្វែងរក ហើយក្រុមណាដែលរកពាក្យវេវចនសព្ទបានច្រើនជាងគេគឺជាក្រុមឈ្នះ។ គ្រូអាចធ្វើដូចនេះសម្រាប់បដិសព្ទ ឬវេវចនសព្ទផ្សេងទៀតបាន។

☑ គ្រូគូសតារាង និងសរសេរពាក្យចម្រុះនៅលើក្ដារខៀន ហើយនៅក្នុងតារាងនេះ មានពាក្យចំនួនបីសម្រាប់ឱ្យសិស្សស្វែងរកវេវចនសព្ទ(ពាក្យន័យដូច)។ គ្រូណែនាំសិស្សរក**វេវចនសព្ទទី១**គូសជុំវិញពាក្យជារង្វង់ ហើយ**វេវចនសព្ទទី២**ឱ្យសិស្សគូសជុំវិញពាក្យនោះជាការេ និង**វេវចនសព្ទទី៣** គូសជុំវិញពាក្យនោះជាត្រីកោណ

វេវចនសព្ទទី១ :○ វេវចនសព្ទទី២ :□ វេវចនសព្ទទី៣ △ :

| | | | | |
|---|---|---|---|---|
| កាល | ល្បីល្បាញ | មហាវិថី | សម័យ | ជាង |
| អបអង | ទឹក | កៀកអង | ប្រហែល | ដំណើរអង |
| ថ្ម | អារម្មណ៍ | មាំមួន | ថ្មើរជើង | គង្គា |

**ចម្លើយ** វេវចនសព្ទទី១ កាល សម័យ វេវចនសព្ទទី២ អបអង កៀកអង ដំណើរអង

វេវចនសព្ទទី៣ ទឹក គង្គា

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៦ង**

លេខ ៦ថ

# សិស្សបកស្រាយន័យនៃល្បះអត្ថបទ និងមេសូត្រ នៅតាមមេរៀនដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ តាមរយៈលំហាត់ផ្សេងៗ។

*ឧទាហរណ៍* ឆ្លើយសំណួរយល់ដឹង បំពេញល្បះ លំហាត់ក្លូស្សៗលៗ។

## បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

សូមមើល មេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០និងទី៥១ (ទំព័រទី១៤០ ទី១៤៨ ទី១៥៦ ទី១៦០និងទី១៦៤)

### ខ្លឹមសារ

ល្បះអត្ថបទ និងមេសូត្រក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

មេរៀនទី៤៣ : សិប្បកម្មថ្មកែវ មេរៀនទី៤៦ : សុជីវធម៌តាមទីសាធារណៈ មេរៀនទី៤៩ : ផ្លាកសញ្ញាសុវត្ថិភាពនានា

មេរៀនទី៥០ : សមិទ្ធផលថ្មីៗ មេរៀនទី៥១ : រឿងទឹកចិត្តប៉ូលិស

### សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរក្នុងមេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១ :

**មេរៀនទី៤៣**

១. តើថ្មកែវមានប្រភពនៅឯណា?

២. តើថ្មកែវមានព័ណដូចម្ដេច?

៣. តើគេយកថ្មកែវមកធ្វើអ្វីខ្លះ?

៤. តើចម្លាក់ថ្មកែវមានសារៈសំខាន់ឬទេ? ពីព្រោះអ្វី?★

**មេរៀនទី៤៦**

១. តើកុមារត្រូវមានទម្លាប់ល្អនៅកន្លែងណាខ្លះ?

២. ពេលប្អូនដើរជិតស្ត្រីមានផ្ទៃពោះ គួរធ្វើដូចម្ដេច?

៣. ពេលប្អូនឃើញចាស់ជរា ឬពិការ តើអ្នកត្រូវធ្វើដូចម្ដេច?

៤. តើការប្រកាន់យកសុជីវធម៌ក្នុងខ្លួន នាំឱ្យប្អូនក្លាយជាមនុស្សបែបណា?

**មេរៀនទី៤៩**

១. តើផ្លាកសញ្ញាសុវត្ថិភាពនានាមានអ្វីខ្លះ?

២. តើផ្លាកសញ្ញាក្បាលខ្មោចមានន័យដូចម្ដេច?

៣. តើផ្លាកសញ្ញាសុវត្ថិភាពមានសារៈសំខាន់ដូចម្ដេចខ្លះ?

**មេរៀនទី៥០**

១. អ្នកកសាងស្ពានដៃថ្មីក្នុងអត្ថបទនេះជាជនជាតិអ្វី?

២. តើសមិទ្ធផលដែលគេបានកសាងមានអ្វីខ្លះ?

៣. ដើម្បីរួមចំណែកថែរក្សាការពារសមិទ្ធផលខាងលើ តើប្អូនត្រូវធ្វើដូចម្ដេច?

៤. តើប្អូនចង់ក្លាយខ្លួនជាអ្នកកសាងស្ពានដៃធំៗដូចខាងលើដែរឬទេ? ព្រោះអ្វី? ★

**មេរៀនទី៥១**

១. តើតារា និងស្រីពេជ្រ ធ្វើដំណើរទៅសាលារៀនដោយមធ្យោបាយអ្វី?

២. តើពួកគេឆ្លងផ្លូវត្រង់កន្លែងណា?

៣. តើភ្លើងសញ្ញាចរាចរណ៍ព័ណអ្វីដែលពួកគេត្រូវឈប់?

៤. តើប៉ូលិសចរាចរណ៍បានធ្វើអ្វីខ្លះ ដើម្បីជួយក្មេងទាំងពីរឆ្លងផ្លូវ?

**សម្គាល់ :** សំណួរដែលមានសញ្ញា ★ (ផ្កាយ) គឺជាសំណួរបន្ថែម ដើម្បីពង្រឹងបំណិនវិភាគ និងដោះស្រាយបញ្ហា។ រាល់ចម្លើយរបស់សិស្សឱ្យតែសមហេតុ ផល ទោះបីជាមិនមាននៅក្នុងអត្ថបទអំណានក៏ដោយ គ្រូត្រូវទទួលទាំងអស់។ ខាងក្រោមនេះគឺជាសំណួរបន្ថែមមួយចំនួនដែលគ្រូអាចពិភាក្សាជាមួយសិស្ស ដើម្បីជួយពួកគេរីកចម្រើនការ

លេខ ៦ច

**បន្ត...**

## សកម្មភាពគំរូ

យល់ដឹងបែបវិភាគលើអត្ថបទអំណានក្នុងមេរៀនទី៤៩ និងទី៥១។

- បើសិនមិនមានស្លាកសញ្ញាបម្រាមទេនោះ តើវាមានលទ្ធផលបែបណាចំពោះជីវិតរបស់អ្នក?(មេរៀនទី៤៩)
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីឱ្យមានសុវត្ថិភាពនៅតាមផ្លូវ? (មេរៀនទី៥១)

☑ សិស្សអាចបំពេញលំហាត់ cloze តាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទមកបំពេញបានត្រឹមត្រូវ។ (មេរៀនទី៥១ទំព័រទី១៦៤)

រៀងរាល់ថ្ងៃ តារា និងស្រីពេជ្រ...(១)ដំណើរទៅសាលារៀនដោយថ្មើរជើង។ ...(២)គេដើរលើចិញ្ចើមផ្លូវ ...(៣)ប្រកាន់ស្តាំជានិច្ច។ អ្នកទាំងពីរ...(៤)ដើរឆ្លងកាត់មហាវិថី...(៥)ទើបទៅដល់សាលា។ គេ...(៦)ដើរឆ្លងកាត់គំនូសពណ៌...(៧)ដែលមានភ្លើងសញ្ញាចរាចរណ៍។ នៅ...(៨)មានភ្លើងសញ្ញាពណ៌ក្រហមពួក...(៩)បានឈប់។

| | | | | | |
|---|---|---|---|---|---|
| **ចម្លើយ** | ១. ចេញ ធ្វើ | ២. ពួក ក្រុម | ៣. និង ហើយ រួច | ៤. បាន | ៥. នានា ផ្សេង |
| | ៦. តែងតែ រមែង | ៧. ស ផ្សេងៗ | ៨. ពេល គ្រា ឱកាស | ៩. ពួកគេ ពួកវា គាត់ | |

☑ គ្រូឱ្យសិស្សអានអត្ថបទណាមួយឡើងវិញ។ រួចឱ្យសិស្សសរសេរពាក្យដែលមិនទាន់ចេះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ បន្ទាប់មក គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យពាក្យមិនចេះនោះតាមទីសេចក្តី (**ទីសេចក្តីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ**)។ រួចសិស្សសរសេរនិយមន័យពាក្យដែលកំណត់តាមការវិភាគនេះ។

ប្រសិនបើសិស្សមិនអាចបកស្រាយនិយមន័យពាក្យណាមួយបានគេអាចសួរគ្រូក្នុងក្រុមធំបាន។ គ្រូគួរសរសេរពាក្យទាំងអស់នោះនៅលើក្តារខៀនឱ្យសិស្សដទៃទៀតមើល ដើម្បីផ្តល់យោបល់ ហើយគ្រូជួយកែលម្អ។ *ឧទាហរណ៍* ថ្មកែវជាធនធានធម្មជាតិមានសារៈសំខាន់ចំពោះប្រទេសកម្ពុជា។ ក្នុងល្បះនេះពាក្យ "ធនធានធម្មជាតិ" បញ្ជាក់ន័យឱ្យពាក្យ ថ្មកែវ។

☑ គ្រូឱ្យរៀបលំដាប់ព្រឹត្តិការណ៍ក្នុងរឿងតាមលំដាប់លំដោយ ក្រោយពីអានរឿងទឹកចិត្តប៉ូលិសក្នុងមេរៀនទី៥១ ទំព័រទី១៦៤។ គ្រូសរសេរព្រឹត្តិការណ៍សំខាន់ៗក្នុងរឿងមិនតាមលំដាប់លំដោយឱ្យសិស្សធ្វើការជាក្រុមឬបុគ្គលដើម្បីដាក់លេខខាងមុខព្រឹត្តិការណ៍នីមួយៗទៅតាមលំដាប់លំដោយបានកើតឡើងក្នុងរឿង។ សូមមើលឧទាហរណ៍ខាងក្រោមដែលដកស្រង់ពីមេរៀនទី៥១ ៖

*ឧទាហរណ៍* គ្រូណែនាំសិស្សឱ្យបង់លេខក្នុងប្រអប់ល្បះនីមួយៗតាមលំដាប់លំដោយព្រឹត្តិការណ៍។

- ☐ ល្ងាចថ្ងៃមួយពួកគេបានចេញពីសាលារៀនដើរទៅផ្ទះដូចសព្វមួយដង។ (២)
- ☐ រៀងរាល់ថ្ងៃតារា និងស្រីពេជ្រ ធ្វើដំណើរទៅសាលារៀនដោយថ្មើរជើង។ (១)
- ☐ ចៃដន្យពេលនោះភ្លើងស្តុបបានដាច់ កុមារទាំងពីរមិនហ៊ានឆ្លងផ្លូវព្រោះឡាន ម៉ូតូបើកលឿនៗបន្តគ្នាច្រើនពេក។(៤)
- ☐ គ្រានោះប៉ូលិសចរាចរណ៍ក៏មកដល់បានជួយដឹកដៃកុមារទាំងពីរឆ្លងផ្លូវ។ (៥)
- ☐ គេតែងដើរឆ្លងតាមគំនូសពណ៌ស ដែលមានភ្លើងសញ្ញាចរាចរណ៍។ (៣)
- ☐ អ្នកទាំងពីរត្រេកអរណាស់ រួចសំពះអរគុណ រួចសំពះអរគុណលោកប៉ូលិសនោះ។ (៦)

## លេខ ៦ថ

**បន្ត...**

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៦ថ**

លេខ ៦៨

# សិស្សសរសេរតួអក្សរនិងពាក្យបានស្អាតល្អ

## បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់

សូមមើល មេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ ទី៥១ (ទំព័រទី១៤៣ ទី១៥១ ទី១៥៩ ទី១៦៣ ទី១៦៧ )

### ខ្លឹមសារ

- ពិនិត្យមើលវិធីគូសបន្ទាត់សម្រាប់សរសេរអក្សរផ្ចង់ នៅទំព័រទី XIII។
- អនុវត្តការសរសេរអក្សរផ្ចង់ សម្រាប់អក្សរ និងពាក្យមួយចំនួនខាងក្រោម៖

មេរៀនទី៤៣ : អក្សរ "យ" និងពាក្យ "យូរយារ" (ទំព័រទី១៤៣)
មេរៀនទី៤៦ : អក្សរ "ណ" និងពាក្យ "ណាល" (ទំព័រទី១៥១)
មេរៀនទី៤៩ : អក្សរ "ស" និងពាក្យ "សរសេរ" (ទំព័រទី១៥៩)
មេរៀនទី៥០ : អក្សរ "ឈ" និងពាក្យ "ឈូសឈើ" (ទំព័រទី១៦៣)
មេរៀនទី៥១ : អក្សរ "យ" និងពាក្យ "យានយន្ត" (ទំព័រទី១៦៧)

### សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីអក្សរ "**ស ណ**" និងពាក្យ "**សរសើរ ណាល**" បានស្អាតល្អតាមទម្រង់អក្សរជ្រៀងនិងការណែនាំពីរបៀបគូសបន្ទាត់សរសេរលើក្ដារខៀន ក្ដារឆ្នួន និងក្នុងសៀវភៅសរសេររៀងខ្លួនបានត្រឹមត្រូវ។

*ឧទាហរណ៍*




☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ ដូចជាអក្សរ **យ ស ឈ ណ** ... ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មក គ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តខាងលើចម្លងចូលក្នុងសៀវភៅសរសេររៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ុត...

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

## លេខ ៦ជ សិស្សសរសេរតាមអានអត្ថបទខ្លី( ពាក្យរាយ និងពាក្យកាព្យ ) ក្នុងលំហាត់សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

### បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន

សូមមើល មេរៀនទី៤៣ ទី៤៤ ទី៤៦ ទី៤៩ ទី៥០ និងទី៥១
(ទំព័រទី១៤៣ ទី១៤៥ ទី១៥០ ទី១៥៩ ទី១៦២ និងទី១៦៧)

### ខ្លឹមសារ

សរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

| | | |
|---|---|---|
| មេរៀនទី៤៣ : ទំព័រទី ១៤៣ | មេរៀនទី៤៦ : ទំព័រទី ១៥០ | មេរៀនទី៥០ : ទំព័រទី ១៦២ |
| មេរៀនទី៤៤ : ទំព័រទី១៤៥ | មេរៀនទី៤៩ : ទំព័រទី ១៥៩ | មេរៀនទី៥១ : ទំព័រទី១៦៧ |

### សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យពិបាកមួយចំនួនដែលដកស្រង់ពីអត្ថបទ សៀវភៅអាន-សរសេរ ភាសាខ្មែរថ្នាក់ទី៣ ឬការកំណត់ដោយគ្រូដាក់លើក្ដារខៀន ហើយគ្រូអានពាក្យទាំងនោះម្ដងមួយៗ ពីរឬបីដងឱ្យសិស្សស្ដាប់។ បន្ទាប់មក សិស្សចង្អុលហើយអានពាក្យនីមួយៗតាមគ្រូ ព្រមទាំងអានតាមដោយធ្វើអក្ខរាវិរុទ្ធផង។ បន្ទាប់មក គ្រូអានពាក្យ នីមួយៗ ហើយឱ្យសិស្សសរសេរពាក្យទាំងនោះដាក់លើក្ដារឆ្នួន គ្រូត្រួតពិនិត្យអក្ខរាវិរុទ្ធ។

*ឧទាហរណ៍* ពាក្យពិបាក ស្រង់ពី អត្ថបទសរសេរតាមអាន "ចម្លាក់ថ្មកែវ" (ទំព័រទី១៤៣)

ខេត្តពោធិ៍សាត់ ធម្មជាតិ អនុស្សាវរីយ៍ សក្ការៈ

- បន្ទាប់មក គ្រូហៅពាក្យទាំងនោះឱ្យសិស្សសរសេរលើក្ដារឆ្នួនរួចកែលម្អ។

☑ គ្រូហៅអត្ថបទក្នុងមេរៀនដែលបានកំណត់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឱ្យសិស្សសរសេរតាមអាន ហើយឆ្លើយសំណួរ និងលំហាត់តាមការកំណត់របស់គ្រូ(សំណួរ និងលំហាត់មានក្នុងតារាងខ្លឹមសារខាងលើ)។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៦ជ

លេខ ៦ឈ

## សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

**បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ**

សូមមើល មេរៀនទី៤៣ ទី៤៦ ទី៤៩ ទី៥០ និងទី៥១
(ទំព័រទី១៤៥ ទី១៥០ ទី១៥១ ទី១៥៩ ដល់ទី១៦៣ និងទី១៦៧)

### ខ្លឹមសារ

ពាក្យ កន្សោមពាក្យឬល្បះ ក្នុងលំហាត់បំពេញល្បះ ឬលំហាត់តែងល្បះតាមរូបភាពក្នុង សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

មេរៀនទី៤៣ : ទំព័រទី ១៤៣
មេរៀនទី៤៦ : ទំព័រទី ១៥០ ទី១៥១
មេរៀនទី៥០ : ទំព័រទី ១៦៣
មេរៀនទី៥១ : ទំព័រទី ១៦៧

### សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សជ្រើសរើសពាក្យពីក្នុងប្រអប់ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ទំព័រទី១៥០ ទៅបំពេញល្បះទី១ ទី២ និងទី៣។

☑ គ្រូផ្ដល់ឱ្យសិស្សនូវបញ្ជីពាក្យ ដែលពាក្យក្នុងជួរនីមួយៗដាក់ចម្រុះគ្នាតាមបែបចៃដន្យ។ សិស្សអានពាក្យក្នុងលំដាប់ជួរនីមួយៗ ហើយបង្កើតល្បះដែលមានន័យ ដោយគូសរង្វង់ជុំវិញពាក្យទាំងនោះដើម្បីបង្កើតជាល្បះ។ បន្ទាប់មក សរសេរល្បះទាំងនោះនៅខាងក្រោមតារាង។ *ឧទាហរណ៍*

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ស្អែក | ល្ងាច | មួយ | ណា | ហើយ | តារា | និង | គេ | ស្រីពេជ្រ | បាន |
| ញុាំ | រៀន | ចេញ | ដល់ | ព្រឹក | ពី | សាលារៀន | ល្អ | ធំ | ដើរ |
| សាលារៀន | ទៅ | គេ | ផ្ទះ | ។ | | | | | |

ល្បះត្រឹមត្រូវ : **ល្ងាចមួយតារានិងស្រីពេជ្របានចេញពីសាលារៀនដើរទៅផ្ទះ។**

☑ គ្រូផ្ដល់ឃ្លាខ្លីៗចំនួន៣ដល់សិស្ស ហើយឱ្យពួកគេផ្សំឃ្លាទាំងនេះទៅជាល្បះមួយដោយប្រើប្រាស់ពាក្យភ្ជាប់ដើម្បីបង្ហាញអំពីហេតុ និងផល។ គ្រូនាំសិស្សធ្វើលំហាត់ប្រភេទនេះដើម្បីបង្កើតល្បះខ្លីផ្សេងៗទៀតឱ្យបានច្រើន។ ពាក្យភ្ជាប់ផ្សេងៗសម្រាប់បង្ហាញ ហេតុ និងផល មានក្នុងមេរៀនទី៣។

*ឧទាហរណ៍*

១. សិប្បកម្មថ្មកែវជាមុខរបរសំខាន់។
២. វាលើកកម្រិតជីវភាពប្រជាជនខេត្តពោធិ៍សាត់។
៣. ធ្វើឱ្យយើងមានគ្រឿងសក្ការៈច្រើនសម្រាប់គោរពនិងតាំងលម្អ។

ដូចនេះ ល្បះដែលអាចបង្កើតបាន រួមមានដូចខាងក្រោម ៖

លេខ
៦ឈ

## បន្ត...

## សកម្មភាពគំរូ

**១.** សិប្បកម្មថ្មកែវជាមុខរបរសំខាន់**ដោយសារ**វាលើកស្ទួយកម្រិតជីវភាពប្រជាជនខេត្តពោធិ៍សាត់ **ហើយ** ធ្វើឱ្យយើងមានគ្រឿងសក្ការៈច្រើនសម្រាប់គោរព និងតាំងលម្អ។

**២.** សិប្បកម្មថ្មកែវជាមុខរបរសំខាន់**ពីព្រោះ**វាលើកស្ទួយកម្រិតជីវភាពប្រជាជនខេត្តពោធិ៍សាត់ **ព្រមទាំង** ធ្វើឱ្យយើងមានគ្រឿងសក្ការៈច្រើនសម្រាប់គោរព និងតាំងលម្អ។

☑ គ្រូឱ្យបញ្ចើពាក្យសំខាន់ៗដល់សិស្សដែលស្រង់ចេញពីមេរៀន។ បន្ទាប់មក សិស្សត្រូវសរសេរជាល្បះពេញលេញ ដោយប្រើប្រាស់ពាក្យនេះ ហើយបន្ថែមល្បះមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងល្បះទី១។

*ឧទាហរណ៍* ពាក្យសំខាន់ **សុជីវធម៌**

សុជីវធម៌សំខាន់ណាស់ក្នុងសង្គមខ្មែរយើង។ នៅពេលប្រជាជនយល់ដឹងពីសុជីវធម៌ ពួកគេនឹងក្លាយជាពលរដ្ឋល្អ ចេះគួរសម។

**សម្គាល់** : បើសិស្សពិបាកធ្វើលំហាត់នេះ ពួកគេអាចបង្កើតតែមួយល្បះក៏បានដែរ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ


ល្បែងទី ២១


ល្បែងទី ២២


ល្បែងទី ២៣


ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់និងអនុវត្តក្នុងថ្នាក់

**លេខ ៦៧**

# សិស្សសរសេរតែងសេចក្ដីពណ៌នាអំពីទីកន្លែង ដោយប្រើលំនាំ អត្ថបទគំរូ គម្រោងតែង សំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣

## បំណិនសំណេរពាក់ព័ន្ធ : តែងសេចក្ដី

សូមមើល មេរៀនទី៤៥ (ទំព័រទី ១៤៦ និងទី១៤៧)

### ខ្លឹមសារ

តែងសេចក្ដីពណ៌នាអំពីទីកន្លែង ដោយប្រើប្រាស់គម្រោងតែង និងសំណួរក្នុងមេរៀនទី៤៥ ទំព័រទី១៤៦ និងទី១៤៧។

### សកម្មភាពគំរូ

☑ ក្រោយពីអានអត្ថបទគំរូរួច គ្រូឱ្យសិស្សឆ្លើយសំណួរនៅទំព័រទី១៤៧។ គោលបំណងនៃលំហាត់នេះគឺចង់ឱ្យសិស្សយល់ពីប្រភេទព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការសរសេរតែងសេចក្ដី។

សំណួរ

១. តើពួកគេបានទៅទស្សនាអ្វី? នៅពេលណា?
២. តើសារមន្ទីរជាតិស្ថិតនៅឯណា?
៣. តើសារមន្ទីរជាតិជាកន្លែងអ្វី? មានអ្វីខ្លះ?
៤. ហេតុអ្វីបានជាភ្ញៀវទេសចរចូលចិត្តមកទស្សនាសារមន្ទីរជាតិ?
៥. តើប្អូនចង់ទៅទស្សនាទីនោះឬទេ? ព្រោះអ្វី?

☑ គ្រូសរសេរល្បះនីមួយៗដែលដកស្រង់ចេញពីគំរូតែងសេចក្ដីនៅទំព័រទី១៤៦ ជាចំរៀកក្រដាស រួចបិទបណ្ណល្បះចម្រុះទាំងនោះនៅលើក្ដារខៀនឱ្យសិស្សទាំងអស់គ្នាអាន។ បន្ទាប់មកទៀត គ្រូពន្យល់អំពីគម្រោងតែងសេចក្ដីឱ្យត្រូវតាមសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់នៅទំព័រទី១៤៦ រួចឱ្យសិស្សរៀបល្បះទាំងនោះទៅតាមផ្នែកនីមួយៗតាមលំនាំខាងក្រោម ជាបន្តរហូតបានជាអត្ថបទមួយពេញលេញជាតែងសេចក្ដី។

| សេចក្ដីផ្ដើម | តួសេចក្ដី | សេចក្ដីបញ្ចប់ |
|---|---|---|
| | | |

ខ្ញុំសប្បាយចិត្តណាស់... ជនជាតិខ្មែរយើងក្នុងអតីតកាលផង។

កាលពីថ្ងៃអាទិត្យមុន ....ជាមួយឪពុក ម្ដាយ។

នៅទីនោះមានដាក់តាំង និងរក្សាទុក .... តាំងក្នុងទូដោយមានរបៀបរៀបរយ។

☑ គ្រូរៀបចំសិស្សជាក្រុម។ ក្នុងមួយក្រុមមានគ្នាយ៉ាងតិច៦នាក់។ គ្រូដាក់ប្រធានបទគំរូមួយស្ដីពី "**ទីកន្លែងដែលជាទីស្រឡាញ់របស់ខ្ញុំ**" ឱ្យសិស្សសរសេររួចណែនាំសិស្សម្នាក់ៗក្នុងក្រុមនីមួយៗ ឱ្យចាប់ផ្ដើមសរសេរសេចក្ដីផ្ដើមមួយល្បះម្នាក់រៀងៗខ្លួន។ បន្ទាប់មក សិស្សម្នាក់ៗ ឱ្យល្បះនោះបន្តពីសិស្សម្នាក់ ទៅម្នាក់ទៀតអាន និងសរសេរតួសេចក្ដីមួយ

លេខ ៦៣

## ចន្ទ...

# សកម្មភាពគំរូ

ឈ្មោះម្នាក់ៗទៀត លើសន្លឹកក្រដាសបន្តពីសេចក្តីផ្តើម រហូតអស់ចំនួនឈ្មោះក្នុងតួសេចក្តី ទើបបន្តឱ្យសិស្សសរសេរបញ្ចប់លើសន្លឹកក្រដាសតពីតួសេចក្តីពីម្នាក់ទៅម្នាក់ទៀតដើម្បីអាន រួចសរសេរបញ្ចប់សេចក្តីមួយឈ្មោះម្នាក់ៗទៀត រហូតវេនសិស្សចុងក្រោយ។

**សម្គាល់** : ចំនួនសិស្សក្នុងក្រុម ស្មើនឹងចំនួនឈ្មោះដែលសិស្សត្រូវសរសេរ។ មានន័យថា សិស្សម្នាក់ៗត្រូវសរសេរឈ្មោះដែលមានឈ្មោះសេចក្តីផ្តើមមួយ ឈ្មោះតួសេចក្តី១ឬ២ឈ្មោះ និងសេចក្តីបញ្ចប់ម្នាក់មួយឈ្មោះ។




គ្រូរំឭកឱ្យសិស្សប្រើប្រាស់ពាក្យភ្ជាប់ ដើម្បីធ្វើឱ្យឈ្មោះមានភាពរលូនពីមួយទៅមួយ។ ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួនមានបង្ហាញជូនតារាងខាងក្រោម ៖

*ឧទាហរណ៍* ប្រធានបទគំរូ "<u>ទីកន្លែងដែលជាទីស្រឡាញ់របស់ខ្ញុំ</u>"

***ពាក្យភ្ជាប់ដែលមានប្រយោជន៍មួយចំនួន ៖***

| | |
|---|---|
| ពេលវេលា | ក្រោយពី ពីមុន រហូតដល់ ជាទីបំផុត ពេល ខណៈដែល |
| ហេតុ និង ផល | ដោយសារ ដូចនេះ ដើម្បី ហេតុនេះ ពីព្រោះ មកពី ទើប ដូច្នោះ នោះ |
| ការបន្ថែម | ម្យ៉ាងទៀត ហើយ ហើយនឹង ព្រមទាំង លើសពីនេះទៀត យ៉ាងណាមិញ |
| សេចក្តីសន្និដ្ឋាន | ជាលទ្ធផល ដូចនេះ ហេតុនេះ អាស្រ័យហេតុនេះ |
| ការផ្លាស់ប្តូរ | ក៏ប៉ុន្តែ ទោះបីជា យ៉ាងណាក៏ដោយ លុះត្រាតែ |
| ការប្រៀបធៀប | ដូចជា ប្រហាក់ប្រហែល ចំណែកឯ ខណៈដែល ដរាបណា |
| លក្ខខណ្ឌ | ប្រសិនបើ  លើកលែងតែ ក្នុងករណី លុះត្រាតែ |
| ទីកន្លែង | ទីណាដែល កន្លែងដែល |

☑ គ្រូឱ្យសិស្សបំពេញតារាងខាងក្រោម ដោយប្រើព័ត៌មានដែលត្រូវការពណ៌នាអំពី "សាលារៀន" មួយដូចលំនាំបង្ហាញក្នុងទំព័រទី១៤៦ ធ្វើជាកិច្ចការមុនសំណេរ ដើម្បីជួយសិស្សឱ្យចេះរៀបចំព័ត៌មានផ្អែកតាមសំណួរ។

*ឧទាហរណ៍* លំហាត់មុនសំណេរ សម្រាប់សរសេរតែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍នេះ។

**លេខ ៦៣**

**បន្ត...**

## សកម្មភាពគំរូ

| សេចក្ដីផ្ដើម | |
|---|---|
| **ប្រភេទព័ត៌មាន** | **ព័ត៌មានជាក់លាក់** |
| ◆ ឈ្មោះសាលារៀន ៖ តើសាលារៀននេះឈ្មោះអ្វី?<br>◆ ទីកន្លែង ៖ តើសាលារៀននេះស្ថិតនៅ ឯណា? | |
| **តួសេចក្ដី** | |
| ◆ ទិដ្ឋភាពមើលពីចម្ងាយ និងមើលជិត ៖ មានអ្វីជុំវិញ សាលារៀនធំ ឬតូច ហើយស្ថិតក្នុងភូមិ កណ្ដាលភូមិ នៅចុងភូមិ ក្នុងវត្ត ក្បែរវត្ត មានដើមឈើតូច ធំ មានពណ៌ អ្វីខ្លះ មានរបៀប ឬអត់។ល។<br>◆ ក្នុងសាលារៀនមាន ៖ សួនកុមារ បណ្ណាល័យ កន្លែងលេងបាល់ ទីចាត់ការ មានកន្លែងគោរពទង់ជាតិ ដងទង់ជាតិ សួនផ្កា។ | |
| **សេចក្ដីបញ្ចប់** | |
| ការវាយតម្លៃ ៖ ចូលចិត្តសាលារៀនឬទេ? ហេតុអ្វី។ | |

បន្ទាប់ពីសិស្សបានឆ្លើយសំណួរទាំងនេះរួចហើយ សិស្សត្រូវចាប់ផ្ដើមសរសេរតែងសេចក្ដីឱ្យចេញជាទម្រង់ល្បះ និងកថាខណ្ឌពេញលេញ។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់និងអនុវត្តក្នុងថ្នាក់




**ដំណាក់កាលទី ៦ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

<u>តេស្តដំណាក់កាលទី ៦</u>

នៃឧបសម្ព័ន្ធ ៣ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៧៧ ដល់ ១៨០

# ដំណាក់កាលទី ៧ : មេរៀនទី៥៣ ដល់ទី៦៤(២៤)

## (ទំព័រទី១៧០ ដល់ទី២០៨)

*១. មេរៀនទី៥៣ : បុណ្យសមុទ្រ*
*២. មេរៀនទី៥៤ : រឿងភាពស្មោះត្រង់*
*៣. មេរៀនទី៥៥ : បកស្រាយរូបភាព "ការសម្អាតបរិស្ថាន"*
*៤. មេរៀនទី៥៦ : កន្លែងទេសចរណ៍ក្នុងប្រទេសកម្ពុជា*
*៥. មេរៀនទី៥៧ : បន្តក់ " ់ "*
*៦. មេរៀនទី៥៨ : ធនធានធម្មជាតិ*
*៧. មេរៀនទី៥៩ : បំណងខ្ញុំ*
*៨. មេរៀនទី៦០ : រឿងភូមិ ឃុំ  មានសុវត្ថិភាព*
*៩. មេរៀនទី៦១ : ឧបករណ៍តន្ត្រីខ្មែរ*
*១០. មេរៀនទី៦២ : ខ្ញុំស្រឡាញ់ទឹកដីខ្មែរ*
*១១. មេរៀនទី៦៣ : ផលប្រយោជន៍នៃបច្ចេកវិទ្យាព័ត៌មាន*
*១២. មេរៀនទី៦៤ : សមាគមអាស៊ាន*

*( ៦៣ម៉ោងប្រហែល៥សប្តាហ៍)*

**កំណត់សម្គាល់ ៖** **(២៤)** ចំពោះមេរៀនទី៥៤ សមត្ថភាពស្តាប់មានចំនួន៥ម៉ោងសិក្សា មេរៀនទី៥៥ សមត្ថភាពនិយាយមានចំនួន៣ម៉ោងសិក្សា មេរៀនទី៦០ សមត្ថភាពស្តាប់មានចំនួន៥ម៉ោងសិក្សា។ មេរៀនទាំងនេះមិនទាក់ទងស្តង់ដាអំណានទេ។ គ្រូត្រូវបង្រៀនតាមធម្មតា។

លេខ ៧ក

# សិស្សពន្យល់ពាក្យពិបាក បដិសព្ទ ទេវចនសព្ទ និងសទិសសព្ទ ពាក្យមានច្រើនន័យ ឬសញ្ញាសក់ក ដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ

**បំណិនអំណានពាក់ព័ន្ធ : ការចេះវាក្យសព្ទ ការស្គាល់តួអក្សរនិងសូរ**

សូមមើល មេរៀនទី៥៣ ទី៥៦ ទី៥៨ ទី៥៩ ទី៦១ ទី៦២ ទី៦៣ និងទី៦៤
(ទំព័រទី១៧០ ទី១៨០ ទី១៨៥ ទី១៩០ ទី១៩៦ ទី២០០ ទី២០៤ និងទី២០៨)

## ខ្លឹមសារ

ពាក្យដែលសិស្សបានរៀនក្នុងមេរៀនទី៥៣ ទី៥៦ ទី៥៨ ទី៥៩ ទី៦១ ទី៦២ ទី៦៣ និងទី៦៤ ដូចជា ៖

### ពន្យល់ពាក្យ

**មេរៀនទី៥៣**

- ទេសចរណ៍ (ន.) : ការធ្វើដំណើរកំសាន្ត។
- សុវត្ថិភាព (ន.) : ការប្រកបដោយសេចក្ដីសុខ។

**មេរៀនទី៥៦**

- រដ្ឋ (ន.) : ដែន ប្រទេស។
- បវរ (គុ.) : ប្រសើរ ថ្លៃថ្លា ក្រៃលែង។
- ប្រជាខេមរា (ន.) : ប្រជាជនខ្មែរ។
- ព្រះខ័ន (ន.) :ដាវ។

**មេរៀនទី៥៨**

- មាតុភូមិ (ន.) : ភូមិកំណើត ស្រុកកំណើត។
- ម្រឹគីម្រឹគា (ន.) : ពួកសត្វចតុប្បាទញីឈ្មោល ដែលរស់នៅក្នុងព្រៃ។
- **ប្រពៃ** (គុ.) : ល្អប្រពៃ ល្អហ្មត់ហ្មង

**មេរៀនទី៥៩**

- មមៃ (កិ.) :ភ្នកនឹករឿយៗមិនភ្លេច នឹកមមៃ គិតមមៃ។
- ប្រប (ន.) : ជិត ក្បែរ ទៀប។
- ត្រសុំ (គុ.) : ដែលមានបរិមណ្ឌលល្មមុលជុំគ្នា។
- កម្រៃ (គុ.) : ដែលចំណេញ ចរិកាចំណេញ។

**មេរៀនទី៦១**

- តូរ្យតន្ត្រី (ន.) : គ្រឿងភ្លេង ដេញដំ ផ្លុំ កូត។
- ឧបករណ៍ (ន.) : គ្រឿងទប់ទល់គ្រឿងប្រុង គ្រឿងប្រកបផ្សំគ្នា។
- ធម្មជាតិ (ន.) : សភាវៈកើតឡើងឯងៗ។
- អត្តសញ្ញាណជាតិ (ន.) : គ្រឿងសម្គាល់ជាតិមួយ សញ្ញាសម្គាល់ជាតិមួយ។

**មេរៀនទី៦២**

- សុវណ្ណភូមិ (ន.): ភូមិមាស ដែនដីមាស។
- រមណីយដ្ឋាន (ន.): ទីកន្លែង ដែលជាទីរីករាយ សប្បាយ។
- ប្រទូសរ៉ាយ (កិ.) : បៀតបៀន រករឿង រកហេតុធ្វើឱ្យអាក្រក់ឱ្យវិនាស។
- ប្រឹថពី (ន.) : ផែនដី ផ្ទៃដីទាំងមូល។
- សព្ទសាធុការ (ន.) : សំឡេងដែលបញ្ចេញថា "សាធុ"។
- ស្វាគមន៍ (កិ.) : ដំណើរមកដល់ដោយប្រពៃ។

**មេរៀនទី៦៣**

- គមនាគមន៍ (ន.) :ដំណើរទៅ និងមក ផ្លូវទាក់ទងសម្រាប់ធ្វើដំណើរទៅមក។
- ប្រព័ន្ធ (ន.) :ចង់រឹតរួត ឆ្នាក់ជំពាក់។
- ប្រៃសណីយ៍ (ន.) : ក្រុមរាជការទទួលបន្ទុកខាងការបញ្ជូន និងការនាំសំបុត្រស្នាមផ្សេងៗ។

**មេរៀនទី៦៤**

- ថាមពល (ន) កម្លាំងដ៏លើសលប់ កម្លាំងដ៏ស្វាហាប់។
- វប្បធម៌ (ន) ការសាបព្រោះ ឬបណ្ដុះវិជ្ជា និងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើន។
- សេដ្ឋកិច្ច (ន) មុខរបរជាប្រយោជន៍សំខាន់ៗក្នុងប្រទេស។
- វឌ្ឍនភាព (ន) ដំណើរនាំឱ្យរីកចម្រើន។

លេខ ៧ក

**បន្ត...**

## ខ្លឹមសារ

**បដិសព្ទ**

| | | | | | | |
|---|---|---|---|---|---|---|
| មេរៀនទី៥៣ : | បុណ្យ | ≠ | បាប | ល្អ | ≠ | អាក្រក់ |
| មេរៀនទី៥៦ : | ផ្លូវផង់ | ≠ | សៅហ្មង | សង់ | ≠ | កម្ទេច |
| មេរៀនទី៥៨ : | ទំនាប | ≠ | ទួល | ថ្កើងថ្កាន | ≠ | ដុនដាប |
| មេរៀនទី៥៩ : | ថ្លៃ | ≠ | ថោក | ធាត់ | ≠ | ស្គម |
| មេរៀនទី៦១ : | រីក | ≠ | រួម | ថែរក្សា | ≠ | បំផ្លាញ |
| មេរៀនទី៦២ : | សត្រូវ | ≠ | មិត្ត | សង្គ្រាម | ≠ | សន្តិភាព |
| មេរៀនទី៦៣ : | រហ័ស | ≠ | យឺត | ចំណាយ | ≠ | ចំណូល |
| មេរៀនទី៦៤ : | បង្កើត | ≠ | បំផ្លាញ | រួបរួម | ≠ | បែកបាក់ |

**វេវចនសព្ទ**

មេរៀនទី៥៣ : វេវចនសព្ទនឹងពាក្យ "**មាតុភូមិ**" **មាតុប្រទេស ប្រទេសកំណើត ភូមិកំណើត**

មេរៀនទី៥៦ : វេវចនសព្ទនឹងពាក្យ "សមុទ្រ" **សមុទ្រ សាគរ ជលសា**

មេរៀនទី៥៨ : វេវចនសព្ទនឹងពាក្យ "ទី" **ទី កន្លែង តំបន់ ស្ថាន**

មេរៀនទី៦១ : វេវចនសព្ទនឹងពាក្យ "ឧបករណ៍" ឧបករណ៍ គ្រឿង ប្រដាប់

មេរៀនទី៦២ : វេវចនសព្ទនឹងពាក្យ "សុវណ្ណ" សុវណ្ណ មាស

មេរៀនទី៦៣ : វេវចនសព្ទនឹងពាក្យ "ទំនើប" ទំនើប ថ្មី ទាន់សម័យ

មេរៀនទី៦៤ : វេវចនសព្ទនឹងពាក្យ "រួបរួម" រួបរួម សាមគ្គី ចងបាច់ ប្រមូលផ្តុំ។

**សទិសសព្ទ**

មេរៀនទី៥៨ : សទិសសព្ទនឹងពាក្យ "គួរ"

- គួរ (គុ.) : សម គប្បី ឥតទាស់។
- ក្នួរ (ន.) : ចង្កោម ផ្លែ សំណុំផ្លែ។

មេរៀនទី៥៩ : វេវចនសព្ទនឹងពាក្យ "**រៀង**"

- រៀង (កិ.) : ដាក់តាមលំដាប់ ធ្វើឱ្យត្រូវលំដាប់។ *ឧទាហរណ៍* រៀងរាប រៀងដរាប។
- រាង (កិ.) : លែងចង់ លែងត្រូវការទៀត។ *ឧទាហរណ៍* ខ្ញុំរាងហើយ។
- រាង (ន.) : សណ្ឋាន ទ្រង់ទ្រាយ។ *ឧទាហរណ៍* រាងស្ដើង។

មេរៀនទី៦១ : សទិសសព្ទនឹងពាក្យ "បទ"

- បទ (ន.) : ឧបាយ រឿងហេតុ ទី ការរក្សា ចំណែក ជើង ស្នាម ជើង ផ្លូវ ទំនង ដំណើរទំនង ដើមទង។

*ឧទាហរណ៍* បទចម្រៀង......។

- បត់ (កិ.) : ត្រឡប់តាមទំនង តាមផ្លូវដែលមកវិញ ត្រឡប់ប្រសព្វមុខ។ *ឧទាហរណ៍* បត់ក្រដាស។

លេខ ៧ក

បន្ត...

## ខ្លឹមសារ

**មេរៀនទី៦២ :** សទិសសព្ទនឹងពាក្យ "សឹក"
- ♦ សឹក (គុ.) : ផេចរឹល រឹលផេច។
- ♦ សឹក (កិ.) : ផ្លាស់ភេទពីព្រះសង្ឃមកជាគ្រហស្ថ។ *ឧទាហរណ៍* លោកសឹក។
- ♦ សឹក (ន.) : ចម្បាំង សឹកសង្គ្រាម។

**មេរៀនទី៦៣ :** សទិសសព្ទនឹងពាក្យ "សារ"
- ♦ សារ (ន.) : ខ្លឹម សេចក្ដីខ្ជាប់ខ្ជួន មាំមួន។ *ឧទាហរណ៍* សារលិខិត។
- ♦ សា (កិ.) : មូរឡើងវិញ។ *ឧទាហរណ៍* សាកន្ទេល។
- ♦ សា (ន.) : ស្រូវឬដំណាំពួកខ្លះ ដែលដុះលូតលាស់ពីគល់ចាស់ ឬពីជញ្ជ្រាំង។ *ឧទាហរណ៍* សាស្រូវ សាឪឡឹក។

**មេរៀនទី៦៤ :** សទិសសព្ទនឹងពាក្យ "ចក្រ"
- ♦ ចក្រ (ន.) : កង់មានកាំ រង្វង់មូល ប្រទេស។
- ♦ ចាក់ (កិ.) : ដោយគ្រឿងប្រហារមានមុខស្រួច។

## សកម្មភាពគំរូ

☑ គ្រូរំឭកឡើងវិញពីការរៀនពាក្យពិបាកៗមួយចំនួន ក្នុងមេរៀនចំនួនពីរឬបីមេរៀន រួចឱ្យសិស្សអាន ហើយគ្រូធ្វើ "អក្ខរវិញ្ញាស" ដើម្បីជួយសិស្សដោយប្រើតារាងពាក្យនៅលើក្ដារខៀន។ ពាក្យទាំងនោះអាចជាពាក្យព្យាង្គតម្រួត និងពាក្យមានតួអក្សរមិនអានខ្លះដូចជាមានសញ្ញាទណ្ឌឃាត "៍" នៅលើតួអក្សរខាងចុងពាក្យ ដែលមិនទាន់អាន។ បន្ទាប់មក គ្រូឱ្យសិស្ស១០នាក់ក្នុងក្រុមធំអានឮៗចំនួនមួយឬពីរពាក្យ ហើយគ្រូជាអ្នកគូសសញ្ញាកំណត់ "0" គឺអានត្រូវ និងសញ្ញា "x" សិស្សអានមិនត្រូវ។ ធ្វើបែបនេះ គ្រូអាចវាយតម្លៃ និងជួយសិស្សអានមិនត្រូវបានតាមរយៈការធ្វើលំញែកព្យាង្គ និងអក្ខរវិញ្ញាស។

| ពាក្យពិបាក | លំញែកព្យាង្គ<br>ដើម្បីអានពាក្យ | អក្ខរវិញ្ញាស<br>(ការរាប់តួអក្សរក្នុងពាក្យ) | ការវាយតម្លៃ<br>(សិស្ស១០នាក់) |
|---|---|---|---|
| ឧបករណ៍<br>តន្ត្រី | អ៊ុ - ប៉ៈ - ក<br>ដន់ - ត្រី | ឧ ប ក រ ណ និង " ៍ "<br>ត ន ្ត ្រ និង " ី " | ............................<br>............................ |
| ♦ ស្វាគមន៍<br>♦ គមនាគមន៍<br>♦ ប្រៃសណីយ៍<br>♦ ប្រយោជន៍<br>♦ ចរាចរណ៍<br>♦ ទេសចរណ៍<br>♦ អាស៊ីអាគ្នេយ៍ | ................................<br>................................<br>................................<br>................................<br>................................<br>................................ | ................................<br>................................<br>................................<br>................................<br>................................<br>................................ | ............................<br>............................<br>............................<br>............................<br>............................<br>............................ |

លេខ ៧ក

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូគូសតារាងពាក្យពិបាក និងនិយមន័យដូចតារាងខាងក្រោម រួចឱ្យសិស្សកំណត់ន័យរបស់ពាក្យពិបាកនោះ ដោយគូសភ្ជាប់សញ្ញាព្រួញ។ *ឧទាហរណ៍* ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យ ពីឆ្វេងទៅស្ដាំ ឱ្យត្រូវនឹងនិយមន័យរបស់ពាក្យនីមួយៗ។

| ពាក្យពិបាក | និយមន័យ | ពាក្យពិបាក | និយមន័យ |
|---|---|---|---|
| ឧបករណ៍ | ♦ គ្រឿងប្រដាប់ធ្វើដំណើរ។<br>♦ គ្រឿងទប់ទល់ គ្រឿងប្រុង គ្រឿងប្រកបផ្សំគ្នា។<br>♦ ម៉ាស៊ីនគ្រប់ប្រភេទ។ | ទេសចរណ៍ | ♦ ការធ្វើដំណើរទៅវិញទៅមក។<br>♦ ការធ្វើដំណើរទៅធ្វើការ។<br>♦ ការធ្វើដំណើរកំសាន្ត។ |
| រមណីយដ្ឋាន | ♦ ទីកន្លែងដែលជាទីគោរព។<br>♦ ទីកន្លែង ដែលជាទីរីករាយ សប្បាយ។<br>♦ ទីកន្លែងរំឭកការចងចាំ។ | រដ្ឋ | ♦ ទីកន្លែង។<br>♦ ទីតាំង។<br>♦ ដែនប្រទេស។ |
| ម្រឹគីម្រឹគា | ♦ ពួកសត្វទ្វេបាទញីឈ្មោលដែលរស់នៅក្នុងព្រៃ។<br>♦ ពួកសត្វចតុប្បាទញីឈ្មោលដែលរស់នៅក្នុងព្រៃ។<br>♦ ពួកសត្វស្លាបញីឈ្មោលដែលរស់នៅក្នុងព្រៃ។ | វឌ្ឍនភាព | ♦ ដំណើរនាំឱ្យផ្លាស់ប្ដូរ។<br>♦ ដំណើរនាំឱ្យប្រែប្រួល។<br>♦ ដំណើរនាំឱ្យរីកចម្រើន។ |

☑ គ្រូឱ្យសិស្សពិនិត្យតារាងខាងក្រោម ហើយបង្ហាញសិស្សពីឧទាហរណ៍ទី១ពាក្យ "ឃឹម" រួចគូសសញ្ញា "✓" ក្នុងប្រអប់ចម្លើយទាំង៣ ក្នុងតារាងដែលត្រូវន័យនឹងពាក្យនោះ។ ចម្លើយអាចមានច្រើន។ បន្ទាប់មក គ្រូឱ្យសិស្សគូសសញ្ញា "✓" នេះដើម្បីរកពាក្យដទៃទៀតដោយខ្លួនឯង។

| លេខ | ពាក្យ | ជាទីកន្លែង | ជាឧបករណ៍ម៉្យាង | ធ្វើឱ្យមានអារម្មណ៍សប្បាយ | ផលិតផលមានប្រយោជន៍ |
|---|---|---|---|---|---|
| ១ | ឃឹម | | ✓ | ✓ | ✓ |
| ២ | ឆ្នេរសមុទ្រ | | | | |
| ៣ | រដ្ឋ | | | | |
| ៤ | រមណីយដ្ឋាន | | | | |
| ៥ | ទេសចរណ៍ | | | | |
| ៦ | ព្រះខ័ន | | | | |
| ៧ | កុំព្យូទ័រ | | | | |

លេខ ៧ក

**បន្ត...**

## សកម្មភាពគំរូ

☑ គ្រូបង្កើតដ្យាក្រាម ហើយសរសេរពាក្យនៅចំកណ្ដាល។ បន្ទាប់មក គ្រូឱ្យសិស្សស្វែងរកពាក្យផ្សេងទៀត ដែលមានន័យផ្ទុយ (បដិសព្ទ) ហើយសរសេរពាក្យទាំងនោះនៅជុំវិញពាក្យកណ្ដាល។




សម្គាល់ : ពាក្យដែលគ្រូអាចជ្រើសរើសមកធ្វើលំហាត់ ជាបដិសព្ទ ឬពាក្យផ្ទុយបាន អាចមានពាក្យផ្ទុយច្រើន(ដូចជាពាក្យ **ទុក្ខ**អាចផ្ទុយនឹងពាក្យ សុខ រីករាយ សប្បាយ ក្សេមក្សាន្ត . . .) ខ្លះទៀតអាចមានពាក្យផ្ទុយតែមួយឬពីរប៉ុណ្ណោះ។

☑ គ្រូបង្កើតបណ្ដុំពាក្យ ឬសរសេរពាក្យដែលបានដកស្រង់ពីមេរៀន បង្ហាញសិស្សនៅលើក្ដារខៀន រួចឱ្យសិស្សរកពាក្យដែលមានន័យផ្ទុយនឹងពាក្យទាំងនោះឱ្យបានត្រឹមត្រូវ។

| | | | | | | |
|---|---|---|---|---|---|---|
| បុណ្យ | ថ្កើងថ្កាន | ល្អ | ផ្សផង់ | សង | ទំនាប | ថ្លៃ |
| រីក | ថែរក្សា | រហ័ស | ចំណាយ | ធាត់ | បង្កើត | រួបរួម |

- បន្ទាប់មក គ្រូឱ្យសិស្សអាន និងផ្ទៀងផ្ទាត់ចម្លើយនៅក្នុងសៀវភៅសិស្សឡើងវិញ។

☑ គ្រូចែកសិស្សជាក្រុមៗ ដែលមួយក្រុមមានគ្នា៤ ទៅ៥នាក់។ គ្រូសរសេរពាក្យមួយ នៅលើក្ដារខៀន ហើយឱ្យសិស្សរកវេវចនសព្ទទាក់ទងនឹងពាក្យនោះឱ្យបានច្រើនតាមដែលអាចរកបាន។ គ្រូផ្ដល់ពេលប្រហែលបីឬបួននាទីប៉ុណ្ណោះ សម្រាប់ស្វែងរក ហើយក្រុមណាដែលរកពាក្យវេវចនសព្ទបានច្រើនជាងគេគឺជាក្រុមឈ្នះ។ គ្រូអាចធ្វើសកម្មភាពដូចគ្នានេះ សម្រាប់ពាក្យបដិសព្ទ ឬវេវចសព្ទផ្សេងទៀតក៏បាន។

☑ គ្រូគូសតារាងនៅលើក្ដារខៀន។ តារាងទី១ជាវេវចនសព្ទ តារាងទី២ជាបដិសព្ទ។ បន្ទាប់មក គ្រូសរសេរបញ្ជីពាក្យនៅលើក្ដារខៀន ហើយឱ្យសិស្សធ្វើចំណាត់ថ្នាក់ពាក្យទាំងនេះ ទៅតាមតារាង វេវចនសព្ទ និងបដិសព្ទ។

*ឧទាហរណ៍* គ្រូសរសេរពាក្យខាងក្រោម ដាក់លើក្ដារខៀនរួចបង្ហាញឧទាហរណ៍ខាងក្រោមពន្យល់សិស្ស។ បន្ទាប់មក ឱ្យសិស្សរកដោយខ្លួនឯង។ **តារាងពាក្យ** ៖ មាតុភូមិ សមុទ្រ បុណ្យ រឿង ផ្សផង់ ឧបករណ៍ សង់ ទី ថ្កើងថ្កាន ធាត់ រីក សុវណ្ណ បង្កើត។

| វេវចនសព្ទ | បដិសព្ទ |
|---|---|
| មាតុភូមិ ភូមិកំណើត<br>................ | សង់ ≠ កម្ទេច<br>......... ≠ .......... |

## លេខ ៧ក

## បន្ត...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៧ក**

**លេខ ៧ខ**

# សិស្សបកស្រាយន័យនៃល្បះអត្ថបទ និងមេសូត្រ នៅតាមមេរៀនដែលបានកំណត់ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ តាមរយៈលំហាត់ផ្សេងៗ

*ឧទាហរណ៍* ឆ្លើយសំណួរយល់ដឹង បំពេញចន្លោះ បំពេញល្បះ លំហាត់ក្លូស្ស។ល។)

## បំណិនអំណានពាក់ព័ន្ធ : ការអានដើម្បីយល់ន័យ

**សូមមើល មេរៀនទី៥៣ ទី៥៦ ទី៥៨ ទី៥៩ ទី៦១ ទី៦២ ទី៦៣ និងទី៦៤**
**(ទំព័រទី១៧០ ទី១៨០ ទី១៨៥ ទី១៩០ ទី១៩៦ ទី២០០ ទី២០៤ និងទី២០៨)**

### ខ្លឹមសារ

ល្បះអត្ថបទ និងមេសូត្រក្នុងមេរៀនទី៥៣ ទី៥៦ ទី៥៨ ទី៥៩ ទី៦១ ទី៦២ ទី៦៣ និងទី៦៤ ៖

- មេរៀនទី៥៣ : បុណ្យសមុទ្រ
- មេរៀនទី៥៦ : កន្លែងទេសចរណ៍ក្នុងប្រទេសកម្ពុជា
- មេរៀនទី៥៨ : ធនធានធម្មជាតិ
- មេរៀនទី៥៩ : បំណងខ្ញុំ
- មេរៀនទី៦១ : ឧបករណ៍តន្ត្រីខ្មែរ
- មេរៀនទី៦២ : ខ្ញុំស្រឡាញ់ទឹកដីខ្មែរ
- មេរៀនទី៦៣ : ផលប្រយោជន៍នៃបច្ចេកវិទ្យាព័ត៌មាន
- មេរៀនទី៦៤ : សហគមអាស៊ាន

### សកម្មភាពគំរូ

☑ សិស្សឆ្លើយសំណួរក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរថ្នាក់ទី៣ ៖

**មេរៀនទី៥៣**

១. តើបុណ្យសមុទ្រប្រព្រឹត្តទៅនៅថ្ងៃណា? ខែណា? ឆ្នាំណា?
២. តើឆ្នេរសមុទ្រអូរឈើទាលស្ថិតនៅក្នុងខេត្តណា?
៣. តើបុណ្យសមុទ្រផ្តោតលើអត្ថន័យសំខាន់ៗប៉ុន្មាន?
៤. ហេតុអ្វីបានជាគេរៀបចំបុណ្យសមុទ្រ?

**មេរៀនទី៥៦**

១. តើកន្លែងទេសចរណ៍ដែលជាប្រាសាទបុរាណមានចំនួនប៉ុន្មាន? អ្វីខ្លះ?
២. តើកន្លែងទេសចរណ៍ធម្មជាតិមានចំនួនប៉ុន្មាន? អ្វីខ្លះ?
៣. តើយើងត្រូវធ្វើដូចម្តេច ដើម្បីឱ្យសម្បត្តិទាំងនេះនៅគង់វង្ស?

**មេរៀនទី៥៨**

១. តើប្រទេសកម្ពុជាសម្បូរធនធានធម្មជាតិនៅកន្លែងណាខ្លះ?
២. តើតំបន់ព្រៃភ្នំ មានធនធានធម្មជាតិអ្វីខ្លះ?
៣. តើតំបន់ខ្ពង់រាប និងវាលទំនាបមានធនធានធម្មជាតិអ្វីខ្លះ?
៤. តើប្អូនត្រូវថែរក្សាការពារធនធានធម្មជាតិដូចម្តេច?

**មេរៀនទី៥៩**

១. តើនៅក្នុងមេសូត្រខាងលើនេះ គេនឹកមម៉ៃចង់បានអ្វី?
២. ចំពោះអ្នកវិញ តើអ្នកចង់បានដូចគេដែរឬទេ? ព្រោះអ្វី?
៣. តើអ្នកចង់ធ្វើសួនដាំដំណាំ និងចិញ្ចឹមសត្វដែរឬទេ? ព្រោះអ្វី? ★

**មេរៀនទី៦១**

១. តើនរណាបង្កើតឱ្យមានតូរ្យតន្ត្រីខ្មែរ?
២. តើឧបករណ៍តូរ្យតន្ត្រីខ្មែរមានអ្វីខ្លះ?
៣. តើឧបករណ៍ និងបទភ្លេងខ្មែរបុរាណគេយកទៅប្រើក្នុងពិធីអ្វីខ្លះ?
៤. តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យតូរ្យតន្ត្រីខ្មែរបានគង់វង្ស? ★

លេខ ៧ខ

**បន្ត...**

## សកម្មភាពគំរូ

**មេរៀនទី៦២**

១. នៅពេលមានសត្រូវមកឈ្លានពានយាយី តើប្រជាជនខ្មែរបាន ធ្វើដូចម្ដេច?

២. តើប្អូនមានអារម្មណ៍ដូចម្ដេចខ្លះ ចំពោះមាតុភូមិ របស់ប្អូន? ★

**មេរៀនទី៦៣**

១. តើបច្ចេកវិទ្យាព័ត៌មានប្រើសម្រាប់ធ្វើអ្វី?

២. តើបច្ចេកវិទ្យាព័ត៌មាន ជាឧបករណ៍យ៉ាងដូចម្ដេច?

៣. តើបច្ចេកវិទ្យាព័ត៌មាន មានប្រយោជន៍ដូចម្ដេចខ្លះ?

**មេរៀនទី៦៤**

១. ដូចម្ដេចដែលហៅថា "អាស៊ាន" ?

២. តើសមាគមអាស៊ានមានប៉ុន្មានប្រទេស? ប្រទេសណាខ្លះ?

៣. តើទង់និមិត្តសញ្ញាតំណាងអាស៊ានមានអ្វីខ្លះ?

៤. តើអាស៊ានបង្កើតឡើងដើម្បីអ្វី?

៥. នៅឆ្នាំ២០១២ ប្រទេសណាជាប្រធានសមាគមអាស៊ាន?

**សម្គាល់ :** **ក.** សំណួរដែលមានសញ្ញា ★ (ផ្កាយ) គឺជាសំណួរបន្ថែម ដើម្បីពង្រឹងបំណិនវិភាគ និងដោះស្រាយបញ្ហា។ រាល់ចម្លើយរបស់សិស្សឱ្យតែសមហេតុ ផល ទោះបីជាមិនមាននៅក្នុងអត្ថបទអំណានក៏ដោយ គ្រូត្រូវទទួលទាំងអស់។

**ខ.** សំណួរបន្ថែមខាងក្រោមនេះ គ្រូអាចពិភាក្សាជាមួយសិស្ស ដើម្បីជួយកែលម្អសមត្ថភាពគំនិតដោយវិភាគក្នុងអត្ថបទ មេរៀនទី៥៣ ទី៥៦ ទី៥៨ ទី៦៣ និងទី៦៤ ៖

**មេរៀនទី៥៣ :** តើអ្នកគិតថា អ្នកចង់ចូលរួមបុណ្យសមុទ្រឬទេ? ព្រោះអ្វី?

**មេរៀនទី៥៦ :** តើតំបន់ទេសចរណ៍ប្រភេទណាដែលអ្នកចង់ទៅលេង? ព្រោះអ្វី?

**មេរៀនទី៥៨ :** តើនរណាគួរទទួលបានប្រយោជន៍ច្រើនបំផុតពីប្រភពធនធានធម្មជាតិរបស់ប្រទេសកម្ពុជា? ហេតុអ្វីបានជាអ្នកគិតដូច្នោះ?

**មេរៀនទី៦៣ :** បើសិនជាអ្នកមានកុំព្យូទ័រ តើអ្នកនឹងប្រើវាសម្រាប់ធ្វើអ្វីខ្លះ ?

**មេរៀនទី៦៤ :** តើប្រទេសណាខ្លះក្នុងអាស៊ានដែលអ្នកចង់ទៅលេង? ព្រោះអ្វី?

☑ សិស្សអាចបំពេញលំហាត់ cloze តាមរយៈការជ្រើសរើសពាក្យន័យដូចគ្នានឹងពាក្យក្នុងអត្ថបទ មកបំពេញបានត្រឹមត្រូវ។ (មេរៀនទី៦៤ ទំព័រទី២០៨)។

អាស៊ានជាសមាគមនៃ ...**(១)**អាស៊ីអាគ្នេយ៍ដែលមាន...**(២)**ប្រទេសជាសមាជិក។ សមាគម...**(៣)**ត្រូវបានបង្កើតឡើង...**(៤)**ថ្ងៃទី០៨ ខែសីហា...**(៥)**១៩៦៧។ ប្រទេសជាសមាជិកអាស៊ាន...**(៦)**ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ...**(៧)**ប្រ៊ុយណេ ឡាវ មីយ៉ាន់ម៉ា វៀតណាម ...**(៨)**ព្រះរាជាណាចក្រកម្ពុជា។

**ចម្លើយ :** **១.** ប្រជាជាតិ ប្រជាជន សហគមន៍ **២.** ដប **៣.** អាស៊ាន សហគមន៍អាស៊ាន សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ **៤.** នៅ នា កាលពី **៥.** ឆ្នាំ គ្រិះសករាជ **៦.** មាន ដូចជា គឺ **៧.** ថៃ សៀម **៨.** និង ហើយនិង។

☑ **ទីសេចក្ដីជាឧទាហរណ៍ពន្យល់ន័យរបស់ពាក្យ ៖** គ្រូឱ្យសិស្សអានអត្ថបទណាមួយឡើងវិញ រួចឱ្យសិស្សសរសេរពាក្យដែលមិនទាន់ចេះដាក់ក្នុងសៀវភៅរៀងៗខ្លួន។ បន្ទាប់មក គ្រូរៀបចំសិស្សជាដៃគូ ហើយឱ្យគេព្យាយាមកំណត់និយមន័យ

លេខ
៧ខ

## បន្ត...

## សកម្មភាពគំរូ

ពាក្យមិនចេះនោះតាមទីសេចក្តី។ រួចសិស្សសរសេរនិយមន័យពាក្យដែលកំណត់តាមការវិភាគនេះ។ ប្រសិនបើសិស្សមិនអាចបកស្រាយនិយមន័យពាក្យណាមួយបាន គេអាចសួរគ្រូក្នុងក្រុមធំបាន។ គ្រូគួរសរសេរពាក្យទាំងអស់នោះនៅលើក្តារខៀនឱ្យសិស្សដទៃទៀតមើល ដើម្បីផ្តល់យោបល់ ហើយគ្រូជួយកែលម្អ។ *ឧទាហរណ៍* ចូរបង្ហាញពាក្យទីសេចក្តីកំណត់ន័យរបស់ពាក្យ "ទ្រ ស្គរ តាខេ ឃឹម រនាត គង ស្រឡៃ ចាប៉ី សាដៀវ ឈិង ឆាប ក្រាប។ល។"

គ្រឿងភ្លេងបុរាណខ្មែររួមមាន ៖ ទ្រ ស្គរ តាខេ ឃឹម រនាត គង ស្រឡៃ ចាប៉ី សាដៀវ ឈិង ឆាប ក្រាប។ល។ ដូចនេះពាក្យ "ទ្រ ស្គរ តាខេ ឃឹម រនាត គង ស្រឡៃ ចាប៉ី សាដៀវ ឈិង ឆាប ក្រាប។ល។" គឺជាទីសេចក្តីបញ្ជាក់ន័យរបស់ពាក្យ "**គ្រឿងភ្លេងបុរាណខ្មែរ**"។

☑ ការរៀបល្បះតាមលំដាប់លំដោយខ្លឹមសារអត្ថបទបានត្រឹមត្រូវ។ ក្រោយពីអានខ្លឹមសារអត្ថបទ "**គ្រឿងភ្លេងបុរាណខ្មែរ**" គ្រូសរសេរល្បះមួយចំនួនមិនតាមលំដាប់លំដោយ រួចឱ្យសិស្សដាក់លេខខាងមុខប្រអប់ល្បះនីមួយៗទៅតាមលំដាប់លំដោយខ្លឹមសារអត្ថបទឱ្យបានត្រឹមត្រូវ។

*ឧទាហរណ៍* គ្រូណែនាំសិស្សឱ្យបង់លេខក្នុងប្រអប់ល្បះនីមួយៗតាមលំដាប់លំដោយអត្ថបទ។

- ☐ គ្រឿងភ្លេងបុរាណខ្មែរមាន ទ្រ ស្គរ តាខេ ឃឹម រនាត គង ស្រឡៃ ចាប៉ី សាដៀវ ឈិង ឆាប ក្រាប។ល។ (២)
- ☐ ឧបករណ៍ទាំងនេះងាយស្រួលធ្វើ ពុំលំបាកដូចភ្លេងគ្រឿងបរទេសទំនើបឡើយ ហើយក៏មិនចំណាយថវិកាច្រើនសម្រាប់ផលិតដែរ។ (៤)
- ☐ ឧបករណ៍តន្ត្រីខ្មែរត្រូវបានប្រគំឡើងតាមរយៈការដេញ ដំ ផ្លុំ កូត ហើយការប្រគំបទភ្លេងស្របតាមពិធីបុណ្យប្រពៃណីផ្សេងៗ។ (៣)
- ☐ រីឯបទភ្លេងបុរាណខ្មែរ អ្នកនិពន្ធរៀបចំតាមលំនាំធម្មជាតិដែលមានសំនៀងពីរោះលន្លង់លន្លោច ទន់ភ្លន់។ (៥)
- ☐ ឧបករណ៍ និងបទភ្លេងខ្មែរបុរាណគេយកទៅប្រើប្រាស់ក្នុងពិធីបុណ្យផ្សេងៗទៅតាមវង់ប្រគំ ដូចជាពិណពាទ្យ មហោរីប្រពៃណី ឆៃយ៉ាំ យីកេ ល្ខោនជាដើម។ (១)

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៧ខ**

លេខ
៧គ

## សិស្សរកសូរចួនក្នុងពាក្យដែលគ្រូអាននិងសរសេរ

**សម្គាល់ :** មុនបង្រៀនពាក្យចួន ក្នុងអត្ថបទសំណេរគ្រូគួរ រំឭកបញ្ញត្តិពាក្យចួនដោយប្រើភាសានិយាយសិន។

**បំណិនអំណានពាក់ព័ន្ធ : ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ**

**សូមមើល មេរៀនទី៥៦ ទី៥៨ ទី៥៩ និងទី៦២ (ទំព័រទី១៨០ ទី១៨៥ ទី១៩០ និងទី២០០)**

### ខ្លឹមសារ

និយមន័យ "ពាក្យចួន"

**ពាក្យចួន** គឺជាពាក្យដែលមានសូរស្រៈដូចគ្នា ឬសូរស្រៈប្រកបនឹងព្យញ្ជនៈដូចគ្នា ក្នុងវគ្គរបស់កំណាព្យ ឬមេសូត្រ និងចម្រៀង។

*ឧទាហរណ៍* មេសូត្រ (បទកាកគតិ) មេរៀនទី៥៨ ទំព័រទី១៨៥

- ពាក្យ "កម្ពុជា" ចួននឹង "នានា"
- ពាក្យ "កន្លែង" ចួននឹង "វែង" និង"ស្វែង" ។

### សកម្មភាពគំរូ

☑ គ្រូនិយាយប្រាប់សិស្សថា គ្រូនឹងប្រាប់ពាក្យចំនួន៤។ ចូរប្អូនស្ដាប់ដោយយកចិត្តទុកដាក់ ហើយឆ្លើយប្រាប់គ្រូវិញថា តើពាក្យមួយណាក្នុងចំណោមពាក្យទាំងបួននោះ ដែលមិនមែនជាពាក្យចួន។ (ការស្គាល់សូរ)

*ឧទាហរណ៍*

| | | | |
|---|---|---|---|
| កម្ពុជា | ធានា | **គំរូ** | ពណ៌នា |
| ភ្នំ | **ដី** | ធំ | ជុំ |
| ខ្ពង់រាប | ទំនាប | គាប | **បឹង** |
| **ស្រែ** | ព្រៃ | ថ្លៃ | ក្រៃ |

ដូចនេះ ពាក្យដែលមានសូរស្រៈ និងព្យញ្ជនៈប្រកបដូចគ្នា គឺជាពាក្យចួន។

**សម្គាល់ :** គ្រូគួរចាំថានៅពេលធ្វើលំហាត់នេះ គឺមិនត្រូវសរសេរពាក្យទាំងនេះនៅលើក្ដារខៀននោះទេ ប៉ុន្តែគ្រូត្រូវធ្វើដោយផ្ទាល់មាត់។ (ការស្គាល់សូរ)

☑ គ្រូសរសេរពាក្យចួនមួយចំនួនលើក្ដារខៀន រួចឱ្យសិស្សរកសូរអក្សរណា ដែលមានសូរដូចគ្នានៅខាងចុងឱ្យបានច្រើនតាមអាចធ្វើបាន។ (ការស្គាល់តួអក្សរនិងសូរ)

*ឧទាហរណ៍* ពាក្យ "**ទំនាប**" ចួននឹងពាក្យ "**វាលរាប**" គឺមានព្យញ្ជនៈ "**ទ**" អំ "**ន**" អា និង**ប** ចួននឹង "**វ**" អា និង**ល** "**រ**" អា និង "**ប**" ដែលមានសូរ អា និងព្យញ្ជនៈប្រកប "**ប**" ដូចគ្នា។

ដូចនេះ ពាក្យទំនាប ⟶ **ទំនាប** ⟷ **វាលរាប** (**ទំនាប** ចួននឹង**វាលរាប**)។

គ្រូអាចឱ្យឧទាហរណ៍ពាក្យចួនផ្សេងៗទៀតដើម្បីពន្យល់សិស្សបានតាមលំនាំខាងលើ។

☑ គ្រូសរសេរអត្ថបទមេសូត្រ ដាក់លើក្ដារខៀន រួចឱ្យសិស្សឡើងគូសគំនូសតាងពាក្យចួននៅលើក្ដារខៀន។

| | | |
|---|---|---|
| មាតុភូមិកម្ពុជា | ធនធាននានា | គ្រប់ទីកន្លែង |
| សមុទ្រព្រៃភ្នំ | ទន្លេធំវែង | គួរឱ្យស្ញប់ស្ញែង |
| | គ្រប់ប្រជាជាតិ។ | |

លេខ ៧គ

## បន្ត...

## សកម្មភាពគំរូ

តំបន់ព្រៃភ្នំ　　　　ដើមឈើតូចធំ　　　　ជំរំសត្វទៀត

ម្រឹគីម្រឹគា　　　　បក្សាព្រោងព្រាត　　　　រស់តាមក្រុមញាតិ
អឹងកងពេញព្រៃ។

☑ គ្រូផ្តល់កំណាព្យមួយដែលមិនពេញលេញដល់សិស្សដោយមានលុបចេញពាក្យចួនមួយចំនួន។ គ្រូឱ្យសិស្សសរសេរកំណាព្យដែលមិនពេញលេញនោះដាក់ក្នុងសៀវភៅ ហើយធ្វើការជាក្រុមស្វែងរកពាក្យចួន ដែលត្រូវបំពេញ(ពាក្យចួនដូចមានក្នុងចម្លើយរំពឹងទុកខាងក្រោម)។ ពាក្យដែលមានអក្សរដិត គឺជាពាក្យសម្រាប់ឱ្យសិស្សមើលដើម្បីរកពាក្យចួននឹងពាក្យនោះ ហើយពាក្យចួនទាំងនោះសិស្សអាចគិតដោយខ្លួនឯងដើម្បីបំពេញកំណាព្យនេះ។

*ឧទាហរណ៍*

មាតុភូមិកម្ពុជា　　　　ធនធាន(១)...　　　　គ្រប់ទីកន្លែង

សមុទ្រព្រៃភ្នំ　　　　ទន្លេធំ(២)...　　　　គួរឱ្យស្ញប់ស្ញែង
គ្រប់ប្រជាជាតិ។

តំបន់ព្រៃភ្នំ　　　　ដើមឈើតូចធំ　　　　ជំរំសត្វ(៣)...

ម្រឹគីម្រឹគា　　　　បក្សាព្រោង(៤)...　　　　រស់តាមក្រុមញាតិ
អឹងកងពេញព្រៃ។

**ចម្លើយរំពឹងទុក** : (១) នានា　ប្រជា ...　(២) វែង　...　(៣) ទៀត ...　(៤) ព្រាត　...

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៧គ**

លេខ
៧យ

# សិស្សប្រើសញ្ញាបន្តក់ "់" លើព្យញ្ជនៈ ក ខ ច ញ ត ន ប ល ស ដើម្បីកាត់សព្ទវែងឱ្យមានសូរខ្លី។

*ឧទាហរណ៍* កក កក់ កាន កាន់ កង កង់
កាប កាប់ កាច កាច់ សល សល់
ចាញ ចាញ់ ចាស ចាស់ ខាត ខាត់

**បំណិនពាក់ព័ន្ធ : វេយ្យាករណ៍**

សូមមើល មេរៀនទី៥៧ (ទំព័រទី១៨៤)

## ខ្លឹមសារ

- បន្តក់ "់"
- និយមន័យបន្តក់ "់" ជាសញ្ញាសម្រាប់កាត់សព្ទវែងឱ្យជាខ្លី។ សញ្ញានេះត្រូវលើព្យញ្ជនៈ៩តួ "ក ង ច ញ ត ន ប ល ស"
- ពាក្យក្នុងមេរៀន ៖ ខ្យល់ លាន់ ខ្ទាញ់ ទម្លាក់ ទន់ ដល់ បាក់ ធ្លាក់ បន្ទាប់ រន្ទត់ ស្លន់ស្លោ ធ្លាក់ ក្រាស់...។

## សកម្មភាពគំរូ

☑ គ្រូឱ្យសិស្សអានអត្ថបទខ្លីមួយនៅទំព័រ១៨៤ ដែលមានពាក្យជាច្រើនប្រើប្រាស់បន្តក់ (់) ហើយឱ្យសិស្សស្រង់ពាក្យទាំងនោះដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន។

☑ គ្រូឱ្យសិស្សដាក់សញ្ញាបន្តក់លើពាក្យ ដែលគ្មានសញ្ញាបន្តក់ក្នុងល្បះ ឬតាមការកំណត់របស់គ្រូ ដើម្បីមានន័យត្រឹមត្រូវ។ ចូរប្អូនអានល្បះខាងក្រោម ហើយដាក់សញ្ញាបន្តក់លើពាក្យទាំងនេះឱ្យបានត្រឹមត្រូវ។

*ឧទាហរណ៍*

- មីងផា កានតែចាស ហើយគាតមិនសូវសលប្រាកកាកទេ។
- រឿងនេះកានតែ ធ្វើឱ្យគាតកាចហើយចងរសនៅតែឯង។

☑ គ្រូឱ្យសិស្សធ្វើការជាដៃគូ ដើម្បីស្វែងរកពាក្យដែលប្រើបន្តក់ (់) ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយសរសេរដាក់ក្នុងសៀវភៅសរសេររៀងៗខ្លួន។ សិស្សអាចអាន និងរកពាក្យដែលមានប្រើសញ្ញាបន្តក់ក្នុងអត្ថបទសៀវភៅ ឬអត្ថបទអំណានផ្សេងទៀត ដើម្បីរកពាក្យទាំងនោះ។ គ្រូផ្តល់ពេលឱ្យសិស្សប្រហែល១០នាទីសម្រាប់ធ្វើកិច្ចការនេះ។ ក្រុមណាដែលរកពាក្យបានច្រើនជាងគេគឺជាអ្នកឈ្នះ។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៧យ**

លេខ ៧ង

# សិស្សសរសេរតួអក្សរនិងពាក្យបានស្អាតល្អ

## បំណិនសំណេរពាក់ព័ន្ធ : សំណេរអក្សរផ្ចង់

សូមមើល មេរៀនទី៥៤ ទី៥៦ ទី៥៨ ទី៦១ ទី៦២ ទី៦៣ និងទី៦៤
(ទំព័រទី១៧៧ ទី១៨៣ ទី១៨៩ ទី១៩៩ ទី២០៣ ទី២០៧ និងទី២១១)

### ខ្លឹមសារ

| | | | |
|---|---|---|---|
| មេរៀនទី៥៤ : | អក្សរ "ណ" និងពាក្យ | "ណាមកា" | (ទំព័រទី១៧៧) |
| មេរៀនទី៥៦ : | អក្សរ "ឈ" និងពាក្យ | "ដើមឈើ" | (ទំព័រទី១៨៣) |
| មេរៀនទី៥៨ : | អក្សរ "ឃ" និងពាក្យ | "ឃោរឃៅ" | (ទំព័រទី១៨៩) |
| មេរៀនទី៦១ : | អក្សរ "ឃ" និងពាក្យ | "ឃឹម" | (ទំព័រទី១៩៩) |
| មេរៀនទី៦២ : | អក្សរ "ឈ" និងពាក្យ | "ឈប់ឈរ" | (ទំព័រទី២០៣) |
| មេរៀនទី៦៣ : | អក្សរ "ញ" និងពាក្យ | "ញញឹម" | (ទំព័រទី២០៧) |
| មេរៀនទី៦៤ : | អក្សរ "ណ" និងពាក្យ | "តំណាង" | (ទំព័រទី២១១) |

### សកម្មភាពគំរូ

☑ សិស្សសរសេរអក្សរផ្ចង់អំពីអក្សរ "**ណ ឈ ឃ ញ ណ**" និងពាក្យ "**ណាមកា ដើមឈើ ឈប់ឈរ ឃឹម ឃោរឃៅ ញញឹម តំណាង**" បានស្អាតល្អតាមទម្រង់អក្សរជ្រៀង និងការណែនាំពីរបៀបគូសបន្ទាត់ សរសេរលើក្តារខៀន ក្តារឆ្នួន និងក្នុងសៀវភៅសរសេររៀងខ្លួនបានត្រឹមត្រូវ។







លេខ
៧ង

**បន្ត...**

## សកម្មភាពគំរូ







☑ សិស្សសរសេរអក្សរផ្ចង់អំពីតួអក្សរផ្សេងទៀត ដែលគេស្រឡាញ់ ដូចជាអក្សរ **រ វ អ** ... ឱ្យត្រូវនឹងទម្រង់ និងទំហំតាមការកំណត់របស់គ្រូ។ បន្ទាប់មក គ្រូឱ្យសិស្សសរសេរអក្សរផ្ចង់ តាមការពេញចិត្តខាងលើចម្លងចូលក្នុងសៀវភៅសរសេររៀងៗខ្លួន។

**ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ**

គ្រូអាចរកសម្ភារៈផ្សេងៗ ដូចជាក្ដារឆ្នួនមានក្រឡា ផ្ទាំងក្រដាសក្រឡាអ៊ិត...



**ការវាយតម្លៃ**

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមហ្វឹកហាត់ផ្ទាល់ក្នុងថ្នាក់

**លេខ ៧៤**

## សិស្សសរសេរតាមអានអត្ថបទខ្លី(ពាក្យរាយ និងពាក្យការព្យ) ក្នុងលំហាត់សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

**បំណិនសំណេរពាក់ព័ន្ធ : សរសេរតាមអាន**

**សូមមើល មេរៀនទី៥៣ ទី៥៤ ទី៥៦ ទី៥៨ ទី៥៩ ទី៦០ ទី៦១ ទី៦២ ទី៦៣ និងទី៦៤ (ទំព័រទី១៧២ ទី១៧៦ ទី១៨២ ទី១៨៨ ទី១៩៣ ទី១៩៥ ទី១៩៨ ទី២០២ ទី២០៧ និងទី២១០)**

### ខ្លឹមសារ

ការសរសេរតាមអានរៀបចំ និងត្រួតពិនិត្យក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

មេរៀនទី៥៣ : ទំព័រទី ១៧២
មេរៀនទី៥៤ : ទំព័រទី ១៧៦
មេរៀនទី៥៦ : ទំព័រទី ១៨២
មេរៀនទី៥៨ : ទំព័រទី ១៨៨
មេរៀនទី៥៩ : ទំព័រទី ១៩៣
មេរៀនទី៦០ : ទំព័រទី១៩៥
មេរៀនទី៦១ : ទំព័រទី ១៩៨
មេរៀនទី៦២ : ទំព័រទី ២០២
មេរៀនទី៦៣ : ទំព័រទី ២០៧
មេរៀនទី៦៤ : ទំព័រទី ២១០

### សកម្មភាពគំរូ

☑ គ្រូសរសេរពាក្យពិបាកមួយចំនួនដែលដកស្រង់ពីអត្ថបទសៀវភៅភាសាខ្មែរអាន -សរសេរ ថ្នាក់ទី៣ ឬការកំណត់ដោយគ្រូ ដាក់លើក្ដារខៀន ហើយឱ្យសិស្ស អានពាក្យទាំងនោះម្ដងមួយពាក្យៗឱ្យឮច្បាស់ឱ្យសិស្ស២ឬ៣នាក់ចង្អុល និងអានតាមដោយធ្វើអក្ខរាវិរុទ្ធផង។

*ឧទាហរណ៍* ពាក្យពិបាកស្រង់ពីអត្ថបទ សរសេរតាមអាន "កន្លែងទេសចរណ៍" (ទំព័រទី១៨២)

មនោរម្យ ប៉ុស្រា យក្សឡោម សមុទ្រ សន្ទឹង នេត្រា សម្បត្តិ គង់វង្ស

- បន្ទាប់មកគ្រូហៅពាក្យទាំងនោះឱ្យសិស្សសរសេរលើក្ដារឆ្នួនរួចកែលម្អ។

☑ គ្រូហៅអត្ថបទក្នុងមេរៀនដែលបានកំណត់ក្នុងសៀវភៅសិក្សាគោលឱ្យសិស្សសរសេរតាមអាន ហើយឆ្លើយសំណួរ និងលំហាត់តាមការកំណត់របស់គ្រូ(សំណួរ និងលំហាត់មានក្នុងខ្ទង់ខ្លឹមសារខាងលើ)។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣

ការវាយតម្លៃ

ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើតេស្តដំណាក់កាលទី ៧៤

## លេខ ៧៨

## សិស្សបំពេញល្បះ ឬតែងល្បះតាមរូបភាព និងខ្លឹមសារផ្សេងៗ ក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ឬតាមការកំណត់របស់គ្រូ។

### បំណិនសំណេរពាក់ព័ន្ធ : ការតែងល្បះ

សូមមើល មេរៀនទី៣៦ ទី៣៧ ទី៣៩ និងទី៤១ (ទំព័រទី១១៧ ទី១២១ ទី១២៩ និងទី១៣៦)

### ខ្លឹមសារ

ពាក្យ កន្សោមពាក្យឬល្បះ ក្នុងលំហាត់បំពេញល្បះ ឬលំហាត់តែងល្បះតាមរូបភាពក្នុង សៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី៣ ៖

- មេរៀនទី៣៦ ទំព័រទី ១១៧
- មេរៀនទី៣៧ ទំព័រទី ១២១
- មេរៀនទី៣៩ ទំព័រទី ១២៩
- មេរៀនទី៤១ ទំព័រទី ១៣៦

### សកម្មភាពគំរូ

១. គ្រូឱ្យសិស្សជ្រើសរើសពាក្យពីក្នុងប្រអប់ក្នុងសៀវភៅអាន-សរសេរថ្នាក់ទី៣ទំព័រ៨៥ ទៅបំពេញល្បះ។

*ឧទាហរណ៍* ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | |
|---|---|---|---|
| ឈប់ | គ្រឿងញៀន | នៅ | សាក |

- អ្នកប្រើប្រាស់......................ធ្វើឱ្យបាត់បង់ការចងចាំ។
- សុភក្រ្ត.............................ដើរលេងទៀតហើយ។
- កូនមិនត្រូវចង់ដឹង ឬចង់.................គ្រឿងញៀននោះទេ។
- កូន និងមិត្តភក្តិត្រូវ............ឱ្យឆ្ងាយពីវា។

២. គ្រូសរសេរពាក្យមួយចំនួនដែលបានដកស្រង់ពីមេរៀនណាមួយដាក់លើក្ដារខៀន មិនតាមលំដាប់ រួចឱ្យសិស្សរៀបជាល្បះពេញលេញ ដើម្បីជួយសិស្សឱ្យយល់ពី "**ល្បះ**" ដែលកើតចេញពីពាក្យច្រើនផ្គុំគ្នា មានន័យពេញលេញស្ដាប់បាន។

*ឧទាហរណ៍* ចូររៀបពាក្យខាងក្រោមជាល្បះត្រឹមត្រូវ។ (មេរៀនទី៣៦ ទំព័រ១១៥)

| | | | | |
|---|---|---|---|---|
| នាំមក | នូវ | ហាត់ប្រាណ | ការ | សុខភាព |

→ ការហាត់ប្រាណ នាំមកនូវសុខភាព។

៣. គ្រូផ្ដល់បញ្ជីពាក្យសំខាន់ៗដល់សិស្សដែលស្រង់ចេញពីមេរៀន។ គ្រូត្រូវប្រាកដថាសិស្សដឹងពីន័យរបស់ពាក្យទាំងនោះ។ បន្ទាប់មក សិស្សត្រូវសរសេរជាល្បះពេញលេញ ដោយប្រើប្រាស់ពាក្យនេះ ហើយបន្ថែមល្បះមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងល្បះទី១។

*ឧទាហរណ៍* ពាក្យសំខាន់ **ការហាត់ប្រាណ**

ការហាត់ប្រាណ មានសារៈសំខាន់ចំពោះសុខភាព។ យើងហាត់ប្រាណដើម្បីសុខភាព។

លេខ ៧ឆ

**បន្ត...**

## សកម្មភាពគំរូ

**សម្គាល់ :** បើសិស្សពិបាកសរសេរល្បះបន្ថែមមួយផ្សេងទៀត ដែលមានទំនាក់ទំនងទៅនឹងល្បះទី១ គ្រូអាចឱ្យសិស្សសរសេរល្បះតែមួយល្បះ ទាក់ទងពាក្យសំខាន់ ឬប្រធានបទសរសេរក៏បាន។

ល្បែងសិក្សាដែលអាចជួយពង្រឹងសមត្ថភាពនេះ



ល្បែងទី ២១



ល្បែងទី ២២



ល្បែងទី ២៣




ដើម្បីធ្វើតេស្តសិស្សអំពីសមត្ថភាពនេះសូមប្រើ **តេស្តដំណាក់កាលទី ៧ឆ**




**ដំណាក់កាលទី៧ ត្រូវបានបញ្ចប់ហើយ!**

សូមធ្វើតេស្តសិស្សដោយប្រើ

<u>តេស្តដំណាក់កាលទី ៧</u>

នៃឧបសម្ព័ន្ធ ២ នៅក្នុងសៀវភៅនេះ

ទំព័រទី ១៨៥ ដល់ ១៨៣

# ឧបសម្ព័ន្ធ១

# បញ្ជីល្បែងសិក្សា

| លរ | ឈ្មោះល្បែងសិក្សា | បំណិនអំណានពាក់ព័ន្ធ | រូបភាព |
|---|---|---|---|
| ១៧ | ល្បែងសិក្សារកបដិសព្ទ (ពាក្យផ្ទុយ)<br>*ដំណាក់កាលទី១ ដល់ទី៤*<br>★ ផ្ដើមពីពាក្យ " រួតរះ" | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ១៨ | ល្បែងសិក្សាពន្យល់ពាក្យ<br>*ដំណាក់កាលទី១ ដល់ទី៤*<br>★ បង្វិលទ្រនិចពាក្យ រួចសរសេរពាក្យឱ្យត្រូវតាមពន្យល់ពាក្យ។ | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ១៩ | ល្បែងសិក្សាថ្នាក់ពាក្យ<br>*ដំណាក់កាលទី១ ដល់ទី៤* | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ២០ | ល្បែងសិក្សាវេវចនសព្ទ (ពាក្យន័យដូច)<br>*ដំណាក់កាលទី១ ដល់ទី៧*<br>★ ចែកបណ្ណពាក្យស្មើៗគ្នា រួចទម្លាក់គ្រាប់ឡុកឡាក់ អ្នកមានបណ្ណពាក្យដែលមានន័យដូចគ្នាដាក់ចុះ រហូតដល់អស់ពីដៃ។ | • ការស្គាល់តួអក្សរនិងសូរ<br>• ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |

| លរ | ឈ្មោះល្បែងសិក្សា | បំណិនអំណានពាក់ព័ន្ធ | រូបភាព |
|---|---|---|---|
| ២១ | ល្បែងសិក្សារកបដិសព្ទ (ពាក្យផ្ទុយ)<br>*ដំណាក់កាលទី៥ ដល់ទី៧*<br>✶ ផ្តើមពីពាក្យ " បង " | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ២២ | ល្បែងសិក្សាពន្យល់ពាក្យ<br>*ដំណាក់កាលទី៥ ដល់ទី៧* | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |
| ២៣ | ល្បែងសិក្សាថ្នាក់ពាក្យ<br>*ដំណាក់កាលទី៥ ដល់ទី៧* | • ការចេះវាក្យសព្ទ<br>• ការចេះអានស្ទាត់<br>• ការអានដើម្បីយល់ន័យ |  |

# ឧបសម្ព័ន្ធ២

# តារាងសង្ខេបតេស្តដំណាក់កាលនិង តេស្តផ្ទាល់មាត់ប្រចាំឆមាស

| តេស្តដំណាក់កាល | | តេស្តផ្ទាល់មាត់ | |
|---|---|---|---|
| លេខតេស្ត ដំណាក់កាល | កម្រិតស្តង់ដាដែល គ្របដណ្តប់ | លេខតេស្ត | កម្រិតស្តង់ដាដែល គ្របដណ្តប់ |
| **តេស្តទី១** | ១ក, ១ខ, ១គ, ១ឃ, ១ង, ១ច, ១ជ | **ឆមាសទី ១** | ១ខ, ១គ |
| **តេស្តទី២** | ២ក, ២ខ, ២គ, ២ឃ, ២ង, ២ឆ | | ២ខ, ២គ |
| **តេស្តទី៣** | ៣ក, ៣ខ, ៣គ, ៣ឃ, ៣ង, ៣ច, ៣ឆ, ៣ជ | | ៣ឃ |
| **តេស្តទី៤** | ៤ក, ៤ខ, ៤គ, ៤ឃ, ៤ង, ៤ច, ៤ជ, ៤ឈ | | ៤គ |
| **តេស្តទី៥** | ៥ក, ៥ខ, ៥គ, ៥ឃ, ៥ង, ៥ឆ, ៥ជ | **ឆមាសទី ២** | ៥គ |
| **តេស្តទី៦** | ៦ក, ៦ខ, ៦គ, ៦ឃ, ៦ង, ៦ច, ៦ជ, ៦ឈ | | ៦ង |
| **តេស្តទី៧** | ៧ក, ៧ខ, ៧គ, ៧ឃ, ៧ច, ៧ឆ | | ៧ក |

# សេចក្ដីណែនាំទូទៅ
# ការធ្វើតេស្តដំណាក់កាល និង តេស្តផ្ទាល់មាត់ប្រចាំឆមាស

## ១. ការធ្វើតេស្តដំណាក់កាល

### ការរៀបចំទូទៅ ៖

- មុនពេលធ្វើតេស្តសំណេរក្នុងថ្នាក់ គ្រូប្រាប់សិស្សជាមុនថា ត្រូវធ្វើតេស្តនៅថ្ងៃណា ពេលព្រឹក ឬ ពេលរសៀល។
- គ្រូកំណត់សិស្សចំនួន២០ទៅ២៥នាក់ក្នុងពេលអនុវត្តតេស្តសំណេរម្ដងៗ បើមានសិស្សនៅសល់គ្រូត្រូវដាក់កិច្ចការ ឱ្យពួកគេដូចជា ចូលបណ្ណាល័យ ធ្វើលំហាត់ជាក្រុមក្នុងទីធ្លាសាលារៀន ដើម្បីរង់ចាំវេនធ្វើតេស្ត។
- គ្រូរៀបចំសិស្សអង្គុយជាជួរ ដោយឃ្លាតពីគ្នាឱ្យបានឆ្ងាយតាមដែលអាចធ្វើបាន។
- គ្រូផ្ដល់សន្លឹកតេស្តអ៊ុតនិងប៊ិកហ្វឺតលុបជ្រះដល់សិស្សម្នាក់ៗ និងប្រាប់សិស្សឱ្យបំពេញឈ្មោះលើសន្លឹកតេស្ត។
- គ្រូត្រូវធ្វើតេស្តសិស្សទៅតាមពេលវេលាកំណត់នៅក្នុងសន្លឹកតេស្តនីមួយៗ និងឱ្យសិស្សធ្វើមួយសំណួរម្ដងៗ មុនបន្តទៅសំណួរបន្ទាប់ទៀត។ ផ្នែកនីមួយៗត្រូវចំណាយពេល៥នាទី រួមទាំងការណែនាំសិស្ស និងការធ្វើសំណួររបស់សិស្ស។

គ្រូពន្យល់សិស្សថាតេស្តនេះ សិស្សម្នាក់ៗត្រូវធ្វើដោយខ្លួនឯង។ បើសំណួរណាដែលមិនចេះ រង់ចាំធ្វើសំណួរបន្ទាប់។ លំហាត់នីមួយៗសិស្សមានពេលកំណត់ច្បាស់លាស់។ បន្ទាប់ពីធ្វើតេស្តចប់ផ្នែកនីមួយៗ គ្រូប្រាប់ថាទៅមុខទៀត។ សិស្សមិនគួរធ្វើកិច្ចការនៅក្នុងផ្នែកណាមួយ មុនការណែនាំរបស់គ្រូឡើយ។ សិស្សគ្រប់រូបត្រូវធ្វើតេស្តក្នុងពេលតែមួយនិងមានចំនួនម៉ោងសម្រាប់ធ្វើកិច្ចការដូចគ្នា។

គ្រូសួរសិស្សថាពួកគេបានត្រៀមខ្លួនរួចហើយឬនៅ បើត្រៀមហើយចាប់ផ្ដើមធ្វើលំហាត់។

## ២. ការធ្វើតេស្តផ្ទាល់មាត់ប្រចាំឆមាស

### ការរៀបចំទូទៅ ៖

គ្រូបង្រៀននិងគ្រូបង្វឹកអំណានរៀបចំធ្វើតេស្តមួយទល់មួយ (សិស្សនិងគ្រូ) ដើម្បីពិនិត្យតាមដានដោយផ្ទាល់ទៅលើសមត្ថភាពសិស្សលើការអាននិងការបញ្ចេញសំឡេងអក្សរនិងពាក្យ។ ផ្នែកនេះមានសារៈសំខាន់ណាស់ក្នុងការបណ្ដុះបំណិនចេះអានស្ទាត់ និងចេះវាក្យសព្ទ។ ដើម្បីធ្វើការវាយតម្លៃបែបនេះបាន គ្រូត្រូវមានជំនួយនិងរៀបចំពេលវេលាឱ្យសិស្សធ្វើការសិក្សាដោយខ្លួនឯង ខណៈដែលគ្រូកំពុងធ្វើតេស្តសិស្សផ្សេងទៀត។

## សេចក្តីណែនាំ
## តេស្តដំណាក់កាលទី១ (៣៥នាទី)

**១ក. សិស្សកំណត់សូរដើមនិងសូរបន្ទាប់តាមរយៈ ការស្តាប់ពាក្យដែលគ្រូអាន និងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយគ្រូឱ្យសិស្សរកសូរដើមនិងសូរបន្ទាប់នៃពាក្យមួយនោះ រួចឱ្យសិស្សគូសរង្វង់ចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះតាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**១ខ. សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និង សទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយ ឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកនិយមន័យ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យបដិសព្ទ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះតាមសមត្ថភាពខ្លួនឯង។ សំណួរទី៣ ទី៤ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យវេវចនសព្ទ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៥។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យសទិសសព្ទ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៦។

**១គ. សិស្សអានពាក្យ និងកន្សោមពាក្យ ដោយមិនចាំបាច់ផ្សំនិងប្រកប។ (ការចេះអានស្ទាត់ និងការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យ ឬ ល្បះណាមួយក្នុងជួរនីមួយៗ ឱ្យសិស្សស្តាប់ពីរដងៗ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញត្រង់ពាក្យ ឬ ល្បះដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**១ឃ. សិស្សរកសូរចួន ក្នុងពាក្យដែលគ្រូអាន និងសរសេរបានត្រឹមត្រូវ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យដែលមានសូរចួន នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**១ង. សិស្សបកស្រាយន័យនៃល្បះ និងអត្ថបទ តាមរយៈការជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញក្នុងចន្លោះល្បះ បានត្រឹមត្រូវ។ (ការអានដើម្បីយល់ន័យ)**

*សំណួរបំពេញល្បះ គឺតម្រូវឱ្យសិស្សជ្រើសរើសពាក្យណាមួយ ទៅបំពេញល្បះនោះឱ្យមានន័យគ្រប់គ្រាន់។*

- គ្រូឱ្យសិស្សអានល្បះ ដើម្បីរកពាក្យឬលេខសម្គាល់ពាក្យនោះ ទៅបំពេញចន្លោះល្បះនីមួយៗដើម្បី ឱ្យល្បះនោះមានន័យគ្រប់គ្រាន់ ស្តាប់បាន តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**១ច. សិស្សសរសេរតាមអាន ពាក្យ  កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។ (សរសេរតាមអាន)**

*សរសេរតាមអានត្រួតពិនិត្យ គឺតម្រូវឱ្យសិស្ស ស្ដាប់គ្រូអានឮៗ ហើយសិស្សសរសេរតាមគ្រូបានហៅ។*

- គ្រូអានពាក្យ និងល្បះឱ្យសិស្សស្ដាប់ពីរដងឮៗ។ បន្ទាប់មក ឱ្យសិស្សសរសេរតាមគ្រូហៅ សិស្សសរសេរឱ្យបានត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ក្នុងពេលវេលាកំណត់មួយជាក់លាក់លើសន្លឹកតេស្ត។
- គ្រូដាក់ពិន្ទុលើពាក្យមួយគឺ ០,៥០ ពិន្ទុ។ ចំណែកពាក្យក្នុងល្បះជាអក្សរដិតទាំង៦ពាក្យគឺមួយពាក្យស្មើនឹង ០,៥០ពិន្ទុដូចគ្នា។

| ទឹក | អគារ | បរិវេណ | ឧស្សាហ៍ | ផ្ដេសផ្ដាស | បុត្រខេមរា |
|---|---|---|---|---|---|
| ពេលមក **សាលារៀន សិស្សានុសិស្ស** ទាំងអស់ត្រូវ **គោរព ទង់ជាតិ** មុនចូល **ថ្នាក់** រៀន **ជានិច្ច**។ | | | | | |

**១ជ. សិស្សបំពេញល្បះ តាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ។ (ការតែងល្បះ)**

*សំណួរបំពេញល្បះ និងតែងល្បះ គឺតម្រូវឱ្យសិស្សសរសេរពាក្យ ឬល្បះ ដោយមើលរូបភាព ឱ្យមានន័យគ្រប់គ្រាន់។*

- គ្រូឱ្យសិស្សមើលរូបភាពម្ដងមួយផ្ទាំងៗ ហើយពណ៌នាដោយមាត់ទទេសិន។ បន្ទាប់មក ឱ្យសិស្សសរសេរសេចក្ដីពណ៌នាក្នុងសន្លឹកតេស្តទៅតាមខ្លឹមសារនៃរូបភាពដែលគ្រូកំណត់ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ អនុវត្តដូចគ្នា។

# តេស្តដំណាក់កាលទី ១ (៣៥នាទី)

ឈ្មោះសិស្ស ...............................

**១ក.** សិស្សកំណត់សូរដើម និងសូរបន្ទាប់តាមរយៈការស្ដាប់ពាក្យដែលគ្រូអាន និងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)

**សំណួរពហុជ្រើសរើស**

ចូរប្រាប់សូរដើម និងសូរបន្ទាប់នៃពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។ ដោយគូសរង្វង់កន្លែងដែលត្រឹមត្រូវ

| | | | | |
|---|---|---|---|---|
| ១ | ខំ | ខ និង អុំ | អំ និង ខ | ខ និង អំ |
| ២ | កា | អា និង ក | ក និង អា | ក និង អៀ |
| ៣ | ទូ | ទ និង អូ | អ៊ូ និង ទ | ទ និង អ៊ូ |
| ៤ | ជុំ | ជ និង អុំ | ជ និង អ៊ុំ | ជ និង អំ |
| ៥ | តែ | ត និង អែ | អែ និង ត | ត និង អ៊ែ |
| ៦ | ធំ | ធ និង អ៊ំ | ធ និង អំ | ធ និង អុះ |

ពិន្ទុ

| |
|---|
| ៦ |

**១ខ.** សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)

**សំណួរពហុជ្រើសរើស**

ចូរគូសរង្វង់ជុំវិញពាក្យដែលត្រូវនឹងនិយមន័យ បដិសព្ទ វេវចនសព្ទ និងសទិសសព្ទឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | ពន្យល់ពាក្យ **"កុមារមេត្រី"** | ដែលជាទីមោទនភាពក្រៃលែង។ | ដែលជាទីគោរពដឹងគុណ។ | ដែលជាទីសប្បាយរីករាយរបស់កុមារ។ |
| ២ | ពន្យល់ពាក្យ **"បរិវេណ"** | ទីជិតខាងឆ្ងាយពីគ្នា។ | ទីជិតខាងដែលព័ទ្ធជុំវិញ។ | ទីជិតខាងក្បែរៗគ្នា។ |
| ៣ | បដិសព្ទ **"ឧស្សាហ៍"** | ព្យាយាម | ខ្ជិល | ស្មៀមស្ងាត់ |
| ៤ | បដិសព្ទ **"មិត្ត"** | សត្រូវ | ជួបជុំ | សម្លាញ់ |
| ៥ | វេវចនសព្ទ **"ភ្នែក"** | ច្រមុះ | ចក្ខុ | អវយវៈ |
| ៦ | សទិសសព្ទ **"ចិត្ត"** | ខិត | គិត | ចិត |

ពិន្ទុ

| |
|---|
| ៦ |

**១គ.** សិស្សអានពាក្យ និងកន្សោមពាក្យ ដោយមិនចាំបាច់ផ្សំ និងប្រកប។ ( ការចេះអានស្ទាត់ និងការចេះវាក្យសព្ទ )

**សំណួរពហុជ្រើសរើស**

ចូរអានពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | | |
|---|---|---|---|---|---|
| ១ | មេត្រី | អគារ | បរិវេណ | សិស្សានុសិស្ស | ជានិច្ច |
| ២ | អនាម័យ | ឧស្សាហ៍ | មិត្តភក្តិ | កិច្ចការ | បទបញ្ជា |
| ៣ | ផ្តេសផ្តាស | លទ្ធផល | ភារកិច្ច | បន្ទប់ | បង្គួច |
| ៤ | ស្អាត | បន្ទប់ | កម្មេចកម្ទី | សរសើរ | សម្អាត |
| ៥ | ថ្នាក់រៀន | ខេមរា | សញ្ញាណ | សញ្ចប់ | បុព្វបុរស |
| ៦ | រូតរះ | ខ្ចីឃ្នាត | បុត្រខេមរា | ជាតិប្រជា | បុរសជាតិខ្មែរ |

| ពិន្ទុ |
|---|
| |
| ៦ |

**១ឃ.** សិស្សរកសូរចួន ក្នុងពាក្យដែលគ្រូអាន និងសរសេរបានត្រឹមត្រូវ។ (ការស្គាល់តួអក្សរនិងសូរ)

**សំណួរពហុជ្រើសរើស**

ចូរគូសរង្វង់ជុំវិញពាក្យដែលមានសូរចួននឹងពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | ពាក្យ "**សិក្សា**" ចួននឹង | កុមារ | ព្យាយាម | ខិតខំ |
| ២ | ពាក្យ "**សំភី**" ចួននឹង | ធានា | នារី | ជាតិ |
| ៣ | ពាក្យ "**រំហើយ**" ចួននឹង | កន្ទើយ | រំដោះ | ការពារ |
| ៤ | ពាក្យ "**ប្រពៃ**" ចួននឹង | កំណាព្យ | ប្រជា | ពន្លៃ |
| ៥ | ពាក្យ "**ខេមរា**" ចួននឹង | សិក្សា | សំភី | ឃ្នាត |
| ៦ | ពាក្យ "**ជាតិ**" ចួននឹង | បរិវេណ | ឆ្លៀត | មេត្រី |

| ពិន្ទុ |
|---|
| |
| ៦ |

**១ង.** សិស្សបកស្រាយន័យនៃល្បះនិងអត្ថបទ តាមរយៈការជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងចន្លោះល្បះបានត្រឹមត្រូវ។

(ការអានដើម្បីយល់ន័យ)

ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | | | |
|---|---|---|---|---|---|---|
| (១) នាំមក | (២) ធូលី | (៣) សរសើរ | (៤) ព្រឹកនេះ | (៥) ស្អាត | (៦) ភារកិច្ច | (៧) ប្រមូល |

| | |
|---|---|
| ១ | ការសម្អាតថ្នាក់ជា............................. របស់យើងទាំងអស់គ្នា។ |
| ២ | .................................. ដល់វេនក្រុមខ្ញុំសម្អាតបន្ទប់រៀន។ |
| ៣ | អ្នកខ្លះ.................... សំរាម កម្ទេចកម្ទី កើបប្រមូលយកទៅដាក់ក្នុងធុងសំរាម។ |
| ៤ | ថ្នាក់រៀនខ្ញុំ............................ជានិច្ចដោយសិស្សចូលរួមសម្អាតទាំងអស់គ្នា។ |
| ៥ | គ្រូតែង................................ពួកយើងគ្រប់ៗគ្នា។ |
| ៦ | អនាម័យ................................នូវសុខភាព។ |

| ពិន្ទុ |
|---|
| |
| ៦ |

**១ច.** សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។ (សរសេរតាមអាន)

**សរសេរតាមអាន**

| ពិន្ទុ |
|---|
| |
| ៦ |

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

| ពិន្ទុ |
|---|
| |
| ៦ |

**១ឆ.** សិស្សបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ។ (ការតែងល្បះ)

**សំណួរតែងល្បះ និងបំពេញល្បះ**

ចូរបំពេញល្បះឱ្យត្រូវនឹងរូបភាពនីមួយៗ ឱ្យបានត្រឹមត្រូវ។



១. សុខា..................នៅផ្ទះ។



២. "សម្អាត"........................

..........................................



៣. .....................................

..........................................

## សេចក្តីណែនាំ
## តេស្តដំណាក់កាលទី២ (៣០នាទី)

**២ក. សិស្សកំណត់ស្គាល់តួរដើមនិងតួរបន្ទាប់តាមរយៈ ការស្តាប់ពាក្យដែលគ្រូអាន និងសរសេរ។ (ការស្គាល់តួអក្សរនិងស្រៈ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកតួរដើម និងតួរបន្ទាប់នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**២ខ.សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកនិយមន័យ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ តែមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យបដិសព្ទ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។សំណួរទី៣ទី៤ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យវេវចនសព្ទ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះតាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៥ ។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យសទិសសព្ទ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៦។

**២គ. សិស្សអានពាក្យ និងកន្សោមពាក្យ ដោយមិនចាំបាច់ផ្សំ និងប្រកប។ (ការចេះអានស្ទាត់ និងការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យ ឬឃ្លាណាមួយក្នុងជួរនីមួយៗ ឱ្យសិស្សស្តាប់ពីរដងៗ បន្ទាប់មកឱ្យសិស្សគូសរង្វង់ជុំវិញលើពាក្យ ឬឃ្លា ដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**២ឃ. សិស្សបកស្រាយន័យនៃឃ្លា និងអត្ថបទ តាមរយៈការជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញក្នុងចន្លោះឃ្លាបានត្រឹមត្រូវ។ (ការអានដើម្បីយល់ន័យ)**

*សំណួរបំពេញឃ្លា គឺតម្រូវឱ្យសិស្សជ្រើសរើសពាក្យណាមួយទៅបំពេញឃ្លានោះ ឱ្យមានន័យគ្រប់គ្រាន់។*

- គ្រូឱ្យសិស្សអានឃ្លា ដើម្បីរកពាក្យ ឬលេខសម្គាល់ពាក្យនោះ ទៅបំពេញចន្លោះឃ្លានីមួយៗ ឱ្យឃ្លានោះមានន័យគ្រប់គ្រាន់ស្តាប់បាន តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**២ង. សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងឃ្លាបានត្រឹមត្រូវ។ (សរសេរតាមអាន)**

*សរសេរតាមអាន គឺតម្រូវឱ្យសិស្ស ស្តាប់គ្រូអានពីរដងៗ ហើយសិស្សសរសេរតាមគ្រូបានហៅ។*

- គ្រូអានពាក្យ និងឃ្លា ឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សសរសេរតាមគ្រូហៅ សិស្សសរសេរឱ្យបានត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ក្នុងពេលវេលាកំណត់មួយជាក់លាក់លើសន្លឹកតេស្ត។
- គ្រូដាក់ពិន្ទុលើពាក្យមួយគឺ ០,៥០ ពិន្ទុ។ ចំណែកពាក្យក្នុងឃ្លាជាអក្សរដិតទាំង៦ពាក្យគឺមួយពាក្យស្មើនឹង ០,៥០ពិន្ទុ ដូចគ្នា។

<table>
<tr><td>គុណ</td><td>ការងារ</td><td>រាជការ</td><td>ចម្ការ</td><td>ទ្វេហារ</td><td>ត្អូញត្អែរ</td></tr>
<tr><td colspan="6">កុលបុត្រ កុលធីតា ត្រូវតែ តបស្នង សងគុណ មាតាបិតា ដោយការខិតខំ រៀនសូត្រ។</td></tr>
</table>

**២ឆ. សិស្សបំពេញឈ្មោះ តាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ។ (ការតែងឈ្មោះ)**

*សំណួរបំពេញឈ្មោះ និងតែងឈ្មោះ គឺតម្រូវឱ្យសិស្សសរសេរពាក្យ ឬឈ្មោះ ដោយមើលរូបភាព ឱ្យមានន័យគ្រប់គ្រាន់។*

- គ្រូឱ្យសិស្សមើលរូបភាពម្តងមួយផ្ទាំងៗ ហើយពណ៌នាដោយមាត់ទទេសិន។ បន្ទាប់មកឱ្យសិស្សសរសេរសេចក្តីពណ៌នាក្នុងសន្លឹកតេស្តទៅតាមខ្លឹមសារនៃរូបភាពដែលគ្រូកំណត់ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ អនុវត្តដូចគ្នា។

# តេស្តដំណាក់កាលទី ២ (៣០នាទី)

ឈ្មោះសិស្ស ................................

**២ក.** សិស្សកំណត់សូរដើមនិងសូរបន្ទាប់ តាមរយៈការស្ដាប់ពាក្យដែលគ្រូអាននិងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)

**សំណួរពហុជ្រើសរើស**

ចូរប្រាប់សូរដើមនិងសូរបន្ទាប់នៃពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | ខែ | ខ និង អេ | ខ និង អែ | ខ និង អៃ |
| ២ | ចៅ | ច និង អៅ | អៅ និង ច | ច និង អោ |
| ៣ | បង | ង និង ប | ប និង ង | ប និង ន |
| ៤ | គោ | អ៊ោ និង គ | គ និង អោ | គ និង អ៊ោ |
| ៥ | ទេ | អេ និង ទ | ទ និង អ៊េ | ទ និង អេ |
| ៦ | មេ | អ៊េ និង ម | អេ និង ម | ម និង អ៊េ |

| ពិន្ទុ |
|---|
| |
| ៦ |

**២ខ.** សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)

**សំណួរពហុជ្រើសរើស**

ចូរគូសរង្វង់ជុំវិញពាក្យដែលត្រូវនឹងនិយមន័យ បដិសព្ទ វេវចនសព្ទនិងសទិសសព្ទឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | ពន្យល់ពាក្យ **"មណ្ឌលសុខភាព"** | ទីកន្លែងសម្រាប់ទៅបោះឆ្នោត។ | ទីកន្លែងសម្រាប់ពិនិត្យនិងព្យាបាលអ្នកជំងឺនៅក្នុងឃុំ។ | កន្លែងសម្រាប់ទៅចុះឈ្មោះធ្វើសំបុត្រកំណើត។ |
| ២ | ពន្យល់ពាក្យ **"ប្រាជ្ញា"** | ការមានស្នាដៃ។ | ការមានភាពឈ្លាសវៃ។ | ការយល់ដឹងជាក់ច្បាស់។ |
| ៣ | បដិសព្ទ **"ស្អប់"** | ព្រម | ស្រឡាញ់ | ឆ្លាត |
| ៤ | បដិសព្ទ **"ពូកែ"** | សុខ | នឿយហត់ | ខ្សោយ |
| ៥ | វេវចនសព្ទ **"ទូន្មាន"** | ព្រហើន | ប្រដៅ | ស្រួលចិត្ត |
| ៦ | សទិសសព្ទ **"សួរ"** | រីករាយ | វិន័យ | សួគ៌ |

| ពិន្ទុ |
|---|
| |
| ៦ |

**២គ.** សិស្សអានពាក្យ និងកន្សោមពាក្យ ដោយមិនចាំបាច់ផ្សំនិងប្រកប។ ( ការចេះអានស្ទាត់ និងការចេះវាក្យសព្ទ )

**សំណួរពហុជ្រើសរើស**

ចូរអានពាក្យខាងក្រោមដោយមិនចាំបាច់ផ្សំនិងប្រកប ឱ្យបានត្រឹមត្រូវ។ ដោយគូសរង្វង់កន្លែងដែលត្រឹមត្រូវ

| | | | | | |
|---|---|---|---|---|---|
| ១ | សុខទុក្ខ | បន្តិចបន្តួច | គោរព | អារម្មណ៍ | ត្រេកអរ |
| ២ | មណ្ឌលសុខភាព | ដឹងគុណគ្រូ | សាធារណៈ | វិន័យ | ក្រុមប្រឹក្សាកុមារ |
| ៣ | ចរិយា | មារយាទ | ទូន្មាន | ប្រៀនប្រដៅ | នាយក |
| ៤ | ខ្ជាប់ខ្ជួន | ជរា | គ្រួសារ | ជីវភាព | បន្ទុក |
| ៥ | កិច្ចការ | ទុក្ខធុរៈ | សុភមង្គល | យោគយល់ | បន្តិចបន្តួច |
| ៦ | សះស្បើយ | សារិកា | ត្អូញត្អែរ | ទន្ត | រអ៊ូទាំ |

ពិន្ទុ

| |
|---|
| |
| ៦ |

**២ឃ.** សិស្សបកស្រាយន័យនៃល្បះ និងអត្ថបទ តាមរយៈការជ្រើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងចន្លោះល្បះបានត្រឹមត្រូវ។ (ការអានដើម្បីយល់ន័យ)

ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| (១) ជីដូនជីតា | (២) សមាជិក | (៣) ភារកិច្ច | (៤) គ្រួសារ | (៥) អនាគត |
| (៦) ជីវភាព | | | (៧) ទាំងអស់ | |

ពិន្ទុ

| |
|---|
| |
| ៦ |

គ្រួសារខ្ញុំមាន....................ជាច្រើននាក់ ហើយម្នាក់ៗមាន......................រៀងៗខ្លួន។ ..........................នៅផ្ទះមើលថៃចៅ។ ពុកម៉ែខ្ញុំជាមេ........................ គាត់ប្រកបរបររកស៊ីដើម្បីផ្គត់ផ្គង់..........................គ្រួសារ។ កូនៗមានភារកិច្ចសំខាន់ជាងគេ គឺខិតខំរៀនសូត្រ ដើម្បីមាន ......................ល្អ។

**២ង.** សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។ (សរសេរតាមអាន)

| ពិន្ទុ |
| --- |
| |
| ៦ |

**សរសេរតាមអាន**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**២ឆ.** សិស្សបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ។ (ការតែងល្បះ)

**សំណួរតែងល្បះ និងបំពេញល្បះ**

ចូរបំពេញល្បះឱ្យត្រូវនឹងរូបភាពនីមួយៗ ឱ្យបានត្រឹមត្រូវ។

| ពិន្ទុ |
| --- |
| |
| ៦ |




១. ស្រីនាថ និងម្តាយទៅ.........................អ្នកជំងឺ។



២. នារីកំពុង .......................................... មុខផ្ទះ។



៣. ....................................................................

..........................................................................

## សេចក្តីណែនាំ
## តេស្តដំណាក់កាលទី៣ (៤០នាទី)

**៣ក. សិស្សប្រាប់ពាក្យជានាម តាមនិយមន័យបានត្រឹមត្រូវ។ (វេយ្យាករណ៍)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយដែលត្រឹមត្រូវ។*

- ♦ គ្រូមិនអានពាក្យទាំងប្រាំឱ្យសិស្សស្តាប់ទេ តែគ្រូណែនាំសិស្សឱ្យសង្កេតមើល ពាក្យណាមួយជានាម ក្នុងជួរដេកនីមួយៗមានប្រាំពាក្យ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញលើពាក្យ ដែលត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៣ខ. សិស្សកំណត់សូរដើម និងសូរបន្ទាប់តាមរយៈ ការស្តាប់ពាក្យដែលគ្រូអាន និងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកសូរដើម និងសូរបន្ទាប់នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៣គ. សិស្សប្រើសញ្ញាខណ្ឌ "។" ក្នុងល្បះបានត្រឹមត្រូវ។ (វេយ្យាករណ៍)**

*សំណួរឆ្លាស់ គឺតម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗត្រូវ ឬ ខុស។*

- ♦ គ្រូឱ្យសិស្សអានល្បះនីមួយៗចំនួនពីរដង។ បន្ទាប់មក ឱ្យសិស្សគូសសញ្ញា ✓ នៅខាងចុងនៃល្បះនោះ ប្រសិនបើប្រើ។ ល្បះនោះមានន័យគ្រប់គ្រាន់ ស្តាប់បាន តែបើល្បះនោះគ្មានន័យគ្រប់គ្រាន់ ស្តាប់បានទេ សិស្សត្រូវគូសសញ្ញា × នៅខាងចុងនៃល្បះនោះ។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៣ឃ. សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកនិយមន័យ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរដេកនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ អនុវត្តដូចគ្នា។
- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកពាក្យបដិសព្ទ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី៣ ទី៤ អនុវត្តដូចគ្នា។
- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកពាក្យវេវចនសព្ទ នៃពាក្យមួយនោ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៥ ។
- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកសទិសសព្ទ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៦។

**៣ង. សិស្សរកសូរច្ចេន ក្នុងពាក្យដែលគ្រូអាន និងសរសេរបានត្រឹមត្រូវ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- ♦ គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងឮៗ ហើយឱ្យសិស្សរកពាក្យដែលមានសូរច្ចេន នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរដេកនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៣ច. សិស្សបកស្រាយន័យនៃអត្ថបទ តាមរយៈការរៀបចំល្បះ តាមលំដាប់នៃខ្លឹមសាររឿងបានត្រឹមត្រូវ។ (ការអានដើម្បីយល់ន័យ)**

*សំណួរឆ្លាស់ គឺតម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗត្រូវ ឬ ខុស។*

- គ្រូណែនាំសិស្សថា ក្រោយពីបានអានល្បះទាំងអស់ចប់។ បន្ទាប់មក សម្រេចចិត្តដាក់លេខរៀងទីប៉ុន្មាន? (បើគិតថា ល្បះនោះជាល្បះដើមគេ ត្រូវដាក់លេខ១ ហើយល្បះណាត្រូវដាក់លេខ២ ល្បះណាត្រូវដាក់លេខ៣ ... រហូតដល់ល្បះណាត្រូវដាក់លេខ៦។

**៣ឆ. សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។ (សរសេរតាមអាន)**

*សរសេរតាមអាន គឺតម្រូវឱ្យសិស្ស ស្ដាប់គ្រូអានឮៗ ហើយសិស្សសរសេរតាមគ្រូហៅ។*

- គ្រូអានពាក្យ ឬល្បះឱ្យសិស្សស្ដាប់ពីរដងឮៗ ហើយឱ្យសិស្សសរសេរតាមគ្រូហៅ សិស្សសរសេរឱ្យបានត្រឹមត្រូវតាមសមត្ថភាពខ្លួនឯង ក្នុងពេលវេលាកំណត់មួយជាក់លាក់លើសន្លឹកតេស្ត។
- គ្រូដាក់ពិន្ទុលើពាក្យមួយគឺ ០,៥០ ពិន្ទុ។ ចំណែកពាក្យក្នុងល្បះដែលមានអក្សរដិតទាំង៦ពាក្យគឺមួយពាក្យស្មើនឹង ០,៥០ពិន្ទុ ដូចគ្នា។

| | | | | | |
|---|---|---|---|---|---|
| ជ្រូក | ស្មោះសរ | កុលបុត្រ | បរិភោគ | សុខសាន្ត | ដំបូន្មាន |
| យើង **គោរព ដឹងគុណ** លោកទាំង **ពីរ** ដែល **ខិតខំ** ធ្វើការ **ដើម្បី ចិញ្ចឹម** យើង។ | | | | | |

**៣ជ. សិស្សតែងល្បះតាមរូបភាពបានត្រឹមត្រូវ។ (ការតែងល្បះ )**

*សំណួរតែងល្បះគឺតម្រូវឱ្យសិស្សមើលរូបភាព រួចតែងល្បះតាមរូបភាពនោះឱ្យបានត្រឹមត្រូវ។*

- គ្រូឱ្យសិស្សមើលរូបភាពទី១ និងទី២។ បន្ទាប់មកឱ្យសិស្សតែងល្បះតាមរូបភាពនោះឱ្យមានន័យគ្រប់គ្រាន់ ហើយត្រឹមត្រូវ។

# តេស្តដំណាក់កាលទី ៣ (៤០នាទី)

ឈ្មោះសិស្ស ..............................

**៣ក.** សិស្សប្រាប់បានពាក្យជានាម តាមនិយមន័យបានត្រឹមត្រូវ។ (វេយ្យាករណ៍)

**សំណួរពហុជ្រើសរើស**

ចូរគូសរង្វង់ជុំវិញពាក្យដែលជានាមឱ្យបានត្រឹមត្រូវ។

| | | | | | |
|---|---|---|---|---|---|
| ១ | ដើរ | ខ្មៅ | ក្របី | សរសេរ | រៀន |
| ២ | ដើមត្នោត | ក្រហម | ឈរ | ខ្ពស់ | មើល |
| ៣ | រូតរះ | ខិតខំ | បណ្ណាល័យ | ប្រសើរ | ខ្ជិល |
| ៤ | ស្តាប់ | លាង | កាត់ | សុខា | ក្រោយ |
| ៥ | ជួយ | និយាយ | សុខសាន្ត | សាប៊ូ | ស្គម |
| ៦ | ខ្ញុំ | ចម្ការ | មាំមួន | ពីរ | រាប់ |

| ពិន្ទុ |
|---|
| |
| ៦ |

**៣ខ.** សិស្សកំណត់សូរដើមនិងសូរបន្ទាប់ តាមរយៈការស្តាប់ពាក្យដែលគ្រូអាននិងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)

**សំណួរពហុជ្រើសរើស**

ចូរប្រាប់សូរដើម និងសូរបន្ទាប់នៃពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | នាំ | ន និង អាំ | អុំា និង ន | ន និង អុំា |
| ២ | ទា | ទ និង អ៊ា | អ៊ា និង ទ | ទ និង អា |
| ៣ | ចេះ | អេះ និង ច | ច និង អេះ | ច និង អ៊េះ |
| ៤ | សួរ | ស និង អួ (រ) | ស និង អូ (រ) | អួ និង ស (រ) |
| ៥ | លាង | ល អា និង ង | ល ង និង អ៊ា | ល អ៊ា និង ង |
| ៦ | ប្រឹង | ប្រ ង និង អឹ | ប្រ អឹ និង ង | ប្រ អ៊ឹ និង ង |

| ពិន្ទុ |
|---|
| |
| ៦ |

**៣គ.** សិស្សប្រើសញ្ញាខណ្ឌ "។ " ក្នុងល្បះបានត្រឹមត្រូវ។ (វេយ្យាករណ៍)

**សំណួរឆ្លាស់**

ចូរប្អូនគូសសញ្ញា ✓ចំពោះល្បះណាដែលប្រើសញ្ញា "។" ត្រឹមត្រូវនិងគូសសញ្ញា× ចំពោះល្បះណាដែលប្រើសញ្ញា "។" មិនត្រឹមត្រូវ។

| | | |
|---|---|---|
| ១ | តើគ្រួសារប្អូនមានសមាជិកប៉ុន្មាននាក់។ | |
| ២ | គាត់ខំធ្វើការ ដើម្បីជីវភាពគ្រួសារ។ | |
| ៣ | ការខ្ជិលច្រអូស។ | |
| ៤ | កូនល្អស្ដាប់ម៉ែ សិស្សពូកែស្ដាប់គ្រូ។ | |
| ៥ | ការខស្សាហ៍ព្យាយាម។ | |
| ៦ | ពេលទំនេរ ខ្ញុំទៅអានសៀវភៅនៅបណ្ណាល័យ។ | |

| ពិន្ទុ |
|---|
| |
| ៦ |

**៣ឃ.** សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។ (ការចេះវាក្យសព្ទ)

**សំណួរពហុជ្រើសរើស**

| | | | | |
|---|---|---|---|---|
| ១ | ពន្យល់ពាក្យ **"ដំបូន្មាន"** | ពាក្យគោរព។ | ពាក្យសរសើរ។ | ពាក្យប្រដៅ។ |
| ២ | ពន្យល់ពាក្យ **"បវរ"** | ភាពស្មោះត្រង់។ | ភាពល្អប្រសើរលើសលប់។ | ភាពកោតសរសើរ។ |
| ៣ | បដិសព្ទ **"មាំមួន"** | បរិភោគ | សុខភាព | ទន់ជ្រាយ |
| ៤ | បដិសព្ទ **"សុខសាន្ត"** | ស្ងប់ស្ងាត់ | ទុក្ខព្រួយ | ខ្ចីឃ្លាត |
| ៥ | វេវចនសព្ទ **"រួតរះ"** | ម្ចីម្នា | ស្មោះ | ខ្ជិល |
| ៦ | សទិសសព្ទ **"រស់"** | ប្រពៃ | មុន | រស |

| ពិន្ទុ |
|---|
| |
| ៦ |

ចូរគូសរង្វង់ជុំវិញពាក្យដែលត្រូវនឹងនិយមន័យ បដិសព្ទ វេវចនសព្ទ និងសទិសសព្ទឱ្យបានត្រឹមត្រូវ។

**៣ង.** សិស្សរកសូរចួន ក្នុងពាក្យដែលគ្រូអាននិងសរសេរបានត្រឹមត្រូវ។ ( ការស្គាល់តួអក្សរនិងសូរ)

**សំណួរពហុជ្រើសរើស**

ចូរគូសរង្វង់ជុំវិញពាក្យដែលមានសូរចួននឹងពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ១ | ពាក្យ "អក្សរ" ចួននឹង | ប្រាប់ | ស្ងួន | បន្ត |
| ២ | ពាក្យ "ត្រី" ចួននឹង | ស្រី | ប្រៀន | ស្តាប់ |
| ៣ | ពាក្យ "តើ" ចួននឹង | រូតរះ | ហោះ | ដើរ |
| ៤ | ពាក្យ "ការពារ" ចួននឹង | បវរ | ធានា | បុត្រ |
| ៥ | ពាក្យ "ជួយ" ចួននឹង | ស្ងួយ | ស្តម | ភ្នែក |
| ៦ | ពាក្យ "ប្រដាប់ប្រដា" ចួននឹង | សម្អាត | កខ្វក់ | សិក្សា |

ពិន្ទុ

| |
|---|
| |
| ៦ |

**៣ច.** សិស្សបកស្រាយន័យ នៃអត្ថបទ តាមរយៈការរៀបល្បះតាមលំដាប់ព្រឹត្តិការណ៍រឿងបានត្រឹមត្រូវ។

(ការអានដើម្បីយល់ន័យ)

**សំណួរឆ្លាស់**

ចូររៀបល្បះខាងក្រោមតាមលំដាប់លំដោយរឿង ដោយសរសេរពីលេខ១ ដល់លេខ៦។

| | |
|---|---|
| | អ្នកបម្រើឆ្លើយថា ល្អ អាក្រក់មកពីសំដី និងចិត្ត គឺអណ្តាត និងបេះដូងនេះឯង។ |
| | ចៅហ្វាយបញ្ជាឱ្យយកអ្វីដែលល្អក្នុងខ្លួនជ្រូកមកជូនគាត់។ បុរសនោះយកអណ្តាត ជ្រូក និងបេះដូងជ្រូកជូនគាត់។ |
| | បន្ទាប់មក អ្នកបម្រើយកអណ្តាត និងបេះដូងជូនចៅហ្វាយ។ |
| | ថ្ងៃមួយអ្នកបម្រើសម្លាប់ជ្រូកតាម បញ្ជារបស់ចៅហ្វាយ។ |
| | បន្ទាប់មកទៀត ចៅហ្វាយឱ្យបុរសនោះយកអ្វីក្នុងខ្លួនជ្រូក ដែលអាក្រក់មកជូនគាត់ម្តងទៀត។ បុរសនោះក៏យកអណ្តាតនិងបេះដូងជ្រូកជូនគាត់ដដែល។ |
| | ចៅហ្វាយឆ្ងល់សួរ ហេតុអ្វីបានជាយកអណ្តាតនិងបេះដូងដដែលៗ មកជូនគាត់។ |

ពិន្ទុ

| |
|---|
| |
| ៦ |

**៣ឆ.** សិស្សសរសេរតាមអាន ពាក្យ កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។ (សរសេរតាមអាន)

**សរសេរតាមអាន**

........................................................................................................................................ ពិន្ទុ

........................................................................................................................................

........................................................................................................................................

| |
|---|
| |
| ៦ |

**៣ជ. សិស្សតែងល្បះតាមរូបភាពបានត្រឹមត្រូវ។ (ការតែងល្បះ)**

ចូរប្អូនតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។








ពិន្ទុ

| |
|---|
| |
| ៦ |

...........................

...........................

...........................

...........................។

...........................

...........................

...........................

...........................។

...........................

...........................

...........................

...........................។

## សេចក្តីណែនាំ
## តេស្តដំណាក់កាលទី៤ (៤០នាទី)

**៤ក. សិស្សប្រាប់បានពាក្យជាគុណនាម តាមនិយមន័យបានត្រឹមត្រូវ។ (វេយ្យាករណ៍)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយដែលត្រឹមត្រូវ។*

- គ្រូមិនអានពាក្យទាំងប្រាំឱ្យសិស្សស្តាប់ទេ តែគ្រូណែនាំសិស្សឱ្យសង្កេតមើល ពាក្យណាមួយជាពាក្យគុណនាម ក្នុងជួរនីមួយៗដែលមានប្រាំពាក្យ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញលើពាក្យដែលត្រឹមត្រូវ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ និងទី៦ អនុវត្តដូចគ្នា។

**៤ខ. សិស្សកំណត់សូរដើម និងសូរបន្ទាប់តាមរយៈ ការស្តាប់ពាក្យដែលគ្រូអាននិងសរសេរ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកសូរដើមនិងសូរបន្ទាប់នៃពាក្យនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៤គ. សិស្សពន្យល់ពាក្យពិបាក បដិសព្ទ វេវចនសព្ទ និងសទិសសព្ទបានត្រឹមត្រូវ។(ការចេះវាក្យសព្ទ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកនិយមន័យ នៃពាក្យមួយនោះ។ បន្ទាប់មកឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យបដិសព្ទ នៃពាក្យមួយនោះ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី៣ ទី៤ អនុវត្តដូចគ្នា។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យវេវចនសព្ទ នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៥។
- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកសទិសសព្ទនៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ អនុវត្តសំណួរទី៦។

**៤ឃ. សិស្សរកសូរច្នួន ក្នុងពាក្យដែលគ្រូអាននិងសរសេរបានត្រឹមត្រូវ។ (ការស្គាល់តួអក្សរនិងសូរ)**

*សំណួរពហុជ្រើសរើស គឺតម្រូវឱ្យសិស្ស គូសរង្វង់ជុំវិញយកចម្លើយតែមួយតាមគ្រូកំណត់។*

- គ្រូហៅពាក្យខាងដើមសំណួរមួយឱ្យសិស្សស្តាប់ពីរដងៗ ហើយឱ្យសិស្សរកពាក្យដែលមានសូរច្នួន នៃពាក្យមួយនោះ។ បន្ទាប់មក ឱ្យសិស្សគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវណាមួយក្នុងជួរនោះ តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៤ង. សិស្សរកនិយមន័យ នៃពាក្យហេតុ និងផល។ ព្រឹត្តិការណ៍ ឬរឿងអ្វីមួយជាហេតុ។ ការបង្កឱ្យកើតព្រឹត្តិការណ៍ ឬរឿងមួយផ្សេងទៀតជាផល។ (បំណិន ការស្គាល់ហេតុនិងផល)**

*សំណួរឆ្លាស់ គឺតម្រូវឱ្យសិស្សសម្រេចចិត្តថា ចម្លើយនីមួយៗត្រូវ ឬ ខុស។*

- គ្រូឱ្យសិស្សអានល្បះនីមួយៗ ចំនួនពីរដង បន្ទាប់មកឱ្យសិស្សគូសសញ្ញា ✓ នៅខាងចុងនៃល្បះនោះ ប្រសិនបើល្បះនោះមានន័យគ្រប់គ្រាន់ស្តាប់បាន តែបើល្បះនោះគ្មានន័យគ្រប់គ្រាន់ ស្តាប់មិនបាន សិស្សត្រូវគូសសញ្ញា × នៅខាងចុងនៃល្បះនោះ។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៤ច. សិស្សបកស្រាយន័យ នៃល្បះ និងអត្ថបទតាមរយៈការជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញក្នុងចន្លោះល្បះ បានត្រឹមត្រូវ។ (ការអានដើម្បីយល់ន័យ)**

*សំណួរបំពេញល្បះ គឺតម្រូវឱ្យសិស្សជ្រើសរើសពាក្យណាមួយទៅបំពេញល្បះនោះ ឱ្យមានន័យគ្រប់គ្រាន់។*

- គ្រូឱ្យសិស្សអានល្បះ ដើម្បីរកពាក្យ ឬលេខសម្គាល់ពាក្យនោះ ទៅបំពេញចន្លោះល្បះនីមួយៗ ឱ្យល្បះនោះមានន័យគ្រប់គ្រាន់ ស្ដាប់បាន តាមសមត្ថភាពខ្លួនឯង។ សំណួរទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ អនុវត្តដូចគ្នា។

**៤ជ. សិស្សសរសេរតាមអាន ពាក្យ  កន្សោមពាក្យ និងល្បះបានត្រឹមត្រូវ។(សរសេរតាមអាន)**

*សរសេរតាមអាន គឺតម្រូវឱ្យសិស្ស ស្តាប់គ្រូអានឮៗ ហើយសិស្សសរសេរតាមគ្រូបានហៅ។*

